## រាជរដ្ឋាភិបាលកម្ពុជា

## គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០១៩
# នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ
# សាធារណៈ ដំណាក់កាលទី ៣

**អគ្គលេខាធិការដ្ឋានគណៈកម្មាធិការ**
**ដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

# មាតិកា


បុព្វកថា....................................................................................................i
អារម្ភកថា....................................................................................................iv
សេចក្តីសង្ខេប.............................................................................................viii
១. សេចក្តីផ្តើម.............................................................................................1
១.១. ទិដ្ឋភាពទូទៅ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ.............................1
១.២. ស្ថានភាពសេដ្ឋកិច្ច....................................................................................3
១.៣. ស្ថានភាពហិរញ្ញវត្ថុសាធារណៈ....................................................................4
១.៤. សនិទានកម្ម និងគោលបំណងនៃរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ ២០១៩...................5
២. វឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រចាំឆ្នាំ២០១៩...........7
២.១. ការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ...........7
ផ្នែកទី១ “បន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា”.....................................................7
ផ្នែកទី២ “បន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ”..................................................16
ផ្នែកទី៣ “ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ”........................................22
ផ្នែកទី៤ “ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់”....................................................28
ផ្នែកទី៥ “ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព”...........31
២.២. ការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី៣ របស់ក្រសួង-ស្ថាប័ន.........................33
២.២.១. ការពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងការប្រមូលចំណូល និងចំណាយ......................34
២.២.២. ការពង្រីក និងពង្រឹងការអនុវត្តប្រព័ន្ធ FMIS នៅតាមក្រសួង-ស្ថាប័ន......................35
២.២.៣. ការពង្រឹងការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធី..............................36
២.៣. យោបល់ដៃគូអភិវឌ្ឍន៍លើប្រព័ន្ធ FMIS និង សិទ្ធិភាព BSP-PB.................................38
២.៣.១. ប្រព័ន្ធ FMIS.....................................................................................38
២.៣.២. សិទ្ធិភាព BSP-PB...............................................................................38
៣. បញ្ហាប្រឈម និងសំណើដំណោះស្រាយ......................................................................40
៤. សេចក្តីសន្និដ្ឋាន..............................................................................................44
ឧបសម្ព័ន្ធ.......................................................................................................47
ឧបសម្ព័ន្ធទី ១ ÷ វឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់ គ.ហ.ស. ..................................48
ឧបសម្ព័ន្ធទី ២ ÷ តារាងថវិកា និងសមិទ្ធកម្ម តាមអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ............52
ឧបសម្ព័ន្ធទី ៣ ÷ តារាងថវិកា និងសមិទ្ធកម្ម តាមក្រសួង-ស្ថាប័ន..................................53
ឧបសម្ព័ន្ធទី ៤ ÷ តារាងសង្ខេបវឌ្ឍនភាពប្រចាំឆ្នាំ២០១៩...............................................55
ឧបសម្ព័ន្ធទី ៥ ÷ របាយការណ៍លទ្ធផលនៃកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រង
ហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ.......................................................89
ឧបសម្ព័ន្ធទី ៦ ÷ របាយការណ៍លទ្ធផលនៃកិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រង
ហិរញ្ញវត្ថុសាធារណៈ ជាមួយតំណាងដៃគូអភិវឌ្ឍន៍ ........................................................102
ឧបសម្ព័ន្ធទី ៧ ÷ របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០១៩ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រង
ហិរញ្ញវត្ថុសាធារណៈ (ជាភាសាអង់គ្លេស) ..........................................................................121

# បុព្វកថា

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាកម្មវិធីកែទម្រង់ស្នូលមួយ នៃកម្មវិធីកែទម្រង់សំខាន់ៗ របស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីឈានឆ្ពោះទៅពង្រឹងអភិបាលកិច្ច ដែលជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ ។ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានទស្សនវិស័យប្រកបដោយមហិច្ឆិតា និងប្រាកដនិយម ពោលគឺការកសាងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាឱ្យស្របតាមឧត្តមានុវត្តន៍អន្តរជាតិ ដែលមានគោលដៅផ្លាស់ប្តូរ "**ប្រព័ន្ធដែលផ្តោតលើ ធាតុចូល និងមានលក្ខណៈមជ្ឈការ**" ឆ្ពោះទៅ "**ប្រព័ន្ធដែលផ្តោតលើធាតុចេញ ឬលទ្ធផល និងវិមជ្ឈការ**" ។ និយាយម្យ៉ាងទៀត ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមួយរឹងមាំ នឹងឈានទៅសម្រេចបាននូវលទ្ធផលចុងក្រោយទាំង៣ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមមាន (១) បូរណភាពនៃការគោរពវិន័យថវិកា, (២) ប្រសិទ្ធភាពនៃថវិកា ទាំងក្នុងផ្នែកវិភាជន៍ ទាំងក្នុងផ្នែកប្រតិបត្តិការ និង (៣) ស័ក្តិសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ។

រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានផ្តល់អាទិភាព និងចាត់ទុកភាពរឹងមាំនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាឆ្អឹងខ្នងនៃការអនុវត្តរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាឱ្យសម្រេចបានប្រកបដោយជោគជ័យ និងចីរភាព ។ ក្នុងន័យនេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពិតជាមានសារៈសំខាន់ក្នុងការជំរុញការអភិវឌ្ឍប្រកបដោយផលភាព, វិបុលភាព និងបរិយាប័ន្ន ។ អាស្រ័យហេតុនេះ បណ្តាដៃគូអភិវឌ្ឍន៍ រួមមាន សហភាពអឺរ៉ុប មូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី បានវាយតម្លៃខ្ពស់លើកិច្ចខិតខំប្រឹងប្រែងក្នុងការកែទម្រង់របស់រាជរដ្ឋាភិបាល និងមានជំនឿថាសេដ្ឋកិច្ចកម្ពុជា នៅតែអាចបន្តកំណើនខ្ពស់ និងរឹងមាំ ក្នុងរយៈពេលខ្លី និងមធ្យម ខាងមុខ ។

ផ្អែកលើលទ្ធផលនៃរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០១៩ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ បានឆ្លុះបញ្ចាំងនូវវឌ្ឍនភាពដូចខាងក្រោម÷

១. ការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលប្រកបដោយភាពម៉ឺងម៉ាត់ និងមុតស្រួច បានធ្វើឱ្យចំណូលមានការកើនឡើងជាលំដាប់ ដែលជាមធ្យមចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨ ចំណូលចរន្តបានកើនឡើងប្រមាណ ១,៤ ពិន្ទុភាគរយនៃ ផ.ស.ស. ក្នុងមួយឆ្នាំ ។ រីឯឆ្នាំ២០១៩ មានកំណើន ៣,១១ ពិន្ទុភាគរយនៃ ផ.ស.ស.។ សមិទ្ធផលនេះទទួលបានមូលវិចារណ៍ល្អគួរជាទីមោទនៈ ទាំងពីសំណាក់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា និងពីសំណាក់ដៃគូអភិវឌ្ឍន៍ និងស្ថាប័នអន្តរជាតិ ព្រមទាំងបានអនុញ្ញាតឱ្យរាជរដ្ឋាភិបាលអាចបង្វែរថវិកាកាន់តែច្រើនទៅកាន់វិស័យអាទិភាព ក៏ដូចជាអាចបង្កើនយ៉ាងច្រើននូវធនធានវិនិយោគសាធារណៈក្នុងស្រុក ពិសេស លើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលជាប្រការជួយលើកស្ទួយមួយកម្រិតទៀត ដល់ឯករាជ្យភាពផ្នែកថវិការបស់កម្ពុជា ។

២. ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ត្រូវបាននិងកំពុងប្រើប្រាស់ជាផ្លូវការក្នុងការគ្រប់គ្រង និងការកត់ត្រាប្រតិបត្តិការពាក់ព័ន្ធនឹងធានាចំណាយថវិកា, ផ្នែកខ្លះនៃកិច្ចលទ្ធកម្ម (បញ្ជីទំនិញ-សេវា, ប្រគល់ទទួលទំនិញ-សេវា ជាដើម), ចំណាយថវិកា, ចំណូលថវិកា, ចលនាថវិកា, កិច្ចបញ្ជិកាគណនេយ្យ និងប្រតិបត្តិការហិរញ្ញវត្ថុ ផ្សេងៗទៀត នៅអគ្គនាយកដ្ឋានគន្លឹះនៃក្រសួងសេដ្ឋកិច្ចនិង

ហិរញ្ញវត្ថុចំនួន ៩, អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួង-ស្ថាប័នចំនួន ២០, អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនៅថ្នាក់កណ្តាលចំនួន ១២, មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្តទាំង ២៥, រតនាគាររាជធានី-ខេត្តទាំង ២៥ និងសន្ធានកម្មជាមួយប្រព័ន្ធខាងក្រៅចំនួន ៨ កន្លែង ដែលមានអ្នកប្រើប្រាស់សរុបជាង ១ ៣០០ នាក់ និងត្រូវបានប៉ាន់ស្មានថានឹងកើនឡើងជាង ១ ៧០០ នាក់ក្នុងឆ្នាំ២០២០ ។

៣. ការអនុវត្តថវិកាកម្មវិធី ត្រូវបាននិងកំពុងដាក់ឱ្យអនុវត្តនៅគ្រប់ក្រសួង-ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្តចំនួន ១៨ ។ គ្រប់រដ្ឋបាលរាជធានី-ខេត្តចំនួន ២៥ នឹងត្រូវអនុវត្តថវិកាកម្មវិធីត្រឹមឆ្នាំ២០២១ ។ ជាមួយគ្នានេះ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំ និងកំពុងកែសម្រួលក្របខណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម និងក្របខណ្ឌថវិការយៈពេលមធ្យម ដើម្បីពង្រឹងប្រសិទ្ធភាពនៃការរៀបចំថវិកាផ្សារភ្ជាប់ទៅនឹងគោលនយោបាយ ។

៤. រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា បានបន្តផ្តោតលើគោលដៅអាទិភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ បន្ទាប់ពីដាក់ឱ្យអនុវត្ត **«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥»** និងផែនការសកម្មភាពលម្អិតនៃយុទ្ធសាស្ត្រនេះ ដែលជាស្នូលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, រាជរដ្ឋាភិបាលបានរៀបចំ និងដាក់ឱ្យអនុវត្ត **«យុទ្ធសាស្ត្រគៀរគរចំណូល ២០១៩-២០២៥»**, **«យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥»**, **«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥»** និង **«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ឆ្នាំ២០១៩-២០២៥»** រីឯផែនការសកម្មភាពលម្អិតនៃយុទ្ធសាស្ត្រទាំងបួនខាងលើ ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត ក្នុងកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅត្រីមាសទី ១ ឆ្នាំ ២០២០ ។ យុទ្ធសាស្ត្រនីមួយៗ បានកំណត់គោលបំណង និងគោលដៅច្បាស់លាស់ សម្រាប់តម្រង់ទិសសកម្មភាពកែទម្រង់នៅក្នុងរយៈពេលមធ្យមខាងមុខ ដែលមានអគ្គនាយកដ្ឋានទទួលបន្ទុកជាអ្នករៀបចំផ្ទាល់ ដោយធានាបាននូវភាពជាម្ចាស់ក្នុងការងារកែទម្រង់ ។

ផ្អែកលើវឌ្ឍនភាពគន្លឹះៗសម្រេចបានខាងលើ ចក្ខុវិស័យកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកាន់តែមានភាពច្បាស់លាស់ និងប្រាកដនិយម ។ ក្នុងន័យនេះ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(គ.ហ.ស.) អាចសន្និដ្ឋានបានថា (១) ភាពជឿទុកចិត្តនៃថវិកានៅតែអាចរក្សាបានជាសារវ័ន្ត ប៉ុន្តែត្រូវពង្រឹងបន្ថែមលើប្រសិទ្ធភាពចំណាយ និងការគ្រប់គ្រងចំណូល ជាពិសេសការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ, (២) ប្រព័ន្ធគណនេយ្យភាព បាននិងកំពុងកសាងតាមរយៈការដាក់ឱ្យអនុវត្តប្រព័ន្ធ FMIS ជំហានទី១ និងទី២ ប៉ុន្តែត្រូវពង្រឹងបន្ថែមទៀតនូវគុណភាពនៃសមាសធាតុនីមួយៗ, (៣) ការពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី គឺជាមូលដ្ឋានគ្រឹះសម្រាប់រៀបចំ និងកំណត់ការផ្លាស់ប្តូរប្រព័ន្ធថវិកាកម្ពុជា ទន្ទឹមនឹងការបន្តពង្រឹងការរៀបចំ និងអនុវត្តក្របខណ្ឌហិរញ្ញវត្ថុសាធារណៈ និងក្របខណ្ឌថវិការយៈពេលមធ្យម ដែលជាឧបករណ៍សំខាន់សម្រាប់ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ, (៤) យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា និងយុទ្ធសាស្ត្រគាំទ្រប្រព័ន្ធថវិកា ជាសមាសធាតុសំខាន់ ដើម្បីកំណត់ទិសដៅគណនេយ្យភាពសមិទ្ធកម្ម ដែលជាគោលដៅចុងក្រោយនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង (៥) ប្រព័ន្ធលើកទឹកចិត្ត បានក្លាយជាឧបករណ៍ ក្នុងការជំរុញការធ្វើស្ថាប័ននីយកម្មឱ្យស្របតាមការវិវឌ្ឍនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ រីឯការកសាង

ធនធានមនុស្ស បាននិងកំពុងពង្រឹងសមត្ថភាពមន្ត្រីរាជការជាលំដាប់ តាមរយៈការដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាពក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

ជាចុងក្រោយ សមិទ្ធផលសម្រេចបានខាងលើ បានបង្ហាញអំពីការចូលរួមពីគ្រប់តួអង្គពាក់ព័ន្ធ រួមមានក្រសួង-ស្ថាប័ន, អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍ ។ ក្នុងនាម គ.ហ.ស. និងរូបខ្ញុំផ្ទាល់ សូមធ្វើការវាយតម្លៃខ្ពស់ និងកោតសរសើរចំពោះក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួង-ស្ថាប័ន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, កិច្ចសហប្រតិបត្តិការភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍ ជាពិសេស អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលបានខិតខំបំពេញមុខងាររបស់ខ្លួនជាឧត្តមសេនាធិការជូន គ.ហ.ស. ទាំងការងារដឹកនាំ, សម្របសម្រួល, គាំទ្រ និងត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាពកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទាំងប្រចាំត្រីមាស និងប្រចាំឆ្នាំ ប្រកបដោយភាពគ្រប់ជ្រុងជ្រោយ និងឆ្លុះបញ្ចាំងទាំងទិដ្ឋភាពការងារកែទម្រង់ និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទាំងមូល ៕

ថ្ងៃ ចន្ទ ០៣រោច ខែ ជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# អារម្ភកថា

អនុលោមតាមសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ ០៩ សរ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៥ ស្តីពី "វិធាន និងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ", អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) ជាលេខាធិការជូន គ.ហ.ស. រៀបចំរបាយការណ៍ត្រួតពិនិត្យតាមដានវឌ្ឍនភាពប្រចាំត្រីមាស និងប្រចាំឆ្នាំ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ ដើម្បីដាក់ឆ្លងកិច្ចប្រជុំ គ.ហ.ស. ពិនិត្យ និងសម្រេច ។ របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០១៩ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ បង្ហាញអំពីការបូកសរុបលទ្ធផលរួមគ្នាទាំងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័ន ព្រមទាំងដោះស្រាយបញ្ហាប្រឈមនៃការអនុវត្តលិខិតបទដ្ឋានគតិយុត្តមួយចំនួន កន្លងមកផងដែរ ។

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ ត្រូវបានកំណត់ និងដាក់ចេញនូវគោលដៅអាទិភាពចំនួន ៣ រួមមាន (១) ពង្រឹងការគ្រប់គ្រង និងការអនុវត្តផែនការប្រមូលចំណូល និងចំណាយ, (២) ពង្រឹង និងពង្រីកការដាក់ឱ្យអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) និង (៣) ពង្រឹងនិងពង្រីកការអនុវត្តថវិកាកម្មវិធី ។

ក្នុងកិច្ចដំណើរការរៀបចំរបាយការណ៍វឌ្ឍនភាពឆ្នាំ២០១៩ ដោយមានការអនុញ្ញាតពី គ.ហ.ស., អ.គ.ហ. បានជ្រើសរើសវិធីសាស្ត្រចំនួន ៣ ដើម្បីធ្វើការសិក្សា និងរៀបចំរបាយការណ៍នេះឡើង ក្នុងនោះរួមមាន (១) ការត្រួតពិនិត្យតាមដាន និងបូកសរុបវឌ្ឍនភាព ស្របតាមក្របខ័ណ្ឌផែនការសកម្មភាពរួម ដំណាក់កាលទី៣ ឆ្នាំ២០១៩-២០២០, (២) ការចុះជួបពិភាក្សាជាមួយក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅតាមក្រសួង-ស្ថាប័ន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការរៀបចំ និងអនុវត្តផែនការសកម្មភាព (MAP/GDAP) ឆ្នាំ២០១៩ ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងគោលដៅពិនិត្យចំណុចអាទិភាព រួមមាន ការគ្រប់គ្រងការប្រមូលចំណូល និងចំណាយ (ការគ្រប់គ្រងចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ និងការគ្រប់គ្រងទ្រព្យ-សម្បត្តិរដ្ឋ), ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ចំណាត់ថ្នាក់ថវិកា, របាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាគណនេយ្យសម្រាប់វិស័យសាធារណៈអន្តរជាតិ (IPSAS), សន្ទានកម្មរវាងប្រព័ន្ធ FMIS និងប្រព័ន្ធផ្សេងទៀត, ការគ្រប់គ្រងការផ្លាស់ប្តូរ និងព័ត៌មានពីអ្នកប្រើប្រាស់ប្រព័ន្ធ), ផែនការយុទ្ធសាស្ត្រថវិកានិងថវិកាកម្មវិធី (ការផ្សារភ្ជាប់រវាងផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធី, លក្ខណៈសម្បត្តិអង្គភាពថវិកា និងការត្រួតពិនិត្យថវិកាកម្មវិធី) និង (៣) ការចូលរួមពីដៃគូអភិវឌ្ឍន៍ (សហភាពអឺរ៉ុប, ធនាគារអភិវឌ្ឍន៍អាស៊ី, ធនាគារពិភពលោក, អង្គការយូនីសេហ្វ និងមូលនិធិរូបិយវត្ថុអន្តរជាតិ) លើការគ្រប់គ្រងការផ្លាស់ប្តូរ និងការតម្រង់ទិសនីតិវិធីអនុវត្តការងារ និងការត្រួតពិនិត្យលើសមានគតិភាពរវាងផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធី ។

របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០១៩ ត្រូវបានបែងចែកជា ៤ ផ្នែកសំខាន់ៗ រួមមាន (១) សេចក្តីផ្តើមដែលបង្ហាញអំពីស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, គោលបំណង និងវិធីសាស្ត្រនៃការរៀបចំរបាយកាណ៍, (២) វឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

និងក្រសួង-ស្ថាប័ន, (៣) បញ្ហាប្រឈម និងសំណើដំណោះស្រាយផ្តោតលើការងារគន្លឹះៗ ដើម្បីសម្រេចឱ្យបានក្នុងឆ្នាំ២០២០ និង (៤) សន្និដ្ឋានលើលទ្ធផលរួមនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

ផ្អែកលើវឌ្ឍនភាពប្រចាំឆ្នាំ២០១៩, អ.គ.ហ. ពិនិត្យឃើញថា វឌ្ឍនភាពដែលបាននិងកំពុងលេចរូបរាងឡើងនេះ បាននិងកំពុងពង្រឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាបណ្តើរៗ តាមរយៈការរៀបចំ និងការកែលម្អប្រព័ន្ធក្របខណ្ឌគតិយុត្ត យន្តការស្ថាប័ន និងការអភិវឌ្ឍន៍ធនធានមនុស្ស ។ ទោះបីជាយ៉ាងនេះក្តី ខ្ញុំសូមកត់សម្គាល់ថា ប្រសិទ្ធភាពនៃការអនុវត្តប្រព័ន្ធ និងលិខិតបទដ្ឋានគតិយុត្ត បង្ហាញថានៅមានកម្រិត ដែលទាមទារឱ្យមានការយកចិត្ត-ទុកដាក់ និងពង្រឹងបន្ថែម ។

ខ្ញុំរំពឹងថា របាយការណ៍វឌ្ឍនភាពនេះ នឹងក្លាយជាធាតុចូលដ៏សំខាន់ សម្រាប់ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅតាមក្រសួង-ស្ថាប័ន និងក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់រៀបចំ និងកែសម្រួលផែនការសកម្មភាព (MAP/GDAP) ឱ្យកាន់តែមានគុណភាព ស្របតាមក្របខណ្ឌផែនការសកម្មភាពរួម ដំណាក់កាលទី៣ ជាមួយនឹងការអនុវត្តប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ។

ជាចុងបញ្ចប់ ក្នុងនាម អ.គ.ហ. និងរូបខ្ញុំផ្ទាល់ សូមសម្តែងកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតជូនឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាន គ.ហ.ស. ដែលបានផ្តល់អនុសាសន៍ណែនាំដ៏មានតម្លៃ និងតម្រង់ទិសដល់ អ.គ.ហ. និងក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទាំងការរៀបចំ និងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមទាំងកិច្ចសហ-ប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ ឱ្យសម្រេចបានតាមគោលដៅប្រកបដោយជោគជ័យ និងចីរភាព ។

ថ្ងៃ សុក្រ ១៥កើត ខែ ជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០២០

**អគ្គលេខាធិការ**

**អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំ**

**ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**រស់ សីលវ៉ា**

# អក្សរកាត់

| | | |
|---|---|---|
| ADB | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| BSP | Budget Strategic Plan | ផែនការយុទ្ធសាស្ត្រថវិកា |
| BSRS | Budget System Reform Strategy | យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា |
| CAP | Consolidated Action Plan | ផែនការសកម្មភាពរួម |
| CoA | Chart of Accounts | ប្លង់គណនេយ្យ |
| DMFAS | Debt Management and Financial Analysis System | ប្រព័ន្ធវិភាគហិរញ្ញវត្ថុ និងគ្រប់គ្រងបំណុល |
| EFI | Economics and Finance Institute | វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (វសហ.) |
| GDICDM | General Department of Cooperation and Debt Management | អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល (អ.ស.ប.) |
| FMIS | Financial Management Information System | ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| FMWG | FMIS project Management Working Group | ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| GDB | General Department of Budget | អគ្គនាយកដ្ឋានថវិកា (អ.ថ.) |
| GDCE | General Department of Customs and Excise | អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (អ.គ.រ.) |
| GDIA | General Department of Internal Audit | អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង (អ.ស.ក.) |
| GDNT | General Department of National Treasury | អគ្គនាយកដ្ឋានរតនាគារជាតិ |
| GDPP | General Department of Public Procurement | អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ |
| GDSNAF | General Department of Sub-National Administration Finance | អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ |
| GDSPNR | General Department of State Property and Non-Tax Revenue | អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ (អ.ទ.ច.) |
| GDT | General Department of Taxation | អគ្គនាយកដ្ឋានពន្ធដារ (អ.ព.ដ.) |
| GDP | General Department of Policy/ Gross Domestic Product | អគ្គនាយកដ្ឋានគោលនយោបាយ/ ផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) |
| GFS | Government Finance Statistics | ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល |
| GSC | General Secretariat of Public Financial Management Reform Steering Committee | អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(អ.គ.ហ.) |
| IMF | International Monetary Fund | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| LM | Line Ministry | ក្រសួង-ស្ថាប័ន |
| LCs | Legal Council Secratariat | លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម (លកន) |
| MEF | Ministry of Economy and Finance | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ.) |
| MTBF | Medium-Term Budget Framework | ក្របខណ្ឌថវិការយៈពេលមធ្យម |

| | | |
|---|---|---|
| MTFF | Medium-Term Fiscal Framework | ក្របខណ្ឌហិរញ្ញវត្ថុរយៈពេលមធ្យម |
| NAA | National Audit Authority | អាជ្ញាធរសវនកម្មជាតិ |
| NSDP | National Strategic Development Plan | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| PFM | Public Financial Management | ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| TOFE | Table of Fiscal and Economic Operations of the Government | តារាងប្រតិបត្តិការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរដ្ឋាភិបាល |
| WB | World Bank | ធនាគារពិភពលោក |
| PFMRC | Public Financial Management Reform Commission | គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| PFMSC | Public Financial Management Reform Steering Committee | គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| MoEYS | Ministry of Edcation, Youth and Sport | ក្រសួងអប់រំ យុវជន និងកីឡា |
| EFMS | Education Financial Management System | ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា |
| PB | Program Budgeting | ថវិកាកម្មវិធី |
| NRMIS | Non-tax Reveue Management Information System | ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ |
| SARMIS | State Asset Register Management Information System | ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងសារពើភណ្ឌទ្រព្យ-សម្បត្តិរដ្ឋ |

## បញ្ជីដ្យាក្រាម


ដ្យាក្រាមទី 1 ÷ ការអនុវត្តផែនការប្រមូលចំណូល ........................................ 4
ដ្យាក្រាមទី 2 ÷ ការអនុវត្តថវិការដ្ឋឆ្នាំ២០១៣-២០១៩ ........................................ 4
ដ្យាក្រាមទី 3 ÷ វឌ្ឍនភាពតាមផ្នែកនៃ CAP3 (២០១៦-២០១៩) ........................................ 7
ដ្យាក្រាមទី 4 ÷ ការអនុវត្តសូចនាករសមិទ្ធកម្មគន្លឹះទាំង ៦ ........................................ 8
ដ្យាក្រាមទី 5 ÷ ការអនុវត្តផែនការប្រមូលចំណូលមិនមែនសារពើពន្ធ ........................................ 34


## បញ្ជីតារាង


តារាងទី 1 ÷ ផែនការអនុវត្តថវិកាកម្មវិធីនៅរដ្ឋបាលរាជធានី-ខេត្ត ........................................ 24
តារាងទី 2 ÷ ការប្រែប្រួលក្របខណ្ឌផែនការសកម្មភាពរួមដំណាក់កាលទី២ និងដំណាក់កាលទី៣ ........................................ 2
តារាងទី 3 ÷ សន្និធិបំណុលសាធារណៈ ឆ្នាំ២០១៣ - ២០១៩ ........................................ 5

# សេចក្តីសង្ខេប

១. សុខុមាលភាពប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាឆ្អឹងខ្នងគាំទ្រការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាឱ្យសម្រេចបានប្រកបដោយជោគជ័យ និងចីរភាព ។ ចាប់តាំពីឆ្នាំ២០០៥ រហូតមកដល់បច្ចុប្បន្ន កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បាននិងកំពុងកសាង "**ប្រព័ន្ធ ក្របខណ្ឌគតិយុត្ត យន្តការស្ថាប័ន និងធនធានមនុស្ស**[1]" ដែលជាកត្តាគន្លឹះកំណត់ភាពជោគជ័យ ធានាវិន័យ តម្លាភាព គណនេយ្យភាព ស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព នៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។




២. គោលបំណងនៃការរៀបចំរបាយការណ៍វឌ្ឍនភាព ប្រចាំឆ្នាំ ២០១៩ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺមិនត្រឹមតែពិនិត្យប្រសិទ្ធភាពនៃការអនុវត្តផែនការសកម្មភាពកែទម្រង់ប៉ុណ្ណោះទេ ប៉ុន្តែលើកកម្ពស់ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងការផ្តល់ជាធាតុចូលសម្រាប់រៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០១៩ ក្នុងនោះរួមមាន អង្គភាពក្រោមឱវាទ កសហវ., ក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ ។ ក្នុងន័យនេះ, របាយការណ៍ប្រចាំឆ្នាំ២០១៩ ដែលរៀបចំ និងបូកសរុបដោយ អ.គ.ហ. នឹងក្លាយជារបាយការណ៍រួមរបស់គ្រប់តួអង្គក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

៣. អគ្គនាយកដ្ឋានពន្ធដារ បានបន្តធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ ដោយសិក្សារៀបចំផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាព័ត៌មាន ដោយបង្កើតឱ្យមានមជ្ឈមណ្ឌលរក្សាទិន្នន័យរួមរបស់អគ្គនាយកដ្ឋានពន្ធដារ, រៀបចំធ្វើបច្ចុប្បន្នភាព និងសិក្សារៀបចំបន្ថែមនូវបទប្បញ្ញត្តិស្តីពីពន្ធដារ សម្រាប់គាំទ្រដល់ការគ្រប់គ្រងការប្រមូលចំណូលពន្ធ និងការបន្តធ្វើបច្ចុប្បន្នភាពព័ត៌មានអចលនទ្រព្យទាំងអស់នៅរាជធានីភ្នំពេញ និងនៅតាមតំបន់ដែលជាកម្មវត្ថុនៃពន្ធលើអចលនទ្រព្យ ។ រីឯ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នឹងបន្តធ្វើទំនើបកម្មរដ្ឋបាលពន្ធគយបន្ថែមទៀត ។ ប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) បានដាក់ឱ្យប្រើប្រាស់ជាផ្លូវការចំនួន ១៤ ក្រសួង-ស្ថាប័ន កាលពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០១៨[2] និង ៩ ក្រសួង-ស្ថាប័ន បន្ថែមនៅក្នុងខែតុលា ឆ្នាំ២០១៨ ហើយគ្រោងនឹងដាក់ឱ្យអនុវត្តនៅមន្ទីរជំនាញរាជធានី-ខេត្តចំនួន ១៨ ។ ជាទិសដៅបន្ត ការបង់ចំណូលមិនមែនសារពើពន្ធតាមរយៈបណ្តាញអេឡិចត្រូនិក E-PAYMENT ដោយជំហានទី១ ត្រូវបានគិតគូរលើចំណូលមិនមែនសារពើពន្ធពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង កសហវ.។

---

[1] *-ប្រព័ន្ធ មិនត្រឹមតែសំដៅលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសំដៅលើកិច្ចដំណើរការរបស់ក្រសួង-ស្ថាប័ន ឱ្យស្របតាមបរិបទកែទម្រង់*
*-យន្តការ សំដៅលើការបង្កើត/រៀបចំយន្តការដោះស្រាយបញ្ហាប្រឈម ឬការអនុវត្តតាមទិសដៅនៃការកែទម្រង់*
*-ក្របខណ្ឌគតិយុត្ត សំដៅលើការរៀបចំច្បាប់, អនុក្រឹត្យ, ប្រកាស, សារាចរ ជាដើម និង*
*-ធនធានមនុស្ស សំដៅលើការកសាង/អភិវឌ្ឍសមត្ថភាពទាំងបច្ចេកទេស និងភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។*

[2] *សារាចរណែនាំលេខ ០០៣ សហវ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨ និងសេចក្តីជូនដំណឹងលេខ ០០២ សហវ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨ ។*

៤. គម្រោង FMIS ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តជំហានទី១ នៅឆ្នាំ២០១៤ និងជំហានទី២ នៅឆ្នាំ២០១៧ ។ មុខងារស្នូល និងចំណាត់ថ្នាក់ថវិកាត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធ FMIS ជាបន្តបន្ទាប់ស្របតាមជំហានយុទ្ធសាស្ត្រនៃប្រព័ន្ធ ។ ជាក់ស្តែងមុខងារស្នូលទាំង ៦ រួមមាន (១) មុខងារវិភាជន៍ថវិកា, (២) មុខងារគណនីត្រូវសង, (៣) មុខងារគណនីត្រូវទារ, (៤). មុខងារគ្រប់គ្រងសាច់ប្រាក់ (៥) មុខងារការទិញ និង (៦). មុខងារសៀវភៅធំ ។

ចំណាត់ថ្នាក់នៃចាតិកាថវិកា




ក្រុមការងារ FMIS បាននិងកំពុងអភិវឌ្ឍមុខងារបន្ថែមចំនួន ២ គឺមុខងាររៀបចំផែនការថវិកា និងមុខងារលទ្ធកម្ម និងគ្រប់គ្រងកិច្ចសន្យា ។ មុខងារទាំង ២ នេះ នឹងត្រូវដាក់ឱ្យអនុវត្តសាកល្បង ក្នុងឆ្នាំ២០២១ នៅ កសហវ. និង ១ ក្រសួង ផ្សេងទៀត ។ រីឯ មុខងារចំនួន ២ ទៀត គឺមុខងារគ្រប់គ្រងទ្រព្យសម្បត្តិ និងមុខងារគ្រប់គ្រងសន្និធិ

មុខងារក្នុងប្រព័ន្ធ FMIS




នឹងត្រូវគិតគូរក្នុងជំហានបន្ទាប់ ។ ទន្ទឹមនេះ, កសហវ. បានធ្វើការកែសម្រួលប្លង់គណនេយ្យថ្មីឱ្យស្របតាមស្តង់ដារអន្តរជាតិ ព្រមទាំងបានរៀបចំ និងដាក់ឱ្យអនុវត្តប្រកាសស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់ទាំង ៧[3] រួមមាន (១) ចំណាត់ថ្នាក់អង្គភាពប្រតិបត្តិ និងរដ្ឋបាល, (២) ចំណាត់ថ្នាក់ភូមិសាស្ត្រ, (៣) ចំណាត់ថ្នាក់សេដ្ឋកិច្ច (៤) ចំណាត់ថ្នាក់កម្មវិធី, (៥) ចំណាត់ថ្នាក់មុខងារ, (៦) ចំណាត់ថ្នាក់គម្រោង និង (៧) ចំណាត់ថ្នាក់មូលនិធិ ។ ទន្ទឹមនេះ ផែនការពង្រីកប្រព័ន្ធ FMIS មានដូចខាងក្រោម ÷

[3] នាពេលបច្ចុប្បន្ន ចំណាត់ថ្នាក់ថវិកាចំនួន ៧ រួមមាន ÷ សេដ្ឋកិច្ច, កម្មវិធី, រដ្ឋបាល, មុខងារ, ភូមិសាស្ត្រ, មូលនិធិ និងគម្រោង។ ចំណាត់ថ្នាក់ថវិកាចំនួន ២ (មុខងារ និងភូមិសាស្ត្រ) មានបញ្ហាប្រឈមពាក់ព័ន្ធនឹងគុណភាពទិន្នន័យ ដែលចាំបាច់ត្រូវជំរុញការអនុវត្ត និងធ្វើការកែលម្អ ។

- **ឆ្នាំ២០១៨**÷ ក្រសួង-ស្ថាប័នចំនួន ១០ ត្រូវបានដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS ជាផ្លូវការ ក្នុងនោះរួមមាន (១) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, (២) ក្រសួងអប់រំ យុវជន និងកីឡា, (៣) ក្រសួងសុខាភិបាល, (៤) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, (៥) ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, (៦) ក្រសួងកិច្ចការនារី, (៧) ក្រសួងបរិស្ថាន, (៨) ក្រសួងមុខងារសាធារណៈ, (៩) ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និង (១០) ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងអង្គភាពថវិកាដែលជាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ១២ ។
- **ឆ្នាំ២០១៩**÷ ក្រសួង-ស្ថាប័ន ចំនួន ១០ បន្ថែម និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត ទាំង២៥ ត្រូវបានដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS ។ ក្រសួង-ស្ថាប័នទាំង ១០ រួមមាន (១) ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, (២) ក្រសួងសាធារណការ និងដឹកជញ្ជូន, (៣) ក្រសួងអភិវឌ្ឍន៍ជនបទ, (៤) ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, (៥) ក្រសួងទេសចរណ៍, (៦) ក្រសួងពាណិជ្ជកម្ម, (៧) ក្រសួងធនធានទឹក និងឧតុនិយម, (៨) ក្រសួងព័ត៌មាន, (៩) រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និង (១០) ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។
- **ឆ្នាំ២០២០**÷ ក្រសួង-ស្ថាប័នចំនួន ១៧ បន្ថែម រួមមាន (១) អគ្គលេខាធិការដ្ឋានរដ្ឋសភា, (២) អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា, (៣) ក្រសួងព្រះបរមរាជវាំង, (៤) ក្រុមប្រឹក្សាធម្មនុញ្ញ, (៥) ទីស្តីការគណៈរដ្ឋមន្ត្រី, (៦) ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, (៧) ក្រសួងមហាផ្ទៃ, (៨) ក្រសួងការពារជាតិ, (៩) ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច, (១០) ក្រសួងរ៉ែ និងថាមពល, (១១) ក្រសួងធម្មការ និងសាសនា, (១២) ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, (១៣) ក្រសួងផែនការ, (១៤) អាជ្ញាធរសវនកម្មជាតិ, (១៥) អង្គភាពប្រឆាំងអំពើពុករលួយ, (១៦) ក្រសួងយុត្តិធម៌ (រួមទាំងអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាអង្គចៅក្រម, តុលាការកំពូល និងសាលាឧទ្ធរណ៍) និង (១៧) គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ព្រមទាំងអង្គភាពថវិកាដែលជាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ១៣ នឹងត្រូវដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS ជាផ្លូវការ ។

៥. ក្រៅពីមុខងារស្នូល និងមុខងារបន្ថែមថ្មីខាងលើ ប្រព័ន្ធ FMIS ក៏បានរៀបចំ អភិវឌ្ឍ និងដាក់ឱ្យដំណើរការរួចរាល់នូវមុខងារសន្ធានកម្មមួយចំនួន រួមមាន (១) សន្ធានកម្មរបាយការណ៍ធនាគារ (Bank Statement) ជាមួយធនាគារជាតិនៃកម្ពុជា, ធនាគារកាណាឌីយ៉ា, ធនាគារអេស៊ីលីដា, ធនាគារកម្ពុជាសាធារណៈ, ធនាគារវឌ្ឍនៈ និងធនាគារ ANZ Royal, (២) សន្ធានកម្មការទូទាត់តាមអេឡិចត្រូនិក (EFT) ជាមួយធនាគារជាតិនៃកម្ពុជា, (៣) សន្ធានកម្មចំណូលពន្ធគយ និងរដ្ឋាករជាមួយប្រព័ន្ធ ASYCUDA របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, (៤) សន្ធានកម្មចំណូលមូលធនជាមួយប្រព័ន្ធ DMFAS របស់អគ្គនាយកដ្ឋានសហប្រតិបត្តិការ និងគ្រប់គ្រងបំណុល និង (៥) សន្ធានកម្មចំណូលមិនមែនសារពើពន្ធ ជាមួយប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធរបស់អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ។




៦. អង្គភាពហិរញ្ញវត្ថុ និងគ្រប់អង្គភាពថវិកាដែលជាអាណាប័កផ្ទេរសិទ្ធិពេញលេញ បានអនុវត្តប្រព័ន្ធ FMIS នេះ ជាមួយនឹងអ្នកប្រើប្រាស់សរុបជាង ១៣០០ នាក់ នៅឆ្នាំ២០១៩ និងត្រូវបានប៉ាន់ស្មានថានឹងកើនឡើងរហូតដល់ជា ១ ៧០០ នាក់ នៅឆ្នាំ២០២០ ។ សម្រាប់ផែនការសកម្មភាពអាទិភាពនៃប្រព័ន្ធ FMIS ដំណាក់កាលទី២ នៅឆ្នាំ២០១៩ ផ្ដោតលើការងារសំខាន់ៗ រួមមាន (១) ពង្រីកការប្រើប្រាស់ប្រព័ន្ធ FMIS, (២) អភិវឌ្ឍរបាយការណ៍ហិរញ្ញវត្ថុចេញពីប្រព័ន្ធ FMIS, (៣) ការរៀបចំមុខងារ FMIS ថ្មី, (៤) បន្តធ្វើសន្ធានកម្មជាមួយប្រព័ន្ធផ្សេងទៀត និង (៥) តម្រង់ទិសនីតិវិធីអនុវត្តការងារ (Busniess process streamling) ។

៧. បន្ថែមពីនេះ ផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តតាមប្រព័ន្ធ FMIS ឆ្នាំ 2020-2025 ត្រូវបានដាក់ឱ្យអនុវត្ត ក្នុងកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ។

៨. ផែនការពង្រីកការអនុវត្តគម្រោង FMIS ដំណាក់កាលទី៣ (២០២១-២០២៥) នឹងត្រូវរៀបចំឡើង និងដាក់ឱ្យអនុវត្តនៅក្នុងឆ្នាំ២០២១ ខាងមុខ និងរំពឹងថាមានវិសាលភាពគ្របដណ្ដប់ការពង្រីកការអនុវត្តលើមុខងារស្នូលទៅរដ្ឋបាលរាជធានី-ខេត្ត ទាំង២៥, មន្ទីរជំនាញអាទិភាពនៅទូទាំងប្រទេស, អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនៅថ្នាក់កណ្ដាល រួមទាំងថ្នាក់មូលដ្ឋានថ្មីៗ បន្ថែមទៀត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល, ការពង្រីកការអនុវត្តមុខងាររៀបចំផែនការថវិកា និងមុខងារពាក់ព័ន្ធនឹងកិច្ចលទ្ធកម្ម និងការគ្រប់គ្រងកិច្ចសន្យា ទៅគ្រប់ក្រសួង-ស្ថាប័ន និងអង្គភាពនៅថ្នាក់មូលដ្ឋាន, និងការគិតគូររៀបចំ និងអភិវឌ្ឍបន្ថែមលើមុខងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងគ្រប់គ្រងសន្និធិ នៅក្នុងប្រព័ន្ធ FMIS ។

៩. ប្រព័ន្ធគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋតាមបច្ចេកវិទ្យាព័ត៌មាន ត្រូវបានផ្ដួចផ្ដើមឡើងចាប់ពីឆ្នាំ២០១៦ មក ក្នុងគោលបំណងត្រួតពិនិត្យ តាមដាន កត់ត្រា និងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ តាមក្រសួង-ស្ថាប័ន, អង្គភាពប្រើប្រាស់ និងអង្គភាពកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

១០. ការអនុវត្តថវិកាកម្មវិធី ត្រូវបាននិងកំពុងដាក់ឱ្យអនុវត្តគ្រប់ក្រសួង-ស្ថាប័ន និងគ្រប់រដ្ឋបាលរាជធានី-ខេត្ត ។ ជាវឌ្ឍនភាព ក្រសួង-ស្ថាប័ន ចំនួន ១០ អនុវត្តថវិកាកម្មវិធី ក្នុងឆ្នាំ២០១៥, ក្រសួង-ស្ថាប័ន ចំនួន ១៥ ក្នុងឆ្នាំ២០១៦ និងក្រសួង-ស្ថាប័ន ចំនួន ១១ ក្នុងឆ្នាំ២០១៧ និង ក្រសួង-ស្ថាប័ន ចំនួន ៣ ក្នុងឆ្នាំ២០១៨ សរុបចំនួន

៣៩ ក្រសួង-ស្ថាប័ន ។ រីឯ រដ្ឋបាលរាជធានី-ខេត្ត ត្រូវបានដាក់ឱ្យអនុវត្តថវិកាកម្មវិធីចាប់ពីឆ្នាំ២០១៧ ដល់ ២០២១ ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបណ្តុះបណ្តាលលើការរៀបចំផែនការយុទ្ធសាស្ត្រថវិកា, ការរៀបចំ និង ការអនុវត្តថវិកាកម្មវិធី, នីតិវិធីអនុវត្តកិច្ចលទ្ធកម្មសាធារណៈ និងនីតិវិធីចំណាយរដ្ឋទេយ្យបុរេប្រទាន ជាដើម ។ ជាជំហានបន្ទាប់, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងជ្រើសរើសក្រសួង-ស្ថាប័ន សម្រាប់ធ្វើការត្រួតពិនិត្យសូចនាករ លទ្ធផលក្នុងឆ្នាំ, ការអនុវត្តថវិកាកម្មវិធី និងផែនការយុទ្ធសាស្ត្រថវិកា ព្រមទាំងអង្គភាពថវិកា ដើម្បីកំណត់ ចំណុចខ្លាំង និងចំណុចខ្សោយ ដើម្បីផ្តល់អនុសាសន៍សម្រាប់ធ្វើការពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី ។ មកដល់ពេលនេះ, អង្គភាពថវិកាចំនួន ៩១២ ក្នុងនោះអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិចំនួន ៦៦៤ និងមិនទាន់ ផ្ទេរសិទ្ធិចំនួន ២៤៨ ។ សម្រាប់ថ្នាក់កណ្តាលមានចំនួន ៣០៨ ក្នុងនោះអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិ ចំនួន ៦០ និងមិនទាន់ផ្ទេរសិទ្ធិចំនួន ២៤៨ និងសម្រាប់ថ្នាក់មូលដ្ឋានមានចំនួន ៦០៤ ជាអាណាប័កផ្ទេរសិទ្ធិទាំងអស់ ។

១១. យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥ ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រី នៅដើម ត្រីមាសទី១ ឆ្នាំ២០១៨ ។ រីឯ ផែនការសកម្មភាពលម្អិតសម្រាប់អនុវត្តយុទ្ធសាស្ត្រនេះ ត្រូវបានដាក់ឱ្យអនុវត្ត នៅពាក់កណ្តាល ឆ្នាំ២០១៩ ។ តាមរយៈយុទ្ធសាស្ត្រខាងលើ ប្រព័ន្ធថវិកាកម្ពុជា ត្រូវបានកំណត់ជាប្រព័ន្ធថវិកា ព័តិមានសមិទ្ធកម្ម ឬថវិកាសមិទ្ធកម្ម ។ យុទ្ធសាស្ត្រចំនួន ៤ ផ្សេងទៀត រួមមាន (១) យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣, (២) យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១៩-២០២៥, និង (៣) យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ត្រូវបានអនុម័ត ក្នុងអំឡុងត្រីមាសទី២ ឆ្នាំ២០១៩ រីឯ (៤) យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥ ត្រូវបានអនុម័ត ក្នុងអំឡុងត្រីមាសទី៤ ឆ្នាំ២០១៩ ។ រីឯផែនការសកម្មភាពលម្អិតសម្រាប់អនុវត្តយុទ្ធសាស្ត្រទាំង ៤ ខាងលើ ត្រូវបានឯកភាព និង ដាក់ឱ្យអនុវត្តក្នុងខែមីនា ឆ្នាំ២០២០ ។

១២. ទោះបីជាមានការវិវឌ្ឍគួរឱ្យកត់សម្គាល់នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏នៅមាន ការងារដែលត្រូវធ្វើ ដើម្បីសម្រេចនូវជំហានទី៣ "**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**" ក្នុងនោះរួមមាន (១) **កត្តាស្ថាប័ន** ÷ ភាពជាអ្នកដឹកនាំ ឆន្ទៈ ការយល់ដឹង និងការចូលរួមរបស់ក្រសួង-ស្ថាប័ន កើនឡើងជាលំដាប់ ប៉ុន្តែនៅពុំទាន់គ្រប់គ្រាន់ក្នុងការជំរុញការងារកែទម្រង់ឱ្យកាន់តែមានសន្ទុះ ជាពិសេសកម្រិតថ្នាក់ដឹកនាំ ជាន់ខ្ពស់ និង (២) ខណៈតួនាទីរបស់ក្រសួង-ស្ថាប័ន កាន់តែមានសារៈសំខាន់ឡើង ក្នុងការចូលរួម និងអនុវត្ត កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ក្រសួង-ស្ថាប័នចាំបាច់ត្រូវពង្រឹងការចូលរួមបន្ថែមទៀត លើ ការងារកែទម្រង់ពាក់ព័ន្ធនឹងការពង្រឹងការគ្រប់គ្រងការប្រមូលចំណូលមិនមែនសារពើពន្ធ, ការអនុវត្តប្រព័ន្ធ FMIS, ការរៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធី និងការអនុវត្តលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធវិស័យហិរញ្ញវត្ថុសាធារណៈ ប្រកបដោយប្រសិទ្ធភាព ។

១៣. ជាមួយគ្នានេះ ការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ទាំងជំនួយបច្ចេកទេស និងហិរញ្ញប្បទានទាំងឥតសំណង និងមាន សំណង បានរួមចំណែកក្នុងការដោះស្រាយបញ្ហាប្រឈមនៃការអនុវត្តកម្មវិធីកែទម្រង់ និងការផ្តល់ធាតុចូលសម្រាប់ ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់ ។ ក្នុងដំណាក់កាលទី៣នេះ ដៃគូអភិវឌ្ឍន៍ ដែលគាំទ្រកម្មវិធីកែទម្រង់ រួមមាន ***សហភាពអឺរ៉ុប, ក្រសួងហិរញ្ញវត្ថុនៃសាធារណរដ្ឋបារាំង, ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត, ធនាគារអភិវឌ្ឍន៍ អាស៊ី, អង្គការយូនីសេហ្វ, ធនាគារពិភពលោក, មូលនិធិរូបិយវត្ថុអន្តរជាតិ និងក្រសួងរតនាគារសហរដ្ឋអាមេរិក ។***

១៤. រាជរដ្ឋាភិបាលសម្រេចបាននូវវឌ្ឍនភាពគន្លឹះៗជាច្រើន ដើម្បីកសាងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្របតាមនិយាម និងឧត្តមានុវត្តអន្តរជាតិ ។ រហូតមកដល់ឆ្នាំ២០១៩ នេះ, ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំពុងបន្តជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន ដូចខាងក្រោម ÷

ទី១) ការគៀរគរចំណូលទទួលបានលទ្ធផលល្អ ប៉ុន្តែនៅមិនទាន់មានចីរភាពពេញលេញនៅឡើយ ។ ម្យ៉ាង, ទោះបីជាការប្រមូលចំណូលពន្ធកៀកនឹងសក្តានុពល, ប៉ុន្តែរចនាសម្ព័ន្ធចំណូលមិនទាន់មានភាពរឹងមាំ ដែលអាចធានាបាននូវចីរភាពក្នុងរយៈពេលវែង នៅឡើយ ។ ម៉្យាងទៀត, ការប្រមូលចំណូលមិនមែនសារពើពន្ធ ក៏នៅមានសក្តានុពលគួរកត់សម្គាល់ ។ លើសពីនេះ, ការធ្វើស្ថាបនីយកម្មយន្តការប្រមូល និងការគ្រប់គ្រងចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ នៅមានលទ្ធភាពកែលម្អបន្ថែមទៀត ។

ទី២) ប្រព័ន្ធ FMIS ជាប្រព័ន្ធស្នូលនៃគណនេយ្យភាពហិរញ្ញវត្ថុ ហើយត្រូវបានពង្រីក និងដាក់ឱ្យអនុវត្តគ្រប់ក្រសួង-ស្ថាប័ន ។ ចំណូល-ចំណាយថវិកាជាតិ និងថ្នាក់ក្រោមជាតិ ដែលឆ្លងកាត់រតនាគារជាតិ ត្រូវបានកត់ត្រាទាំងស្រុងក្នុងប្រព័ន្ធ FMIS តាមចំណាត់ថ្នាក់ថវិកាទាំង៧ និងតាមប្លង់គណនេយ្យសាធារណៈ ។ បន្ថែមពីនេះ របាយការណ៍ចំណូល-ចំណាយថវិកាជាតិប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ តារាងតុល្យភាពថវិកា អាចផលិតចេញពីប្រព័ន្ធ FMIS ។ ប៉ុន្តែប្រព័ន្ធ FMIS នៅមិនទាន់អាចផលិតបាននូវរបាយការណ៍គ្រប់ជ្រុងជ្រោយ និងមិនទាន់បានធ្វើស្វ័យប្រវត្តិកម្មការអនុវត្តថវិកានៅឡើយ មានន័យថា ការអនុវត្តថវិកានៅត្រូវប្រើក្រដាសស្នាមផង និងប្រើប្រព័ន្ធ FMIS ផង ដែលការងារមួយចំនួន មានលក្ខណៈត្រួតគ្នា ។

ទី៣) ការអនុវត្តថវិកាកម្មវិធី និងអង្គភាពថវិកា ÷ កសហវ. បានយកចិត្តទុកដាក់លើការកែលម្អនូវគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី, ការយកចិត្តទុកដាក់លើការពង្រឹងការអនុវត្តខ្លឹមសារនៃសារាចរណែនាំការកែលម្អខ្លឹមសារ ក្នុងគោលដៅពង្រឹងការផ្សារភ្ជាប់រវាងផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធី ក្នុងគោលដៅធ្វើឱ្យប្រព័ន្ធថវិកា កាន់តែក្លាយទៅជាឧបករណ៍គោលនយោបាយយ៉ាងពិតប្រាកដក្នុងការវិភាជ និងប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ។ ពិតមែនតែត្រូវបានដាក់ឱ្យអនុវត្តនៅគ្រប់ក្រសួង-ស្ថាប័ន ថ្នាក់ជាតិ ប៉ុន្តែគុណភាពនៃកម្មវិធី នៅមិនទាន់ពេញលេញ តាមការចង់បាននៅឡើយ ទាំងខ្លឹមសារ, រចនាសម្ព័ន្ធ និងសមិទ្ធកម្ម ។ លើសពីនេះ ការរៀបចំកម្មវិធីរបស់ក្រសួង-ស្ថាប័នមួយចំនួន នៅចំណុះទៅនឹងរចនាសម្ព័ន្ធរដ្ឋបាល ដែលធ្វើឱ្យមានការលំបាកខ្លះក្នុងការផ្សារភ្ជាប់កម្មវិធីទៅនឹងគោលបំណងគោលនយោបាយ ក៏ដូចជាការផ្សារភ្ជាប់កម្មវិធីទៅនឹងការអនុវត្តជាក់ស្តែង ។ ម៉្យាងទៀត, ក្រសួង-ស្ថាប័នមួយចំនួនក៏នៅរក្សាការគ្រប់គ្រងថវិកាតាមបែបប្រមូលផ្តុំនៅឡើយ ដោយអនុញ្ញាតឱ្យមានអង្គភាពថវិកាចំនួនតិចតួច ដែលមានន័យថាថវិកាផ្តល់ដល់អង្គភាពអនុវត្តផ្ទាល់ ក៏មានតិចតួចផងដែរ ។

ទី៤) នីតិវិធីនៃការអនុវត្តថវិកាត្រូវបានកែលម្អច្រើន, ប៉ុន្តែនៅមិនទាន់អាចធានាបាននូវភាពឆាប់រហ័ស, ភាពត្រឹមត្រូវ និងភាពអាចប៉ាន់ប្រមាណបាន តាមការរំពឹងទុកនៅឡើយ ។ ការងារនេះមិនមែនជាការងារដាច់ដោយឡែករបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនោះទេ ប៉ុន្តែក៏ជាការងារផ្ទាល់របស់ក្រសួង-ស្ថាប័នផងដែរ ។ កសហវ. បានធ្វើការកែសម្រួលមួយចំនួនហើយលើបញ្ហានេះ, ក៏ប៉ុន្តែក្រសួង-ស្ថាប័នសាមី ក៏ត្រូវខិតខំកាត់បន្ថយនីតិវិធីផ្ទៃក្នុងរបស់ខ្លួន ដើម្បីបង្កើនប្រសិទ្ធភាព និងតម្លាភាពផ្ទៃក្នុងរបស់ខ្លួនផងដែរ ។

ទី៥) ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅតែជាបញ្ហាប្រឈមសំខាន់ ដែលជាចំណែកមួយនៃការគ្រប់គ្រងធនធានសាធារណៈ ។ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ទាំងទ្រព្យហិរញ្ញវត្ថុ និងទ្រព្យមិនមែនហិរញ្ញវត្ថុ ត្រូវការយកចិត្តទុកដាក់ច្រើនថែមទៀត ខណៈដែលផ្នែកផ្សេងៗនៃការកែទម្រង់កំពុងមានវឌ្ឍនភាពល្អទៅមុខ ។

ទី៦) ការរៀបចំក្របខណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម និងក្របខណ្ឌថវិការយៈពេលមធ្យម ទើបត្រូវបានចាប់ផ្តើមអនុវត្តសាកល្បងនៅឆ្នាំ២០១៩ សម្រាប់ថវិកាឆ្នាំ២០២០-២០២២ ដើម្បីតម្រង់ទិសផែនការយុទ្ធសាស្ត្រថវិកា ឱ្យមានគុណភាពប្រសើរឡើង ។

ទី៧) ការពង្រឹងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងពុំទាន់មានប្រសិទ្ធភាព ។ ខណៈដែលការរៀបចំថវិកាត្រូវបានធ្វើឡើងតាមកម្មវិធី, ការគ្រប់គ្រងស្ថាប័នត្រូវធ្វើទំនើបកម្មថែមទៀត តាមរយៈការផ្តល់សិទ្ធិអំណាចកាន់តែច្រើនដល់អ្នកអនុវត្ត ដែលក្នុងនោះថ្នាក់ដឹកនាំ ឬថ្នាក់គ្រប់គ្រង ទទួលខុសត្រូវជាសំខាន់លើសមិទ្ធកម្ម ឬការត្រួតពិនិត្យលើលទ្ធផលនៃការអនុវត្ត, ចំណែកឯការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុ ត្រូវធ្វើឡើងតាមរយៈការពង្រឹងមុខងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ចនៃក្រសួង-ស្ថាប័ន ។

ទី៨) ភាពចាំបាច់ក្នុងការបន្តការយកចិត្តទុកដាក់លើការពង្រឹងសមត្ថភាពផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីគាំទ្រ និងឆ្លើយតបទៅនឹងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេសឆ្ពោះទៅប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម ។

១៥. ផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យវឌ្ឍនភាពឆ្នាំ២០១៩, គ.ហ.ស. អាចវាយតម្លៃ និងសន្និដ្ឋានជារួម ដូចខាងក្រោម÷

- ថវិកាកាន់តែមានភាពជឿទុកចិត្ត និងបានក្លាយជាកម្លាំងចលករក្នុងការទ្រទ្រង់ និងជំរុញកំណើនសេដ្ឋកិច្ច
- បុរេលក្ខណៈសំខាន់ៗត្រូវបានកសាង និងពង្រឹងបន្ថែម ដើម្បីធានាគណនេយ្យភាពហិរញ្ញវត្ថុ
- ក្របខណ្ឌថវិកាកម្មវិធី ត្រូវបានរៀបចំ ពង្រឹង និងពង្រីកការអនុវត្ត ដែលជាឧបករណ៍សំខាន់សម្រាប់ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល
- សមត្ថភាពមន្ត្រីនៃក្រសួង-ស្ថាប័ន ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានពង្រឹងជាបណ្តើរៗ និង
- ការយល់ដឹង និងការចូលរួមអនុវត្តកម្មវិធីកែទម្រង់ មានការកើនឡើងជាលំដាប់ ។

## ១. សេចក្តីផ្តើម

### ១.១. និដ្ឋភាពទូទៅ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

១៦. កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នាថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៤ ក្នុងគោលបំណងកែប្រែជាជំហានៗ នូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ឆ្ពោះទៅឧត្តមានុវត្តន៍អន្តរជាតិ ដោយប្រកាន់យកអភិក្រមជាខឿន និងបែងចែកជា ៤ ដំណាក់កាល ។



១៧. **ដំណាក់កាលទី១ “ភាពជឿទុកចិត្តនៃថវិកា”** ដែលអនុវត្តចាប់ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៨ បានបញ្ចប់នូវស្ថានភាពកង្វះសាច់ប្រាក់ដ៏រ៉ាំរ៉ៃ មកជាអតិរេកសាច់ប្រាក់ តាមរយៈការលុបបំបាត់ទាំងស្រុងនូវបំណុលកកស្ទះនៅរតនាគារជាតិ ដែលជាហេតុធ្វើឱ្យរាជរដ្ឋាភិបាលកម្ពុជា ដោះស្រាយបាននូវការបើកប្រាក់បៀវត្សទៀងទាត់ និងទាន់ពេលវេលា ជូនមន្ត្រីរាជការ ។ ការបង្កើតគណនីទោលនៅរតនាគារជាតិដែលជាការប្រមូលផ្តុំគណនីទាំងអស់របស់រាជរដ្ឋាភិបាល បានក្លាយជាមូលដ្ឋានដ៏សំខាន់សម្រាប់បោះជំហានទៅរកដំណាក់កាលទី២ ។

១៨. **ដំណាក់កាលទី២ “បន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ”** ដែលត្រូវបានអនុវត្តពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៥ ដោយមានការកែលម្អជាច្រើនលើនីតិវិធីអនុវត្តថវិកា ជាពិសេស ការដាក់ឱ្យអនុវត្តមាតិកាថវិកាថ្មី និងប្លង់គណនេយ្យថ្មី ព្រមទាំងការដាក់ឱ្យដំណើរការនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)[4] ។

១៩. **ដំណាក់កាលទី៣ “ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ”** ត្រូវបានអនុវត្តចាប់ពីឆ្នាំ២០១៦ រហូតដល់ឆ្នាំ២០២០ ក្នុងគោលបំណងផ្លាស់ប្តូរជាបណ្តើរៗ នូវប្រព័ន្ធគ្រប់គ្រងដែលផ្អែកលើធាតុចូល និងមធ្យោបាយ ឆ្ពោះទៅជាប្រព័ន្ធដែលផ្តោតលើលទ្ធផល ឬសមិទ្ធកម្ម និងវិមជ្ឈការ តាមរយៈការពង្រឹង និងពង្រីកការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា ការអនុវត្តថវិកាកម្មវិធី[5] និងការអនុវត្តអង្គភាពថវិកា ។

---

[4] *ត្រឹមឆ្នាំ២០១៩ ប្រព័ន្ធ FMIS ត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការនៅគ្រប់រតនាគារទាំង២៥ រាជធានី-ខេត្ត, មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ២៥ រាជធានី-ខេត្ត និងក្រសួង-ស្ថាប័នចំនួន ២០ ។ នៅដើមឆ្នាំ២០២០ នេះ គ្រោងនឹងប្រកាសដាក់ឱ្យអនុវត្តនៅក្រសួង-ស្ថាប័នចំនួន ១៧ បន្ថែម ពោលគឺគ្រប់ក្រសួង-ស្ថាប័ននឹងត្រូវអនុវត្តជាផ្លូវការត្រឹមឆ្នាំ២០២០។*

[5] *ការអនុវត្តថវិកាកម្មវិធី ដែលជាស្នូលនៃដំណាក់កាលទី៣ ត្រូវបានដាក់ឱ្យអនុវត្តពេញលេញនៅគ្រប់ក្រសួង-ស្ថាប័នត្រឹមឆ្នាំ២០១៨ និងត្រូវបានដាក់ឱ្យអនុវត្តនៅរដ្ឋបាលខេត្តចំនួន ១៨ ត្រឹមឆ្នាំ២០១៩ ហើយគ្រោងដាក់ឱ្យអនុវត្តនៅគ្រប់រដ្ឋបាលរាជធានី-ខេត្តត្រឹមឆ្នាំ២០២១ ។*

២០. **ដំណាក់កាលទី៤ "គណនេយ្យភាពសមិទ្ធកម្ម"** គ្រោងអនុវត្តចាប់ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៥។ យុទ្ធសាស្ត្រ នៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥ បានកំណត់ទិសដៅកែទម្រង់ប្រព័ន្ធថវិកាឆ្ពោះទៅប្រព័ន្ធថវិកាសមិទ្ធកម្មក្នុងម៉ូដែលជា "ថវិកាព័ត៌មានសមិទ្ធកម្ម" ។ យុទ្ធ-សាស្ត្រនេះ បានរក្សាទុកគោលបំណងដើមនៃការអនុវត្ត ថវិកាកម្មវិធីពេញលេញ មានន័យថា



ប្រើប្រាស់កម្មវិធីជាឧបករណ៍ដើម្បីផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយឱ្យបាននៅឆ្នាំ២០២០ ហើយបន្ទាប់ពីនោះ នឹងចាប់ផ្តើមឈានទៅអនុវត្តថវិកាសមិទ្ធកម្ម ចាប់ពីឆ្នាំ២០២២ តទៅ ដោយពង្រឹងជាបណ្តើរៗ នូវព័ត៌មានសមិទ្ធកម្ម/លទ្ធផល និងគណនេយ្យភាព ដើម្បីមានពេលវេលាគ្រប់គ្រាន់ក្នុងការត្រៀមខ្លួនសម្រាប់អនុវត្តថវិកាសមិទ្ធកម្មពេញលេញនៅឆ្នាំ២០២៥ ។




២១. កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ ដែលត្រូវបានដាក់ឱ្យអនុវត្តនៅឆ្នាំ២០១៦ ដោយ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានកំណត់គោលដៅអាទិភាពចំនួន ០៣ រួមមាន (១) ការពង្រឹងការគ្រប់គ្រង និងអនុវត្តផែនការប្រមូលចំណូល និងចំណាយ, (២) ការពង្រឹង និងពង្រីកការដាក់ឱ្យអនុវត្តប្រព័ន្ធ FMIS និង (៣) ការពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី ។

*តារាងទី 1 ÷ ការប្រែប្រួលក្របខណ្ឌផែនការសកម្មភាពរួម ដំណាក់កាលទី២ និងដំណាក់កាលទី៣*

| រចនាសម្ព័ន្ធ CAP | CAP2 | CAP2 New | CAP3 2016-2020 | CAP3 2017-2020 | CAP3 2018-2020 |
|---|---|---|---|---|---|
| ផ្នែក | ៣ | ៤ | ៥ | ៥ | ៥ |
| គោលបំណង | ១៤ | ១៦ | ២១ | ២១ | ២១ |
| ចង្កោមសកម្មភាព | ៦២ | ៧១ | ៦៨ | ៦៩ | ៦៨ |

## ១.២. ស្ថានភាពសេដ្ឋកិច្ច

២២. បន្ទាប់ពីកំណើនសេដ្ឋកិច្ចរឹងមាំជាប់ៗគ្នា ជាង ២ ទសវត្សរ៍, កម្ពុជាបានចាកចេញពីប្រទេសចំណូលទាបទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាបកាលពីឆ្នាំ២០១៥ និងត្រូវបានប្រសិទ្ធនាមថាជា "**ខ្លាសេដ្ឋកិច្ចថ្មីមួយនៅអាស៊ី**" ក្នុងឆ្នាំ២០១៦ ។ សមិទ្ធផលពីកំណើនសេដ្ឋកិច្ចជាមធ្យមក្នុងរង្វង់ ៧% ក្នុង ១ ឆ្នាំ បើទោះជាមានការថមថយបន្តិចត្រឹម ៦,៥%[6] ក្នុងឆ្នាំ២០២០ បានចែកផ្លែផ្កាជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធតាមរយៈការដំឡើងប្រាក់បៀវត្សជាប្រចាំឆ្នាំ និងប្រជាពលរដ្ឋទូទៅតាមរយៈការបង្កើតការងារ និងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ។ ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជានឹងកសាងប្រទេសឆ្ពោះទៅរកឋានៈជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ ។



២៣. សេដ្ឋកិច្ចកម្ពុជាមានកំណើនរហូតដល់ ៧,៥% ក្នុងឆ្នាំ២០១៨ ដែលគាំទ្រដោយវិស័យកាត់ដេរ, សំណង់រឹងមាំ, វិស័យអចលនទ្រព្យ និងស្ថានភាពល្អប្រសើរនៃការលក់ដុំ និងលក់រាយ ព្រមទាំងការដឹកជញ្ជូន និងទូរគមនាគមន៍ ។ អត្រាអតិផរណាមធ្យមប្រចាំឆ្នាំស្ថិតក្នុងរង្វង់ ២,៥ % និងអត្រាប្តូរប្រាក់មធ្យមប្រមាណ ៤ ០៥៣ រៀល ក្នុងមួយដុល្លារសហរដ្ឋអាមេរិក ។ ការបន្តមានកំណើនបែបនេះ បានធ្វើឱ្យ ផ.ស.ស. សម្រាប់មនុស្សម្នាក់ កើនឡើងដល់ ១ ៥៤៨ ដុល្លារសហរដ្ឋអាមេរិក ។ ដោយឡែក សម្រាប់ឆ្នាំ២០១៩ កំណើនសេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងថានឹងបន្តសម្រេចក្នុងរង្វង់ ៧,១ % ហើយ ផ.ស.ស. តាមថ្លៃបច្ចុប្បន្នឆ្នាំ២០១៩ ត្រូវបានប៉ាន់ស្មានស្មើនឹង ១០៨ ២៩៨[7] ប៊ីលានរៀល ហើយកំណើននេះនឹងថមថយមកត្រឹម ៦,៥% ក្នុងឆ្នាំ២០២០ ដោយសារការរំពឹងទុកអំពីផលប៉ះពាល់នៃលទ្ធភាពក្នុងការដកប្រព័ន្ធអនុគ្រោះពន្ធ "**អ្វីគ្រប់យ៉ាងលើកលែងតែសព្វាវុធ**" (EBA) ដែលអាចនឹងដាក់សម្ពាធដល់ការនាំចេញរបស់កម្ពុជា ជាពិសេសលើផលិតផលកាត់ដេរទៅកាន់ទីផ្សារអឺរ៉ុប ហើយ ផ.ស.ស. តាមថ្លៃបច្ចុប្បន្ន ឆ្នាំ២០២០ ត្រូវបានព្យាករក្នុងចំនួន ១១៨ ៤៩០[8] ប៊ីលានរៀល ដែលកំណើននេះ



គាំទ្រដោយវិស័យកសិកម្ម, វិស័យឧស្សាហកម្ម និងវិស័យសេវាកម្ម ។ ឱនភាពគណនីចរន្ត ត្រូវបានព្យាករថានឹងស្ថិតក្នុងអត្រា ៩,៣% នៃ ផ.ស.ស. នៅឆ្នាំ២០២០ ។[9] ទន្ទឹមនេះ ហានិភ័យដែលអាចនឹងប៉ះពាល់ខ្លាំងដល់កំណើនសេដ្ឋកិច្ចកម្ពុជាពេលថ្មីៗនេះ គឺការរីករាលដាលនៃជម្ងឺកូវីដ១៩[10] ។

---

[6] *ការវាយតម្លៃវឌ្ឍនភាពពាក់កណ្តាលឆ្នាំ២០១៩ ដោយអគ្គនាយកដ្ឋានគោលនយោបាយ*

[7] *ការវាយតម្លៃវឌ្ឍនភាពពាក់កណ្តាលឆ្នាំ២០១៩ ដោយអគ្គនាយកដ្ឋានគោលនយោបាយ*

[8] *ការវាយតម្លៃវឌ្ឍនភាពពាក់កណ្តាលឆ្នាំ២០១៩ ដោយអគ្គនាយកដ្ឋានគោលនយោបាយ*

[9] *យោងតាមសារាចរលេខ ០៦ សរណន ស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសាធារណៈសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០*

[10] *បទបង្ហាញស្តីពីស្ថានភាព និងទស្សនវិស័យសេដ្ឋកិច្ចកម្ពុជា នៅវេទិកាសាធារណៈ កាលពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០*

## ១.៣. ស្ថានភាពហិរញ្ញវត្ថុសាធារណៈ

២៤. ក្នុងក្របខណ្ឌនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ការប្រមូលចំណូលមានស្ថានភាពរឹងមាំ ដែលចំណូលកើនឡើងជាមធ្យមប្រមាណ ២០% ក្នុងមួយឆ្នាំ ក្នុងរយៈពេល ៧ ឆ្នាំចុងក្រោយ ហើយចំណូលចរន្តថវិកាជាតិបានកើនឡើងពី ១៤,៧៧% នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៣ ដល់ ២៥,០៥% នៃ ផ.ស.ស.[11] ក្នុងឆ្នាំ ២០១៩ ពោលគឺទំហំចំណូលចរន្តកើនឡើងជិត ៣ ដង ឬ ប្រមាណ ១០,២៨ ពិន្ទុភាគរយនៃ ផ.ស.ស. (ព័ត៌មានបន្ថែមអំពីចំណូលមានបញ្ជាក់ក្នុងគោលបំណង ១១) ។ រីឯថវិកាចំណាយចាប់ពីឆ្នាំ២០១៣ មានទំហំ ៩ ៤៧៧ ប៊ីលានលានរៀល កើនឡើងដល់ទំហំ ២៣ ៨៦៨ ប៊ីលានរៀល នៅឆ្នាំ២០១៩ ឬត្រូវបានកើនឡើង ២,២ ដង ហើយត្រូវបានគិតគូរលើវិស័យអាទិភាពសំខាន់ៗ ក្នុងនោះចំណាយសរុបរបស់ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានបង្កើនជាង ៣,៤ ដង, ក្រសួងសុខាភិបាល ត្រូវបានបង្កើន ២,១ ដង និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានបង្កើន ២,៦ ដង ។

*ដ្យាក្រាមទី 1 ÷ ការអនុវត្តផែនការប្រមូលចំណូល*



*ប្រភព ÷ អគ្គនាយកដ្ឋានរតនាគារជាតិ និងអគ្គនាយកដ្ឋានគោលនយោបាយ*

២៥. ដ្យាក្រាមទី២ បង្ហាញអំពីការអនុវត្តថវិកាមានភាពប្រសើរប្រចាំឆ្នាំ (ឆ្នាំ២០១៩) រីឯការចំណាយប្រចាំត្រីមាស មានភាពយឺតយ៉ាវ ហើយគរក្នុងត្រីមាសទី៤ ដែលបណ្តាលមកពីសមត្ថភាពអង្គភាពថវិកា, ការរៀបចំផែនការថវិកាមិនទាន់ច្បាស់លាស់, ការធ្វើនិយ័តឆ្លងកម្មវិធី អនុកម្មវិធី និង ចង្កោមសកម្មភាព, ការទូទាត់ថវិកាបុរេប្រទាន និងការទូទាត់ប្រាក់រង្វាន់មានភាពយឺតយ៉ាវ និងការចាប់ផ្តើមអនុវត្តគម្រោងវិនិយោគក្នុងស្រុក ដោយថវិកាជាតិមានភាពយឺតយ៉ាវ ជាដើម ។

*ដ្យាក្រាមទី 2 ÷ ការអនុវត្តថវិការដ្ឋឆ្នាំ២០១៣-២០១៩*



*ប្រភព ÷ អគ្គនាយកដ្ឋានរតនាគារជាតិ*

[11] *ទំហំ ផ.ស.ស. ÷ ១១០ ០១៤ ប៊ីលានរៀល (ប្រភព÷អគ្គនាយកដ្ឋានគោលនយោបាយ)*

២៦. ដើម្បីដោះស្រាយបញ្ហានេះ, ក្រសួង-ស្ថាប័ន រៀបចំកម្មវិធីចំណាយ ត្រូវមានការចូលរួមពីអង្គភាពហិរញ្ញវត្ថុ និងអង្គភាពទទួលបន្ទុក, ពង្រឹងការរៀបចំផែនការថវិកាប្រចាំឆ្នាំ, ពន្លឿនការបើកផ្តល់ថវិកាពីដើមឆ្នាំ, កាត់បន្ថយនីតិវិធីត្រួតពិនិត្យ និងពន្លឿនលំហូរឯកសារផ្ទៃក្នុង ។

២៧. ក្នុងការគ្រប់គ្រងបំណុលសាធារណៈ រាជរដ្ឋាភិបាលប្រកាន់ខ្ជាប់នូវស្មារតីប្រុងប្រយ័ត្នខ្ពស់ ដោយបានអនុវត្តយ៉ាងម៉ឺងម៉ាត់នូវគោលការណ៍គន្លឹះៗ ទាំង ៥ រួមមាន÷

(១) ត្រូវខ្ចីឥណទានក្នុងទំហំសមស្របដែលស្ថានភាពថវិកា និងសេដ្ឋកិច្ចអាចទ្រាំទ្របាន

(២) ត្រូវខ្ចីតែឥណទានដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះខ្ពស់

(៣) ត្រូវខ្ចីសម្រាប់តែវិស័យអាទិភាពទ្រទ្រង់ចីរភាពនៃកំណើនសេដ្ឋកិច្ច និងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ច ឬផលិតភាពផលិតកម្ម

(៤) ត្រូវប្រើប្រាស់ឥណទាន ប្រកបដោយតម្លាភាព, គណនេយ្យភាព, ប្រសិទ្ធភាព, និងស័ក្តិសិទ្ធភាពខ្ពស់បំផុត

(៥) ត្រូវប្រើប្រាស់ឥណទានសម្រាប់ហិរញ្ញប្បទានគម្រោងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដែលត្រូវមានស្តង់ដា និងគុណភាពខ្ពស់ ស្របតាមគោលការណ៍នៃការគ្រប់គ្រងការវិនិយោគសាធារណៈ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍជាតិនៅក្នុងដំណាក់កាលថ្មី ពិសេសការធានាបាននូវចីរភាពសេដ្ឋកិច្ច, សង្គម, បរិស្ថាន និងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ។

២៨. តាមរយៈការគោរពយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍គន្លឹះៗខាងលើ បានធ្វើឱ្យស្ថានភាពបំណុលសាធារណៈរបស់កម្ពុជាមានលក្ខណៈល្អប្រសើរជាលំដាប់ ។ ជាក់ស្តែង ផ្អែកតាមការវិភាគចីរភាពបំណុល បង្ហាញថា អនុបាតបំណុលទាំង ៥ របស់កម្ពុជា សុទ្ធតែស្ថិតក្រោមអនុបាតគោលទាំងអស់ ក្នុងនោះ អនុបាតបំណុលសំខាន់ជាងគេ គឺអនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ផ.ស.ស. មានត្រឹម ២១,៣% នៅឆ្នាំ២០១៩ ដែលមានកម្រិតទាបជាងអនុបាតគោល ៤០% ។ តាមបទដ្ឋានបច្ចេកទេសអន្តរជាតិ លទ្ធផលនេះបញ្ជាក់ថា ស្ថានភាពបំណុលសាធារណៈកម្ពុជាមាន “**ចីរភាព**” និង “**ហានិភ័យកម្រិតទាប**” ។

*តារាងទី2 ÷ សន្និធិបំណុលសាធារណៈ ឆ្នាំ២០១៣ - ២០១៩*

| - | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ ប៉ាន់. |
|---|---|---|---|---|---|---|---|
| បំណុលសាធារណៈក្រៅប្រទេស (លាន $) | ៤ ៨៧១ | ៥ ២៧៩ | ៥ ៦៤៨ | ៥ ៨៦ | ៦ ៦៦៩ | ៧ ០២១ | ៧ ៨៧៧ |
| ធៀបនឹង ផ.ស.ស. | ៣១,៩ | ៣១,៦ | ៣១,២ | ២៩,២ | ៣០,១ | ២៨,៨ | ២៩,៥ |
| សេវាបំណុលសាធារណៈ ក្រៅប្រទេស (លាន $) | ១១២ | ១៣៤ | ១៣៧ | ១៨៦ | ២១១ | ២៦៦ | ៣២២ |
| ធៀបនឹងការនាំចេញ | ១,១ | ១,១ | ១,០ | ១,៣ | ១,៣ | ១,៤ | ១,៥ |

*ប្រភព ÷ អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល*

## ១.៤. សន្និដ្ឋានកម្ម និងគោលបំណងនៃរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ ២០១៩

២៩. របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ ២០១៩ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ ត្រូវបានរៀបចំស្របតាមទស្សនាទានដែលទទួលបានការផ្តល់យោបល់បន្ថែមពីដៃគូអភិវឌ្ឍន៍ ។ ការផ្តួចផ្តើមរៀបចំរបាយការណ៍ត្រួតពិនិត្យវឌ្ឍនភាពប្រចាំឆ្នាំ២០១៩ គឺក្នុងគោលបំណងបង្កើនការចូលរួមក្នុងដំណើរការនៃការរៀបចំពីអង្គភាពក្រោមឱវាទ កសហវ. ក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ ។

៣០. ក្នុងកិច្ចដំណើរការរៀបចំរបាយការណ៍វឌ្ឍនភាពឆ្នាំ២០១៩ ដោយមានការអនុញ្ញាតពី គ.ហ.ស., អ.គ.ហ. បានជ្រើសរើសវិធីសាស្ត្រចំនួន ៣ ដើម្បីធ្វើការសិក្សា និងរៀបចំរបាយការណ៍នេះឡើង ក្នុងនោះរួមមាន (១) ការត្រួតពិនិត្យតាមដាន និងបូកសរុបវឌ្ឍនភាពស្របតាមក្របខ័ណ្ឌផែនការសកម្មភាពរួម ដំណាក់កាលទី៣ ឆ្នាំ ២០១៩-២០២០, (២) ការចុះជួបពិភាក្សាជាមួយក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតាមក្រសួង-ស្ថាប័ន និងអង្គភាពក្រោមឱវាទ កសហវ. ស្តីពីការរៀបចំ និងការអនុវត្តផែនការសកម្មភាព (MAP/GDAP) ឆ្នាំ២០១៩ ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ[12], និងតាមដានការអនុវត្តអនុសាសន៍របស់ គ.ហ.ស. និង (៣) ការចូលរួមពីដៃគូអភិវឌ្ឍន៍ (សហភាពអឺរ៉ុប, ធនាគារអភិវឌ្ឍន៍អាស៊ី, ធនាគារពិភពលោក, អង្គការយូនីសេហ្វ និងមូលនិធិរូបិយវត្ថុអន្តរជាតិ) ចូលរួមរៀបចំរបាយការណ៍ពាក់ព័ន្ធនឹងការគ្រប់គ្រងការផ្លាស់ប្តូរ និងការតម្រង់ទិសនីតិវិធីអនុវត្តការងារ (Business Process Streamlining) និងការត្រួតពិនិត្យលើសមានគតិភាពនៃ BSP និង PB ។

៣១. វិធីសាស្ត្រនៃការគណនាពិន្ទុ[13] តាមផ្នែក និងតាមអង្គភាពក្រោមឱវាទ កសហវ. និងក្រសួង-ស្ថាប័ន គឺប្រើប្រាស់ទម្ងន់តាមកម្រិតចង្កោមសកម្មភាព គោលបំណង និងផ្នែក ដូចខាងក្រោម÷

*ទី១÷ វឌ្ឍនភាពតាមចង្កោមសកម្មភាព → បូកសរុបជាមធ្យមនូវវឌ្ឍនភាពជាភាគរយគ្រប់សកម្មភាពរបស់អង្គភាពក្រោមឱវាទ កសហវ.*

*ទី២÷ វឌ្ឍនភាពតាមគោលបំណង → វឌ្ឍនភាពជាភាគរយតាមចង្កោមសកម្មភាព គុណនឹងទម្ងន់តាមចង្កោម → បូកសរុបលទ្ធផលតាមចង្កោមសកម្មភាព នៃគោលបំណង*

*ទី៣÷ វឌ្ឍនភាពតាមផ្នែក → វឌ្ឍនភាពជាភាគរយតាមគោលបំណង គុណនឹងទម្ងន់តាមគោលបំណង → បូកសរុបលទ្ធផលតាមគោលបំណងនៃផ្នែក*

*ទី៤÷ វឌ្ឍនភាពកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល → វឌ្ឍនភាពតាមផ្នែក គុណនឹងទម្ងន់តាមផ្នែក → បូកសរុបផ្នែកទាំង ៥ ។*

---

[12] *ចុះប្រមូលព័ត៌មានបន្ថែមនៅអង្គភាពក្រោមឱវាទ កសហវ. និងក្រសួង-ស្ថាប័ន ចាប់ពីថ្ងៃទី១៣-២៧ ខែកុម្ភៈ ឆ្នាំ២០២០ ក្នុងនោះអង្គភាពក្រោមឱវាទ កសហវ. រួមមាន អគ្គនាយកដ្ឋានគោលនយោបាយ, អគ្គនាយកដ្ឋានថវិកា, អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល, អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគណនេយ្យ, អគ្គនាយកដ្ឋានរតនាគារជាតិ, អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ, អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ, អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង, អគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្រសួង-ស្ថាប័ន រួមមាន ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងសុខាភិបាល, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ក្រសួងរ៉ែ និងថាមពល, អាជ្ញាធរសវនកម្មជាតិ, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ក្រសួងមុខងារសាធារណៈ និងក្រសួងផែនការ ។ ទន្ទឹមនេះ រដ្ឋបាលរាជធានី-ខេត្ត រួមមាន រដ្ឋបាលរាជធានីភ្នំពេញ, រដ្ឋបាលខេត្តកណ្តាល និងរដ្ឋបាលខេត្តព្រៃវែង ត្រូវបានជ្រើសរើសសម្រាប់ការសិក្សា ផងដែរ ។*

[13] *ពិន្ទុនៃវឌ្ឍនភាពកម្មវិធីកែទម្រង់តាមចង្កោមសកម្មភាព គោលបំណង និងផ្នែក គឺមិនបូកបញ្ចូលវឌ្ឍនភាពរបស់ក្រសួង-ស្ថាប័ន ។ វិធីសាស្ត្រគណនាខាងលើក៏ត្រូវបានប្រើប្រាស់សម្រាប់គណនាពិន្ទុ នៃអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័ននីមួយៗ ផងដែរ ។ លទ្ធផលនៃពិន្ទុដែលបានគណនាតាមអង្គភាព/ស្ថាប័ន នីមួយៗ គឺជាកម្មវត្ថុនៃការផ្តល់ប្រាក់ឧបត្ថម្ភមុខងារកែទម្រង់ ។ រូបមន្តនៃការដាក់ពិន្ទុ ; ពិន្ទុសម្រេចបាន = ទម្ងន់ X លទ្ធផលសម្រេចបាន ។*

៣២. រចនាសម្ព័ន្ធនៃរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០១៩ ត្រូវបានបែងចែកជា ៤ ផ្នែកដូចខាងក្រោម÷

**១. សេចក្ដីផ្ដើម** ÷ ទិដ្ឋភាពទូទៅនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ; និងសនិទានកម្ម និងគោលបំណងនៃរបាយការណ៍ត្រួតពិនិត្យប្រចាំឆ្នាំ២០១៩នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ ។

**២. វឌ្ឍនភាពប្រចាំឆ្នាំ២០១៩ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣** ÷ ការអនុវត្តផែនការសកម្មភាពរួមដំណាក់កាលទី៣ របស់អង្គភាពក្រោមឱវាទ កសហវ. និងក្រសួង-ស្ថាប័ន ។

**៣. បញ្ហាប្រឈម និងសំណើដំណោះស្រាយ** ÷ ផ្ដោតលើបញ្ហាប្រឈម និងសំណើដំណោះស្រាយនៃអង្គភាពក្រោមឱវាទ កសហវ. និងក្រសួង-ស្ថាប័ន ដែលជួបប្រទះក្នុងអំឡុងពេលអនុវត្តកម្មវិធីកែទម្រង់ និងបញ្ហាប្រឈមរបស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

**៤. សន្និដ្ឋាន**÷ វិភាគ និងសន្និដ្ឋានវឌ្ឍនភាពជារួម ដោយចង្អុលបង្ហាញអំពីផ្នែកនីមួយៗ នៃផែនការសកម្មភាពរួម ដំណាក់កាលទី៣ ព្រមទាំងសមិទ្ធកម្មរបស់អង្គភាពក្រោមឱវាទកសហវ. និងក្រសួង-ស្ថាប័ន ភ្ជាប់ជាមួយនឹងសំណើសម្រាប់ធ្វើការកែលម្អសមិទ្ធកម្ម ។

## ២. វឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រចាំឆ្នាំ២០១៩

### ២.១. ការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៣៣. តាមរយៈការត្រួតពិនិត្យវឌ្ឍនភាព នៃការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ២០១៩ បានបង្ហាញថា ផ្នែកទី១ "បន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា" សម្រេចបាន ៩៧%, ផ្នែកទី២ "បន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ" សម្រេចបាន ៩៧%, ផ្នែកទី៣ "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ" សម្រេចបាន ៩៨%, ផ្នែកទី៤ "ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់" សម្រេចបាន ៩៨% និងផ្នែកទី៥ "ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព" សម្រេចបាន ៩៩% ។ ផ្អែកលើវឌ្ឍនភាពឆ្នាំ២០១៩ នេះ ផ្នែកទី៤ ត្រូវបានអនុវត្ត និងសម្រេចវឌ្ឍនភាពគួរឱ្យកត់សម្គាល់ តាមរយៈការដាក់ចេញនូវយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ និងផែនការសកម្មភាពលម្អិតសម្រាប់អនុវត្តយុទ្ធសាស្ត្រនេះ ។

*ដ្យាក្រាមទី 3 ÷ វឌ្ឍនភាពតាមផ្នែកនៃ CAP3 (២០១៦-២០១៩)*




*ប្រភព ÷ ក្រុមការងារ អ.គ.ហ.*

#### ផ្នែកទី១ "បន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា"

៣៤. ផ្នែកភាពជឿទុកចិត្តនៃថវិកា ផ្ដោតលើគោលបំណងចំនួន ៤ រួមមាន (១) ពង្រឹងការគ្រប់គ្រងចំណូល និងការអនុវត្តផែនការប្រមូលចំណូល, (២) បន្តពង្រឹងការគ្រប់គ្រងបំណុល, (៣) ពង្រឹងការគ្រប់គ្រងសាច់ប្រាក់

និងគណនី, និង (៤) កែលម្អការអនុវត្តថវិកា និងពង្រឹងការអនុវត្តផែនការចំណាយ ។ ទន្ទឹមនេះ ការអនុវត្តចំណូល និងចំណាយប្រចាំត្រីមាស និងប្រចាំឆ្នាំ ត្រូវមានភាពរលូន និងអាចប៉ាន់ស្មានបាន ពោលគឺកម្រិតលម្អៀងនៃការអនុវត្តស្ថិតក្នុងរង្វង់ +/-៥% ធៀបនឹងច្បាប់ថវិកា ។

*គោលបំណង១១ ÷ បន្តពង្រឹងការគ្រប់គ្រងចំណូល និងការអនុវត្តផែនការប្រមូលចំណូល*

៣៥. **ការអនុវត្តចំណូល សម្រេចបានលើសផែនការពោលគឺប្រមាណ ១៣១.០ % ដែលមានទំហំប្រមាណ ២៧ ៧៤០ ប៊ីលានរៀល រីឯចំណាយថវិកាជាតិសម្រេចបាន ៩៩,០៥ %[14] ក្នុងទំហំប្រមាណ ២៣ ៦៦៨ ប៊ីលានរៀល ។** បើធៀបនឹង ផ.ស.ស. មានកំណើន **៣.១៨** ពិន្ទុភាគរយ[15] ។ ការប្រមូលចំណូលដោយ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាប្រមាណ ១៤១,៨% (ធៀបនឹងច្បាប់ថវិកា) ឬស្មើនឹងប្រមាណ ១២ ៨៩៧ ប៊ីលានរៀល ដែលជាចំណូលខ្ពស់លើសពីការរំពឹងទុក ដោយសារការកើនឡើង នៃបរិមាណនាំចូលមុខទំនិញសំខាន់ៗ ជាពិសេស យានយន្ត និងការកែសម្រួលគោលនយោបាយពន្ធអាករគយលើមុខទំនិញមួយចំនួន ដែលមានវេទយិទភាពលើចំណូល ។ ការប្រមូលចំណូលដោយអគ្គនាយកដ្ឋានពន្ធដារ ចំណូលពន្ធសម្រេចបានប្រមាណ ១១៧,៦% (ធៀបនឹងច្បាប់ថវិកា) ឬស្មើនឹងប្រមាណ ៩ ១៥៥ ប៊ីលានរៀល ទន្ទឹមនឹងការប្រមូលចំណូលមិនមែនសារពើពន្ធសម្រេចបាន ១២៣.១ % (ធៀបនឹងច្បាប់ថវិកា) ឬស្មើនឹង ៣ ៣៤១ ប៊ីលានរៀល ។ រីឯការប្រមូលចំណូលនៅថ្នាក់ក្រោមជាតិសម្រេចបាន ១៥៥,៣% (ធៀបនឹងច្បាប់ថវិកា) ឬស្មើនឹង ២ ១៦៣ ប៊ីលានរៀល ។ ទន្ទឹមនេះ ការទូទាត់តាមប្រព័ន្ធធនាគារសម្រេចបាន ១០០% ក្នុងនោះក្រសួង-ស្ថាប័ន បានបើកបៀវត្សតាមប្រព័ន្ធធនាគារ ២ ដង ក្នុងមួយខែ បានទាន់ពេលវេលា ខណៈមិនមានការកកើតឡើងវិញនៃបំណុលកកស្ទះ គិតត្រឹម ៦០ ថ្ងៃ ។[16]

*ដ្យាក្រាមទី 4 ÷ ការអនុវត្តសូចនាករសមិទ្ធកម្មគន្លឹះទាំង៦*




*ប្រភព÷ អគ្គនាយកដ្ឋានរតនាគារជាតិ និងអគ្គនាយកដ្ឋានគោលនយោបាយ*

៣៦. **ពង្រឹងការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល** ÷ គសហវ. បានធ្វើការវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល ២០១៤-២០១៨ ដោយលទ្ធផលបង្ហាញថាក្នុងរយៈពេល ៥ ឆ្នាំ (២០១៤-២០១៨) ចំណូលចរន្តបានបន្តកើនឡើងយ៉ាងខ្លាំង ពោលគឺមានកំណើនជាមធ្យម ១,៤ ពិន្ទុភាគរយនៃ ផ.ស.ស. ។ លទ្ធផលនៃការវាយតម្លៃនេះ បានក្លាយជាមូលដ្ឋានដ៏សំខាន់សម្រាប់រៀបចំយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ ដែលត្រូវបានឯកភាពដោយរាជរដ្ឋាភិបាលកាលពីពាក់កណ្តាលឆ្នាំ២០១៩ កន្លងទៅ ។ ទន្ទឹមនេះ គសហវ. បានរៀបចំផែនការ

[14] ការចំណាយសរុប បូកបញ្ចូលចំណាយចរន្ត (ការទិញ, សេវាកម្ម, បន្ទុកបុគ្គលិក, បន្ទុកហិរញ្ញវត្ថុ, អត្ថប្រយោជន៍សង្គម, ឧបត្ថម្ភធន, ពន្ធ និងអាករ, និងចំណាយមិនបានគ្រោងទុក) និងចំណាយមូលធន (ការខ្ចី, អចលកម្មរូបី, ការវិនិយោគ, និងអចលកម្មហិរញ្ញវត្ថុផ្សេងៗ) ។

[15] លើសជាង ១០ ដង នៃគោលដៅដែលបានដាក់ចេញក្នុងយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ ខណៈគោលដៅត្រឹម ០,៣ ពិន្ទុភាគរយនៃ ផ.ស.ស. ។

[16] តួលេខចំណូល-ចំណាយទាំងអស់ គិតត្រឹមថ្ងៃទី២៥ ខែមករា ឆ្នាំ២០២០ (ប្រភព÷អគ្គនាយកដ្ឋានរតនាគារជាតិ) ។

សកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ [17] ដោយបានរៀបចំក្របខណ្ឌផែនការសកម្មភាព និងក្របខណ្ឌតាមដាន និងវាយតម្លៃច្បាស់លាស់ ។ ទន្ទឹមនេះ **លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធមួយចំនួនត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត** ក្នុងនោះ រួមមាន (១) ប្រកាសស្តីពីការអនុវត្តការលើកទឹកចិត្តផ្នែកគយសម្រាប់សហគ្រាសធុនតូច និងមធ្យម, (២) ប្រកាសស្តីពីការដាក់ឱ្យអនុវត្តជំហានដំបូងប្រព័ន្ធបញ្ចរតែមួយជាតិ, (៣) ប្រកាសអន្តរក្រសួងស្តីពីកិច្ចសហការរវាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានិងអគ្គនាយកដ្ឋានកាំកុងត្រូ, (៤) ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃច្រកចេញចូលតែមួយក្នុងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, (៥) ប្រកាសអន្តរក្រសួងស្តីពីកម្រងសេវាសាធារណៈ និងការកែប្រែអត្រាប្រាក់រង្វាន់លើកទឹកចិត្តលើការផ្តល់សេវាសាធារណៈ ចំនួន ១៥ និង (៦) ប្រកាសលេខ ៨៣៩ សហវ.ប្រក ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០១៩ ស្តីពីបែបបទ និងនីតិវិធីនៃការបង់ភាគលាភរបស់សហគ្រាសសាធារណៈ និងក្រុមហ៊ុនចម្រុះដែលរដ្ឋមានភាគកម្មសាធារណៈជាចំនួនភាគតិច" ។ ការធ្វើវិសោធនកម្មអនុក្រឹត្យលេខ ១៣៩ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិរដ្ឋ នៃគ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវបានសម្រេច និងចុះហត្ថលេខាដោយប្រមុខរាជរដ្ឋាភិបាលតាមរយៈអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះហត្ថលេខានាថ្ងៃទី១៥ ខែមករា ឆ្នាំ ២០១៩ ។ សេចក្តីព្រាងអនុក្រឹត្យ ឬ ព្រះរាជក្រឹត្យថ្មីស្តីពីការបង្កើតគ្រឹះស្ថានសាធារណៈរដ្ឋបាល សរុបចំនួន ២៦/២៨ ត្រូវបានបញ្ចប់ការរៀបចំ និងត្រូវបានរៀបចំស្នើសុំប្រមុខរាជរដ្ឋាភិបាលពិនិត្យសម្រេច និងចុះហត្ថលេខាដើម្បីដាក់ឱ្យអនុវត្ត ។ បន្ថែមពីនេះ ការអង្កេតអចលនទ្រព្យនៅរាជធានីភ្នំពេញ ដើម្បីផ្តល់សេវាពន្ធដារលើការចុះបញ្ជី និងធ្វើបច្ចុប្បន្នភាពព័ត៌មានអចលនទ្រព្យត្រូវបានធ្វើឡើងនៅខណ្ឌចំនួន ៤[18] ទន្ទឹមនឹងការកែសម្រួលឧបសម្ព័ន្ធស្តីពីតម្លៃអចលនទ្រព្យសម្រាប់មូលដ្ឋានគិតពន្ធប្រថាប់ត្រា ក្នុងរាជធានី-ខេត្ត ។ ដោយឡែក ការចុះបញ្ជីអ្នកជាប់ពន្ធទៅក្នុងប្រព័ន្ធថ្មីចំពោះអ្នកជាប់ពន្ធដែលមិនទាន់បានចុះបញ្ជីពន្ធដារ ត្រូវបានពង្រឹង និងជំរុញបន្ថែម (ចុះបញ្ជីសហគ្រាសសរុបក្នុងឆ្នាំ២០១៩ បានចំនួន ១៤ ៦១៨) ។

៣៧. **បន្តកែលម្អគោលនយោបាយ និងរដ្ឋបាលគយ ពន្ធដារ និងចំណូលមិនមែនសារពើពន្ធ** ÷ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាបានសិក្សា និងលើកសំណើកែសម្រួលអត្រាពន្ធអាករ និងអនុលោមភាពតាមកាតព្វកិច្ចអត្រាពន្ធអាករ មួយចំនួនរួមមាន ÷ (១) សំណើកែ-សម្រួលអត្រាអាករពិសេសលើមុខទំនិញបារី, (២) លិខិតអនុ-វត្តការបញ្ចុះអត្រាអាករនាំចេញ



[17] *យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ បានកំណត់គោលដៅនៃកំណើនចំណូលចរន្តសរុប ០,៣ ពិន្ទុភាគរយនៃ ផ.ស.ស. ។ ប៉ុន្តែជាក់ស្តែង ការអនុវត្តឆ្នាំដំបូងមានកំណើនរហូតដល់ជាង ៣ ពិន្ទុភាគរយនៃ ផ.ស.ស. ។*

[18] *ខណ្ឌដូនពេញ, ខណ្ឌ៧មករា, ខណ្ឌសែនសុខ និងខណ្ឌឫស្សីកែវ*

លើមុខទំនិញប្រភេទឈើដាំ និងវត្ថុធ្វើពីឈើដាំ, (៣) សំណើបញ្ចុះអត្រាពន្ធគយ និងអត្រាអាករពិសេសរបស់សហគ្រាសតូនតូច និងមធ្យម និង (៤) កែសម្រួលអត្រាពន្ធអាករ ដើម្បីប៉ះប៉ូវការបាត់បង់ចំណូលលើមុខទំនិញចំនួន ២៤៩ បន្ទាត់ពន្ធ ។ ទន្ទឹមនេះ អគ្គនាយកដ្ឋានពន្ធដារ បានបញ្ចប់សេចក្តីព្រាងប្រកាសស្តីពីពន្ធលើចំណេញមូលធនរបស់រូបវន្តបុគ្គល (Capital Gains Tax) ក្នុងកម្រិតអគ្គនាយកដ្ឋានពន្ធដារ ។ ដោយឡែក សេចក្តីព្រាងអនុក្រឹត្យស្តីពីចំណាយ និងទាយជ្ជទាន សម្រាប់គណនាប្រាក់ចំណូលជាប់ពន្ធរបស់រូបវន្តបុគ្គល (Personal Income Tax) និងសេចក្តីព្រាងប្រកាសស្តីពីចំណាយ និងទាយជ្ជទាន សម្រាប់គណនាប្រាក់ចំណូលជាប់ពន្ធរបស់រូបវន្តបុគ្គល (Personal Income Tax) ត្រូវបានបន្តកែសម្រួលកម្រិតអគ្គនាយកដ្ឋានពន្ធដារ នៅឡើយ ។រីឯ សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រូវបានបញ្ចប់ការតាក់-តែង និងដាក់ឆ្លងយោបល់ពីក្រុមប្រឹក្សានីតិកម្ម ទន្ទឹមនឹងសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ ត្រូវបានបញ្ជូនពីគណៈរដ្ឋមន្ត្រីមកក្រសួងយុត្តិធម៌ និង កសហវ. ដើម្បីពិនិត្យផ្នែកទោសបញ្ញត្តិឱ្យបានគ្រប់ជ្រុងជ្រោយបន្ថែម ។




៣៨. **ពង្រឹងការវិភាគ និងការព្យាករចំណូល** ÷ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាបានជ្រើសរើសវិធីសាស្ត្រ Buoyancy សម្រាប់ធ្វើការសាកល្បងព្យាករចំណូលគយ និងបានរៀបចំរបាយការណ៍វាយតម្លៃលទ្ធផលនៃការព្យាករ ធៀបនឹងការអនុវត្តប្រចាំឆ្នាំ២០១៩ និងបានធ្វើការព្យាករចំណូលគយប្រចាំឆ្នាំ២០២០ ។

៣៩. **ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងបំណុលក្នុងឆ្នាំ** ÷ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា បានកំណត់តួលេខបំណុលពន្ធ និងអាករប្រចាំឆ្នាំ២០១៩ និងបានធ្វើលិខិតជំរុញក្រុមហ៊ុនឱ្យទូទាត់ប្រាក់ពន្ធ និងអាករគយឆ្នាំ២០១៩ ។ រីឯបំណុលឆ្នាំ២០១៨ ត្រូវបានទូទាត់រួចរាល់ ។រីឯអគ្គនាយកដ្ឋានពន្ធដារបានរៀបចំសំណុំឯកសារសហគ្រាសជំពាក់បំណុលពន្ធទូទាំងប្រទេស និងការចាត់ថ្នាក់បំណុលពន្ធជា“**បំណុលពន្ធអាចប្រមូលបាន**” និង “**បំណុលពន្ធមិនអាចប្រមូលបាន**” សម្រាប់ដាក់បញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រង និងប្រមូលបំណុលពន្ធដារថ្មី ។ ចំណែកឯបំណុលមិនមែន

សារពើពន្ធ ក្រុមការងារបំណុលតាមវិស័យបានប្រជុំដោះស្រាយទាក់ទងការងារគ្រប់គ្រងបំណុល និងការអនុវត្តនីតិវិធីតាមគោលការណ៍សម្រេចរបស់រាជរដ្ឋាភិបាល ក្នុងនោះរួមមានក្រុមការងារបំណុលប្រេសណីយ៍ និងក្រុមការងារបំណុលវិស័យអាកាសចរស៊ីវិល, វិស័យកសិកម្ម និងវិស័យរ៉ែ ដែលបានបន្តនីតិវិធីគ្រប់គ្រងបំណុលដូចជាការតឹងទារបំណុល និងជំរុញការអនុវត្តអនុក្រឹត្យលេខ ៧២ ស្ដីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ។

៤០. **អនុវត្តការប្រមូលចំណូលផ្ទាល់/ចំណូលចែករំលែករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ÷** អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ បានរៀបចំរបាយការណ៍សិក្សាលទ្ធភាពនៃការបង្កើនធនធានថវិកាជូនរដ្ឋបាលឃុំ សង្កាត់ ។ អនុក្រឹត្យស្ដីពីការបង្កើនធនធានថវិកាជូនរដ្ឋបាលឃុំ-សង្កាត់ សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ។ ទន្ទឹមនេះ សេចក្ដីព្រាងអនុក្រឹត្យនៃការបែងចែកប្រាក់រង្វាន់ដែលប្រមូលតាមច្រកចេញចូលតែមួយរវាងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ត្រូវបានដាក់ប្រជុំពិភាក្សាជាមួយអង្គភាពដែលមានការពាក់ព័ន្ធ[19] ។



*គោលបំណង ១២ ÷ បន្តពង្រឹងការគ្រប់គ្រងបំណុល*

៤១. **អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល បានបង្កើតប្រព័ន្ធ In-house Database សម្រាប់កត់ត្រា និងរក្សាទុកទិន្នន័យពាក់ព័ន្ធ ក្រៅពីទិន្នន័យបំណុលដែលអាចកត់ត្រាបាននៅក្នុងប្រព័ន្ធ DMFAS[20] ។** ប្រព័ន្ធ In-house Database បានសម្រួលដល់ប្រតិបត្តិការការងារប្រចាំថ្ងៃជាច្រើន ដូចជា ការគ្រប់គ្រង និងតាមដានប្រតិបត្តិការការងារពាក់ព័ន្ធប្រចាំថ្ងៃ, ការផ្ដល់ដំណឹងដោយស្វ័យប្រវត្តិ និងជាពិសេសស្វ័យប្រវត្តិកម្មការងារទូទាត់សេវាបំណុលជូនឥណទាយក និងប្រមូលចំណូលសេវាបំណុលពីឥណទាយិក ។ ប្រព័ន្ធនេះត្រូវបានដាក់ឱ្យអនុវត្តតាមរយៈប្រកាសលេខ ១៦២០ សហវ.ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៨ ។ ការប្រើប្រាស់

---

[19] *អនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ ស្ដីពីការគ្រប់គ្រងចំណូលសេវារបស់អង្គភាពច្រកចេញចូលតែមួយ ត្រូវបានដាក់ឱ្យអនុវត្ត ។*

[20] *ប្រព័ន្ធ DMFAS (Debt Management and Financial Analysis System) version 5.3 ត្រូវបានដំឡើងនៅឆ្នាំ២០០៧ ។ នៅឆ្នាំ២០១២ ប្រព័ន្ធ DMFAS ត្រូវបានពង្រីកទៅអគ្គនាយកដ្ឋានពាក់ព័ន្ធចំនួន ៣ រួមមាន អគ្គនាយកដ្ឋានរតនាគារជាតិ, អគ្គនាយកដ្ឋានគោលនយោបាយ, និងអគ្គនាយកដ្ឋានថវិកា ដើម្បីអាចទាញយករបាយការណ៍ទិន្នន័យបំណុល ។ នៅឆ្នាំ២០១៤ ដោយបន្តទទួលបានជំនួយបច្ចេកទេសបន្ថែមពីធនាគារអភិវឌ្ឍន៍អាស៊ី, កសហវ. បានដំឡើងប្រព័ន្ធ DMFAS ពី version 5.3 ទៅ version 6.0 ដែលជា version ចុងក្រោយ ។ ប្រព័ន្ធ DMFAS ត្រូវបានធ្វើសន្ទានកម្មជាមួយប្រព័ន្ធ FMIS នៅឆ្នាំ២០១៦ ។*

ប្រព័ន្ធ DMFAS និងប្រព័ន្ធ In-house Database បានផ្តល់នូវសារៈប្រយោជន៍ជាច្រើន ក្នុងការគ្រប់គ្រងទិន្នន័យបំណុល ប្រកបដោយប្រសិទ្ធភាព, សុក្រឹតភាព, និងភាពគ្រប់ជ្រុងជ្រោយ ដែលជាមូលដ្ឋានក្នុងការវិភាគ, រៀបចំរបាយការណ៍ជូនស្ថាប័នពាក់ព័ន្ធ ទាំងស្ថាប័នជាតិ និងទាំងស្ថាប័នអន្តរជាតិ, ព្រមទាំងបោះផ្សាយ និងផ្សព្វផ្សាយព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈប្រចាំឆមាស បានជាទៀតទាត់ និងទាន់ពេលវេលា ។

៤២. **ពង្រឹងការអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ** ÷ ក្នុងគោលដៅបន្តរក្សាចីរភាពបំណុលសាធារណៈរយៈពេលមធ្យម និងវែង និងកម្រិតហានិភ័យបំណុលឱ្យនៅទាប សំដៅរួមចំណែកជំរុញកំណើនសេដ្ឋកិច្ច និងលើកស្ទួយកម្រិតជីវភាពប្រជាជន ស្របតាមបរិការណ៍សេដ្ឋកិច្ចកម្ពុជា រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវវិធានការជាយុទ្ធសាស្ត្រសម្រាប់ពង្រឹងប្រសិទ្ធភាព នៃការគ្រប់គ្រងបំណុលសាធារណៈតាមរយៈការដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩-២០២៣ ។

៤៣. ទន្ទឹមនេះ បញ្ហាប្រឈមនៅក្នុងការគ្រប់គ្រងបំណុលសាធារណៈរបស់កម្ពុជាបច្ចុប្បន្ន មានដូចខាងក្រោម ÷

- **យន្តការចំពោះកិច្ចសម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន** ÷ បើទោះជាគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០[21] ក៏ប៉ុន្តែប្រសិទ្ធភាពនៃការអនុវត្តនៅមានកម្រិតនៅឡើយ ដោយហេតុថាយន្តការចំពោះកិច្ចនៅតែត្រូវបានយកមកប្រើប្រាស់សម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន ថ្មីៗ មួយចំនួន ។
- **សមត្ថភាពស្ថាប័ន និងធនធានមនុស្សក្នុងកិច្ចការគ្រប់គ្រងបំណុលសាធារណៈ** ÷ ថ្វីត្បិតតែសមត្ថភាពស្ថាប័ន និងធនធានមនុស្សក្នុងកិច្ចការគ្រប់គ្រងបំណុលសាធារណៈ ត្រូវបានពង្រឹងក្តី ក៏ប៉ុន្តែបច្ចុប្បន្ន មុខងារការិយាល័យជួរមុខ នៅមានភាពបែកខ្ញែកគ្នានៅឡើយ រវាងការគ្រប់គ្រងបំណុលសាធារណៈក្នុងប្រទេស និងក្រៅប្រទេស រីឯមុខងារនៃការគ្រប់គ្រងកាតព្វកិច្ចបំណុលជាយថាហេតុ ដែលកើតចេញពីការធានាក៏ពុំទាន់មានលក្ខណៈប្រមូលផ្តុំ ។ ទន្ទឹមនេះ សមត្ថភាពធនធានមនុស្សទាំងចំនួន និងកម្រិតសមត្ថភាពមន្ត្រីនៅពុំទាន់អាចឆ្លើយតបបានតាមតម្រូវការការងារបច្ចុប្បន្ន ក៏ដូចជាទៅអនាគតនៅឡើយ ។
- **ការកត់ត្រាកាតព្វកិច្ចបំណុលជាយថាហេតុ** ÷ ទិន្នន័យនៃកាតព្វកិច្ចបំណុលជាយថាហេតុមួយចំនួន ដូចជាការធានារបស់រដ្ឋលើគម្រោងវិនិយោគក្នុងវិស័យថាមពល និងដឹកជញ្ជូន ត្រូវបានប្រមូលយកមកកត់ត្រា និងវិភាគក្តី ក៏ប៉ុន្តែ ទិន្នន័យនេះនៅពុំទាន់មានភាពគ្រប់ជ្រុងជ្រោយនៅឡើយ[22]។ ប្រការនេះ នាំឱ្យលទ្ធផលនៃការវិភាគ ពុំអាចធានាបាននូវសុក្រឹតភាពពេញលេញ ដើម្បីធ្វើការសន្និដ្ឋានឱ្យបានច្បាស់លាស់អំពីទំហំ និងផលប៉ះពាល់នៃកាតព្វកិច្ចបំណុលជាយថាហេតុ មកលើស្ថានភាពបំណុលសាធារណៈ ។

៤៤. **ការគ្រប់គ្រងលើវិស័យមូលបត្ររដ្ឋ** ÷ ក្របខណ្ឌបទប្បញ្ញត្តិសម្រាប់អភិវឌ្ឍទីផ្សារមូលបត្ររដ្ឋ ត្រូវបាននិងកំពុងរៀបចំ ។ ច្បាប់មូលបត្ររដ្ឋ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០៧ ប៉ុន្តែដោយសារតែស្ថានភាពសេដ្ឋកិច្ច, លក្ខខណ្ឌហិរញ្ញប្បទាន និងកម្រិតនៃការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុ នៅមិនទាន់អំណោយផល, រាជរដ្ឋាភិបាលកម្ពុជាក៏មិនទាន់សម្រេចបោះផ្សាយលក់មូលបត្ររដ្ឋនៅឡើយ ។ បច្ចុប្បន្ននេះ អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ

---

21 *គោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦ -២០២០ ត្រូវបានអនុម័ត និងប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ នៅក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី កាលពីខែកញ្ញា ឆ្នាំ២០១៦ ។*

22 *ទិន្នន័យពាក់ព័ន្ធមួយចំនួនទៀត ដូចជា ការធានារបស់រដ្ឋលើគម្រោងវិនិយោគក្នុងវិស័យផ្សេងទៀត, គម្រោងដែលរដ្ឋបានបញ្ចប់កិច្ចសន្យាមុនកាលកំណត់ ហើយទិញត្រឡប់មកវិញ, និងកាតព្វកិច្ចបំណុលជាយថាហេតុ ក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ ជាដើម ។ល។*

រួមជាមួយនឹងដៃគូអភិវឌ្ឍន៍ បាននិងកំពុងសិក្សាស្រាវជ្រាវបន្ថែម ដើម្បីធ្វើវិសោធនកម្មច្បាប់ស្តីពីច្បាប់មូលបត្ររដ្ឋ ។ បន្ថែមពីនេះ កសហវ. នឹងបន្តរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការបោះផ្សាយ និងគ្រប់គ្រងមូលបត្ររដ្ឋ, អនុក្រឹត្យស្តីពីគណៈកម្មាធិការធិការគ្រប់គ្រងមូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ, សេចក្តីព្រាងឯកសារយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍទីផ្សារមូលបត្ររដ្ឋនៅកម្ពុជា, សេចក្តីព្រាងប្រកាសស្តីពីប្រតិបត្តិការមូលបត្ររដ្ឋ, សេចក្តីព្រាងសៀវភៅណែនាំប្រតិបត្តិការមូលបត្ររដ្ឋនៅកម្ពុជា, បញ្ជីសម្រាំង (Checklist) ភាពគ្រប់គ្រាន់សម្រាប់ការដាក់ឱ្យដំណើរការទីផ្សារមូលបត្ររដ្ឋនៅកម្ពុជា និងសេចក្តីព្រាងផែនទីបង្ហាញផ្លូវក្នុងការបោះផ្សាយសញ្ញាបណ្ណរដ្ឋ ។

*គោលបំណង ១៣÷ ពង្រឹងការគ្រប់គ្រងសាច់ប្រាក់ និងគណនី*

៤៥. **បន្តកែលម្អ និងពង្រឹងការរៀបចំផែនការសាច់ប្រាក់** ÷ អគ្គនាយកដ្ឋានរតនាគារជាតិ បានរៀបចំផែនការសាច់ប្រាក់ជាប្រចាំ និងរៀបចំវគ្គបណ្តុះបណ្តាលដល់ក្រសួង-ស្ថាប័ន ចំនួន ៣០ អំពីការបញ្ចូលទិន្នន័យក្នុងប្រព័ន្ធ Web-Based Application ទន្ទឹមនឹងការបន្តតាមដានការបញ្ចូលទិន្នន័យក្នុងប្រព័ន្ធ ។ ដោយឡែក សម្រាប់ការពិនិត្យតាមដានអំពីសមតុល្យសាច់ប្រាក់ប្រចាំថ្ងៃក្នុងរចនាសម្ព័ន្ធគណនីទោលនៅរតនាគារ ត្រូវបានធ្វើឡើងជាប្រចាំ ។

៤៦. **បន្តពង្រឹងការប្រើប្រាស់ប្រព័ន្ធធនាគារ និងសិក្សាអំពីលទ្ធភាពឈានទៅអនុវត្តការទូទាត់តាម E-Transfer** ÷ អគ្គនាយកដ្ឋានរតនាគារជាតិ បានបន្តតាមដាន និងសហការជាមួយក្រសួង-ស្ថាប័ន ដើម្បីជំរុញការបើកប្រាក់តាមប្រព័ន្ធធនាគារ ទន្ទឹមនឹងការសហការជាមួយរតនាគាររាជធានី-ខេត្ត ដើម្បីពង្រឹងការប្រើប្រាស់សេវាធនាគារពាណិជ្ជ ទាំងផ្នែកចំណូល និងចំណាយតាមរយៈកិច្ចប្រជុំជាប្រចាំខែ ។ អគ្គនាយកដ្ឋានរតនាគារជាតិ បានរៀបចំកិច្ចប្រជុំពិភាក្សាជាមួយនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន និងធនាគារកាណាឌីយ៉ា អំពីការធ្វើសន្ទានកម្ម និងការភ្ជាប់បណ្តាញរវាងប្រព័ន្ធ FMIS និងប្រព័ន្ធធនាគារកាណាឌីយ៉ា ក្នុងការប្រើប្រាស់ EFT ។ ជាលទ្ធផល អនុស្សារណៈយោគយល់ស្តីពីការប្រើប្រាស់ EFT រវាង កសហវ. និងធនាគារកាណាឌីយ៉ា កំពុងស្ថិតនៅក្នុងការពិនិត្យ ។

៤៧. **រៀបចំយន្តការប្រមូលផ្តុំ និងប្តូកសរុបរបាយការណ៍អនុវត្តថវិកាគម្រោងរបស់ដៃគូអភិវឌ្ឍន៍ ដែលនៅក្រៅប្រព័ន្ធរតនាគារ** ÷ អង្គភាពដែលមានការពាក់ព័ន្ធ បានរៀបចំកិច្ចប្រជុំអំពីការអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិកាថ្មី (CoA) សម្រាប់គម្រោង/កម្មវិធីហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍សម្រាប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ។ ដើម្បីជំរុញក្រសួង-ស្ថាប័នឱ្យប្រើប្រាស់ប្លង់គណនេយ្យថវិកាថ្មី អង្គភាពដែលទទួលបន្ទុកលើការងារនេះបានស្នើក្រសួង-ស្ថាប័នដាក់បញ្ចូលជាផែនការសកម្មភាពនៅក្នុងការងារកែទម្រង់ (MAP) ។

៤៨. **បន្តតាមដានបំណុលកកស្ទះ និងពិនិត្យការសុំបើកគណនីរបស់ក្រសួង-ស្ថាប័ន** ÷ អគ្គនាយកដ្ឋានរតនាគារជាតិបានបន្តតាមដានបំណុលកកស្ទះជាប្រចាំ ពោលគឺបំណុលកកស្ទះ ត្រូវបានលុបបំបាត់ទាំងស្រុង និងមិនមានការកកើតឡើងវិញ ។ ទន្ទឹមនេះ គណនីបានកើនឡើង ពី ៩២ ក្នុងឆ្នាំ២០១៨ ដល់ ៩៩ ក្នុងឆ្នាំ២០១៩ ដោយសារមានការកើនឡើងគម្រោងនៃការខ្ចី ដែលតម្រូវឱ្យបើកគណនីសម្រាប់គម្រោងនីមួយៗ ។

៤៩. **ពន្លឿនការទូទាត់បុរេប្រទាន** ÷ ថវិកាបុរេប្រទានត្រូវបានកត់ត្រាតាមដានក្នុងបញ្ជីវិភាគ និងរបាយការណ៍ជាប្រចាំដោយលម្អិតតាមថ្ងៃ ខែ ឆ្នាំ និងតាមឈ្មោះក្រសួង-ស្ថាប័ននីមួយៗ ។ គិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៩ ស្ថានភាព

បុរេប្រទានក្នុងឆ្នាំ២០១៩ ដែលក្រសួង-ស្ថាប័ន បានបុរេប្រទានមានចំនួនប្រមាណ ៨៧៣ ប៊ីលានរៀល ក្នុងនោះ ថវិកាចរន្តប្រមាណ ៤០៧ ប៊ីលានរៀល និងវិនិយោគប្រមាណ ៤៦៦ ប៊ីលានរៀល ។ របាយការណ៍ចំណាយបុរេប្រទានត្រូវបានរៀបចំជាប្រចាំត្រីមាស ដើម្បីជាមូលដ្ឋានចាត់វិធានការជំរុញការទូទាត់ ។

### *គោលបំណង ១៤÷ កែលម្អការអនុវត្តថវិកា និងពង្រឹងការអនុវត្តផែនការចំណាយ*

៥០. **កែលម្អប្រព័ន្ធលទ្ធកម្មសាធារណៈឱ្យស្របនឹងយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកាជាតិ** ÷ យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ឆ្នាំ២០១៩-២០២៥ ដែលត្រូវបានឯកភាពដោយរាជរដ្ឋាភិបាលកាលពីថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩ មានគោលបំណងធ្វើឱ្យប្រព័ន្ធលទ្ធកម្មសាធារណៈក្លាយទៅជា “**ប្រព័ន្ធមួយដែលកាន់តែមានភាពជឿទុកចិត្ត ប្រសិទ្ធភាព ការប្រកួតប្រជែង និងការសន្សំសំចៃ ព្រមទាំងស្របតាមឧត្តមានុវត្តន៍អន្តរជាតិ**” ។ យុទ្ធសាស្ត្រនៃការទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥ បានកំណត់នូវទិសដៅជាយុទ្ធសាស្ត្រអាទិភាព លើការកែទម្រង់គន្លឹះៗ រួមមាន (១)ការរៀបចំ និងការអនុម័តផែនការលទ្ធកម្ម, (២) ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ, (៣) ការត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តកិច្ចលទ្ធកម្ម (សវនកម្មកិច្ចលទ្ធកម្ម), (៤) ការពង្រឹងឯករាជ្យភាពនៃយន្តការដោះស្រាយបណ្តឹងតវ៉ា និងបង្កើតឱ្យមានរបបដាក់ទោសទណ្ឌ និង (៥) ហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់ ដែលរួមមាន ការកែលម្អក្របខណ្ឌគតិយុត្តពាក់ព័ន្ធលទ្ធកម្មសាធារណៈ, ការរៀបចំសៀវភៅណែនាំស្តីពីលទ្ធកម្មសាធារណៈ, ការសិក្សាអំពីការប្រើប្រាស់លទ្ធកម្មសាធារណៈតាមប្រព័ន្ធអេឡិចត្រូនិក និងការកសាងសមត្ថភាព ។




៥១. **ស្របតាមយុទ្ធសាស្ត្រខាងលើ** ប្រកាសស្តីពីការផ្តល់កម្រិតទឹកប្រាក់សិទ្ធិសម្រេចក្នុងកិច្ចលទ្ធកម្មសាធារណៈ ត្រូវបានដាក់ឱ្យអនុវត្ត ទន្ទឹមនឹងគោលការណ៍ណែនាំស្តីពីការភ្ជាប់ផែនការលទ្ធកម្មជាមួយនឹងសំណើសុំថវិកាប្រចាំឆ្នាំត្រូវបានដាក់ឱ្យអនុវត្ត តាមរយៈសារាចរណែនាំលេខ ០០៦ សហវ. ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការរៀបចំគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំ ។ ទន្ទឹមនេះ ផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រខាងលើ ត្រូវបានរៀបចំដោយធ្វើការកំណត់ច្បាស់លាស់អំពីវិធានការជាយុទ្ធសាស្ត្រ(ទាំងវិធានការជាយុទ្ធសាស្ត្របន្ទាន់ចំពោះមុខ និងវិធានការជាយុទ្ធសាស្ត្ររយៈពេលមធ្យម), ក្របខណ្ឌរួមនៃផែនការសកម្មភាពលម្អិត ព្រមទាំងយន្តការសម្របសម្រួល និងត្រួតពិនិត្យតាមដាន និងវាយតម្លៃ ។

៥២. **អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ បាននិងកំពុងបន្តអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងលទ្ធកម្មសាធារណៈតាមប្រព័ន្ធព័ត៌មានវិទ្យា (Public Procurement Management Information System - PPMIS)** សម្រាប់ការគ្រប់គ្រងការងាររបស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ជាងមុន ។ គិតត្រឹមឆ្នាំ២០១៩ មុខងារចំនួន ៥ ត្រូវបានអភិវឌ្ឍរួចរាល់ ក្នុងនោះរួមមាន (១) មុខងារគ្រប់គ្រងផែនការលទ្ធកម្ម, (២) មុខងារគ្រប់គ្រងបុគ្គលិក, (៣) មុខងារគ្រប់គ្រងបញ្ជីអ្នកដេញថ្លៃ, (៤) មុខងារគ្រប់គ្រងការប្រគល់ទទួល, (៥) មុខងារគ្រប់គ្រងទិដ្ឋាការលើឯកសារដេញថ្លៃ ។ ដោយឡែក មុខងារចំនួន ២ កំពុងត្រូវបានបន្តអភិវឌ្ឍ ក្នុងនោះរួមមាន មុខងារគ្រប់គ្រងកិច្ចសន្យា និងមុខងារគ្រប់គ្រងលំហូរឯកសារ ។

៥៣. **ពង្រឹងការរៀបចំ និងអនុវត្តផែនការចំណាយ ÷** អគ្គនាយកដ្ឋានថវិកាបានកែលម្អ និងដាក់ឱ្យអនុវត្តទម្រង់ថ្មីនៃកម្មវិធីចំណូល-ចំណាយតាមកម្មវិធី ។ ការរៀបចំកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស ត្រូវបានធ្វើឡើងមិនឱ្យលើសពីសប្តាហ៍ទី ៣ នៃត្រីមាសបន្ទាប់ ។ ទន្ទឹមនេះ របាយការណ៍មួយចំនួនត្រូវបានរៀបចំជាប្រចាំ រួមមាន របាយការណ៍អនុវត្តចំណាយប្រចាំត្រីមាសតាមមាតិកាសេដ្ឋកិច្ច, របាយការណ៍ចំណាយចរន្តថ្នាក់ជាតិ, របាយ-ការណ៍ចំណាយចរន្តធៀបនឹងផែនការចំណាយ និងរបាយការណ៍អនុវត្តចំណាយវិនិយោគ ។

៥៤. **ពិនិត្យ និងធ្វើបច្ចុប្បន្នភាពក្របខណ្ឌគតិយុត្ត សម្រាប់ចំណាយរដ្ឋទេយ្យបុរេប្រទាន ÷** អង្គភាពដែលមានការពាក់ព័ន្ធ បានរៀបចំកិច្ចប្រជុំស្តីពីការបន្ទាន់នីតិវិធី និងការកត់ត្រាប្រតិបត្តិការនៅក្នុងប្រព័ន្ធ FMIS សម្រាប់អនុវត្តនៅក្នុងឆ្នាំសារពើពន្ធ២០២០ លើថវិការដ្ឋទេយ្យបុរេប្រទានរបស់ក្រសួង-ស្ថាប័ន ទន្ទឹមនឹងការសិក្សាអំពីបញ្ហាប្រឈមនៃការអនុវត្តនីតិវិធីរដ្ឋទេយ្យបុរេប្រទាន ។

៥៥. **បន្តពង្រឹងប្រសិទ្ធភាពចំណាយវិនិយោគសាធារណៈ ÷** យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥ ដែលត្រូវបានឯកភាពដោយរាជរដ្ឋាភិបាលកាលពីថ្ងៃទី ២២ ខែតុលា ឆ្នាំ២០១៩ មានគោលបំណងកំណត់ក្របខណ្ឌទស្សនាទានរួមមួយ សម្រាប់បង្កើតប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈពីគ្រប់ប្រភពហិរញ្ញប្បទាន[23] និងនៅគ្រប់កម្រិតរដ្ឋបាល ។ ទន្ទឹមនេះ អនុក្រឹត្យលេខ១៨១ អនក្រ. បក ចុះថ្ងៃទី ០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមសម្រាប់ការគ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ត្រូវបានប្រកាសដាក់ឱ្យអនុវត្ត ។

៥៦. **ពង្រឹងប្រសិទ្ធភាពគ្រប់គ្រង និងការអនុវត្តការងារជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ÷** សេចក្តីព្រាងបឋមស្តីពីការរៀបចំគោលការណ៍ណែនាំស្តីការគ្រប់គ្រង និងការអនុវត្តថវិកាសម្រាប់ការងារជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ (ផ្លូវថ្នល់ ៦១ ០៥៣) កំពុងស្ថិតក្នុងការពិភាក្សាកែសម្រួល ដោយមិនទាន់បានសម្រេចនៅឡើយ[24] ។ ទោះយ៉ាងនេះក្តី សេចក្តីព្រាងបឋមត្រូវបានរៀបចំរួចរាល់ ដោយក្រុមការងារទទួលបន្ទុក ។ យោងតាមយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥, សកម្មភាពនេះនឹងត្រូវបញ្ចប់ត្រឹមឆ្នាំ២០២០ ។

---

[23] *ទាំងថវិកាថ្នាក់ជាតិ ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ និងទុនវិនិយោគឯកជនតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន*

[24] *ដោយសារជ្រើសរើសទីប្រឹក្សាមិនទាន់បាន*

**ការងារធ្វើបន្ត**

- អនុវត្តផែនការសកម្មភាពនៃយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣
- អនុវត្តផែនការសកម្មភាពនៃយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ឆ្នាំ២០១៩-២០២៥
- អនុវត្តផែនការសកម្មភាពនៃយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥ ។

**ផ្នែកទី២ "បន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ"**

៩៧. ផ្នែកពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ ផ្តោតលើគោលបំណងចំនួន ៥ រួមមាន (១) ពង្រឹងការអនុវត្តថវិកា និងប្លង់គណនេយ្យថ្មី, (២) ពង្រឹងការអនុវត្តប្រព័ន្ធថវិកាថ្មី និងដំណើរការប្រតិបត្តិការថ្មី, (៣) ពង្រឹងការអនុវត្តប្រព័ន្ធគណនេយ្យថ្មី ប្រព័ន្ធកត់ត្រាថ្មី និងប្រព័ន្ធរបាយការណ៍ថ្មី, (៤) ពង្រឹងការអនុវត្តឧបករណ៍ និងយន្តការដើម្បីបង្កើនការទទួលខុសត្រូវ និងគណនេយ្យភាព, និង (៥) បង្កើនតម្លាភាពថវិកា ។

៩៨. **ប្រព័ន្ធ FMIS បច្ចុប្បន្នមានមុខងារស្នូលចំនួន ៦** ដែលកំពុងដំណើរការប្រើប្រាស់ដោយការដ្ឋានដែលបានរៀបរាប់ខាងលើ រួមមាន មុខងារវិភាជន៍ថវិកា (BA), មុខងារការទិញ (PO), មុខងារគណនីត្រូវសង (AP), មុខងារគណនីត្រូវទារ (AR), មុខងារគ្រប់គ្រងសាច់ប្រាក់ (CM) និងមុខងារសៀវភៅធំ (GL)។ មុខងារថ្មីចំនួនពីរបន្ថែមត្រូវបានឯកភាពឱ្យរៀបចំ និងអភិវឌ្ឍ នៅក្នុងក្របខណ្ឌគម្រោង FMIS ដំណាក់កាលទី២ គឺមុខងាររៀបចំផែនការថវិកា និងមុខងារកិច្ចលទ្ធកម្ម និងគ្រប់គ្រងកិច្ចសន្យា ។ ការរៀបចំមុខងាររៀបចំផែនការថវិកា សម្រេចបាននូវការរៀបចំឯកសារតម្រូវការមុខងារ, ឯកសារនីតិវិធីអនុវត្តការងារបច្ចុប្បន្ន, ឯកសារដេញថ្លៃផ្គត់ផ្គង់ និងបានដាក់ប្រកាសឱ្យដេញថ្លៃរួចរាល់ ដែលគ្រោងនឹងបញ្ចប់ការដេញថ្លៃនៅក្នុងត្រីមាសទី១ ឆ្នាំ២០២០ ។ ចំណែកឯការរៀបចំមុខងារកិច្ចលទ្ធកម្ម និងគ្រប់គ្រងកិច្ចសន្យា សម្រេចបាននូវការឯកភាពជាគោលការណ៍ក្នុងការជ្រើសរើសកម្មវិធី Oracle PeopleSoft Software មកប្រើប្រាស់ដោយទិញបន្ថែមនូវអាជ្ញាបណ្ណម៉ូឌុលថ្មីពីរគឺ Supplier Contract Management និង Strategic Sourcing តាមរយៈការចុះកិច្ចសន្យាផ្ទាល់ជាមួយក្រុមហ៊ុនដៃគូក្នុងស្រុករបស់ក្រុមហ៊ុន Oracle ដែលគ្រោងនឹងបញ្ចប់ចុះកិច្ចសន្យាផ្ទាល់ជាមួយក្រុមហ៊ុនផ្គត់ផ្គង់ក្នុងត្រីមាសទី១ ឆ្នាំ២០២០ ។

៩៩. **ប្រព័ន្ធ FMIS ត្រូវបានរៀបចំ អភិវឌ្ឍ និងដាក់ឱ្យដំណើរការរួចរាល់នូវមុខងារសន្ធានកម្មមួយចំនួន** រួមមាន (១) សន្ធានកម្មរបាយការណ៍ធនាគារ (Bank Statement) ជាមួយធនាគារជាតិនៃកម្ពុជា, ធនាគារកាណាឌីយ៉ា, ធនាគារអេស៊ីលីដា, ធនាគារកម្ពុជាសាធារណៈ, ធនាគារវឌ្ឍនៈ និងធនាគារ ANZ Royal, (២) សន្ធានកម្មការទូទាត់តាមអេឡិកត្រូនិក (EFT) ជាមួយធនាគារជាតិនៃកម្ពុជា, (៣) សន្ធានកម្មចំណូលពន្ធគយ និងរដ្ឋាករជាមួយប្រព័ន្ធ ASYCUDA របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, (៤) សន្ធានកម្មចំណូលមូលធនជាមួយប្រព័ន្ធ DMFAS របស់អគ្គនាយកដ្ឋានសហប្រតិបត្តិការ និងគ្រប់គ្រងបំណុល និង (៥) សន្ធានកម្មចំណូលមិនមែនសារពើពន្ធជាមួយប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធរបស់ក្រុមការងារកែសម្រួលនីតិវិធីនៃការប្រមូលចំណូលមិនមែនសារពើពន្ធ ។ ដោយឡែក ការរៀបចំ និងអភិវឌ្ឍសន្ធានកម្មចំណូលពន្ធដារជាមួយប្រព័ន្ធគ្រប់គ្រងចំណូលពន្ធដាររបស់អគ្គនាយកដ្ឋានពន្ធដារសម្រេចបានក្នុងរង្វង់ ៩០% និងគ្រោងនឹងដាក់ឱ្យដំណើរការនៅក្នុងឆ្នាំ ២០២០ ។ ទន្ទឹមនឹងនេះ សន្ធានកម្មចំណាយបៀវត្សជាមួយប្រព័ន្ធគ្រប់គ្រងបៀវត្សមន្ត្រីរាជការស៊ីវិល

របស់ក្រសួងមុខងារសាធារណៈ ក៏បានសិក្សារួមគ្នាអំពីលទ្ធភាពបច្ចេកទេសរួចរាល់ និងបានដាក់ចេញនូវផែនការបន្តការសិក្សារៀបចំ និងអភិវឌ្ឍនៅក្នុងឆ្នាំ ២០២០ នេះ ផងដែរ ។

### *គោលបំណង ២១÷ ពង្រឹងការអនុវត្តថវិកា និងប្លង់គណនេយ្យថ្មី*

៦០. **កែលម្អ និងជំរុញការអនុវត្តចំណាត់ថ្នាក់ទាំង ៧ ÷** ចំណាត់ថ្នាក់មុខងារត្រូវបានធ្វើបច្ចុប្បន្នភាពសម្រាប់ក្រសួង-ស្ថាប័នដែលបានកែសម្រួលរចនាសម្ព័ន្ធកម្មវិធី ទន្ទឹមនឹងប្រកាសស្តីពីការបន្ថែមឱ្យអនុវត្តចំណាត់ថ្នាក់គម្រោងនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ ត្រូវបានរៀបចំ ។ លេខកូដ និងសេចក្តីបរិយាយ នៃចំណាត់ថ្នាក់ទាំង ៧ ត្រូវបានធ្វើបច្ចុប្បន្នភាពនៅក្នុងប្រព័ន្ធ FMIS ស្របតាមការកែសម្រួលពីអង្គភាពពាក់ព័ន្ធ ។ ដើម្បីភាពងាយស្រួលក្នុងការពិនិត្យរបាយការណ៍តាមចំណាត់ថ្នាក់ថវិកា, ក្រុមការងារ FMIS បានអភិវឌ្ឍរបាយការណ៍សាមញ្ញភាពតាមចំណាត់ថ្នាក់ថវិកាទាំង ៧ និងបានដំណើរការសាកល្បងចេញពីប្រព័ន្ធ FMIS រួចរាល់ ។ ទន្ទឹមនេះ ប្រកាសស្តីពីការកែសម្រួលចំណាត់ថ្នាក់ភូមិសាស្ត្ររដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានដាក់ឱ្យអនុវត្ត ។ ទិន្នន័យនៃការរៀបចំថវិកា, ការឧបត្ថម្ភថវិកាពីថ្នាក់ជាតិ និងការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានកត់ត្រានៅក្នុងប្រព័ន្ធ FMIS ។ ដោយឡែក អគ្គនាយកដ្ឋានថវិកាបានរៀបចំឯកសារទស្សនាទានស្តីពី ចំណាត់ថ្នាក់សេដ្ឋកិច្ចបំពេញ ។ សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ នៅក្នុងទម្រង់ និងមាតិកាថ្មី គឺតាមចំណាត់ថ្នាក់កម្មវិធី និងចំណាត់ថ្នាក់សេដ្ឋកិច្ចបំពេញ ខាងលើនេះ នឹងត្រូវដាក់ជូនស្ថាប័ននីតិបញ្ញត្តិ ដើម្បីពិនិត្យពិនិស្ស័យ និងសុំការអនុម័តនៅឆ្នាំ២០២២ ។

៦១. **ពង្រឹងការអនុវត្តប្លង់គណនេយ្យសាធារណៈ÷** ប្លង់គណនេយ្យសាធារណៈត្រូវបានត្រួតពិនិត្យលើការអនុវត្តនៅគ្រឹះស្ថានសាធារណៈរដ្ឋបាល ចំនួន ៣ រួមមាន (១) មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត, (២) សាលាជាតិកសិកម្មព្រែកលៀប និង (៣) សាលាជាតិកសិកម្មកំពង់ចាម ។

៦២. **ពង្រឹងសង្គតិភាពរវាងចំណាត់ថ្នាក់នៃមាតិកាថវិកា, ជញ្ជីងទូទាត់, គណនេយ្យជាតិ និងស្ថិតិរូបិយវត្ថុនិងហិរញ្ញវត្ថុ ជាមួយក្របខណ្ឌស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល ÷** អគ្គនាយកដ្ឋានគោលនយោបាយបានសិក្សា និងរៀបចំរបាយការណ៍ពិនិត្យផ្ទៀងផ្ទាត់សង្គតិភាព នៃស្ថិតិ GFS ជាមួយប្រព័ន្ធស្ថិតិម៉ាក្រូសេដ្ឋកិច្ច ។

### *គោលបំណង ២២÷ ពង្រឹងការអនុវត្តប្រព័ន្ធអនុវត្តថវិកាថ្មី និងដំណើរការប្រតិបត្តិការថ្មី*

៦៣. **រៀបចំបរិបទនៃប្រតិបត្តិការចំណាយនៅតាមក្រសួង-ស្ថាប័នឱ្យស្របតាមប្រព័ន្ធ FMIS ÷** ក្រសួង-ស្ថាប័នចំនួន ១៧ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការបន្ថែមកាលពីចុងខែកុម្ភៈ ឆ្នាំ២០២០ ។ ជាមួយគ្នានេះ សៀវភៅណែនាំស្តីពីការបញ្ចូលប្រតិបត្តិការចំណាយក្នុងប្រព័ន្ធ FMIS ត្រូវបានកែលម្អស្របតាមស្ថានភាពជាក់ស្តែង ។ ក្រុមការងារ FMIS បានរៀបចំផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារតាមប្រព័ន្ធ FMIS ២០២០-២០២៥[25] ដោយបានចាប់ផ្តើមពីការកំណត់មុខសញ្ញានីតិវិធីទូទាត់ចំណាយដែលមានហានិភ័យទាប (ចំណាយបៀវត្ស និងចំណាយទូទាត់ត្រង់) យកមកសិក្សាក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីផ្តល់គំរូសម្រាប់ពង្រីកការអនុវត្តនីតិវិធីកែសម្រួល និងតម្រង់ទិសថ្មីនេះ ទៅកាន់ក្រសួង-ស្ថាប័នផ្សេងៗ ទៀត ។

---

[25] *ផែនការយុទ្ធសាស្ត្រនេះ ត្រូវបានឯកភាពកាលពីថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០២០ ក្នុងកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។*

៦៤. **កែលម្អប្រតិបត្តិការគណនេយ្យហិរញ្ញវត្ថុ÷** អគ្គនាយកដ្ឋានរតនាគារជាតិ បានរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យនៃទ្រព្យសកម្មរយៈពេលវែង Fixed Asset Threshold ។

៦៥. **កសាងសមត្ថភាពគ្រប់គ្រងគម្រោង FMIS ÷** មន្ត្រីនៃក្រសួង-ស្ថាប័នទាំង ១៧ បន្ថែមថ្មី ចំនួន ៣៧២ រូប បានទទួលការបណ្តុះបណ្តាលលើការប្រើប្រាស់ប្រព័ន្ធ FMIS ។ មន្ត្រីនៃក្រសួង-ស្ថាប័នចំនួន ១០ និងមន្ទីរទាំង ២៥ រាជធានី-ខេត្ត សរុបចំនួន ២៣០ រូប (ជាមន្ត្រីបង្គោល) បានទទួលការបណ្តុះបណ្តាលបំប៉នសមត្ថភាពបន្ថែម ។ ជារួម ក្រសួង-ស្ថាប័នចំនួន ២០ និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទាំង២៥ រាជធានី-ខេត្ត អាចយល់ដឹងកាន់តែស៊ីជម្រៅអំពីប្រព័ន្ធ FMIS និងចូលរួមយ៉ាងសកម្មលើការអនុវត្តប្រព័ន្ធ FMIS ក្នុងការទាញផលប្រយោជន៍ជាអតិបរមាពីប្រព័ន្ធ តាមរយៈការចូលរួមវគ្គបណ្តុះបណ្តាលគន្លឹះ ដូចជា ការទាញទិន្នន័យជា Query ដើម្បីរៀបចំរបាយការណ៍ផ្សេងៗ, ការផលិតរបាយការណ៍ចេញពីប្រព័ន្ធ FMIS, និងការពិនិត្យតាមដានបញ្ជីប្រតិបត្តិការ ។

៦៦. **ពង្រីកការអនុវត្ត FMIS ÷** ក្រុមការងារអនុវត្តគម្រោង FMIS និងឯកសារនីតិវិធីអនុវត្តការងារបច្ចុប្បន្ន និងនីតិវិធីអនុវត្តការងារថ្មីតាមប្រព័ន្ធ FMIS នៅតាមក្រសួង-ស្ថាប័ន បន្ថែមទាំង ១៧ ត្រូវបានរៀបចំរួចរាល់ ។ ឧបករណ៍សម្ភារៈបច្ចេកវិទ្យាព័ត៌មានសម្រាប់អ្នកប្រើប្រាស់ និងសម្រាប់បណ្តាញតភ្ជាប់ ត្រូវបានផ្គត់ផ្គង់ និងដំឡើងគ្រប់គ្រាន់សម្រាប់ការដ្ឋានប្រព័ន្ធ FMIS ទាំងអស់ ដើម្បីបញ្ចប់ការដ្ឋានក្នុងការអនុវត្តគម្រោង FMIS ដំហានទី២ ។ ក្រុមការងារ FMIS បានធ្វើការគាំទ្រ និងដោះស្រាយបញ្ហាប្រឈមលើការប្រើប្រាស់ប្រព័ន្ធ FMIS តាមរយៈការដាក់ឱ្យដំណើរការប្រព័ន្ធ Help Desk ថ្មីមានឈ្មោះថា PK-The Helper និងមជ្ឈមណ្ឌលដោះស្រាយបឋម (Front Desk Center) ។

៦៧. **ការកែលម្អនីតិវិធីអនុវត្តការងារ ÷** ក្រុមការងារ FMIS បានរៀបចំរួចរាល់នូវផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារតាមប្រព័ន្ធ FMIS ឆ្នាំ២០២០-២០២៥ ដោយបានចាប់ផ្តើមពីការកំណត់មុខសញ្ញានីតិវិធីទូទាត់ចំណាយដែលមានហានិភ័យទាប (ចំណាយបៀវត្ស និង ចំណាយទូទាត់ត្រង់) និងបន្តពង្រីកការសិក្សាលើនីតិវិធីអនុវត្តការងារទូទាត់ចំណាយដែលមានហានិភ័យនៅកម្រិតបន្តបន្ទាប់ទៀតក្នុងក្របខណ្ឌថវិកាចរន្ត ដោយបែងចែកនីតិវិធីអនុវត្តការងារជា ៤ ប្រភេទធំៗ គឺ (១) នីតិវិធីអនុវត្តការងារលើការធានាចំណាយ និងទូទាត់ចំណាយ, (២) នីតិវិធីអនុវត្តការងារលើការធ្វើចលនាឥណទានថវិកា, (៣) នីតិវិធីអនុវត្តការងារលើការអនុវត្តចំណូលថវិកា និង (៤) នីតិវិធីអនុវត្តការងារពាក់ព័ន្ធនឹងកិច្ចលទ្ធកម្ម ។ នីតិវិធីអនុវត្តការងារលើការទូទាត់បៀវត្ស និងទូទាត់ចំណាយត្រង់ក្នុងក្របខណ្ឌ កសហវ. ត្រូវបានសិក្សា ។ ផ្អែកលើលទ្ធផលនៃករណីសិក្សាលើនីតិវិធីទូទាត់ចំណាយបៀវត្ស, នីតិវិធីត្រូវបានកាត់បន្ថយពី ៨៦ ជំហាន មកត្រឹម ១៣ ជំហាន ដែលបានផ្តល់នូវធាតុចូលដ៏សំខាន់សម្រាប់ការរៀបចំឯកសារផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារតាមប្រព័ន្ធ FMIS ឆ្នាំ២០២០-២០២៥ ។

៦៨. **ការគ្រប់គ្រងការផ្លាស់ប្តូរ÷** ការគ្រប់គ្រងការផ្លាស់ប្តូរគឺជាចលករមួយក្នុងការជំរុញការអនុវត្តគម្រោង FMIS ឱ្យទទួលបានជោគជ័យ ។ សមាសធាតុសំខាន់ៗនៃការគ្រប់គ្រងការផ្លាស់ប្តូរដែលបានអនុវត្តកន្លងមក រួមមាន (១)ការសិក្សាលើអ្នកពាក់ព័ន្ធនឹងការផ្លាស់ប្តូរ, (២) ការវាយតម្លៃលើការត្រៀមលក្ខណៈក្នុងការផ្លាស់ប្តូរ, (៣) ការវាយតម្លៃលើផលប៉ះពាល់, (៤) ការទំនាក់ទំនងផ្សព្វផ្សាយ និង (៥) ការបណ្តុះបណ្តាលជំនាញថ្មី ។ មន្ត្រី

ទទួលបន្ទុកអនុវត្តចំណូល-ចំណាយថវិកា កិច្ចបញ្ជិកាគណនេយ្យ អនុវត្តកិច្ចលទ្ធកម្ម និងគ្រប់គ្រងហិរញ្ញវត្ថុ ប្រមាណជាង ១៣០០ នាក់ មកពីគ្រប់ការដ្ឋានរបស់ប្រព័ន្ធ FMIS ។ ផែនការគ្រប់គ្រងការផ្លាស់ប្តូរត្រូវបានរៀបចំឡើង ដោយមានគោលដៅប្រែក្លាយអ្នកពាក់ព័ន្ធនឹងការផ្លាស់ប្តូរទាំងអស់ពីការរង់ចាំទទួលព័ត៌មានពីការផ្លាស់ប្តូរពី គសហវ. ទៅជាម្ចាស់នៃការងារផ្លាស់ប្តូររបស់ខ្លួនវិញ, ប្រែក្លាយពីការប្រើប្រាស់ប្រព័ន្ធ FMIS ដើម្បីតែកត់ត្រា និងរៀបចំរបាយការណ៍ ទៅជាការប្រើប្រាស់ប្រព័ន្ធFMIS ដើម្បីគ្រប់គ្រង តាមដាន និងវិភាគលើការអនុវត្តថវិកា និងកម្មវិធីវិញ, ប្រែក្លាយនីតិវិធីអនុវត្តការងារដោយដៃផង និងដោយប្រព័ន្ធផង ទៅជានីតិវិធីអនុវត្តការងារតាមប្រព័ន្ធ FMIS ទាំងស្រុង ។ល។ ផ្សារភ្ជាប់នឹងផែនការកែសម្រួល និងតម្រង់ទិសនីតិវិធីអនុវត្តការងារ ការគ្រប់គ្រងការផ្លាស់ប្តូរគឺជាផ្នែកមួយចាំបាច់មិនអាចខ្វះបាន ដើម្បីជំរុញឱ្យមានការកែសម្រួលនីតិវិធីអនុវត្តការងារដែលមានបច្ចុប្បន្ន ទៅជានីតិវិធីថ្មីមួយដែលសាមញ្ញ ចំណេញពេលវេលា និងមានគណនេយ្យភាពច្បាស់លាស់ ។

***គោលបំណង ២៣÷ ពង្រឹងការអនុវត្តប្រព័ន្ធគណនេយ្យថ្មី ប្រព័ន្ធកត់ត្រាថ្មី ប្រព័ន្ធរបាយការណ៍ថ្មី***

៦៩. **រៀបចំស្តង់ដាគណនេយ្យសាធារណៈស្របតាមស្តង់ដា IPSAS និងដាក់ឱ្យអនុវត្តជាបណ្តើរៗ តាមលំដាប់-លំដោយ** ÷ គសហវ. បានដាក់ឱ្យអនុវត្តប្រកាសលេខ ៥៤៥ សហវ.ប្រក ចុះថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសាធារណៈកម្ពុជាមូលដ្ឋានសាច់ប្រាក់ ។ ស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានសាច់ប្រាក់ ត្រូវបានផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់រតនាគារទាំង ២៥ រាជធានី-ខេត្ត ។ ក្រុមប្រឹក្សាជាតិគណនេយ្យ បានរៀបចំសេចក្តីព្រាងចុងក្រោយនៃផែនការយុទ្ធសាស្រ្តអភិវឌ្ឍគណនេយ្យសាធារណៈកម្ពុជា[26] ដើម្បីឈានទៅអនុវត្តប្រព័ន្ធគណនេយ្យបង្គរ ។ ទន្ទឹមនេះ សមាសធាតុចំនួន ៣ នៅក្នុងរបាយការណ៍ IPSAS Cash Basis ត្រូវបានកែលម្អឱ្យអនុលោមភាពតាមគោលការណ៍ស្តង់ដា IPSAS Cash Basis តាមរយៈ (១) ការរៀបចំរបាយការណ៍ស្តីពីស្ថានភាពគណនីប្រាក់បញ្ញើរូបិយបណ្ណនៅធនាគារ, (២)ការរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំស្តីពីការទទួលស្គាល់ប្រតិបត្តិការរូបិយបណ្ណបរទេស, និង (៣) ការរៀបចំបញ្ចូលគោលកាណ៍បំព្រួញតួលេខចំណូល-ចំណាយ នៅក្នុងកំណត់ពន្យល់ហិរញ្ញវត្ថុ ។ ទន្ទឹមនេះ អគ្គនាយកដ្ឋានរតនាគារជាតិបានសាកល្បងរៀបចំសេចក្តីព្រាងរបាយការណ៍ IPSAS ឆ្នាំ២០១៧ ផ្អែកលើមូលដ្ឋានតួលេខដែលទាញចេញពីប្រព័ន្ធ FMIS ។

៧០. **កែលម្អទម្រង់របាយការណ៍អនុវត្តថវិកា** ÷ របាយការណ៍ និងតារាងឧបសម្ព័ន្ធសម្រាប់ភ្ជាប់ជាមួយច្បាប់ទូទាត់បានរៀបចំរួចរាល់ក្នុងប្រព័ន្ធ FMIS និងកំពុងដំណើរការធ្វើតេស្តសាកល្បង ក្នុងនោះរួមមាន តារាង គ១, តារាង គ២, តារាង គ៤, តារាង ខ២, តារាង ខ៣, តារាង ខ៤, ឧបសម្ព័ន្ធ ២, ឧបសម្ព័ន្ធ ៣, ឧបសម្ព័ន្ធ ៦, ឧបសម្ព័ន្ធ ៧, និងឧបសម្ព័ន្ធ ៨ ។ ដោយឡែក របាយការណ៍តារាង ក១, តារាង ក២, តារាង ក៣, តារាង ក៤, និងតារាង ក៥ កំពុងស្ថិតក្នុងដំណាក់កាលអភិវឌ្ឍន៍ ដែលរបាយការណ៍ទាំងនេះ ពឹងផ្អែកទៅលើលទ្ធផលនៃ

[26] *ផែនការយុទ្ធសាស្រ្តអភិវឌ្ឍគណនេយ្យសាធារណៈកម្ពុជាឆ្នាំ២០១៩-២០៣១ ត្រូវបានបែងចែកជាបួនដំណាក់កាល ដូចតទៅ÷*

*ដំណាក់កាលទី១ ÷ ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា មូលដ្ឋានសាច់ប្រាក់ ចាប់ពីឆ្នាំ២០២០-២០២៤*

*ដំណាក់កាលទី២ ÷ស្តង់ដាគណនេយ្យសាធារណៈកម្ពុជាមូលដ្ឋានសាច់ប្រាក់កែសម្រួលចាប់ពីឆ្នាំ២០២៥-២០២៧*

*ដំណាក់កាលទី៣ ÷ស្តង់ដាគណនេយ្យសាធារណៈកម្ពុជាមូលដ្ឋានបង្គរកែសម្រួលចាប់ពីឆ្នាំ២០២៨-២០៣០*

*ដំណាក់កាលទី៤÷ ស្តង់ដាគណនេយ្យសាធារណៈកម្ពុជាមូលដ្ឋានបង្គរពេញលេញចាប់ពីឆ្នាំ២០៣១។*

របាយការណ៍ផ្សេងៗទៀត ដែលបានអភិវឌ្ឍរួចរាល់ ។ ទោះបីជាយ៉ាងនេះក្តី ប្រព័ន្ធ FMIS ពុំទាន់អាចផលិតរបាយការណ៍សំខាន់ៗ មួយចំនួនសម្រាប់អគ្គនាយកដ្ឋានរតនាគារជាតិ និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅឡើយ ។

៧១. **ដាក់ឱ្យអនុវត្តយន្តការដើម្បីបញ្ចប់ការចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ និងធ្វើបច្ចុប្បន្នភាពជាប្រចាំ** ÷ អនុលោមតាមអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧ បានកម្រិតអាជ្ញាធរកាន់កាប់រហូតដល់រដ្ឋបាលក្រុង-ស្រុក-ខណ្ឌ និងឃុំ-សង្កាត់ ដែលនាំឱ្យចំនួនអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ មានការកើនឡើងពីចំនួន ៦១ រហូតដល់ ១ ៩១០ អាជ្ញាធរកាន់កាប់ ។ ក្នុងឆ្នាំ២០១៩ ក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋទាំងអស់ត្រូវរៀបចំតារាងកើនឡើង និងថយចុះនូវទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ២០១៨ ទូទាំងប្រទេស ដែលមានចំនួនសរុប ១ ៩១០ អាជ្ញាធរកាន់កាប់ ដោយមានអង្គភាពប្រើប្រាស់សរុបចំនួន ២ ៨៨៧ អង្គភាព ក្នុងនោះបានរៀបចំ និងបញ្ជូនមក កសហវ. និងមន្ទីរសហវ រាជធានី-ខេត្ត ចំនួន ២០៤៨ អង្គភាព ស្មើនឹង ៧១% នៃចំនួនអង្គភាពប្រើប្រាស់សរុប ។ ចំណែកនៅសល់ចំនួន ២៩% ស្មើនឹង ៨៣៩ អង្គភាពទៀត គឺមិនទាន់រៀបចំ និងបញ្ជូនមក កសហវ. នៅឡើយទេ ។



៧២. **អគ្គនាយកដ្ឋានគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ** បានរៀបចំសេចក្តីព្រាងប្រកាសស្តីពីគំរូនៃសៀវភៅបញ្ជីសារពើភណ្ឌឆ្នាំគោល និងតារាងកើនឡើង និងថយចុះនូវទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ ទន្ទឹមនឹងប្រកាសស្តីពីវិធាន និងនីតិវិធីលម្អិតនៃការជម្រះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវបានដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០២០ ។ ជាមួយគ្នានេះ អគ្គនាយកដ្ឋានគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ បានរៀបចំកម្មវិធីគ្រប់គ្រងទិន្នន័យទ្រព្យសម្បត្តិរដ្ឋតាមប្រព័ន្ធព័ត៌មានវិទ្យាដោយផ្សារភ្ជាប់ទៅអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋទាំងអស់នៅទូទាំងប្រទេស ហើយកម្មវិធីកំពុងត្រូវបានរៀបចំ ដោយចែកចេញជា ២ គឺ (១) កម្មវិធីមេ ដែលត្រូវគ្រប់គ្រងដោយ កសហវ. ដែលជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និង (២) កម្មវិធីគ្រប់គ្រងទិន្នន័យសម្រាប់ដាក់ឱ្យក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិ ។ ក្រសួង-ស្ថាប័នចំនួន ១០ នឹងត្រូវដាក់ឱ្យអនុវត្តសាកល្បងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងទ្រព្យ-សម្បត្តិរដ្ឋ ក្នុងនោះរួមមាន (១) ក្រសួងការពារជាតិ, (២) ក្រសួងមហាផ្ទៃ, (៣) ក្រសួងរៀបចំដែនដី នគរូបនីយ-កម្ម និងសំណង់, (៤) ក្រសួងឧស្សាហកម្ម និងសិប្បកម្ម, (៥) ក្រសួងសាធារណការ និងដឹកជញ្ជូន, (៦) ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, (៧) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, (៨) ក្រសួងអប់រំ យុវជន និងកីឡា, (៩) ក្រសួងសុខាភិបាល និង (១) ក្រសួងបរិស្ថាន ។

### *គោលបំណង ២៤÷ ពង្រឹងការអនុវត្តឧបករណ៍ និងយន្តការដើម្បីបង្កើនការទទួលខុសត្រូវ និងគណនេយ្យភាព*

៧៣. **ទណ្ឌកម្មរដ្ឋបាលសមស្របចំពោះកំហុសឆ្គង ឬការគ្រប់គ្រងធនធានសាធារណៈមិនសមស្រប និងគ្មានប្រសិទ្ធភាព** ÷ លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម បានរៀបចំសៀវភៅកម្រងសម្រង់វិធានការរួមនៃការដាក់ទណ្ឌកម្ម

ហិរញ្ញវត្ថុសាធារណៈ និងបានធ្វើបច្ចុប្បន្នភាពទណ្ឌកម្មរដ្ឋបាលសមស្របចំពោះកំហុសឆ្គង ឬការគ្រប់គ្រងធនធានសាធារណៈមិនសមស្រប និងគ្មានប្រសិទ្ធភាព មានចែងនៅក្នុងលិខិតបទដ្ឋានគតិយុត្តដែលនៅមានជាធរមាន ។

៣៤. **រៀបចំ និងដាក់ឱ្យអនុវត្តទម្រង់របាយការណ៍វឌ្ឍនភាពអនុវត្តថវិកាប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ÷** គ្រប់អង្គភាពថវិកានៃក្រសួង-ស្ថាប័ន បានអនុវត្តទម្រង់របាយការណ៍ហិរញ្ញវត្ថុ និងទម្រង់របាយការណ៍សមិទ្ធកម្ម/លទ្ធផល ប្រចាំត្រីមាស និងឆមាស ។

៣៥. **ពង្រឹងការត្រួតពិនិត្យលើប្រព័ន្ធព័ត៌មានវិទ្យា ÷** អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង បានចុះសាកល្បងធ្វើសវនកម្មលើប្រព័ន្ធ FMIS នៅអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ និងរតនាគារខេត្តចំនួន ៥ រួមមាន រតនាគារខេត្តកោះកុង, ខេត្តព្រៃវែង, ខេត្តត្បូងឃ្មុំ, ខេត្តរតនគិរី និងខេត្តកណ្ដាល និង នៅអង្គភាពថវិកានៃក្រសួង-ស្ថាប័នចំនួន ៤ រួមមាន ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងការងារ បណ្ដុះបណ្ដាល និងវិជ្ជាជីវៈ, ក្រសួងធនធានទឹក និងឧតុនិយម, និងក្រសួងអភិវឌ្ឍន៍ជនបទ ។

### *គោលបំណង ២៥÷ បង្កើនតម្លាភាពថវិកា*

៣៦. **គសហវ. បានយកចិត្តទុកលើការបើកចំហ** ឱ្យមានការចូលរួមមតិយោបល់ពីស្ថាប័នមិនមែនរដ្ឋាភិបាលនៅក្នុងវេទិកាពិគ្រោះយោបល់ផ្សេងៗនៅក្នុងដំណើរការ នៃការរៀបចំថវិកា និងការពង្រីកការបើកទូលាយព័ត៌មានថវិកាជាសាធារណៈ ក្នុងគោលដៅពង្រឹងការផ្សារភ្ជាប់រវាងផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធី និងក្នុងគោលដៅធ្វើឱ្យប្រព័ន្ធថវិកាកាន់តែក្លាយទៅជាឧបករណ៍គោលនយោបាយពិតប្រាកដក្នុងការបែងចែក និងប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ។

៣៧. **បង្កើនការចូលរួមពីសាធារណជនក្នុងដំណើរការថវិកា÷** ដើម្បីបង្កើនការចូលរួមពីសាធារណជន, អគ្គនាយកដ្ឋានថវិកាបានរៀបចំវេទិកាសាធារណៈ ស្ដីពីក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច និងក្របខណ្ឌថវិកាប្រចាំឆ្នាំ កាលពីដើមឆ្នាំ២០១៩ កន្លងទៅ ។ អគ្គនាយកដ្ឋានថវិកាក៏បានរៀបចំជាសៀវភៅថវិកាសង្ខេបនៃច្បាប់ថវិកាប្រចាំឆ្នាំ ព្រមទាំងឯកសារពន្យល់មួយចំនួន រួមមាន ឯកសារសេចក្ដីការពន្យល់សង្ខេបស្ដីពីសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ និងឯកសារសេចក្ដីពន្យល់សង្ខេបសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ។





៣៨. **បង្កើនការផ្សព្វផ្សាយឯកសារថវិកា ÷** គសហវ. បានធ្វើការផ្សព្វផ្សាយជាសាធារណៈនូវឯកសារពាក់ព័ន្ធមួយចំនួន រួមមាន (១) ឯកសារថវិកាប្រចាំឆ្នាំ (២) សៀវភៅថវិកាសង្ខេបនៃច្បាប់ថវិកាប្រចាំឆ្នាំ, (៣) សារាចរណែនាំស្ដីពីការអនុវត្តច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០, (៤) សារាចររៀបចំផែនការយុទ្ធសាស្ត្រថវិកា

និងកញ្ចប់ថវិកា, (៥) ប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ (ស្តង់ដា TOFE) ប្រចាំខែ, (៦) របាយការណ៍និន្នាការសេដ្ឋកិច្ច- សង្គម ប្រចាំខែ, (៧) ព្រឹត្តិបត្រស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រចាំត្រីមាស និង (៨) ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ។

៧៩. **បង្កើនតម្លាភាពកិច្ចលទ្ធកម្មសាធារណៈ ÷** អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ បានធ្វើការផ្សព្វផ្សាយលើគេហទំព័រនូវផែនការលទ្ធកម្មប្រចាំឆ្នាំ២០១៩ របស់ស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ និងរបាយការណ៍ត្រួតពិនិត្យកិច្ចលទ្ធកម្មតាមក្រោយប្រចាំឆ្នាំ២០១៨ លើការិយបរិច្ឆេទឆ្នាំ២០១៧ ។

**ការងារធ្វើបន្ត**

- **ប្រព័ន្ធ FMIS ÷** (១) រៀបចំផែនការពង្រីកការអនុវត្តគម្រោង FMIS ដំណាក់កាលទី៣, (២) រៀបចំ និងអភិវឌ្ឍមុខងារកិច្ចលទ្ធកម្ម និងរៀបចំផែនការថវិកា, (៣) ពង្រីកការអនុវត្តប្រព័ន្ធ FMIS លើមុខងារស្នូលទៅរដ្ឋបាលរាជធានី-ខេត្តទាំង ២៥, មន្ទីរជំនាញអាទិភាពនៅទូទាំងប្រទេស, អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនៅថ្នាក់កណ្តាល រួមទាំងថ្នាក់មូលដ្ឋានថ្មីៗបន្ថែមទៀត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល, ការពង្រីកការអនុវត្តមុខងាររៀបចំផែនការថវិកា និងមុខងារកិច្ចលទ្ធកម្ម ទៅគ្រប់ក្រសួង-ស្ថាប័ន និងអង្គភាពនៅថ្នាក់មូលដ្ឋាន, និងការគិតគូររៀបចំ និងអភិវឌ្ឍបន្ថែមមុខងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅក្នុងប្រព័ន្ធ FMIS, (៤) អនុវត្តផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារ តាមប្រព័ន្ធ FMIS ២០២០-២០២៥ ។
- **គណនេយ្យសាធារណៈកម្ពុជា ÷** រៀបចំ និងដាក់អនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់គណនេយ្យសាធារណៈកម្ពុជា ២០១៩ - ២០៣១, រៀបចំរបាយការណ៍តាមដានការអនុវត្តនៃការប្រកាសដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសាធារណៈកម្ពុជា និងរៀបចំស្តង់ដាគណនេយ្យសម្រាប់ការកត់ត្រា គណនីត្រូវទារ និងគណនីត្រូវសង ។
- **ពង្រឹកការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ÷** ក្រសួង-ស្ថាប័ន, មន្ទីររាជធានី-ខេត្ត និងរដ្ឋបាលថ្នាក់ក្រោមជាតិ នឹងត្រូវដាក់ឱ្យអនុវត្តជំហានទី១ ប្រព័ន្ធក្រៅបណ្តាញ (offline system) ឆ្នាំ២០២០ និងប្រព័ន្ធអនឡាញ (online system) ឆ្នាំ២០២៣ ។

### ផ្នែកទី៣ "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ"

៨០. នៅក្នុងផ្នែកផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ គឺផ្តោតលើគោលបំណងចំនួន ៥ រួមមាន ÷ (១) ពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី និងការត្រួតពិនិត្យថវិកា, (២) រៀបចំថវិកាឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងធ្វើសមាហរណកម្មថវិកា, (៣) រៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធបន្ទាត់គណនេយ្យភាព, (៤) ពង្រឹងការរៀបចំគោលនយោបាយ និងការធ្វើផែនការហិរញ្ញវត្ថុសាធារណៈ និង (៥) ពង្រឹងការអនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ ។

*ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ*




៨១. **ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ផ្តោតលើការអនុវត្តប្រព័ន្ធថវិកាកម្មវិធី** ក្នុងគោលដៅផ្លាស់ប្តូរការគ្រប់គ្រងពីការផ្តោតលើការរៀបចំថវិកា និងការរៀបចំរបាយការណ៍ដោយពិនិត្យតែលើអនុលោមភាព និងហិរញ្ញវត្ថុ ទៅជាការគ្រប់គ្រងដែលប្រើប្រាស់ថវិកាជាឧបករណ៍គោលនយោបាយ ដោយផ្សារភ្ជាប់ថវិកាទៅនឹងអាទិភាពគោលនយោបាយជាតិដែលផ្តោតសំខាន់លើការតាមដានវាយតម្លៃលើការសម្រេចបាននូវលទ្ធផល ឬសមិទ្ធកម្ម ។ ដើម្បីធានាបាននូវភាពជាម្ចាស់នៃកម្មវិធី ដោយផ្សារភ្ជាប់រវាងធនធានទៅនឹងការទទួលខុសត្រូវចំពោះការអនុវត្ត និងសមិទ្ធកម្ម, អង្គភាពថវិកាត្រូវបានបង្កើតឡើងក្នុងគោលដៅបង្កើនតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈការពង្រឹងការបែងចែកមុខងារ ភារកិច្ច និងការទទួលខុសត្រូវឱ្យកាន់តែច្បាស់លាស់នៅកម្រិតអនុវត្ត ។

*គោលបំណង ៣១÷ ពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី និងការត្រួតពិនិត្យថវិកា*

៨២. **កែលម្អការអនុវត្តថវិកាកម្មវិធី** ÷ ស្របតាមយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ អគ្គនាយកដ្ឋានថវិកា បានរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំស្តីការរៀបចំថវិកាសមិទ្ធកម្ម ។[27]

៨៣. **ពង្រីកថវិកាកម្មវិធីដល់ក្រសួង-ស្ថាប័ន និងដល់រដ្ឋបាលរាជធានី-ខេត្ត**÷ គ្រប់ក្រសួង-ស្ថាប័នបានចូលរួមអនុវត្តថវិកាកម្មវិធី ត្រឹមឆ្នាំ២០១៨ ។ អនុលោមតាមយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ត្រឹមឆ្នាំ២០១៩ រដ្ឋបាលខេត្តចំនួន១៨ បានអនុវត្តថវិកាកម្មវិធី ។ រដ្ឋបាលរាជធានី-ខេត្តទាំង ២៥ នឹងត្រូវអនុវត្តថវិកាកម្មវិធីត្រឹមឆ្នាំ២០២១ ។ រដ្ឋបាលរាជធានី-ខេត្ត ទាំង១៨ បានទទួលការបណ្តុះបណ្តាលអំពីនីតិវិធីនៃ

[27] *គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាសមិទ្ធកម្ម ត្រូវបានដាក់ឱ្យអនុវត្តតាមរយៈប្រកាសលេខ ២៨៧ សហវ.ប្រក ចុះថ្ងៃទី ១២ ខែមីនា ឆ្នាំ២០២០ ។*

ការអនុវត្តថវិកាកម្មវិធី ។ ទន្ទឹមនេះ អង្គភាពពាក់ព័ន្ធបានរៀបចំវគ្គបណ្តុះបណ្តាលជូនក្រសួង-ស្ថាប័នចំនួន ៨ និងរដ្ឋបាលរាជធានី-ខេត្ត ចំនួន ២៥ ពាក់ព័ន្ធនឹងការរៀបចំ និងការអនុវត្តថវិកាកម្មវិធី ។

*តារាងទី 3 ÷ ផែនការអនុវត្តថវិកាកម្មវិធីនៅរដ្ឋបាលរាជធានី-ខេត្ត*[28]

| ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|
| កំពង់ស្ពឺ | កំពង់ឆ្នាំង | កណ្តាល | កំពង់ចាម | រាជធានីភ្នំពេញ[29] |
| កែប | ពោធិ៍សាត់ | បាត់ដំបង | កំពង់ធំ | |
| កោះកុង | តាកែវ | បន្ទាយមានជ័យ | ព្រះវិហារ | |
| ប៉ៃលិន | កំពត | ស្វាយរៀង | ឧត្តរមានជ័យ | |
| ក្រចេះ | ព្រៃវែង | ត្បូងឃ្មុំ | សៀមរាប | |
| ស្ទឹងត្រែង | រតនគិរី | មណ្ឌលគិរី | ព្រះសីហនុ | |

### *គោលបំណង ៣២÷ រៀបចំថវិកាឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងធ្វើសមាហរណកម្មថវិកា*

៨៤. **រៀបចំផែនការយុទ្ធសាស្ត្រថវិកា ÷** ផែនការយុទ្ធសាស្ត្រថវិកា ត្រូវបានរៀបចំតាមគោលបំណងគោលនយោបាយ និងកម្មវិធី ដោយពន្យល់ខ្លឹមសារនៃគោលបំណង និងសនិទាន, ប្រភេទហិរញ្ញប្បទាន, សូចនាករសមិទ្ធកម្មគន្លឹះសម្រាប់តាមដានការអនុវត្ត និងត្រួតពិនិត្យលទ្ធផល, គោលដៅសមិទ្ធកម្ម, ក្របខណ្ឌពេលវេលា និងតម្រូវការថវិកា ។ ផែនការយុទ្ធសាស្ត្រថវិកា ត្រូវផ្អែកលើពិតានចំណាយ ដែលមាននៅក្នុងក្របខណ្ឌហិរញ្ញវត្ថុសាធារណៈ និងក្របខណ្ឌថវិការយៈពេលមធ្យម ។ ប៉ុន្តែគុណភាពនៃការរៀបចំ នៅមានកម្រិតនៅឡើយ ។

៨៥. **បញ្ចូលចំណូល-ចំណាយដែលនៅក្រៅបរិបទថវិកា ទៅក្នុងថវិកាប្រចាំឆ្នាំ និងថវិកាដៃគូអភិវឌ្ឍន៍ ÷** មាតិកាគណនីនៃប្លង់គណនេយ្យថវិកា (CoA) ថ្មី សម្រាប់គម្រោង/កម្មវិធីហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ត្រូវបានអនុវត្តនៅក្រសួងសុខាភិបាល ។ រីឯក្រសួង-ស្ថាប័នផ្សេងទៀត ត្រូវបាន និងកំពុងគិតគូរដាក់ឱ្យអនុវត្តជាបណ្តើរៗ ។

### *គោលបំណង ៣៣÷ រៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធបន្ទាត់គណនេយ្យភាព*

៨៦. **កំណត់ឱ្យបានច្បាស់នូវបន្ទាត់គណនេយ្យភាពក្នុងការរៀបចំកម្មវិធីវិនិយោគសាធារណៈ ដើម្បីធានាសង្គតិភាពក្នុងថវិកាប្រចាំឆ្នាំ ÷** ផ្អែកលើយុទ្ធសាស្ត្រស្តីពីការកែទម្រង់ការគ្រប់គ្រងវិនិយោគសាធារណៈ ២០១៩-២០២៥ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នឹងត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តក្នុងឆ្នាំ២០២០ នេះ សំដៅពង្រឹងប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងគណនេយ្យភាពចំពោះការគ្រប់គ្រងការវិនិយោគសាធារណៈ ។ សេចក្តីព្រាងអនុក្រឹត្យគោលស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈ មានគោលដៅកំណត់ (១) គោលការណ៍ និងលក្ខខណ្ឌតម្រូវ, (២) ដំណាក់កាលរួមនៃវដ្តគម្រោងវិនិយោគសាធារណៈ, (៣) តួនាទី និងភារកិច្ចរបស់ក្រសួង-ស្ថាប័ន, អង្គភាពសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ, (៤) ការផ្សារភ្ជាប់រវាងផែនការវិនិយោគជាមួយនឹងថវិកានីយកម្មការវិនិយោគសាធារណៈ, (៥) នីតិវិធីប្រតិបត្តិការនៃការរៀបចំ និងការគ្រប់គ្រង និង (៦) កាតព្វកិច្ចរបាយការណ៍ ។

### *គោលបំណង ៣៤÷ ពង្រឹងការរៀបចំគោលនយោបាយ និងការធ្វើផែនការហិរញ្ញវត្ថុសាធារណៈ*

---

[28] *ការអនុវត្តបច្ចុប្បន្ន រដ្ឋបាលរាជធានី-ខេត្ត ជាអង្គភាពថវិកា ។*

[29] *ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី បានឯកភាពលើសំណើរបស់អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយពន្យារពេលដាក់ឱ្យអនុវត្តថវិកាកម្មវិធីនៅរដ្ឋបាលរាជធានីភ្នំពេញ រហូតដល់ឆ្នាំ២០២១ ។*

៨៧. **ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច** ÷ កសហវ. បានរៀបចំក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២០ ។ ទន្ទឹមនេះ កសហវ. បានរៀបចំរបាយការណ៍ឱ្យនភាពពាក់កណ្តាល ឆ្នាំស្តីពីស្ថានភាពសេដ្ឋកិច្ច រយៈពេល ៩ ខែ(ឆ្នាំ២០១៧) និងរបាយការណ៍ Economic Surveillance ប្រចាំត្រីមាសទី២ ឆ្នាំ២០១៩ ។

៨៨. **ក្របខណ្ឌហិរញ្ញវត្ថុសាធារណៈ រយៈពេលមធ្យម (MTFF) និងក្របខណ្ឌថវិការយៈពេលមធ្យម (MTBF)** ÷ អគ្គនាយកដ្ឋានគោលនយោបាយ ទទួលបន្ទុករៀបចំក្របខណ្ឌហិរញ្ញវត្ថុសាធារណៈ រយៈពេលមធ្យម (MTFF)[30] រីឯអគ្គនាយកដ្ឋានថវិកាទទួលបន្ទុករៀបចំក្របខណ្ឌថវិការយៈពេលមធ្យម ។

៨៩. **MTFF ត្រូវបានរៀបចំឡើង**ដើម្បី (១) គាំទ្រការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ដោយផ្អែកលើការគិតគូរពិចារណាអំពីធនធានដែលមាន, លក្ខខណ្ឌម៉ាក្រូសេដ្ឋកិច្ច និងការដាក់កំហិតគោលដៅនៃយុទ្ធាហិរញ្ញវត្ថុសាធារណៈ (fiscal anchor), (២) ពង្រឹងប្រសិទ្ធភាពនៃការវិភាជថវិកា (Allocation effeciecy) និង (៣) ធានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងចីរភាពហិរញ្ញវត្ថុ (macroeconomic and fiscal sustainability)។ បច្ចុប្បន្ន កសហវ. បាននិងកំពុងរៀបចំក្របខណ្ឌ MTFF ២០២១ - ២០២៣[31] ជាឯកសារផ្លូវការសម្រាប់ប្រើប្រាស់ជាមូលដ្ឋានក្នុងការរៀបចំច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ។ MTFF ជាមូលដ្ឋានក្នុងការរៀបចំ MTBF ដែលនឹងរៀបរាប់កាន់តែលម្អិតនូវកម្រិតពិតានចំណាយរបស់ក្រសួង-ស្ថាប័ននីមួយៗ ព្រមទាំងដាក់បញ្ចូលនូវការវិភាគអំពីហានិភ័យហិរញ្ញវត្ថុសាធារណៈ (fiscal risks) សំខាន់ៗ ដែលអាចគំរាមកំហែងដល់ស្ថានភាពហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា ។

៩០. **ដើម្បីឱ្យការរៀបចំឯកសារ MTFF កាន់តែមានប្រសិទ្ធភាព** ជាពិសេសចំពោះទិដ្ឋភាពនៃការពង្រឹងការផ្សារភ្ជាប់រវាងថវិកា និងគោលនយោបាយ ក៏ដូចជាការវិភាគហានិភ័យហិរញ្ញវត្ថុកាន់តែស៊ីជម្រៅ សកម្មភាពសំខាន់ៗ ជាយុទ្ធសាស្ត្រ មានដូចជា÷

- បន្តពង្រឹងកិច្ចសហការក្នុងការរៀបចំទិន្នន័យ និងព័ត៌មានរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- បន្តកែតម្រូវកំហុសរបស់ម៉ូដែលព្យាករណ៍ក្របខណ្ឌចំណូល និងចំណាយដែលបណ្តាលមកពីការប្រែប្រួលនៃកត្តាខាងក្នុង និងកត្តាខាងក្រៅ ដើម្បីធានាភាពជឿទុកចិត្តនៃលទ្ធផលព្យាករណ៍ ដែលប្រើប្រាស់សម្រាប់រៀបចំ MTFF នៅឆ្នាំបន្ទាប់ និង
- បន្តពង្រឹងសមត្ថភាពក្រុមការងារបច្ចេកទេសក្នុងការរៀបចំឯកសារនេះ ដើម្បីឱ្យឆ្លើយតបទៅនឹងបរិបទជាក់ស្តែង និងអនាគត ។

៩១. **MTBF ត្រូវបានបង្កើតឡើង** ដើម្បីប៉ាន់ស្មាននូវធនធានដែលមាន សម្រាប់ជាមូលដ្ឋាននៃការវិភាជថវិកាទៅតាមវិស័យ និងក្រសួង-ស្ថាប័ននីមួយៗ ដោយពិចារណាអំពី ÷

---

[30] *ដោយស្ថានភាពសង្គម-សេដ្ឋកិច្ច មានការប្រែប្រួល MTFF ត្រូវបានពន្យារសម្រាប់ឆ្នាំបន្ទាប់ ។ ក្នុងន័យនេះ កសហវ. នឹងបន្តរៀបចំក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សាធារណៈ សម្រាប់ជាមូលដ្ឋានរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធី ។*

[31] *អគ្គនាយកដ្ឋានគោលនយោបាយ បានគូសបញ្ជាក់ថា ដោយសារការទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរពីការរីករាលដាល នៃជំងឺកូវីដ១៩, ថ្នាក់ដឹកនាំ កសហវ. សម្រេចព្យួរការអនុវត្ត MTFF ដើម្បីជាភាពបត់បែន និងឆ្លើយតបទាន់ពេលវេលា គឺក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ត្រូវបន្តដាក់ឱ្យប្រើប្រាស់ប្រចាំឆ្នាំ (ក្របខណ្ឌ ២០២១-២០២៣) (យោងតាមចំណារដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ០៩ ខែមីនា ឆ្នាំ២០២០) ។*

- ការព្យាករកត្តាជំរុញតម្រូវការ (Demand driver) នៃកម្មវិធី ដែលត្រូវប្រើប្រាស់ថវិកាដើម្បីផ្តល់សេវាដល់អ្នកទទួលផល និង
- ការវិភាជថវិកាពហុឆ្នាំ ដែលរាជរដ្ឋាភិបាលនឹងអាចវិភាជថវិកាបន្ថែមទៅតាមវិស័យអាទិភាព ស្របតាមគោលនយោបាយអាទិភាពរបស់ខ្លួន ។

៩២. **បញ្ហាប្រឈមនៃការរៀបចំ MTBF ÷** សម្រាប់ការអនុវត្តសាកល្បងក្នុងការគ្រោងថវិកាឆ្នាំ ២០២០, ការកំណត់ចំណាយពិតានគោលជូនក្រសួង-ស្ថាប័ន គឺគិតត្រឹមចំណាយចរន្ត ដោយឡែកសម្រាប់ចំណាយវិនិយោគត្រូវរង់ចាំអនុក្រឹតស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈ ។ ក្រសួង-ស្ថាប័ន នៅពុំទាន់គោរពបានការគ្រោងថវិកាតាមកម្រិតនៃចំណាយពិតានគោលរបស់ខ្លួននៅឡើយ ។ ការរៀបចំជាពហុឆ្នាំ ទាមទារមន្ត្រីមានសមត្ថភាពខ្ពស់ក្នុងការព្យាករគម្រោងថវិកាតាមឆ្នាំនីមួយៗ ។

៩៣. **ពង្រឹងសមត្ថភាពវិភាគ និងព្យាករណ៍ស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ÷** វគ្គបណ្តុះបណ្តាលស្តីពីសារៈសំខាន់ និងការប្រើប្រាស់ Online MEF Database សម្រាប់ការវិភាគសេដ្ឋកិច្ច និងផែនការថវិកាមូលដ្ឋានដល់មន្ត្រីស្ថិតិថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំ ។ ម៉ូដែលព្យាករម៉ាក្រូសេដ្ឋកិច្ចកម្ពុជា (Cambodia Macroeconomic Forecasting Model - CMFM) ត្រូវបានធ្វើបច្ចុប្បន្នកម្ម និងប្រើប្រាស់ (version ២.០) ដោយមានជារបាយការណ៍វាយតម្លៃលើម៉ូដែលព្យាករម៉ាក្រូសេដ្ឋកិច្ច និងរបាយការណ៍សិក្សាសមិទ្ធិលទ្ធភាព (Feasibility Study) ស្តីពីការអភិវឌ្ឍ Mobile MEF Database Application ពីប្រព័ន្ធ MEF Database ។

### *គោលបំណង ៣៥÷ ពង្រឹងការអនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ*

៩៤. **អនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ ÷** អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ បានរៀបចំអនុក្រឹត្យស្តីពីការដំឡើងប្រាក់ឧបត្ថមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងបាននិងកំពុងរៀបចំសេចក្តីព្រាងប្រកាសបង្កើតក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការ ប្រចាំ កសហវ, សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងជំនួយការរដ្ឋបាលឃុំ-សង្កាត់ និងសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃមូលនិធិឃុំ-សង្កាត់ ។

៩៥. **អនុវត្តសាកល្បង និងពង្រីកមូលនិធិវិនិយោគសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ (SNIF)[32] ÷** អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៣២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ ទន្ទឹមនឹងការដាក់ឱ្យអនុវត្ត និងផ្សព្វផ្សាយនូវគោលការណ៍ណែនាំស្តីពីការវាយតម្លៃសមិទ្ធកម្មរដ្ឋបាលក្រុង-ខណ្ឌ ។ ជាមួយគ្នានេះ អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏បានរៀបចំសេចក្តីណែនាំបន្ថែមស្តីពីសំណើគម្រោងវិនិយោគរដ្ឋបាលក្រុង ប៉ុន្តែពុំទាន់សម្រេចពេញលេញនៅឡើយ ។

---

32 *យន្តការអនុវត្តមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ (SNIF) ត្រូវបានដាក់ឲ្យអនុវត្តចាប់ពីឆ្នាំ២០១៧ ។ SNIF ជាយន្តការសម្រាប់ផ្តល់ហិរញ្ញប្បទានរបស់រាជរដ្ឋាភិបាល មានភ្ជាប់លក្ខខណ្ឌ និងមានលក្ខណៈជាការប្រកួតប្រជែង សម្រាប់គម្រោងវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ និងសម្រាប់វិស័យណាមួយដែលមានអាទិភាពដែលស្នើឡើងដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ។*

៩៦. **ពិនិត្យមើលឡើងវិញ និងដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីផែនការយុទ្ធសាស្ត្រថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ÷** អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិបានធ្វើការកែលម្អគោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសការផ្សារភ្ជាប់គោលនយោបាយទៅនឹងកម្មវិធី ។

៩៧. **អនុវត្តឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា ÷** យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១៩-២០២៥ ត្រូវបានរៀបចំឡើងដោយមានសង្គតិភាពជាមួយយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ ។ យុទ្ធសាស្ត្រសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ មានទិសដៅពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធីជាបណ្តើរៗ ដើម្បីឈានដល់ការអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកា ដោយធានាឱ្យបាននូវការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ជាពិសេស គោលបំណងគោលនយោបាយរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវតម្រឹមជាមួយនឹងគោលនយោបាយជាតិ និងស្របតាមរចនាសម្ព័ន្ធគ្រប់គ្រងនៃរដ្ឋបាលដែលកំណត់តួនាទី សិទ្ធិអំណាច និងការទទួលខុសត្រូវនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ។ ដើម្បីជំរុញការអនុវត្តប្រកបដោយប្រសិទ្ធភាព, ផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១៩-២០២៥ ត្រូវបានរៀបចំឡើងដោយមានផែនការសកម្មភាពរួម ព្រមទាំងយន្តការសម្របសម្រួល និងតាមដាន និងវាយតម្លៃច្បាស់លាស់ ។




៩៨. **កែសម្រួលគោលការណ៍ណែនាំស្តីពីការរៀបចំ និងនីតិវិធីអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ÷** អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ បានធ្វើការកែលម្អ និងដាក់ឱ្យអនុវត្តនូវគោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធីសម្រាប់រដ្ឋបាលរាជធានី-ខេត្ត ។

៩៩. **បញ្ហាប្រឈមសម្រាប់វិមជ្ឈការហិរញ្ញវត្ថុ និងការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិ ÷** ការធ្វើវិមជ្ឈការហិរញ្ញវត្ថុ និងការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិ ជួបប្រទះនឹងបញ្ហាប្រឈមមួយចំនួន រួមមាន÷ (១) ការបញ្ឈប់ការផ្ទេរធនធានថវិការដ្ឋជូនរដ្ឋបាលរាជធានី ខេត្តចាប់ពីឆ្នាំ២០២១, (២) កំណើនបៀវត្សរបស់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលក្រុង ស្រុក ស្រូបយកចំណាយអភិវឌ្ឍន៍មូលដ្ឋាន, (៣) សមត្ថភាពមន្ត្រីរបស់

រដ្ឋបាលថ្នាក់ក្រោមជាតិ នៅមានកម្រិត, (៤) កង្វះធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ, (៥) មុខងារដែលប្រគល់ឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ មិនអាចអនុវត្តមុខងារនោះបានពេញលេញ, (៦) លក្ខខណ្ឌបច្ចេកទេសក្នុងការផ្ទេរធនធានហិរញ្ញវត្ថុពីក្រសួង-ស្ថាប័នសាមីទៅថ្នាក់ក្រោមជាតិ មិនទាន់ស្របទៅតាមទម្រង់នៃការផ្ទេរមុខងារ, (៧) ពុំទាន់បានរៀបចំការផ្ទេរធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ, (៨) មានភាពយឺតយ៉ាវក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងស្តង់ដា, និង (៩) ពុំទាន់បានរៀបចំផែនការសកម្មភាពច្បាស់លាស់ សម្រាប់គាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីគ្រប់គ្រង និងអនុវត្តមុខងារដែលបានផ្ទេរ ។

**ការងារធ្វើបន្ត**

- រៀបចំ MTFF និងភាពប្រទាក់ក្រឡារវាង MTFF និង MTBF
- រៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈ
- ពង្រឹងការរៀបចំរបាយការណ៍សមិទ្ធកម្ម និងរបាយការណ៍ហិរញ្ញវត្ថុតាមក្រសួង-ស្ថាប័ន
- ពង្រឹងគុណភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធី ដោយកែលម្អគោលបំណងគោលនយោបាយ កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព
- ធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (១) បច្ចុប្បន្នការកត់ត្រាច្បាប់ថវិកា, ការផ្ទេរឧបត្ថម្ភពីថ្នាក់ជាតិ, និងការបង្វែរឥណទាន របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានធ្វើឡើងតាមប្រព័ន្ធ FMIS, (២) ចូលរួមរៀបចំប្រព័ន្ធកត់ត្រាចំណូលមិនមែនសារពើពន្ធតាមប្រព័ន្ធព័ត៌មានវិទ្យា ដែលគ្រោងនឹងដាក់ឱ្យអនុវត្តជាជំហានៗ ចាប់ពីឆ្នាំ២០២១, និង (៣) ចាប់ពីឆ្នាំ២០២២ ដាក់ឱ្យអនុវត្តប្រព័ន្ធ FMIS ជាជំហានៗ នៅរដ្ឋបាលរាជធានី-ខេត្ត ។

### ផ្នែកទី៤ "ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់"

១០០. ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់ផ្តោតលើគោលបំណងចំនួន ៤ រួមមាន (១) បង្កើតក្របខណ្ឌថវិកាផ្អែកលើព័ត៌មានសមិទ្ធកម្ម, (២)រៀបចំ និងដាក់ឱ្យអនុវត្តក្របខណ្ឌគណនេយ្យភាពសមិទ្ធកម្ម, (៣)ពង្រឹងប្រសិទ្ធភាពប្រព័ន្ធត្រួតពិនិត្យ, និង (៤) រៀបចំ និងអនុវត្តផែនការកសាងសមត្ថភាព (ដោយរួមបញ្ចូលទាំងស្ថាប័ននីតិប្បញ្ញត្តិ និងអាជ្ញាធរសវនកម្មជាតិ) ។

#### *គោលបំណង ៤១÷ បង្កើតក្របខណ្ឌថវិកាព័ត៌មានសមិទ្ធកម្ម*

១០១. **ដំណើការនៃការចរចាថវិកាផ្អែកលើធាតុចូល នឹងត្រូវផ្លាស់ប្តូរជាបណ្តើរៗ ឆ្ពោះទៅរកការចរចាថវិកាផ្អែកជាសំខាន់លើលទ្ធផលក្នុងឆ្នាំ និងលទ្ធផលចុងក្រោយនៃកម្មវិធី** ។[33] តាមការចង្អុលបង្ហាញនៅក្នុងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥, ចាប់ពីឆ្នាំ២០១៩ តទៅនឹងត្រូវរៀបចំឱ្យមានកិច្ចព្រមព្រៀងលើលទ្ធផលក្នុងឆ្នាំ ។ រីឯ កិច្ចព្រមព្រៀងរួមបញ្ចូលទាំងលទ្ធផលចុងក្រោយ គឺនឹងត្រូវរៀបចំចាប់ពីឆ្នាំ២០២៣ តទៅ ។ ជាវឌ្ឍនភាព

[33] *យោងតាមយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥*

សម្រាប់ឆ្នាំ២០១៩ ទម្រង់កិច្ចព្រមព្រៀងលើលទ្ធផលក្នុងឆ្នាំត្រូវបានរៀបចំបឋមនៅឡើយ ដែលត្រូវឆ្លងកាត់កិច្ចពិភាក្សាកម្រិតនាយកដ្ឋានជាមុន ។

១០២. **រៀបចំបទដ្ឋានគតិយុត្តសម្រាប់អនុវត្តថវិកាសមិទ្ធកម្ម** ÷ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៨ បានបើកច្រកឱ្យរាជរដ្ឋាភិបាលអាចអនុវត្តសាកល្បងនូវថវិកាកម្មវិធី ដែលជាជំហានមួយនៅលើទិសដៅឆ្ពោះទៅរកប្រព័ន្ធថវិកាសមិទ្ធកម្ម និងវិមជ្ឈការ ។ ក្នុងន័យនេះ ដើម្បីឱ្យប្រព័ន្ធថវិកាសមិទ្ធកម្មអាចអនុវត្តដោយផ្អែកលើបទដ្ឋានគតិយុត្តច្បាស់លាស់ ពេញលេញ និងគ្រប់ជ្រុងជ្រោយ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ចាំបាច់




ត្រូវរៀបចំថ្មី ឬធ្វើវិសោធនកម្ម[34] ។ ជាវឌ្ឍនភាព ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៨ ត្រូវបាន និងកំពុងត្រួតពិនិត្យ និងសិក្សា ពោលគឺកាលពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ បានរៀបចំកិច្ចប្រជុំបូកសរុបពិនិត្យលើ ១៤ ចំណុចពាក់ព័ន្ធនឹងការរៀបចំថវិកា, ការអនុវត្តថវិកា, ការកែទម្រង់គណនេយ្យ, លិខិតបទដ្ឋានគតិយុត្ត និងការប្រើប្រាស់ប្រព័ន្ធ FMIS[35] ។

១០៣. **រៀបចំយន្តការ និងឧបករណ៍សាកល្បងសម្រាប់ត្រួតពិនិត្យសមិទ្ធកម្មសម្រាប់ក្រសួង-ស្ថាប័ន** ÷ ក្របខណ្ឌតាមដាន និងវាយតម្លៃមួយនឹងត្រូវរៀបចំចាប់ពីឆ្នាំ២០១៩ និងដាក់ឱ្យអនុវត្តសាកល្បងនៅឆ្នាំ២០២៣[36]។ ក្របខណ្ឌជាសារវ័ន្តនេះ នឹងវិវឌ្ឍបន្តិចម្តងៗ ទៅជាប្រព័ន្ធតាមដាន និងវាយតម្លៃពេញលេញនៅឆ្នាំ២០២៥ ។ សម្រាប់សូចនាករឆ្នាំ២០១៩ ក្របខណ្ឌទស្សនាទាននៃការតាមដាន និងត្រួតពិនិត្យព័ត៌មានសមិទ្ធកម្ម នឹងត្រូវបានរៀបចំ ប៉ុន្តែពុំទាន់មានវឌ្ឍនភាពនៅឡើយ ។

១០៤. **ត្រួតពិនិត្យអនុក្រឹត្យលេខ ៨១ និង អនុក្រឹត្យលេខ ៨២** ÷ គសហវ. បានបង្កើតក្រុមការងាររៀបចំកែសម្រួលអនុក្រឹតលេខ ៨១ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង

---

*[34] ក្របខណ្ឌពេលវេលាដែលចែងក្នុងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ សម្រាប់ការធ្វើវិសោធនកម្ម គឺចាប់ពីឆ្នាំ២០១៨ - ២០២០*

*[35] ផ្អែកតាមរបាយការណ៍ត្រួតពិនិត្យលើការអនុវត្តផែនការសកម្មភាពរួមដំណាក់កាលទី ៣ របស់ជំនាញការ, ការសម្រេចដោយថ្នាក់ដឹកនាំ គសហវ. គឺត្រូវរៀបចំសេចក្តីព្រាងច្បាប់ថ្មីជាជាងការធ្វើវិសោធនកម្ម ច្បាប់ចាស់តាមមូលដ្ឋានមាត្រានីមួយៗ*

*[36] យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥*

ក្រុងស្វាយរៀង រាជធានីភ្នំពេញ និងអង្គការសាធារណៈ និងអនុក្រឹត្យលេខ៨២ ស្តីពីបទបញ្ញត្តិទូទៅ នៃគណនេយ្យសាធារណៈ ព្រមទាំងបានរៀបចំកិច្ចប្រជុំត្រួតពិនិត្យជាបន្តបន្ទាប់ជាមួយជំនាញការបារាំង ។

*គោលបំណង ៤២÷ រៀបចំ និងដាក់ឱ្យអនុវត្តក្របខណ្ឌគណនេយ្យភាពសមិទ្ធកម្ម*

១០៥. **រៀបចំគោលការណ៍ណែនាំស្តីពីការធ្វើសវនកម្មសមិទ្ធកម្មសម្រាប់សវនកម្មផ្ទៃក្រៅ** ។ អាជ្ញាធរសវនកម្មជាតិ បានរៀបចំគោលការណ៍ណែនាំស្តីពីការធ្វើសវនកម្មប្រតិបត្តិការ[37] និងបានទទួលការអនុម័តកាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩ ។ គោលបំណងចម្បងនៃការធ្វើសវនកម្មប្រតិបត្តិការ គឺដើម្បីលើកកម្ពស់អភិបាលកិច្ចប្រកបដោយភាពសន្សំសំចៃ ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ។ បន្ថែមពីនេះ សវនកម្មលើកិច្ចប្រតិបត្តិការ បង្កើនតម្លាភាពជួយដល់រដ្ឋសភា អ្នកជាប់ពន្ធ និងប្រភពហិរញ្ញប្បទានដទៃទៀត ដែលជាគោលដៅនៃគោលនយោបាយរបស់រដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយឱ្យយល់ដឹងស៊ីជម្រៅអំពីការគ្រប់គ្រង និងសមិទ្ធផលកើតចេញពីសកម្មភាពនានារបស់រដ្ឋាភិបាល ។

១០៦. **រៀបចំរបាយការណ៍សវនកម្មសមិទ្ធកម្ម ដាក់ជូនស្ថាប័ននីតិប្បញ្ញត្តិ** ÷ អាជ្ញាធរសវនកម្មជាតិ បានរៀបចំរបាយការណ៍ចំនួន ៤ រួមមាន (១) របាយការណ៍សវនកម្មលើកិច្ចប្រតិបត្តិការនៃការគ្រប់គ្រងផ្លូវលំជនបទ របស់ក្រសួងអភិវឌ្ឍន៍ជនបទ សម្រាប់ការិយបរិច្ឆេទ ២០១៨, (២) របាយការណ៍សវនកម្មលើកិច្ចប្រតិបត្តិការនៅមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា សម្រាប់ការិយបរិច្ឆេទ ២០១៨, (៣) របាយការណ៍សវនកម្មលើកិច្ចប្រតិបត្តិការស្តីពីយន្តការនៃច្រកចេញចូលតែមួយ សម្រាប់ផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលខេត្តព្រះសីហនុ រដ្ឋបាលក្រុងព្រះសីហនុ និងរដ្ឋបាលស្រុកព្រៃនប់ សម្រាប់ការិយបរិច្ឆេទ ២០១៨ និង (៤) របាយការណ៍សវនកម្មលើកិច្ចប្រតិបត្តិការនៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ នៅរដ្ឋបាលខេត្តឧត្តរមានជ័យ សម្រាប់ការិយបរិច្ឆេទ ២០១៨ ។

*គោលបំណង ៤៣÷ ពង្រឹងប្រសិទ្ធភាពប្រព័ន្ធត្រួតពិនិត្យ*

១០៧. **ត្រួតពិនិត្យមើលមុខងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច នៅក្រសួង-ស្ថាប័ន**[38] ÷ អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃ កសហវ. បានធ្វើការត្រួតពិនិត្យប្រសិទ្ធភាពនៃមុខងារសវនកម្មផ្ទៃក្នុង និងចេញរបាយការណ៍ស្តីពីការចុះត្រួតពិនិត្យជូនក្រសួង-ស្ថាប័នចំនួន ៨ រួមមាន (១) ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, (២) ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, (៣) ក្រសួងទេសចរណ៍, (៤) ក្រសួងកិច្ចការនារី, (៥) ក្រសួងឧស្សាហកម្ម និងសិប្បកម្ម, (៦) ក្រសួងផែនការ, (៧) ក្រសួងយុត្តិធម៌ និង (៨) ក្រសួងបរិស្ថាន ។ ទន្ទឹមនេះ អគាធិការដ្ឋាន បានធ្វើការវិភាគមុខងារអធិការកិច្ចនៅក្រសួង- ស្ថាប័នចំនួន ៥ ។

១០៨. **ពង្រីកបន្ថែមមុខងារនៃការត្រួតពិនិត្យតាមព័ត៌មានវិទ្យា និងសមិទ្ធកម្ម ដើម្បីឱ្យស្របនឹងមុខងារប្រព័ន្ធថវិកាថ្មី** ÷ អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង បានរៀបចំគោលការណ៍ណែនាំស្តីពីសវនកម្មបច្ចេកវិទ្យាព័ត៌មាន (IT Audit) និងបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយកាលពីត្រីមាសទី៤ ឆ្នាំ២០១៩ ។ រីឯការរៀបចំគោលការណ៍ណែនាំស្តីពីសវនកម្មសមិទ្ធកម្មមានភាពយឺតយ៉ាវ[39] ហើយគ្រោងនឹងបញ្ចប់ការរៀបចំនៅត្រីមាសទី ២ ឆ្នាំ២០២០ ។

១០៩. **រៀបចំក្របខណ្ឌអធិការកិច្ចហិរញ្ញវត្ថុ** ÷ អគាធិការដ្ឋានបានរៀបចំសេចក្តីព្រាងស្តង់ដាអធិការកិច្ចហិរញ្ញវត្ថុ និងសេចក្តីព្រាងបឋមផែនការយុទ្ធសាស្ត្រអធិការកិច្ចហិរញ្ញវត្ថុ២០២១-២០២៥ ទន្ទឹមនឹងការប្រកាសដាក់ឱ្យប្រើ-

*[37] អាជ្ញាធរសវនកម្មជាតិប្រើពាក្យប្រតិបត្តិការ ខណៈក្របខណ្ឌផែនការសកម្មភាពរួមដំណាក់កាលទី៣ ប្រើប្រាស់ពាក្យសមិទ្ធកម្ម*

*[38] ក្រសួង-ស្ថាប័នបានបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង ចំនួន ៤៣ (ក្រសួង ចំនួន ២៨ សហគ្រាស ១២ និងស្ថាប័ន ផ្សេងៗ ចំនួន ៣)*

*[39] ដោយសារជំនាញការទទួលបន្ទុករៀបចំមានបញ្ហាផ្ទែកសុខភាព*

ប្រាស់នូវក្រមសីលធម៌វិជ្ជាជីវៈអធិការកិច្ចហិរញ្ញវត្ថុ ។ ដោយឡែក សម្រាប់អនុក្រឹត្យស្តីពីវិធាន និងនីតិវិធីអធិការកិច្ចហិរញ្ញវត្ថុ ត្រូវបានព្យួរទុកតាមការសម្រេចរបស់ថ្នាក់ដឹកនាំ គសហវ. ។

*គោលបំណង ៤៤÷ រៀបចំ និងអនុវត្តផែនការកសាងសមត្ថភាព*

១១០. **ត្រួតពិនិត្យផែនការយុទ្ធសាស្ត្រកសាងសមត្ថភាពដំណាក់កាលទី ៣ និងរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ដំណាក់-កាលទី ៤** ÷ វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានធ្វើការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការកសាងសមត្ថភាពក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ និងបានរៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រស្តីពីការកសាង និងអភិវឌ្ឍន៍សមត្ថភាព សម្រាប់ដំណាក់កាលទី៤ ដោយបានពិគ្រោះយោបល់ជាមួយគ្រប់អង្គភាពក្រោមឱវាទ គសហវ, ក្រសួង-ស្ថាប័ន,មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត និងរតនាគាររាជធានី-ខេត្ត ។ ទន្ទឹមនេះ វិទ្យាស្ថានជួបប្រទះនឹងបញ្ហាប្រឈមពាក់ព័ន្ធគ្រូបង្គោល គ្រូឧទ្ទេស និងសាស្ត្រាចារ្យរបស់វិទ្យាស្ថាន, ការធ្វើទំនើបកម្មលើកម្មវិធីបណ្តុះបណ្តាល និងការទទួលការបំប៉នសមត្ថភាពបន្ថែម រួមទាំងជំនួយបច្ចេកទេស និងថវិកាដើម្បីពង្រឹងសមត្ថភាព នៅក្នុងស្ថាប័ន ។

**ការងារធ្វើបន្ត**

- រៀបចំសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី)
- កែសម្រួលអនុក្រឹត្យលេខ ៨១ និង៨២
- រៀបចំគោលការណ៍ណែនាំស្តីពីការអនុវត្តថវិកាសមិទ្ធកម្ម
- រៀបចំកិច្ចព្រមព្រៀងសមិទ្ធកម្ម
- រៀបចំក្របខណ្ឌត្រួតពិនិត្យនិងវាយតម្លៃ
- **ប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ច**÷ (១) រៀបចំក្របខណ្ឌ និងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ចមួយច្បាស់លាស់ ដើម្បីដោះស្រាយបញ្ហាប្រឈមដែលកំពុងកើតមានឡើង ព្រមទាំងបែងចែកភារកិច្ចគ្នាឱ្យបានជ្រះស្រឡះ នៃអង្គភាពត្រួតពិនិត្យ ស្របតាមការសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៧៧២ សជណ.ហគ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩ និង (២) បញ្ចប់ការរៀបចំគោលការណ៍ណែនាំស្តីពីសមិទ្ធកម្ម សម្រាប់សវនកម្មផ្ទៃក្នុង ។

**ផ្នែកទី៥ "ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព"**

១១១. ផ្នែកគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ ប្រកបដោយជោគជ័យ និងចីរភាព ផ្តោតលើគោលបំណងចំនួន ៣ រួមមាន (១) បង្កើនភាពជាអ្នកដឹកនាំ, សមត្ថភាពគ្រប់គ្រង, និងបណ្តុះឆន្ទៈកំណែទម្រង់ ព្រមទាំងបង្កើនភាពជាម្ចាស់ និងការទទួលខុសត្រូវ, (២) បង្កើនប្រសិទ្ធភាពនៃការកសាងសមត្ថភាព និងវិធានការលើកទឹកចិត្ត, និង (៣) ពង្រឹងការកសាងសមត្ថភាពសម្រាប់អនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ ។

*គោលបំណង ៥១÷ បង្កើនភាពជាអ្នកដឹកនាំ, សមត្ថភាពគ្រប់គ្រង, និងបណ្តុះឆន្ទៈកំណែទម្រង់ ព្រមទាំង បង្កើនភាពជាម្ចាស់ និងការទទួលខុសត្រូវ*

១១២. **ការរៀបចំផែនការសកម្មភាព (GDAP3/MAP3) និងការរាយការណ៍អំពីវឌ្ឍនភាពជាប្រចាំ បង្ហាញអំពីការចូលរួមឆន្ទៈ និងការទទួលខុសត្រូវក្នុងការងារកែទម្រង់** ÷ អង្គភាពក្រោមឱវាទ កសហវ. ទាំង ១៨ និងក្រសួង-ស្ថាប័នទាំង៤១ បានរៀបចំផែនការសកម្មភាព (GDAP3/MAP3) និងពិភាក្សាកម្រិតជំនាញជាមួយ អ.គ.ហ. ដើម្បីកំណត់សកម្មភាពកែទម្រង់ ។ គ្រប់អង្គភាពក្រោមឱវាទ កសហវ. និងគ្រប់ក្រសួង-ស្ថាប័នមានការរាយការណ៍ជាប្រចាំត្រីមាស និងប្រចាំឆ្នាំអំពីវឌ្ឍនភាព និងផ្ញើជូន អ.គ.ហ. ដើម្បីបូកសរុប និងដាក់របាយការណ៍ជូនកិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងដៃគូអភិវឌ្ឍន៍ជាប្រចាំត្រីមាស និងប្រចាំឆ្នាំ ។

***គោលបំណង ៥២÷ បង្កើនប្រសិទ្ធភាពនៃការកសាងសមត្ថភាព និងវិធានការលើកទឹកចិត្ត***

១១៣. **វគ្គបណ្តុះបណ្តាល និងសិក្ខាសាលាពាក់ព័ន្ធ ត្រូវបានរៀបចំឡើងដោយអង្គភាពកសហវ និងក្រសួង-ស្ថាប័ន** ÷ ដើម្បីពង្រឹងសមត្ថភាពមន្ត្រី, អង្គភាពក្រោមឱវាទ កសហវ. បានរៀបចំវគ្គបណ្តុះពាក់ព័ន្ធដូចជា ការរៀបចំ និងការអនុវត្តថវិការដ្ឋបាលក្រុង-ស្រុក, ការប្រើប្រាស់កម្មវិធីព័ត៌មានវិទ្យា, កិច្ចលទ្ធកម្មសាធារណៈ; ការប្រើប្រាស់ប្រព័ន្ធ FMIS, វិធីសាស្ត្របង្រៀន, ច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ, ភាពជាដៃគូរវាងរដ្ឋ និងឯកជន, ភាពជាអ្នកដឹកនាំ, នីតិវិធីក្នុងការរៀបចំសន្និធិផ្ទៃក្នុង, និងថវិកាព័ត៌មានសមិទ្ធកម្ម ។ ទន្ទឹមនេះ ក្រសួង-ស្ថាប័ន បានរៀបចំសិក្ខាសាលាបញ្ជ្រាបការយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិ ការអនុវត្តថវិកាកម្មវិធី និងការអនុវត្តប្រព័ន្ធ FMIS ជាដើម ។

១១៤. **ការវិភាគថវិកា ជាជំនាញសំខាន់មួយដែលបានរំលេចនៅក្នុងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥** ÷ វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីការវិភាគថវិកា ជូនមន្ត្រីវិភាគថវិកាគ្រូបង្គោល និងមន្ត្រីពាក់ព័ន្ធនៃ កសហវ. ចំនួន ៣០ រូប ។

១១៥. **អនុវត្តបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការលើកទឹកចិត្តក្រុមការងារកែទម្រង់** ÷ គ.ហ.ស. បានលើកទឹកចិត្តក្រុមការងារកែទម្រង់ការគ្រប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃអង្គភាព កសហវ. និងក្រសួង-ស្ថាប័ន ដោយអនុវត្តនូវលិខិតបទដ្ឋានគតិយុត្តចំនួន ៥ រួមមាន (១) ប្រកាសលេខ ៦១៦ សហវ.ប្រក ស្តីពីការកំណត់គោលការណ៍យន្តការ នីតិវិធី និងការត្រួតពិនិត្យសម្រាប់ការផ្តល់ការលើកទឹកចិត្តដោយប្រើប្រាស់ប្រាក់រង្វាន់របស់អង្គភាពក្រោមឱវាទ កសហវ. (២) ប្រកាសលេខ ៣៥១ សហវ.ប្រក ស្តីពីវិធាន និងនីតិវិធីនៃការផ្តល់ការលើកទឹកចិត្តជូនក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅតាមក្រសួង-ស្ថាប័ន, (៣) សារាចរលេខ ០០៤ សហវ ស្តីពីការអនុវត្តប្រកាសលេខ ៦១៦ សហវ.ប្រក, (៤) សារាចរលេខ ០០៤ សហវ ស្តីពីការបង់ថវិកាចំណូលមិនមែនសារពើពន្ធចូលក្នុងមូលនិធិនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង (៥) សេចក្តីសម្រេចលេខ ១១៩ សសរ ស្តីពីការប្រើប្រាស់ចំណូលមិនមែនសារពើពន្ធរបស់ក្រសួង-ស្ថាប័នប្រមូលចំណូលសម្រាប់ផ្តល់ការលើកទឹកចិត្តលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ក្នុងន័យនេះ ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃអង្គភាព កសហវ. និងក្រសួង-ស្ថាប័ន បានទទួលប្រាក់ឧបត្ថម្ភក្នុងការងារកែទម្រង់ពេញមួយឆ្នាំ ។ ទោះជាយ៉ាងនេះក្តី ការពង្រឹងគុណភាពនៃការរៀបចំផែនការសកម្មភាពតាំងពីដើមទី គឺជាការសំខាន់ ដើម្បីធានាប្រសិទ្ធភាពនៃការផ្តល់ប្រាក់ឧបត្ថម្ភ ។

***គោលបំណង ៥៣÷ ពង្រឹងការកសាងសមត្ថភាពសម្រាប់អនុវត្តកម្មវិធីកែទម្រង់***

១១៦. **ពង្រឹងសមត្ថភាពពាក់ព័ន្ធការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ÷** វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសចំនួន ៣ វគ្គដែលរួមមានមុខវិជ្ជា ដូចជា(១) គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងសេដ្ឋកិច្ច, (២) ថវិកា, (៣) គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ, (៤) គណនេយ្យសាធារណៈ, និង (៥) សិល្បៈប្រាស្រ័យទាក់ទង ។ សរុបសិក្ខាកាមទាំង ៣ វគ្គនេះ មានចំនួន ១០៥៩ រូប[40] ។ ការបណ្តុះបណ្តាលបានជួបប្រទះនឹងបញ្ហាប្រឈមមួយចំនួន ជាអាទិ៍ (១) អត្រានៃការបោះបង់ការសិក្សារបស់សិក្ខាកាមនៅតែបន្តកើតមាន, (២) សិក្ខាកាមដែលត្រូវបានចាត់បញ្ជូនឱ្យចូលរួមវគ្គបណ្តុះបណ្តាល ទទួលបានការប្រគល់ភារកិច្ចបន្ថែម ក្នុងកំឡុងពេលសិក្សា ដែលជាហេតុធ្វើឱ្យសិក្ខាកាមអវត្តមានច្រើន និងឈានទៅការបោះបង់ការសិក្សា ។

**ការងារធ្វើបន្ត**

- រៀបចំផែនការយុទ្ធសាស្ត្រស្តីពីការកសាង និងអភិវឌ្ឍសមត្ថភាព (ក្របខណ្ឌ PFMRP) ដំណាក់កាលទី៤
- រៀបចំមូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គ្រប់ជ្រុងជ្រោយ ។

## ២.២. ការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី៣ របស់ក្រសួង-ស្ថាប័ន

១១៧. **របាយការណ៍វឌ្ឍនភាពនៃផែនការសកម្មភាព (MAP) របស់ក្រសួង-ស្ថាប័ន** ទាំង៤០ ត្រូវបែងចែកជា ៥ ស្ថាប័ន រួមមាន ÷(១) ស្ថាប័នសេវាសេដ្ឋកិច្ចមានចំនួន ១១ ក្រសួង-ស្ថាប័ន, (២) ស្ថាប័នសេវាហិរញ្ញវត្ថុ ការបរទេស និងសេវាសាធារណៈទូទៅ មានចំនួន ៨ ក្រសួង-ស្ថាប័ន, (៣) ស្ថាប័នសេវាការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ មានចំនួន ៥ ក្រសួង-ស្ថាប័ន, (៤) ស្ថាប័នសេវាសង្គមកិច្ច មានចំនួន ៦ ក្រសួង-ស្ថាប័ន និង (៥) ស្ថាប័នកំពូល និងឯករាជ្យ មានចំនួន ១១ ក្រសួង-ស្ថាប័ន ។

១១៨. **ផ្អែកតាមការវាយតម្លៃវឌ្ឍនភាព, ការរៀបចំផែនការសកម្មភាព (MAP3) មានភាពច្បាស់លាស់ជាងមុន** តែនៅតែមានសកម្មភាពប្រចាំថ្ងៃ ។ ការរៀបចំផែនការសកម្មភាព MAP3 គួរផ្តោតតែលើការងារអាទិភាព និងចូលរួមពង្រឹងប្រសិទ្ធភាពប្រព័ន្ធហិរញ្ញវត្ថុ ដែលក្រសួង-ស្ថាប័ន បាននិងកំពុងបំពេញមុខងារ ។

១១៩. **ខណៈតួនាទីរបស់ក្រសួង-ស្ថាប័ន កាន់តែធំឡើងៗ ក្នុង PFMRP** ការពង្រឹងសមត្ថភាពអង្គភាពនៃក្រសួង-ស្ថាប័ន ជាកិច្ចការមួយដែលត្រូវយកចិត្តទុកដាក់ និងជំរុញបន្ថែម ក្រោមការគាំទ្ររបស់អង្គភាពហិរញ្ញវត្ថុ ប្រកបដោយសកម្ម, បុរេសកម្ម និងអន្តរសកម្មភាព ។ ក្រសួង-ស្ថាប័នស្ថិតក្នុងវិស័យតែមួយ គួររៀបចំគោលនយោបាយឱ្យមានភាពប្រទាក់ក្រឡាគ្នា ដើម្បីសម្រេចឱ្យបានលទ្ធផលចុងក្រោយ សំដៅធានាការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ។ ការកំណត់សកម្មភាពអាទិភាពសម្រាប់ការរៀបចំ និងអនុវត្តសម្រាប់ក្រសួង-ស្ថាប័ន នៅក្នុងឆ្នាំ២០២០ ជាពិសេសបន្តលើកកម្ពស់ និងពង្រឹងការរៀបចំ និងការអនុវត្ត “ការពង្រឹងការគ្រប់គ្រងការប្រមូលចំណូល និងចំណាយ”, “ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ” និង “ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ” ។

១២០. **វឌ្ឍនភាពជារួម ស្ទើរតែគ្រប់ក្រសួង-ស្ថាប័នអនុវត្តផែនការសកម្មភាពទទួលបានលទ្ធផលលើសពី ៨៥%** លើកលែងតែអគ្គលេខាធិការដ្ឋានរដ្ឋសភាសម្រេចបានត្រឹមតែ ១០% (១/១០) ប៉ុណ្ណោះ ។ ទោះបីជាយ៉ាងនេះក្តី

[40] គោលដៅសូចនាករនៃក្របខណ្ឌលទ្ធផលសហភាពអឺរ៉ុប មានចំនួន ១ ០៤៥ រូប

សកម្មភាពមួយចំនួនរបស់ក្រសួង-ស្ថាប័ន ទាមទារឱ្យមានការកែលម្អបន្ថែមទៀត ដើម្បីឱ្យស្របតាមផែនការសកម្មភាពរួម (CAP) ។

១២១. **វឌ្ឍនភាពគន្លឹះៗ របស់ក្រសួង-ស្ថាប័នចូលរួមការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៩** នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ រួមមានដូចខាងក្រោម ÷

- ក្រសួង-ស្ថាប័នប្រមូលចំណូលមិនមែនសារពើពន្ធបានប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) លើកលែងតែប្រភេទចំណូលពាក់ព័ន្ធនឹងការជួលដីសម្បទានសេដ្ឋកិច្ច និងសម្បទានរ៉ែ ។
- ក្រសួង-ស្ថាប័នចំនួន១០បានប្រើប្រាស់ប្រព័ន្ធFMIS សម្រាប់ប្រតិបត្តិការហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នចំនួន១៧ បន្ថែមថ្មី បានត្រៀមរួចរាល់សម្រាប់ការប្រើប្រាស់ប្រព័ន្ធ FMIS ។
- របាយការណ៍សមិទ្ធកម្មតាមដានការអនុវត្តថវិកាកម្មវិធី ត្រូវបានរៀបចំនៅតាមក្រសួង-ស្ថាប័នជាបណ្តើរៗ ប៉ុន្តែគុណភាពនៅមានកម្រិតនៅឡើយ ដោយកង្វះការវិភាគលើសមិទ្ធកម្ម និងបញ្ហាប្រឈម ។
- ក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធី នៅតាមក្រសួង-ស្ថាប័ន ត្រូវបានរៀបចំឡើង ប៉ុន្តែប្រសិទ្ធភាពនៃការអនុវត្ត នៅមានកម្រិត ។
- ផែនការលទ្ធកម្ម និងផែនការរដ្ឋទេយ្យបុរេប្រទាន របស់ក្រសួង-ស្ថាប័ន ត្រូវបានភ្ជាប់ជាមួយគម្រោងសំណើថវិកាឆ្នាំ ២០២០ ។ ចំពោះផែនការលទ្ធកម្មមានតែក្រសួង-ស្ថាប័នចំនួន ៣ ប៉ុណ្ណោះ ដែលផ្ញើមកយឺត ។
- ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា (Education Fianancial Management System – EFMS) ត្រូវបានដាក់ឱ្យប្រើប្រាស់នៅគ្រប់អង្គភាពថវិកាថ្នាក់កណ្តាល និងមន្ទីររាជធានី-ខេត្ត ទាំង២៥ ។
- សៀវភៅស្តីពីនីតិវិធីនៃការអនុវត្តប្រព័ន្ធ EFMS សម្រាប់អ្នកប្រើប្រាស់ត្រូវបានរៀបចំ (ក្រសួង អយក) ។

១២២. ក្រៅពីវឌ្ឍនភាពគន្លឹះដូចបានរៀបរាប់ខាងលើ មានអាទិភាពមួយចំនួន ជាអាទិ៍ ÷ **ការពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងការប្រមូលចំណូល និងចំណាយ, ការពង្រឹង និងការពង្រីកការអនុវត្តប្រព័ន្ធ FMIS នៅតាមក្រសួង-ស្ថាប័ន និងការពង្រឹងការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធី។**

### ២.២.១. ការពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងការប្រមូលចំណូល និងចំណាយ

១២៣. **ក្រសួង-ស្ថាប័នចំនួន ២៣ ទទួលបន្ទុកប្រមូលចំណូលមិនមែនសារពើពន្ធ** ដែលការប្រមូលចំណូលមិនមែនសារពើពន្ធស្ថិតក្នុងចន្លោះ +/-១០% ហើយមានកំណើនប្រមាណជា ៥% ទៅ១០% ប្រចាំឆ្នាំ ។ ប្រភពចំណូល



មិនមែនសារពើពន្ធសំខាន់ៗ រួមមាន ផលទុនរបស់អាកាសចរណ៍ស៊ីវិល, ផលទុននៃសកម្មភាពទេសចរណ៍, ផលទុនរបស់ប្រៃសណីយ៍ និងទូរគមនាគមន៍ និងចំណូលកាតព្វកិច្ចពីកាសស៊ីណូ ។ ដ្យាក្រាមទី៤ បង្ហាញចំណូលមិនមែនសារពើពន្ធកើនឡើងជិត ៣ ដង ពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៩ ។

១២៤. **ដើម្បីពង្រឹងការកៀរគរចំណូលមិនមែនសារពើពន្ធឱ្យមានប្រសិទ្ធភាព,** អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងមិនមែនសារពើពន្ធ បានពង្រឹងរដ្ឋបាលចំណូលមិនមែនសារពើពន្ធ តាមរយៈ ការរៀបចំយន្តការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (ការបង្កើតគណៈកម្មាធិការត្រួតពិនិត្យនិងវាយតម្លៃចំណូលមិនមែនសារពើពន្ធ និងការត្រួតពិនិត្យតាមដានការប្រមូលចំណូលជាប្រចាំ), ការធ្វើទំនើបកម្មការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន(NRMIS), ការធ្វើទំនើបកម្មការគ្រប់គ្រងសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋតាមប្រព័ន្ធបច្ចេកវិទ្យា, រៀបចំលិខិតបទដ្ឋានគតិយុត្ត និងវិធានការផ្សេងៗទៀត ។

១២៥. **ប្រព័ន្ធ NRMIS ជាប្រព័ន្ធប្រើប្រាស់តាមអនឡាញ និងមានមុខងារសំខាន់ៗ** រួមមាន គ្រប់គ្រងការប្រមូល និងកត់ត្រាចំណូលមិនមែនសារពើពន្ធ, គ្រប់គ្រងការបែងចែក និងទូទាត់ប្រាក់រង្វាន់, បោះពុម្ពវិក្កយបត្រ សាលាកបត្របង្វែរចំណូលថវិកាជាតិ និងផលិតរបាយការណ៍, គណនា និងផលិតឯកសារពាក់ព័ន្ធនឹងការទូទាត់ប្រាក់រង្វាន់ដោយស្វ័យប្រវត្តិ, គ្រប់គ្រង និងរក្សាទិន្នន័យ (កិច្ចសន្យា និងឯកសារពាក់ព័ន្ធ) ជាដើម ។ ប្រព័ន្ធ NRMIS ត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ដំណាក់កាលទី១ ចំនួន២៣ ក្រសួង-ស្ថាប័ន ក្នុងឆ្នាំ២០១៨, និងចំនួន១៨ មន្ទីររាជធានី-ខេត្ត នៅដើមឆ្នាំ២០២០ ។ ជាជំហានបន្ទាប់ កសហវ. នឹងសិក្សារៀបចំប្រព័ន្ធ E-PAYMENT ។

១២៦. ជាមួយគ្នានេះ អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ នឹងសម្របសម្រួលជាមួយក្រសួង-ស្ថាប័ន ពិនិត្យលើកិច្ចសន្យាជួលដីសម្បទានសេដ្ឋកិច្ច ដើម្បីរៀបចំឡើងវិញឱ្យស្របតាមបទប្បញ្ញត្តិជាធរមាន និងតម្លៃឈ្នួលដីសម្បទានសេដ្ឋកិច្ច ។

១២៧. សម្រាប់ការអនុវត្តផែនការចំណាយរបស់ក្រសួង-ស្ថាប័ន បានគូសបញ្ជាក់អំពីប្រសិទ្ធភាពចំណាយ និងបញ្ហាប្រឈមក្នុងទំព័រលេខ ៤ ។ ជាមួយគ្នានេះ ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានកំពុងជំរុញការប្រើប្រាស់ប្រព័ន្ធធនាគារ ដោយបន្ថែមការបើកប្រាក់បេសកកម្មតាមប្រព័ន្ធធនាគារ នៅគ្រប់ក្រសួង-ស្ថាប័ន ។

### ២.២.២. ការពង្រីក និងពង្រឹងការអនុវត្តប្រព័ន្ធ FMIS នៅតាមក្រសួង-ស្ថាប័ន

១២៨. **គម្រោង FMIS ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តជំហានទី១ នៅឆ្នាំ២០១៤ និងជំហានទី២ នៅឆ្នាំ២០១៧ ។** មុខងារស្នូល និងចំណាត់ថ្នាក់ថវិកាត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធ FMIS ជាបន្តបន្ទាប់ស្របតាមជំហានយុទ្ធសាស្ត្រនៃប្រព័ន្ធ ។ ផែនការពង្រីកប្រព័ន្ធ FMIS មានដូចខាងក្រោម ÷

- **ឆ្នាំ២០១៨÷** ក្រសួង-ស្ថាប័នចំនួន ១០ ត្រូវបានដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS ជាផ្លូវការ ក្នុងនោះរួមមាន (១) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, (២) ក្រសួងអប់រំ យុវជន និងកីឡា, (៣) ក្រសួងសុខាភិបាល, (៤) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, (៥) ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, (៦) ក្រសួងកិច្ចការនារី, (៧) ក្រសួងបរិស្ថាន, (៨) ក្រសួងមុខងារសាធារណៈ, (៩) ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និង (១០) ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងអង្គភាពថវិកាដែលជាអាណាប័កផ្ទេសិទ្ធិពេញលេញចំនួន ១២ ។

- **ឆ្នាំ២០១៩÷** ក្រសួង-ស្ថាប័ន ចំនួន ១០ បន្ថែម និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត ទាំង២៥ ត្រូវដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS ។ ក្រសួង-ស្ថាប័នទាំង ១០ រួមមាន÷ (១) ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, (២) ក្រសួងសាធារណការ និងដឹកជញ្ជូន, (៣) ក្រសួងអភិវឌ្ឍន៍ជនបទ, (៤) ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, (៥) ក្រសួងទេសចរណ៍, (៦) ក្រសួងពាណិជ្ជកម្ម, (៧) ក្រសួងធនធានទឹក និងឧតុនិយម, (៨) ក្រសួងព័ត៌មាន, (៩) រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និង (១០) ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។
- **ឆ្នាំ២០២០÷** ក្រសួង-ស្ថាប័នចំនួន ១៧ បន្ថែមរួមមាន (១) អគ្គលេខាធិការដ្ឋានរដ្ឋសភា, (២) អគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភា, (៣) ក្រសួងព្រះបរមរាជវាំង, (៤) ក្រុមប្រឹក្សាធម្មនុញ្ញ, (៥) ទីស្តីការគណៈរដ្ឋមន្ត្រី, (៦) ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, (៧) ក្រសួងមហាផ្ទៃ, (៨) ក្រសួងការពារជាតិ, (៩) ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច, (១០) ក្រសួងរ៉ែ និងថាមពល, (១១) ក្រសួងធម្មការ និងសាសនា, (១២) ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, (១៣) ក្រសួងផែនការ, (១៤) អាជ្ញាធរសវនកម្មជាតិ, (១៥) អង្គភាពប្រឆាំងអំពើពុករលួយ, (១៦) ក្រសួងយុត្តិធម៌ (រួមទាំងអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាអង្គចៅក្រម, តុលាការកំពូល និងសាលាឧទ្ធរណ៍) និង (១៧) គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ព្រមទាំងអង្គភាពថវិកាដែលជាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន១៣ នឹងត្រូវដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS ជាផ្លូវការ ។ មុខងារចំនួន ២ (អភិវឌ្ឍន៍ថ្មី) នៃប្រព័ន្ធ FMIS នឹងត្រូវដាក់ឱ្យអនុវត្តសាកល្បង ក្នុងឆ្នាំ២០២១ នៅ កសហវ និងក្រសួងចំនួន ១ ផ្សេងទៀត ។

១២៩. **ក្រសួង-ស្ថាប័នត្រូវបានដាក់ឱ្យអនុវត្តមុខងារស្នូលចំនួន ៤** រួមមាន មុខងារវិភាជន៍ថវិកា (BA) មុខងារការទិញ (PO) មុខងារគណនីត្រូវសង (AP) និងមុខងារគណនីត្រូវទារ (AR) ។ យោងតាមការស្ទាបស្ទង់យោបល់ផ្ទាល់ពីអ្នកប្រើប្រាស់, ប្រព័ន្ធ FMIS នៅមានដំណើរការយឺតនៅពេលបញ្ចូល (Upload) តារាងជាពិសេសផ្នែកលទ្ធកម្ម ដែលមានមុខសញ្ញាច្រើនក្នុងប្រព័ន្ធ និងការផលិតរបាយការណ៍មិនគ្រប់តាមតម្រូវការរបស់អ្នកប្រើប្រាស់នៅឡើយ[41] ។

១៣០. **ការអនុវត្តគម្រោង FMIS ដំណាក់កាលទី២ នៅមានបញ្ហាប្រឈមមួយចំនួន** ដែលទាមទារឱ្យមានការប្រុងប្រយ័ត្នប្រយែង និងត្រៀមខ្លួនក្នុងការដោះស្រាយ ដូចជា ការពង្រឹងលើសុក្រឹតភាព និងគុណភាពនៃការប្រើប្រាស់ប្រព័ន្ធ FMIS ពីសំណាក់អ្នកប្រើប្រាស់ផ្សារភ្ជាប់នឹងការប្រើប្រាស់របាយការណ៍គោលលើការអនុវត្តថវិកាចេញពីប្រព័ន្ធ FMIS, ការផ្លាស់ប្តូរទីតាំងរបស់អ្នកប្រើប្រាស់, និងការផ្លាស់ប្តូរឈ្មោះអ្នកប្រើប្រាស់ ទន្ទឹមនឹងសមត្ថភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់អ្នកប្រើប្រាស់ប្រព័ន្ធ FMIS នៅមានកម្រិត ។

## ៦.២.៣. ការពង្រឹងការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធី

១៣១. **ក្នុងក្របខណ្ឌនៃការអនុវត្តការកែទម្រង់ប្រព័ន្ធថវិកា, ផែនការយុទ្ធសាស្ត្រថវិកា គឺជាផែនការបីឆ្នាំរំកិល តាមអភិក្រមពីក្រោមឡើងលើ** ដែលក្រសួង-ស្ថាប័ន ត្រូវរៀបចំជារៀងរាល់ឆ្នាំ ដោយផ្សារភ្ជាប់អាទិភាពគោលនយោបាយរបស់ក្រសួង-ស្ថាប័ន ទៅនឹងគោលដៅតាមវិស័យ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ផែនការយុទ្ធសាស្ត្រថវិកា

---

[41] *តាមរយៈការឆ្លើយតបរបស់ក្រុមការងារ FMIS, តម្រូវការរបាយការណ៍ផលិតចេញពីប្រព័ន្ធ FMIS របស់ក្រសួង-ស្ថាប័ន និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភាពខុសៗគ្នា ។ ក្រុមការងារ បានប្រមូលតម្រូវការ និងរៀបចំអភិវឌ្ឍរបាយការណ៍ដែលជាតម្រូវការអាទិភាព រួចជាមុន ។*

ត្រូវបានរៀបចំតាមគោលបំណងគោលនយោបាយ និងកម្មវិធី ដោយពន្យល់ខ្លឹមសារនៃគោលបំណង និងសនិទាន, ប្រភេទហិរញ្ញប្បទាន, សូចនាករគន្លឹះសម្រាប់តាមដានការអនុវត្ត និងការត្រួតពិនិត្យលទ្ធផល, គោលដៅសមិទ្ធកម្ម, ក្របខណ្ឌពេលវេលា និងតម្រូវការថវិកា។ ផែនការយុទ្ធសាស្ត្រថវិកា ត្រូវផ្អែកលើពិតាន ចំណាយ ដែលមាននៅក្នុងក្របខ័ណ្ឌថវិការយៈពេលមធ្យម ។ ផែនការយុទ្ធសាស្ត្រថវិកា ត្រូវបានកំណត់ផងដែរ នូវថវិកាចរន្ត និងថវិកាមូលធនដែលត្រូវការប្រើប្រាស់សម្រាប់ឆ្នាំគ្រោងថវិកា(N+1) និងសម្រាប់ពីរឆ្នាំបន្តបន្ទាប់ របស់ក្រសួង-ស្ថាប័ន ។ លើសពីនេះ ផែនការយុទ្ធសាស្ត្រថវិកាជាមូលដ្ឋានសម្រាប់ការរៀបចំ និងវិភាជថវិកា ប្រចាំឆ្នាំឱ្យចំគោលដៅអាទិភាព ក៏ដូចជា ឧបករណ៍មួយសម្រាប់ការធ្វើសមាហរណកម្មថវិកាចរន្ត និងថវិកា វិនិយោគ ព្រមទាំងរវាងថវិកាជាតិ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ ។ ក្រសួង-ស្ថាប័នត្រូវទទួលខុសត្រូវ អនុវត្តតាមសេចក្តីណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ដែលរៀបចំដោយ កសហវ. ។

១៣២. **ក្នុងការអនុវត្តថវិកាកម្មវិធី, ផែនការយុទ្ធសាស្ត្រថវិកាត្រូវបានដាក់ឱ្យអនុវត្តក្នុងគោលបំណង** ដើម្បីធ្វើឱ្យបាន ល្អប្រសើរលើការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ, ការកែសម្រួលរចនាសម្ព័ន្ធកម្មវិធី, ការប្រើប្រាស់ សូចនាករការត្រួតពិនិត្យសមិទ្ធកម្ម/លទ្ធផលនៃកម្មវិធី ដើម្បីធានាបាននូវភាពជាម្ចាស់នៃកម្មវិធី ដោយផ្សារភ្ជាប់ រវាងធនធានទៅនឹងការទទួលខុសត្រូវចំពោះការអនុវត្ត និងសមិទ្ធកម្ម ។ អង្គភាពថវិកាត្រូវបានបង្កើតឡើងក្នុង គោលដៅបង្កើនតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈការពង្រឹង ការបែងចែកមុខងារ ភារកិច្ច និងការទទួលខុសត្រូវឱ្យកាន់តែច្បាស់លាស់នៅកម្រិតអនុវត្ត ។ នៅឆ្នាំ ២០១៨ មានអង្គភាពថវិកាប្រមាណជាង ៨៦៦ ត្រូវបានបង្កើតឡើង ក្នុងនោះ អង្គភាពថវិកាមួយចំនួនរបស់ក្រសួង-ស្ថាប័ន ជាពិសេស គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរជំនាញរាជធានី-ខេត្ត បានក្លាយជាអង្គភាពថវិកាជាអាណាប័ក ផ្ទេរសិទ្ធ ។ គួរកត់សម្គាល់ថា នៅពេលចាប់ផ្តើមអនុវត្តថវិកាកម្មវិធីមានក្រសួង-ស្ថាប័នចំនួន១៧ ក្នុងចំណោម ៣៨ ក្រសួង-ស្ថាប័ន អនុវត្តថវិកាបានតិច៩០% នៃច្បាប់ថវិកា, ប៉ុន្តែស្ថានភាពនេះ ត្រូវបានកែលម្អ ដែលនៅ ឆ្នាំ ២០១៨ ក្រសួង-ស្ថាប័នតែ ២ ដែលអនុវត្តបានតិចជាង ៩០% នៃច្បាប់ និងរហូតដល់ ៣២ អនុវត្តបាន ៩៥% នៃច្បាប់ ។ សម្រាប់ឆ្នាំ២០១៩ អង្គភាពថវិកាចំនួន ៩១២ ក្នុងនោះអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិចំនួន ៦៦៤ និងមិនទាន់ផ្ទេរសិទ្ធិចំនួន ២៤៨, ថ្នាក់កណ្តាលមាន ៣០៨ ក្នុងនោះអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិ ៦០ និង មិនទាន់ផ្ទេរសិទ្ធិ២៤៨ និងថ្នាក់មូលដ្ឋានមាន ៦០៤(ផ្ទេរសិទ្ធិទាំងអស់)។

១៣៣. **ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយតាមរយៈការដាក់ឱ្យអនុវត្តថវិកាកម្មវិធីទាំងរដ្ឋបាលថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ** ។ ប៉ុន្តែការផ្សារភ្ជាប់នៅមានកម្រិតនៅឡើយ ដែលបណ្តាលមកពីកត្តាមួយចំនួន (១) ក្រសួង-ស្ថាប័នស្ថិតក្នុងវិស័យតែមួយពិបាកក្នុងការរៀបចំគោលនយោបាយប្រទាក់ក្រឡាគ្នារួម ទាំងការកំណត់សូចនាករ និងគោលដៅ ជាពិសេសការសម្របសម្រួល, (២) សមាហរណកម្មរវាងចំណាយចរន្ត និងមូលធន, និង (៣) ការកំណត់គោលបំណងគោលនយោបាយ, រចនាសម្ព័ន្ធកម្មវិធី និងស្ថាប័ន និងសូចនាករសមិទ្ធកម្មគន្លឹះ។

១៣៤. **ផែនការជាយុទ្ធសាស្ត្រដើម្បីជំរុញការរៀបចំ BSP និង PB ប្រកបដោយគុណភាព** ចាំបាច់ត្រូវមានផែនការរៀបចំ ច្បាស់លាស់ ដោយមានការចូលរួមពីបណ្តានាយកដ្ឋានពាក់ព័ន្ធ និងមានផែនការបណ្តុះបណ្តាលដោយ គ្រូឧទ្ទេស

មកពី កសហវ., រីឯការគ្រោងថវិកាផែនការយុទ្ធសាស្ត្រថវិការបស់អង្គភាពថវិកានីមួយៗត្រូវមាន លក្ខណៈលម្អិត ។ ជាមួយគ្នានេះ ក្រុមការងាររៀបចំផែនការ គួរមានលក្ខខណ្ឌយោងការងារច្បាស់លាស់ ។

## ២.៣. យោបល់ដែលគួរគិតខ្ពស់លើប្រព័ន្ធ FMIS និង សិទ្ធិភាព BSP-PB

### ២.៣.១. ប្រព័ន្ធ FMIS

១៣៥. **ក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ប្រព័ន្ធ FMIS ដើរតួនាទីស្នូលក្នុងការសម្រួលដល់កិច្ចប្រតិបត្តិការហិរញ្ញវត្ថុ** ទន្ទឹមនឹងការគ្រប់គ្រងចំណាយលើការអនុវត្តគោលនយោបាយ ។ ចាប់តាំងពីប្រព័ន្ធ FMIS ត្រូវបានដាក់ឱ្យដំណើរការពេញលេញក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរតនាគាររាជធានី-ខេត្ត ក្នុងឆ្នាំ ២០១៧ មក, ប្រព័ន្ធនេះ ត្រូវបានពង្រីកទៅកាន់មជ្ឈដ្ឋានអ្នកប្រើប្រាស់កាន់តែទូលំទូលាយ ហើយមជ្ឈមណ្ឌលព័ត៌មាននៃប្រព័ន្ធនេះ ក៏ត្រូវបានបង្កើនសមត្ថភាព ដើម្បីតភ្ជាប់ទៅនឹងប្រព័ន្ធរបស់ធនាគារពាណិជ្ជ និងប្រព័ន្ធកត់ត្រាចំណូលរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ឧ.ប្រព័ន្ធគ្រប់គ្រងព័ត៌មានចំណូលមិនមែនសារពើពន្ធ) ។ ទន្ទឹមនឹងការពង្រីកវិសាលភាព និងទំនើបកម្មបច្ចេកវិទ្យាព័ត៌មាន, ការអនុវត្តប្រព័ន្ធ FMIS ត្រូវបានផ្តោតលើការសម្រួលនីតិវិធី និងតម្រង់ទិសការគ្រប់គ្រងការផ្លាស់ប្តូរ ដើម្បីឱ្យប្រតិបត្តិការរបស់ប្រព័ន្ធអាចរុញច្រានលំហូរថវិកាទៅដល់អង្គភាពផ្តល់សេវាជួរមុខ ។ ធនាគារពិភពលោក បានធ្វើការសិក្សា និងរកឃើញថា (១) ការទូទាត់ចំណាយនៅមានភាពយឺតយ៉ាវ បើទោះបីជាប្រព័ន្ធ FMIS ត្រូវបានរៀបចំឱ្យប្រតិបត្តិស្របតាមនីតិវិធីការងារដែលកំពុងអនុវត្តក៏ដោយ, (២) ប្រតិបត្តិការទូទាត់ក្នុងប្រព័ន្ធ FMIS នៅមានកម្រិតទាបដោយសារនៅកម្រិតថ្នាក់ជាតិប្រព័ន្ធនេះ ត្រូវបានប្រើប្រាស់ក្នុងការស្នើសុំបុរេប្រទានពីរតនាគារ ដើម្បីធ្វើនីតិវិធីទូទាត់ក្រៅប្រព័ន្ធ, (៣) ការគ្រប់-គ្រងការផ្លាស់ប្តូរ ប្រព្រឹត្តទៅនៅមានកម្រិត ពិសេសលើការរៀបចំសកម្មភាពទៀងទាត់ សម្រាប់ជួបពិភាក្សា, លើកទឹកចិត្ត និងពង្រឹងសមត្ថភាពរបស់អ្នកប្រើប្រាស់ប្រព័ន្ធ FMIS, និង (៤) ការជំរុញការប្រើប្រាស់នីតិវិធីការងារតាមប្រព័ន្ធ FMIS ទាមទារការយកចិត្តទុកដាក់បន្ថែម ហើយតួនាទីរបស់អ្នកពាក់ព័ន្ធដូចជា សវនករ និង អ.គ.ហ. លើកិច្ចអន្តរាគមន៍នេះ ក៏ពុំទាន់រៀបចំឱ្យបានពេញលេញនៅឡើយ ។

១៣៦. **លើមូលដ្ឋាននៃរបកគំហើញខាងលើនេះ ធនាគារពិភពលោកបានផ្តល់យោបល់មួយចំនួន** មានជាអាទិ៍ (១) កែលម្អនីតិវិធីការងារ ដោយជំរុញក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដឹកនាំធ្វើជាគំរូ, (២) ពង្រឹងការចូលរួមពីក្រសួង-ស្ថាប័ន ដោយកែលម្អការអនុវត្តការងាររវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័ន, (៣) ជំរុញការត្រួតពិនិត្យ និងវាយតម្លៃលើការសម្រួលនីតិវិធីការងារ, (៤) ធ្វើការវាយតម្លៃពីអត្ថប្រយោជន៍នៃការផ្លាស់ប្តូរ និងរៀបចំផែនការសកម្មភាពគ្រប់គ្រងការផ្លាស់ប្តូរ, និង (៥) បង្កើតនូវបរិយាកាសអំណោយផលសម្រាប់ទាក់ទាញការចូលរួមគាំទ្រ ។

### ២.៣.២ សិទ្ធិភាព BSP-PB

១៣៧. **ឆ្លើយតបសំណើរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើការត្រួតពិនិត្យលើ BSP និង PB, សហភាពអឺរ៉ុបបានផ្តល់ជំនួយបច្ចេកទេស ដោយត្រួតពិនិត្យលើ BSP និង PB ចំនួន ៨ ក្រសួង-ស្ថាប័ន** ក្នុងនោះរួមមាន (១) ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, (២) ក្រសួងអប់រំ យុវជន និងកីឡា, (៣) ក្រសួងសាធារណការ និងដឹកជញ្ជូន, (៤)

ក្រសួងមហាផ្ទៃ-ផ្នែករដ្ឋបាល, (៥) ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, (៦) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, (៧) ក្រសួងអភិវឌ្ឍន៍ជនបទ និង (៨) ក្រសួងសុខាភិបាល ។

១៣៨. **ការធ្វើផែនការ និងរៀបចំថវិកា គឺជាភារកិច្ចសំខាន់របស់រាជរដ្ឋាភិបាល** ហើយនៅកម្ពុជា BSP ត្រូវបានប្រើប្រាស់ជាឧបករណ៍ ដើម្បីរៀបចំរចនាសម្ព័ន្ធកម្មវិធី/អនុកម្មវិធី ដោយឆ្លុះបញ្ចាំងពីផែនការថវិកា ក្នុងការអនុវត្តសកម្មភាពតាមវិស័យ ។ BSP ដែលសហភាពអឺរ៉ុបបានពិនិត្យសុទ្ធសឹងតែមានបញ្ជាក់ពីទំនាក់ទំនងរវាងគោលនយោបាយជាតិ/តាមវិស័យ និងបេសកកម្ម/កម្មវិធីអភិវឌ្ឍន៍របស់ក្រសួង-ស្ថាប័ន ។ លើសពីនេះ BSP ទាំងនោះក៏មានក្របខណ្ឌសមិទ្ធកម្ម ដែលបានអង្គុន់ដល់កម្រិតអនុកម្មវិធី ហើយមានបញ្ជាក់ពីសូចនាករ និងតម្រូវការថវិកាផងដែរ ។ ដោយសារការសម្រេចបាននូវវឌ្ឍនភាពលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, BSP ចាំបាច់ត្រូវមានការកែលម្អបន្ថែម ដើម្បីជំរុញការធ្វើផែនការ និងការរៀបចំថវិកាឱ្យកាន់តែមានភាពប្រទាក់ក្រឡាគ្នា ។

១៣៩. **ក្នុងន័យនេះ របាយការណ៍ត្រួតពិនិត្យ BSP និង PB បានគូសបញ្ជាក់ចំណុចត្រូវកែលម្អចំនួន ៤** រួមមាន (១) ខ្លឹមសារ BSP អាចនឹងពង្រីកបន្ថែមជាមួយនឹងការវិភាគ ដើម្បីឱ្យអ្នកអនុវត្តអាចប្រៀបធៀបរវាងវឌ្ឍនភាពគ្រោងទុក និងវឌ្ឍនភាពជាក់ស្តែង, អាចស្វែងយល់ពីកត្តារាំងស្ទះនៃបញ្ហាប្រឈម និងអាចពន្យល់អំពីតម្រូវការហិរញ្ញវត្ថុ, (២) ក្របខណ្ឌសមិទ្ធកម្ម BSP មិនមានរំលេចព័ត៌មានដូចជា ទិន្នន័យមូលដ្ឋាននៃសូចនាករ, វិធីសាស្ត្រ និងមធ្យោបាយក្នុងការគណនា, មធ្យោបាយក្នុងការផ្ទៀងផ្ទាត់ និងគោលដៅឆ្នាំ n+2 និង n+3 ដែលសុទ្ធសឹងជាសមាសធាតុសំខាន់ ដើម្បីបង្កើនសង្គតិភាពរវាងគោលនយោបាយ, សមិទ្ធកម្ម និងលទ្ធផល ឱ្យកាន់តែប្រសើរឡើង , (៣) BSP ពុំទាន់ត្រូវបានប្រើប្រាស់ ជាឧបករណ៍រៀបចំផែនការរយៈពេលមធ្យម ឱ្យបានពេញលេញនៅឡើយ ដោយសារថវិកាមូលធនវិនិយោគមិនស្ថិតក្នុងនីតិវិធីរៀបចំថវិកាប្រចាំឆ្នាំ ។ ការព្យាយាមធ្វើសមាហរណកម្មថវិកាចរន្ត និងថវិកាមូលធនទៅក្នុងនីតិវិធីរៀបចំថវិកាប្រចាំឆ្នាំ បាននាំឱ្យមានការរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងវិនិយោគសាធារណៈ ប៉ុន្តែការអនុវត្តឋិតក្នុងដំណាក់កាលចាប់ផ្តើមនៅឡើយ, (៤) ការរៀបចំ BSP អាចបង្កើនតម្លៃបន្ថែម បើកិច្ចពិភាក្សាថវិកាប្រចាំឆ្នាំ ជំរុញឱ្យមានអនុលោមភាពជាមួយនឹងដំណើរការរៀបចំផែនការរយៈពេលមធ្យម ដែលប្រើប្រាស់ MTBF ជាអភិក្រមពីលើចុះក្រោមក្នុងការកំណត់ពិតានថវិកា ហើយប្រើប្រាស់ BSP ជាអភិក្រមពីក្រោមឡើងលើ ដើម្បីប្រែក្លាយផែនការយុទ្ធសាស្ត្រជាតិ/វិស័យ ទៅជាផែនការថវិកា ។

១៤០. **ដើម្បីធ្វើឱ្យសំណើកែលម្អខាងលើក្លាយជាសកម្មភាពអនុវត្ត សហភាពអឺរ៉ុបបានផ្តល់យោបល់ចំនួន ៤** ចំណុច រួមមាន (១)សេចក្តីណែនាំការរៀបចំ BSP គួរត្រូវកែសម្រួល ដោយទាមទារឱ្យក្រសួង-ស្ថាប័នផ្តល់ការវិភាគលើវិធីសាស្ត្រនៃការវាយតម្លៃសមិទ្ធកម្ម, លើមូលហេតុដែលបញ្ហាប្រឈមពុំអាចដោះស្រាយបាន និងផ្តល់ការវិភាគលើការប៉ែងចែង និងពន្យល់ពីតម្រូវការថវិកាថ្មី, (២) ទម្រង់រៀបចំក្របខណ្ឌសមិទ្ធកម្ម BSP គួរត្រូវកែសម្រួល ទន្ទឹមនឹងសេចក្តីព្រាងគោលការណ៍ណែនាំស្តីពីថវិកាព័ត៌មានសមិទ្ធកម្ម ក៏គួរតែផ្សព្វផ្សាយ ដើម្បីតម្រង់ការអនុវត្តរបស់ក្រសួង-ស្ថាប័ន តាមរយៈកម្មវិធីពង្រឹងសមត្ថភាព ដើម្បីកែលម្អសូចនាករសមិទ្ធកម្ម និងបង្កើតប្រព័ន្ធព័ត៌មាន សម្រាប់គាំទ្រការកត់ត្រា, ការត្រួតពិនិត្យ, ការវិភាគ និងការរាយការណ៍អំពីក្របខណ្ឌសមិទ្ធកម្ម, (៣) ពេលរៀបចំ BSP ក្រសួង-ស្ថាប័នគួរត្រូវទាមទារឱ្យបញ្ចូលថវិកាមូលធនវិនិយោគជាផ្នែកមួយដាច់ដោយឡែកក្នុង BSP ឬក៏បញ្ជ្រាបថវិកាមូលធនវិនិយោគទៅក្នុងកម្មវិធីនីមួយៗនៃ BSP តាមរយៈអនុកម្មវិធី ឬចង្កោមសកម្មភាពជាគម្រោងមូលធនវិនិយោគ ដែលផ្សារភ្ជាប់ទៅនឹងកម្មវិធីនីមួយៗ, និង (៤) ដំណើរការរៀបចំថវិកាប្រចាំឆ្នាំគួរតែត្រូវបង្កើតឱ្យមានសវនាការផ្លូវការលើ MTBF/BS P ដែលផ្តល់ឱកាសឱ្យមានការពិភាក្សាកំណត់ពិតានហិរញ្ញវត្ថុសម្រាប់ការរៀបចំថវិកាប្រចាំឆ្នាំ និងអនុម័តលើ BSP ដោយរំលេចអំពី ចំនួនថវិកាចាំបាច់សម្រាប់ទ្រទ្រង់សកម្មភាព និងកម្មវិធីដែលកំពុងអនុវត្ត, ចំនួនថវិកាស្នើសុំសម្រាប់អនុវត្តគោលនយោបាយ/

គម្រោងថ្មី, ចំនួនថវិកាចាំបាច់ សម្រាប់ទ្រទ្រង់គម្រោងមូលធនវិនិយោគដែលកំពុងអនុវត្ត និងចំនួនថវិកាស្នើសុំ សម្រាប់អនុវត្តគម្រោងមូលធនវិនិយោគថ្មី ។

### ៣. បញ្ហាប្រឈម និងសំណើដំណោះស្រាយ

១៤១. ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ គ្រោងនឹងបញ្ចប់ក្នុងឆ្នាំ២០២០ ក្នុងន័យនេះ ការបញ្ចប់ការងារសេសសល់ និងដោះស្រាយបញ្ហាប្រឈម ក្នុងឆ្នាំ២០១៩ មានភាពចាំបាច់ និងបន្ទាន់ ដើម្បីបង្កើតជាមូលដ្ឋានគ្រឹះសម្រាប់ឈានទៅដំណាក់កាលទី៤ ។ ខាងក្រោមសង្ខេបបញ្ហាប្រឈម និងដំណោះស្រាយគន្លឹះ សម្រាប់ការអនុវត្តឆ្នាំ២០២០ ឬពេលបន្ទាប់ ÷

| បញ្ហាប្រឈម | សំណើដំណោះស្រាយ |
|---|---|
| **ផ្នែកទី១ "បន្តពង្រឹងភាពជឿទុកចិត្តបាននៃថវិកា"** | |
| ១. ការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ មិនទាន់ពេញលេញនៅឡើយ សម្រាប់ប្រភេទចំណូលមិនមែនសារពើពន្ធលើការជួលដីសម្បទានសេដ្ឋកិច្ច ដែលទទួលបន្ទុកដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសម្បទានរ៉ែ ដែលទទួលបន្ទុកដោយក្រសួងរ៉ែ និងថាមពល ។ | ស្នើអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ សហការជាមួយក្រសួង-ស្ថាប័ន ជំរុញការដោះស្រាយបញ្ហាលើការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច និងសម្បទានរ៉ែ ដើម្បីអនុវត្តប្រព័ន្ធ NRMIS និងពង្រឹងប្រសិទ្ធភាព នៃការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ។ |
| ២. ការពន្លឿនការធ្វើបណ្ណសម្គាល់កម្មសិទ្ធិសម្រាប់ទ្រព្យសម្បត្តិរដ្ឋ នឹងជួយជំរុញឱ្យការគ្រប់គ្រងទ្រព្យសម្បត្តិ និងចំណូលមិនមែនពន្ធ មានប្រសិទ្ធភាព ។ ប៉ុន្តែការធ្វើបណ្ណសម្គាល់កម្មសិទ្ធិដីធ្លីរបស់រដ្ឋ មិនទាន់បានពេញលេញនៅឡើយជាពិសេសនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។ | ▪ ស្នើអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធសហការជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ធ្វើការសិក្សាដោះស្រាយ ដើម្បីពន្លឿនការធ្វើបណ្ណសម្គាល់កម្មសិទ្ធិ ។<br>▪ ស្នើក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សហការជាមួយក្រសួង-ស្ថាប័ន កំណត់ផែនការ និងពេលវេលាច្បាស់លាស់ ជាពិសេសដាក់បញ្ចូលក្នុង MAP3 ។ |
| **ផ្នែកទី២ "បន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ"** | |
| ៣. ប្រព័ន្ធ FMIS[42] បាននិងកំពុងប្រែក្លាយការងារប្រើប្រាស់ប្រព័ន្ធ FMIS ជាការងារស្នូលរបស់មន្ត្រីហិរញ្ញវត្ថុនីមួយៗ ។ ប៉ុន្តែប្រព័ន្ធ FMIS ពុំទាន់អាចផលិតរបាយការណ៍តាមតម្រូវការរបស់មន្ទីរសេដ្ឋកិច្ចរាជធានី-ខេត្ត នៅឡើយ ។ ទម្រង់របាយការណ៍អនុវត្តចំណូល-ចំណាយក្នុងប្រព័ន្ធ FMIS ខុសពីទម្រង់ដែលត្រូវបំពេញ និងរាយការណ៍ជូនអគ្គនាយកដ្ឋានថវិកា នៃ កសហវ. ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ។ | ស្នើក្រុមការងារ FMIS បង្កើតទម្រង់របាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ឆមាស និងឆ្នាំ ក្នុងប្រព័ន្ធ FMIS ស្របតាមតម្រូវការរបស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាជធានី-ខេត្ត ដើម្បីកាត់បន្ថយការធ្វើដោយដៃ ។ |

[42] *ប្រព័ន្ធ FMIS ត្រូវបានយកមកប្រើប្រាស់ ដើម្បីកត់ត្រាគ្រប់ប្រតិបត្តិការហិរញ្ញវត្ថុ និងគណនេយ្យរបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងផលិតរបាយការណ៍នានា ក៏ប៉ុន្តែរបាយការណ៍មួយចំនួន ដែលទាញចេញពីប្រព័ន្ធនៅពុំទាន់អាចប្រើប្រាស់បានជាផ្លូវការនៅឡើយទេ សម្រាប់អគ្គនាយកដ្ឋានរតនាគារជាតិ ។*

| បញ្ហាប្រឈម | អនុសាសន៍ដំណោះស្រាយ |
|---|---|
| ៤.គ្រប់ចំណាត់ថ្នាក់ថវិកាទាំង៧ ត្រូវបានដាក់ឱ្យអនុវត្តក្នុងប្រព័ន្ធ FMIS ។ ប៉ុន្តែការអនុវត្តចំណាត់ថ្នាក់ថវិកាចំនួនពីរ នៅមានបញ្ហាប្រឈមនៅឡើយ រួមមានចំណាត់ថ្នាក់ភូមិសាស្ត្រ និងមុខងារ ដែលគុណភាពទិន្នន័យមិនទាន់ប្រើប្រាស់បាន ។ | ស្នើអង្គភាពពាក់ព័ន្ធជំរុញការងារនេះ ក្នុងករណីមានតម្រូវការជំនួយបច្ចេកទេស/ជំនាញការអន្តរជាតិ, អ.គ.ហ. នឹងទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីពិភាក្សា និងគាំទ្រ ។ បញ្ហានេះ គួរធ្វើការដោះស្រាយបញ្ចប់ក្នុងឆ្នាំ ២០២០ មុនអនុវត្តប្រព័ន្ធ FMIS ដំណាក់កាលទី៣ ។ |
| ៥.ការធ្វើសន្ទានកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន<br>▪ ប្រព័ន្ធ FMIS និងប្រព័ន្ធបៀវត្សរបស់ក្រសួងមុខងារសាធារណៈ[43]<br>▪ ប្រព័ន្ធ FMIS និងប្រព័ន្ធ EFMS របស់ក្រសួងអប់រំ យុវជន និងកីឡា<br>▪ ប្រព័ន្ធ FMIS និងប្រព័ន្ធពន្ធដារ[44]<br>▪ ប្រព័ន្ធពន្ធដារ និងប្រព័ន្ធអាស៊ីគូដា (ASYCUDA) | ស្នើសុំពន្លឿនការសិក្សា និងរៀបចំការធ្វើសន្ទានកម្មសម្រាប់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដោយបញ្ចប់យ៉ាងយូរក្នុងឆ្នាំ២០២០ នេះ ។ ជាមួយគ្នានេះ ខណៈប្រព័ន្ធ ICT បាននិងកំពុងប្រើប្រាស់យ៉ាងទូលំទូលាយក្នុងការគ្រប់គ្រងការប្រមូលចំណូល និងការចំណាយ ដូចនេះ ការរៀបចំគោលនយោបាយ/យុទ្ធសាស្ត្រ/ផែនការមេ សម្រាប់ ICT ពិតជាសំខាន់ដើម្បីធានាការផ្សារភ្ជាប់គ្នា, សន្សំសំចៃ និងនិរន្តរភាពនៃប្រព័ន្ធ ។ |
| **ផ្នែកទី៣ "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ"** | |
| ៦.ប្រសិទ្ធភាពនៃការអនុវត្តថវិកា នៅមានកម្រិតនៅឡើយ ហើយជាទូទៅការចំណាយគរនៅត្រីមាសទី៤ នៃឆ្នាំនីមួយៗ ដែលបណ្តាលមកពីកត្តា (១) សមត្ថភាពរបស់អង្គភាពថវិកា, (២) នីតិវិធីធានាចំណាយ, (៣) គម្រោងវិនិយោគសាធារណៈ ដោយថវិកាជាតិ អាចចាប់ផ្តើមអនុវត្តគម្រោងបាននៅចុងត្រីមាសទី២ ឬដើមត្រីមាសទី៣ ។ | អង្គភាពថវិកានៅតាមក្រសួង-ស្ថាប័នមួយចំនួន ត្រូវបានបង្កើតឡើង ប៉ុន្តែពុំមានសិទ្ធិអំណាច ដូចមានចែងក្នុងប្រកាស និងគោលការណ៍ណែនាំស្តីពីការអនុវត្តថវិកាកម្មវិធី ។ ជាមួយគ្នានេះស្នើអង្គភាពហិរញ្ញវត្ថុក្រសួង-ស្ថាប័ន សម្របសម្រួលជាមួយអង្គភាពថវិកា និងមានផែនការរយៈពេលមធ្យម ដើម្បីពង្រឹងសមត្ថភាព និងបំពេញលក្ខណៈសម្បត្តិអង្គភាពថវិកា ដោយបញ្ចូលក្នុង MAP3 ។ |
| ៧. ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយតាមរយៈការដាក់ឱ្យអនុវត្តថវិកាកម្មវិធី ទាំងរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។ ប៉ុន្តែការផ្សារភ្ជាប់នៅមានកម្រិតនៅឡើយ ដែលបណ្តាលមកពីកត្តាមួយចំនួន (១) ក្រសួង-ស្ថាប័នស្ថិតក្នុងវិស័យតែមួយ ពិបាកក្នុងការរៀបចំគោលនយោបាយប្រទាក់ក្រឡាគ្នា រួមទាំងការកំណត់សូចនាករ និងគោលដៅ ជាពិសេសការសម្របសម្រួល, (២) សមាហរណកម្មរវាងចំណាយចរន្ត និងមូលធន, និង (៣) ការកំណត់គោលបំណង | ជាដំណាក់កាលបឋម, អ.គ.ហ. ស្នើសុំរៀបចំសិក្ខាសាលាចែករំលែកបទពិសោធន៍ក្រសួង-ស្ថាប័នទាំង ១០ ដែលចាប់ផ្តើមអនុវត្តថវិកាកម្មវិធីសាកល្បងពេញលេញ ឆ្នាំ ២០១៥ ស្តីពីការអនុវត្តថវិកាកម្មវិធី ដោយរំលេចអំពីការរៀបចំ, ការអនុវត្ត, និងការត្រួតពិនិត្យតាមដាន និងវាយតម្លៃហិរញ្ញវត្ថុ និងសមិទ្ធកម្ម ព្រមទាំងរំលេចអំពីបញ្ហាប្រឈមនិងដំណោះស្រាយចំពោះក្រសួងនីមួយៗ ។ សិក្ខាសាលានេះ មានគោលដៅចែករំលែកបទពិសោធន៍ |

[43] *សន្ទានកម្មចំណាយបៀវត្សជាមួយប្រព័ន្ធគ្រប់គ្រងបៀវត្សមន្ត្រីរាជការស៊ីវិលរបស់ក្រសួងមុខងារសាធារណៈ ក៏បានសិក្សារួមគ្នាអំពីលទ្ធភាពបច្ចេកទេសរួចរាល់ និងបានដាក់ចេញនូវផែនការបន្តការសិក្សារៀបចំ និងអភិវឌ្ឍនៅក្នុងឆ្នាំ ២០២០ ។*

[44] *ការរៀបចំ និងអភិវឌ្ឍសន្ទានកម្មចំណូលពន្ធដារជាមួយប្រព័ន្ធគ្រប់គ្រងចំណូលពន្ធដាររបស់អគ្គនាយកដ្ឋានពន្ធដារសម្រេចបានក្នុងរង្វង់ ៩០% និងគ្រោងនឹងដាក់ឱ្យដំណើរការនៅក្នុងឆ្នាំ ២០២០ នេះ ។*

| បញ្ហាប្រឈម | សំណើដំណោះស្រាយ |
|---|---|
| គោលនយោបាយ, រចនាសម្ព័ន្ធកម្មវិធី និងស្ថាប័ន និងសូចនាករសមិទ្ធកម្មគន្លឹះ ។ | អនុវត្តថវិកាកម្មវិធីជូនក្រសួង-ស្ថាប័ន ដើម្បីជាមូលដ្ឋានសម្រាប់ពង្រឹងការអនុវត្ត និងសម្របសម្រួលផ្ទៃក្នុង ។ |
| **ផ្នែកទី៥ "ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព"** | |
| ៨. រាជរដ្ឋាភិបាលកម្ពុជាបានដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រអាទិភាព សំដៅគាំទ្រការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យសម្រេចគោលដៅប្រកបដោយជោគជ័យ និងចីរភាព ។ ការរៀបចំផែនការយុទ្ធសាស្ត្រស្តីពីការកសាង និងអភិវឌ្ឍសមត្ថភាពក្នុងក្របខណ្ឌ PFMRP ដំណាក់កាលទី ៤ (SCDP4) គួរតែឆ្លុះបញ្ចាំងអំពី តម្រូវការរបស់យុទ្ធសាស្ត្រនីមួយៗ ដោយមានកិច្ចសហការជាមួយអង្គភាពទទួលបន្ទុកក្រោមឱវាទ កសហវ. ។ ប៉ុន្តែការងារនេះ មានបន្ទុកធ្ងន់សម្រាប់វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីរៀបចំ និងអនុវត្តទៅតាមផែនការ ។ | ▪ ស្នើពង្រឹងយន្តការសម្របសម្រួលការអនុវត្តយុទ្ធសាស្ត្រស្តីពីការកសាង និងអភិវឌ្ឍសមត្ថភាព ក្នុងក្របខណ្ឌ PFMRP ដំណាក់កាលទី ៣<br>▪ ស្នើវិចារណកម្មនិងអាទិភាពកម្មវិធីបណ្តុះបណ្តាល<br>▪ ស្នើបង្កើតកម្មវិធីបណ្តុះបណ្តាលដោយភ្ជាប់ជាមួយវិញ្ញាបនបត្របញ្ជាក់ការសិក្សា (Certificate Program)<br>▪ ស្នើវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សិក្សាវិភាគអំពីតម្រូវការ និងការគាំទ្រលើការកសាងសមត្ថភាព ដើម្បីជួយជំរុញការអនុវត្តយុទ្ធសាស្ត្រ/ផែនការសកម្មភាពឱ្យកាន់តែមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព<br>▪ ស្នើវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រៀបចំវគ្គបណ្តុះបណ្តាលតាមអនឡាញ ។ |
| **ផលប៉ះពាល់អវិជ្ជមាននៃការសម្រេចលទ្ធផលយឺតជាងការគ្រោងទុក (រួមបញ្ចូលបញ្ហាប្រឈមក្នុងដំណាក់កាលទីទី ៤)** | |
| ៩. ការរៀបចំ និង/ឬ អនុម័តលិខិតបទដ្ឋានគតិយុត្តត្រូវចំណាយរយៈពេលច្រើនជាងការរំពឹងទុក ដែលផ្តល់ផលប៉ះពាល់ដល់ការអនុវត្តផែនការសកម្មភាពកែទម្រង់ក៏ដូចជា កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ ក្នុងនោះរួមមានដូចខាងក្រោម ÷<br>❑ សេចក្តីច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ<br>❑ សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ, សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម, សេចក្តីព្រាងច្បាប់ស្តីពីយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន, សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ ។<br>❑ គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាសមិទ្ធកម្ម | ស្នើអង្គភាពពាក់ព័ន្ធបន្តយកចិត្តទុកដាក់និងជំរុញកិច្ចការនេះ (លិខិតបទដ្ឋានគតិយុត្ត និងការងារបច្ចេកទេស) ដើម្បីជៀសវាង/ប៉ះពាល់ដល់កិច្ចការកែទម្រង់/ប្រសិទ្ធភាពនៃការអនុវត្តតាមការដ្ឋានកែទម្រង់ផ្សេងទៀត ។ |

| បញ្ហាប្រឈម | សំណើដំណោះស្រាយ |
|---|---|
| ❑ ការរៀបចំម៉ូឌុលលទ្ធកម្ម និងរៀបចំផែនការថវិកាក្នុងប្រព័ន្ធ FMIS យឺតជាងពេលវេលាគ្រោងទុក ដែលអាចប៉ះពាល់ពេលដល់ពេលវេលាក្នុងធ្វើតេស្តសាកល្បង ព្រមទាំងមិនអាចសម្រេចការអនុវត្តក្របខណ្ឌលទ្ធផលក្រោមកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងសហភាពអឺរ៉ុប ។ | |
| **ភាពប្រទាក់ក្រឡាគ្នារវាងការដ្ឋានកែទម្រង់ ៣ បូក ១** | |
| ១០. ទន្ទឹមការងារកែទម្រង់កាន់តែស៊ីជម្រៅ, ការដ្ឋានកែទម្រង់ ៣ បូក ១ (ហិរញ្ញវត្ថុសាធារណៈ, រដ្ឋបាលសាធារណៈ និងវិមជ្ឈការនិងវិសហមជ្ឈការ និងច្បាប់និងប្រព័ន្ធយុត្តិធម៌) កាន់តែដើរតួនាទីសំខាន់ក្នុងការជំរុញការអនុវត្តចំពោះការងារប្រទាក់ក្រឡាគ្នាឱ្យសម្រេចបានតាមគោលដៅ។ ជាក់ស្តែង ចំពោះការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ, ការបែងចែកប្រាក់រង្វាន់, ការធ្វើប្រតិភូកម្មមុខងារពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ, ការគ្រប់គ្រងចំណូលតាមច្រកចេញ-ចូលតែមួយ, ការបន្សុីចនាសម្ព័ន្ធកម្មវិធីទៅរចនាសម្ព័ន្ធក្រសួង-ស្ថាប័ន, ការវិភាគមុខងារតាមក្រសួង-ស្ថាប័ន ។ល។ ពុំទាន់មានការគិតគូររួមគ្នាសម្រាប់ការដ្ឋានកែទម្រង់ ៣ បូក ១ នៅឡើយ ។ | ▪ គាំទ្រការអនុវត្តកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ ឆ្នាំ២០២០-២០៣០ ដែលគ្រោងនឹងដាក់ឱ្យអនុវត្តនាពេលខាងមុខនេះ ។<br>▪ រៀបចំចក្ខុវិស័យ និងយុទ្ធសាស្ត្រនៃការងារកែទម្រង់ ៣ បូក ១ រយៈពេល ១០ ឆ្នាំ តាមការសម្រេចរបស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ថ្ងៃទី ១១ ខែមីនា ឆ្នាំ២០២០ ។<br>▪ រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ តាមការសម្រេចរបស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ។ |
| ១១. ស្ថានមុខងារនិងភារកិច្ចរវាងសវនកម្មផ្ទៃក្នុង និងអធិការកិច្ច | ស្នើអង្គភាពពាក់ព័ន្ធពន្លឿនការរៀបចំក្របខណ្ឌនិងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ច ។ |
| **ការសម្របសម្រួល** | |
| ១២. គុណភាពការរៀបចំនិងកំណត់ផែនការកម្មភាព សូចនាករសមិទ្ធកម្មគន្លឹះ និងគោលដៅ របស់ក្រសួង-ស្ថាប័ន (ឧ.ការបង្កើនអង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិ, ការប្រគល់សិទ្ធិជូនអង្គភាពថវិកា, ការបង្កើនគុណភាពផែនការយុទ្ធសាស្ត្រថវិកា, ថវិកាកម្មវិធី, ការវាយតម្លៃលក្ខណៈសម្បត្តិអង្គភាពថវិកា ដើម្បីគាំទ្រ និងបំពេញបន្ថែមចំណុចខ្វះខាត) នៅមានកម្រិតនៅ | ▪ អ.គ.ហ. ពង្រឹងកិច្ចសហប្រតិការរវាង អ.គ.ហ., អង្គភាពក្រោមឱវាទ កសហវ. និងក្រសួង-ស្ថាប័ន លើការរៀបចំ និងកំណត់ផែនការកម្មភាព សូចនាករសមិទ្ធកម្មគន្លឹះ និងគោលដៅ របស់ក្រសួង-ស្ថាប័ន<br>▪ ស្នើសុំអង្គភាពពាក់ព័ន្ធក្រោមឱវាទ កសហវ. ជំរុញការអនុវត្តផែនការសកម្មភាពកែទម្រង់ និងតាមដាន |

| បញ្ហាប្រឈម | សំណើដំណោះស្រាយ |
|---|---|
| ឡើយ ហើយមិនទាន់សមស្របតាមក្របខណ្ឌផែនការសកម្មភាពរួមដំណាក់កាលទី៣ ហើយអាចជាបច្ច័យប៉ះពាល់ដល់ការគាំទ្រ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ និងការត្រៀមខ្លួន សម្រាប់ជំហានបន្ទាប់។ កត្តានេះ បណ្តាលមកពីការសម្របសម្រួលគ្រប់ក្រសួងស្ថាប័ន ពាក់ព័ន្ធមិនទាន់ឈានទៅដល់ការកំណត់សូចនាករសមិទ្ធកម្មគន្លឹះ ដែលជះឥទ្ធិពលនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅឡើយ ។ | វឌ្ឍនភាពជាមួយ អ.គ.ហ. (ឧ.ប្រសិទ្ធភាពអង្គភាពថវិកា គុណភាពផែនការយុទ្ធសាស្ត្រថវិកា...)។ |

## ៤. សេចក្តីសន្និដ្ឋាន



១៤២. រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា បានបន្តផ្តោតគោលដៅជាអាទិភាព នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ បន្ទាប់ពីការដាក់ឱ្យអនុវត្ត **«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ឆ្នាំ២០១៨-២០២៥»** និងផែនការសកម្មភាពលម្អិតនៃយុទ្ធសាស្ត្រនេះ ដែលជាស្នូលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, រាជរដ្ឋាភិបាលបានរៀបចំ និងដាក់ឱ្យអនុវត្ត **«យុទ្ធសាស្ត្រគៀរគរចំណូល ២០១៩-២០២៣»**, **«យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥»**, **«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥»** និង **«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ឆ្នាំ២០១៩-២០២៥»** រីឯផែនការសកម្មភាពលម្អិត នៃយុទ្ធសាស្ត្រទាំងបួនខាងលើ ត្រូវបានឯកភាពដាក់ឱ្យអនុវត្ត ក្នុងកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ។ យុទ្ធសាស្ត្រនីមួយៗ បានកំណត់គោលបំណង និងគោលដៅច្បាស់លាស់ សម្រាប់តម្រង់ទិសសកម្មភាពកែទម្រង់នៅក្នុងរយៈពេលមធ្យមខាងមុខ ដែលមានអគ្គនាយកដ្ឋានទទួលបន្ទុកជាអ្នករៀបចំផ្ទាល់ ក្នុងន័យធានាបាននូវភាពជាម្ចាស់ក្នុងការងារកែទម្រង់ ។

១៤៣. ខ្លឹមសារសង្ខេបនៃយុទ្ធសាស្ត្រសំខាន់ៗចំនួន ៤ ខាងលើ មានគូសបញ្ជាក់ដូចខាងក្រោម÷

(១) **យុទ្ធសាស្ត្រគៀរគរចំណូលឆ្នាំ ២០១៩-២០២៣** ÷ ការធ្វើទំនើបភាវូបនីយកម្មរដ្ឋបាល និងគោលនយោបាយចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ដើម្បីធានាការប្រមូលចំណូលប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពខ្ពស់, កែលម្អបរិយាកាសវិនិយោគ និងតម្រង់ទិសវិនិយោគ, ពង្រឹងភាពប្រកួតប្រជែង

និងជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ចជាតិ ។ គោលដៅនៃយុទ្ធសាស្ត្រ ត្រូវសម្រេចឱ្យបានការប្រមូលចំណូលចរន្តសរុបឱ្យកើនយ៉ាងតិច ០,៣ ពិន្ទុភាគរយ នៃ ផ.ស.ស. ជាមធ្យមក្នុងមួយឆ្នាំ និងបង្កើនគុណភាពសេវា និងផលិតភាពក្នុងការផ្តល់សេវាគ្រប់ប្រភេទនៃរដ្ឋបាលប្រមូលចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ។ ជាមួយគ្នានេះ អភិក្រមនៃការរៀបចំយុទ្ធសាស្ត្រ ផ្តោតលើ ៣ ចំណុច រួមមាន (១) ធានាចីរភាពកំណើនសេដ្ឋកិច្ច, (២) រក្សាចីរភាពចំណូលដែលឈានទៅដល់កម្រិតឧត្តមានុពល (Optimal Level), (៣) ធានានូវយុត្តិធម៌ក្នុងការអនុវត្តគោលនយោបាយសារពើពន្ធ និងមិនមែសារពើពន្ធ និងការប្រមូលចំណូល, (៤) ធានានូវសមធម៌សង្គម ដើម្បីចូលរួមចំណែកបន្ធូរបន្ថយបន្ទុកពន្ធដល់ប្រជាជនមានចំណូលទាប, បង្កើនសុខុមាលភាពប្រជាពលរដ្ឋ និងរក្សាការពារបរិស្ថាន ។

**(២) យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ឆ្នាំ២០១៩-២០២៥ ÷** ផ្តោតលើការបង្កើនទឹកប្រាក់សិទ្ធិសម្រេចជូនស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ និងត្រូវធ្វើឡើង ដោយផ្អែកលើលទ្ធផលនៃការវាយតម្លៃលើការអនុវត្តកិច្ចលទ្ធកម្មរបស់ស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ ដោយចាប់ផ្តើមជំហានទី១ នៅឆ្នាំ២០១៩, ជំហានទី២ នៅឆ្នាំ២០២២, និងជំហានទី៣ នៅឆ្នាំ២០២៥ នៅពេលមានគណនេយ្យភាពច្បាស់លាស់ ។ ទន្ទឹមនឹងការធ្វើវិមជ្ឈការលទ្ធកម្ម កសហវ.នឹងរៀបចំផ្ទេរមុខងារលទ្ធកម្ម (មន្ត្រីដែលមានជំនាញលទ្ធកម្មសាធារណៈ) ទៅក្នុងក្រុមអភិបាលថវិកានៅអមក្រសួង-ស្ថាប័នថ្នាក់ជាតិ ជាបណ្តើរៗ ចាប់ពីឆ្នាំ២០២២ តទៅ ។ ជាមួយគ្នានេះដែរ កសហវ. នឹងពង្រឹងយន្តការនៃការប្រមូលរបាយការណ៍ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈរបស់ស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ ក៏ដូចជាការពង្រឹងការធ្វើសវនកម្មកិច្ចលទ្ធកម្ម និងការបង្កើតឱ្យមានរបបដាក់ទោសទណ្ឌ ។

**(៣) យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១៩-២០២៥ ÷** ជាឯកសារតម្រង់ទិសដែលបានកំណត់អំពីទិសដៅ និងក្របខណ្ឌពេលវេលាច្បាស់លាស់ និងបានដាក់ចេញផែនការសកម្មភាពកែទម្រង់ដែលមានសង្គតិភាពជាមួយនឹងប្រព័ន្ធថវិកាជាតិ ដោយផ្សាភ្ជាប់នឹងអភិក្រមសាមញ្ញ ទន់ភ្លន់ តម្លាភាព និងគណនេយ្យភាព ស្របទៅតាមសមត្ថភាព និងបរិការណ៍ជាក់ស្តែងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។

**(៤) យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥÷** រាជរដ្ឋាភិបាលត្រូវបង្កើតឱ្យបាននូវប្រព័ន្ធគ្រប់គ្រងវិនិយោគសាធារណៈរួមមួយរបស់ជាតិ ដែលធានាបាននូវភាពឆ្លើយតបប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព គណនេយ្យភាព និងស្របតាមឧត្តមានុវត្តន៍ និងបរិការណ៍ និងពង្រឹងសមត្ថភាព ប្រកបដោយចីរភាពនៃការបែងចែក និងការប្រើប្រាស់ធនធានសាធារណៈស្របតាមឧត្តមានុវត្តន៍ជាអន្តរជាតិ និងបរិការណ៍ជាក់ស្តែងរបស់កម្ពុជា សំដៅរួមចំណែកបង្កើនល្បឿននៃការធ្វើពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែង ដែលជាមូលដ្ឋានគ្រឹះក្នុងការធានាបានកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព និងបរិយាបន្ន ឆ្ពោះទៅសម្រេចបង្គោលចរឆ្នាំ២០៣០ និងចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ។

១៤៤. ការពង្រឹងប្រសិទ្ធភាពការគ្រប់គ្រងការប្រមូលចំណូល និងចំណាយ, ការពង្រីក និងពង្រឹងការអនុវត្តប្រព័ន្ធ FMIS នៅតាមក្រសួង- ស្ថាប័ន និងការពង្រឹងការអនុវត្តផែនការយុទ្ធសាស្ត្រថវិកានិងថវិកាកម្មវិធី ជួបប្រទះនូវបញ្ហា-

ប្រឈមពាក់ព័ន្ធមួយចំនួន ទាំងកម្រិតស្ថាប័ន, កម្រិតបច្ចេកទេស និងការសម្របសម្រួល ដែលចាំបាច់ត្រូវបន្តពង្រឹង និងត្រួតពិនិត្យតាមដានការអនុវត្តនៅឆ្នាំ២០២០ ។

១៤៥. ការរៀបចំផែនការយុទ្ធសាស្ត្រស្តីពីការកសាង និងអភិវឌ្ឍសមត្ថភាព ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ រួមចំណែក និងដើរតួនាទីសំខាន់ ដើម្បីពង្រឹងសមត្ថភាព មន្ត្រីរាជការ ប៉ុន្តែត្រូវធ្វើវិចារណកម្ម និងអាទិភាពកម្មវិធីបណ្តុះបណ្តាល, ពង្រឹងយន្តការសម្របសម្រួល និងបង្កើតកម្មវិធីបណ្តុះបណ្តាលដោយភ្ជាប់ ជាមួយវិញ្ញាបនបត្របញ្ជាក់ការសិក្សា(Certificate Program) ។



១៤៦. ឈរនៅលើលទ្ធផលទាំងនេះ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំពុងស្ថិតនៅលើមាគ៌ា និងទិសដៅត្រឹមត្រូវ ព្រមទាំងបានជ្រើសរើសយកអភិក្រមអនុវត្ត ដែលមានភាពប្រាកដនិយម និងអាចអនុវត្តបានពិសេសផ្តល់នូវលទ្ធផលជាក់ស្តែងជាបន្តបន្ទាប់ នៅតាមដំណាក់កាលនីមួយៗ ។ ជារួម តាមរយៈវឌ្ឍនភាពដែលបាន និងកំពុងលេចរូបរាងឡើងនេះ, យើងអាចវាយតម្លៃបានថា ប្រព័ន្ធថវិកាយើងកាន់តែមានភាពជឿទុកចិត្ត និងជាឧបករណ៍សំខាន់សម្រាប់ទ្រទ្រង់ និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម, មានបុរេលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីធានាគណនេយ្យភាពហិរញ្ញវត្ថុ, មានក្របខណ្ឌថវិកាកម្មវិធីច្បាស់លាស់ ជាឧបករណ៍សម្រាប់ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល, មានមន្ត្រីកាន់តែមានសមត្ថភាពសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, មានការយល់ដឹងកាន់តែច្រើនឡើង សម្រាប់ចូលរួមអនុវត្តកម្មវិធីកែទម្រង់ និងកំពុងកសាងមូលដ្ឋានជាបណ្តើរៗ ឆ្ពោះទៅកាន់គណនេយ្យភាពសមិទ្ធកម្ម ។



# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី ១ ÷ វឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់ គ.ហ.ស.

ឧបសម្ព័ន្ធទី ២ ÷ តារាងថវិកា និងសមិទ្ធកម្ម តាមអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ឧបសម្ព័ន្ធទី ៣ ÷ តារាងថវិកា និងសមិទ្ធកម្ម តាមក្រសួង-ស្ថាប័ន

ឧបសម្ព័ន្ធទី ៤ ÷ តារាងសង្ខេបវឌ្ឍនភាពប្រចាំឆ្នាំ២០១៩

ឧបសម្ព័ន្ធទី ៥ ÷ របាយការណ៍លទ្ធផលនៃកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ឧបសម្ព័ន្ធទី ៦ ÷ របាយការណ៍លទ្ធផលនៃកិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាមួយតំណាងដៃគូអភិវឌ្ឍន៍

ឧបសម្ព័ន្ធទី ៧ ÷ របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០១៩ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ជាភាសាអង់គ្លេស)

## ឧបសម្ព័ន្ធទី ១ ÷ វឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់ គ.ហ.ស.

| ល.រ | ការសម្រេចរបស់ គ.ហ.ស. | អង្គភាពទទួលបន្ទុក | គោលដៅបញ្ចប់ | វឌ្ឍនភាព |
|---|---|---|---|---|
| *ក. ការរៀបចំផែនការសកម្មភាពលម្អិតសម្រាប់អនុវត្តយុទ្ធសាស្ត្រសំខាន់ៗ* | | | | |
| ១ | ផែនការសកម្មភាពលម្អិតសម្រាប់អនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ | GDP, GDT, GDCE, GDSPNR | ត្រ១ ២០២០ | ផែនការសកម្មភាពលម្អិត ត្រូវបានអនុម័តក្នុងកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ។ |
| ២ | ផែនការសកម្មភាពលម្អិតសម្រាប់អនុវត្តយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥ | GSC, GDICDM, GDB, GDSNAF | ត្រ ១ ២០២០ | ផែនការសកម្មភាពលម្អិត ត្រូវបានអនុម័តក្នុងកិច្ចប្រជុំនៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២០ ក្រោមការដឹកនាំរបស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ។ |
| ៣ | ផែនការសកម្មភាពលម្អិតសម្រាប់អនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥ | GDSNAF | ត្រ ១ ២០២០ | ផែនការសកម្មភាពលម្អិតត្រូវបានអនុម័តក្នុងកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ។ |
| ៤ | ផែនការសកម្មភាពលម្អិតសម្រាប់អនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ឆ្នាំ២០១៩-២០២៥ | GDPP | ត្រ ១ ២០២០ | ផែនការសកម្មភាពលម្អិត ត្រូវបានអនុម័តក្នុងកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ។ |
| ៥ | ការពិនិត្យនិងកែសម្រួលកិច្ចសន្យាជួលនិងដីសម្បទានសេដ្ឋកិច្ច | GDSPNR | ត្រ ១ ២០២០ | វិធានការនេះ ត្រូវបានដាក់បញ្ចូលក្នុងផែនការសកម្មភាព (GDAP3) ឆ្នាំ២០២០ របស់ អ.ទ.ច និងផែនការសកម្មភាព RMS ២០១៩-២០២៣ ។ |
| ៦ | ផែនការសកម្មភាពស្តីពីការកាត់បន្ថយនីតិវិធីអនុវត្តការងារ និងការគ្រប់គ្រងការផ្លាស់ប្តូរ ដែលផ្សារភ្ជាប់ជាមួយនឹងការកសាងសមត្ថភាព និងការកែសម្រួលមុខងាររបស់មន្ត្រី | FMWG<br>GDB<br>GDNT<br>GSMEF | ត្រ ១ ២០២០ | ▪ ផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារតាមប្រព័ន្ធ FMIS ២០២០-២០២៥ ត្រូវបានអនុម័តក្នុងកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ និងបានចុះហត្ថលេខាអនុម័តដ៏ខ្ពង់ខ្ពស់ ដោយ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ ។<br>▪ បានដាក់ឱ្យអនុវត្តនីតិវិធីថ្មីជាផ្លូវការលើការទូទាត់ចំណាយបៀវត្ស និងទូទាត់ចំណាយបន្ទុកបុគ្គលិកផ្សេងៗ ដែលមានគោលរបបកំណត់ច្បាស់លាស់ ស្របតាមផែនការដែលបានដាក់ចេញតាមរយៈសេចក្តីណែនាំលេខ ០០៩ សហវ ចុះពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២០ ។ |

| ល.រ | ការសម្រេចរបស់ គ.ហ.ស. | អង្គភាពទទួលបន្ទុក | គោលដៅបញ្ចប់ | វឌ្ឍនភាព |
|---|---|---|---|---|
| ៧ | ត្រួតពិនិត្យផែនការសកម្មភាពរួម ដំណាក់កាលទី៣ (CAP3) និងរៀបចំផែនការសកម្មភាពរួមដំណាក់កាលទី៤ (CAP4) | GSC | ឆ្នាំ ២០២០ | បានរៀបចំសេចក្តីព្រាងរបាយការណ៍ស្តីពីការវាយតម្លៃផែនការសកម្មភាពរួម ដំណាក់កាលទី៣ និងគ្រោងបញ្ចប់ក្នុងត្រីមាសទី២ ឆ្នាំ២០២០ ។ ផែនការសកម្មភាពរួម ដំណាក់កាលទី៤ (CAP4) ត្រូវបានរៀបចំជាសេចក្តីព្រាងមាតិកា ។ |
| ***ខ. ការរៀបចំសេចក្តីព្រាងច្បាប់*** | | | | |
| ៨ | សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ | GDSPNR, LCs | ត្រីមាស ៤ ២០១៩ | សេចក្តីព្រាងច្បាប់ គ្រោងអនុម័តត្រឹមចុងឆ្នាំ២០២១ ។ |
| ៩ | សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចាត់ចែង និងប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ | GDSPNR | - | យោងតាមចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** កាលពីថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០២០, សេចក្តីព្រាងច្បាប់នឹងរៀបចំបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី នៅចុងខែឧសភា ឆ្នាំ២០២០ ។ |
| ១០ | សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម | GDFI | - | សេចក្តីព្រាងច្បាប់បានកំណត់កាលបរិច្ឆេទកិច្ចប្រជុំជាមួយឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ កាលពីថ្ងៃទី ២១ ខែមេសា ឆ្នាំ២០២០ តែត្រូវបានលុបចោលដោយសារបញ្ហាជំងឺ covid19 ។ បច្ចុប្បន្ន ក្រុមការងារកំពុងសម្របសម្រួលស្នើសុំកាលបរិច្ឆេទថ្មី ពីទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ១១ | សេចក្តីព្រាងច្បាប់ស្តីពីយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន | PPP | ត្រីមាស ៤ ២០១៩ | វឌ្ឍនភាពចុងក្រោយ ត្រឹមថ្ងៃទី ១២ ខែឧសភា ឆ្នាំ២០២០ ÷ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានឯកភាពដាក់សេចក្តីព្រាងច្បាប់ ក្នុងកិច្ចប្រជុំផ្ទៃក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ប៉ុន្តែពុំទាន់មានការកំណត់កាលបរិច្ឆេទសម្រាប់កិច្ចប្រជុំនៅឡើយ) និងបានចង្អុលបង្ហាញឱ្យក្រុមប្រឹក្សានីតិកម្មពិនិត្យជាបឋមលើសេចក្តីព្រាងច្បាប់ មុននឹងដាក់ក្នុងកិច្ចប្រជុំផ្ទៃក្នុង ។ អង្គភាពបានធ្វើការកែសម្រួល តាមអនុសាសន៍របស់ក្រុមប្រឹក្សានីតិកម្មរួចហើយផងដែរ ។ អង្គភាពកំពុងរៀបចំស្នើសុំគោលការណ៍ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** កំណត់កាលបរិច្ឆេទកិច្ចប្រជុំផ្ទៃក្នុង ។ |
| ***គ. ការរៀបចំគោលការណ៍ណែនាំ និងឯកសារគតិយុត្ត*** | | | | |
| ១២ | សេចក្តីព្រាងគោលការណ៍ណែនាំរួមស្តីពីការគ្រប់គ្រងសេចក្តីព្រាងគោលការណ៍ណែនាំរួមស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាល | GSC | ត្រីមាស ១ ២០២០ | សេចក្តីព្រាងបឋមត្រូវបានដាក់ឆ្លងកិច្ចប្រជុំក្រុមការងារបច្ចេកទេសកាលពីថ្ងៃទី០៧ និងថ្ងៃទី១១ ខែឧសភា ឆ្នាំ ២០២០ ក្រោមការដឹកនាំផ្ទាល់ដោយឯកឧត្តមប្រធាន |

| ល.រ | ការសម្រេចរបស់ គ.ហ.ស. | អង្គភាពទទួលបន្ទុក | គោលដៅបញ្ចប់ | វឌ្ឍនភាព |
|---|---|---|---|---|
| | (PFMM) ហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាល (PFMM) | | | ក្រុមការងារ ដើម្បីពិនិត្យ ពិភាក្សា និងផ្តល់ជាធាតុចូលបន្ថែម ។ |
| ១៣ | រៀបចំនិងចាត់ចំណាត់ថ្នាក់ និងការគ្រប់គ្រងទិន្នន័យបំណុលសារពើពន្ធ និងមិនមែនសារពើពន្ធ ឱ្យបានច្បាស់លាស់ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងបំណុល | GDT, GDSPNR | ត្រម ៤ ២០១៩ | **-អពដ.** សំណុំឯកសារសហគ្រាសជំពាក់បំណុលពន្ធទូទាំងប្រទេស និងការចាត់ថ្នាក់បំណុលពន្ធជា "បំណុលពន្ធអាចប្រមូលបាន" និង "បំណុលពន្ធមិនអាចប្រមូលបាន" ត្រូវបានរៀបចំរួចរាល់ សម្រាប់ដាក់បញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រង និងប្រមូលបំណុលពន្ធដារថ្មី ។ យន្តការការងារ និងប្រព័ន្ធគ្រប់គ្រង និងប្រមូលបំណុលពន្ធដារថ្មី សម្រាប់អគ្គនាយកដ្ឋានពន្ធដារ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ។<br>**-អ.ទ.ប.** សេចក្តីព្រាងប្រកាសស្តីពីវិធាន និងនីតិវិធីនៃការតាមដាន ការតឹងទារនិងការជម្រះបញ្ជីនៃបំណុលមិនមែនសារពើពន្ធ កម្រិតនាយកដ្ឋាន ត្រូវបានរៀបចំ។ តារាងចំណាត់ថ្នាក់បំណុលមិនមែនសារពើពន្ធ នឹងរៀបចំបញ្ចប់ត្រឹមត្រីមាសទី៤ ឆ្នាំ២០២០ ។ |
| ១៤ | អនុក្រឹត្យស្តីពីការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ | GSC | ត្រម ៤ ២០១៩ | អនុក្រឹត្យ ត្រូវបានអនុម័តនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ ។ |
| ***ឃ. ការរៀបចំក្របខណ្ឌ និងឯកសារយុទ្ធសាស្ត្រសំខាន់ៗ*** | | | | |
| ១៥ | ក្របខណ្ឌ និងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ច (ទទួលបានគោលការណ៍ឯកភាពពីសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា) | GI និង GDIA | - | -រាជរដ្ឋាភិបាលចេញសេចក្តីជូនដំណឹងលេខ ៧៧២ សជណ. អ.ឆ ចុះថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ២០១៩ ប្រគល់ភារកិច្ចជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។<br>-ចេញសេចក្តីសម្រេចលេខ១៦១ សសរ ចុះថ្ងៃទី ១ ខែតុលា ឆ្នាំ២០១៩ ស្តីពីការបង្កើតក្រុមការងាររៀបចំក្របខណ្ឌ និងវិធាននៃប្រព័ន្ធសវនកម្មនិងអធិការកិច្ច (ក្រុមការងារអន្តរក្រសួង) ។<br>-បានរៀបចំប្រជុំក្រុមការងារអន្តរក្រសួង ចំនួន ៣ ដង ដើម្បីវាយតម្លៃពីតួនាទីភារកិច្ចពាក់ព័ន្ធនឹងប្រព័ន្ធសវនកម្ម និងអធិការកិច្ចនៅតាមបណ្តាក្រសួង-ស្ថាប័ន ។<br>-បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីមុខងារ ភារកិច្ច និងរបៀបរបបបំពេញការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច និងបានដាក់ប្រជុំឆ្លងក្រុមការងារអន្តរក្រសួង ។ |
| ១៦ | សេចក្តីព្រាងយុទ្ធសាស្ត្រនៃការកែទម្រង់គណនេយ្យសាធារណៈកម្ពុជា ឆ្នាំ ២០១៩-២០៣១ | NAC | ត្រម ៤ ២០១៩ | សេចក្តីព្រាងយុទ្ធសាស្ត្រ ត្រូវបានដាក់ប្រជុំពិគ្រោះយោបល់ជាមួយអង្គភាពពាក់ព័ន្ធរួចរាល់ក្នុងខែមករា និងគ្រោងបញ្ចប់ក្នុងឆ្នាំ២០២០ ។ |

| ល.រ | ការសម្រេចរបស់ គ.ហ.ស. | អង្គភាពទទួលបន្ទុក | គោលដៅបញ្ចប់ | វឌ្ឍនភាព |
|---|---|---|---|---|
| ១៧ | សេចក្ដីព្រាងផែនការយុទ្ធសាស្ត្រស្ដីពីការកសាង និងអភិវឌ្ឍសមត្ថភាព ក្នុងក្របខណ្ឌ PFMRP ដំណាក់កាលទី ៤ (SCDP4) | EFI | តម ៤ ២០១៩ | សេចក្ដីព្រាង SCDP4 បានដាក់ពិគ្រោះយោបល់ និងកែលម្អនៅក្នុងសិក្ខាសាលាពិគ្រោះយោបល់នាថ្ងៃទី២៧ ខែធ្នូ ឆ្នាំ ២០១៩ ដោយមានការចូលរួមពីគ្រប់អង្គភាពក្រោមឱវាទ កសហវ, ក្រសួង-ស្ថាប័ន, មន្ទីរសហវ. និង រតនាគារខេត្ត ដើម្បីផ្ដល់ធាតុចូលបន្ថែម ។ |
| ***ង. ការវាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងមូលនិធិ PFMRP*** | | | | |
| ១៨ | វាយតម្លៃក្របខណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA) ថ្នាក់ជាតិ ឆ្នាំ២០២០ | GSC | តម ២ ២០២០ | ▪ បានរៀបចំសមាសភាពក្រុមការងារវាយតម្លៃ ដោយទទួលបានការឯកភាពដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី**<br>▪ បញ្ចប់ការរៀបចំឯកសារទស្សនាទាន និងបានផ្ញើជូនលេខាធិការដ្ឋាន PEFA<br>▪ បានបញ្ចប់ការរៀបចំជាសេចក្ដីព្រាងរបាយការណ៍បឋម (Zero Draft) និងកំពុងពិនិត្យ និងពិភាក្សាកម្រិតក្រុមការងារតាមសរសរស្តម្ភនីមួយៗ ។ |
| ១៩ | វាយតម្លៃក្របខណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA) ថ្នាក់ក្រោមជាតិ ឆ្នាំ២០២០ | GSC | តម ១ ២០២០ | បានរៀបចំជាសេចក្ដីព្រាង និងកំពុងផ្ទៀងផ្ទាត់ទិន្នន័យជាមួយជំនាញការមុនផ្ញើជូនលេខាធិការដ្ឋាន PEFA ពិនិត្យលើគុណភាព ។ |
| ២០ | រៀបចំមូលនិធិ PFMRP គ្រប់ជ្រុងជ្រោយសម្រាប់គាំទ្រកម្មវិធីកែទម្រង់ឱ្យអនុវត្តប្រកបដោយជោគជ័យ និងចីរភាព | GSC | តម ៤ ២០២០ | បាននិងកំពុងសិក្សាអំពីការរៀបចំ ហើយនឹងជំរុញការងារនេះបញ្ចប់ក្នុងត្រីមាសទី៤ ឆ្នាំ២០២០ ខាងមុខនេះ។ |

## ឧបសម្ព័ន្ធទី ២ ÷ តារាងថវិកា និងសមិទ្ធកម្ម តាមអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

| ល.រ. | អង្គភាពក្រោមឱវាទ កសហវ | ថវិកាឆ្នាំ២០១៩ | | | | សកម្មភាពសម្រេចបាន | វឌ្ឍនភាពប្រចាំឆ្នាំ២០១៩ |
|---|---|---|---|---|---|---|---|
| | | ថវិកាអនុវត្ត PFMRP | ឧបត្ថម្ភលើកទឹកចិត្ត PFM | ឧបត្ថម្ភលើកទឹកចិត្តក្រៅ PFM | ថវិកាសរុប | | |
| ១ | អគ្គនាយកដ្ឋានគោលនយោបាយ | 736,743,638 | 945,143,600 | | 1,681,887,238 | 18/18 | 100% |
| ២ | អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | 577,124,118 | - | - | 577,124,118 | 15/17 | 98% |
| ៣ | អគ្គនាយកដ្ឋានពន្ធដារ | 674,991,254 | - | - | 674,991,254 | 24/32 | 98% |
| ៤ | អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ | 284,409,837 | - | - | 284,409,837 | 10/15 | 94% |
| ៥ | អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ | 35,109,590 | - | - | 35,109,590 | 5/6 | 94% |
| ៦ | អគ្គនាយកដ្ឋានថវិកា | 550,368,672 | 645,559,200 | 317,214,400 | 1,513,142,272 | 68/73 | 98% |
| ៧ | អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ | 643,023,827 | 356,519,800 | - | 999,543,627 | 30/46 | 97% |
| ៨ | អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល | 1,012,685,764 | - | - | 1,012,685,764 | 11/12 | 99% |
| ៩ | អគ្គនាយកដ្ឋានរតនាគារជាតិ | 330,552,869 | 532,243,200 | 840,000,000 | 1,702,796,069 | 33/33 | 100% |
| ១០ | អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ | 501,067,559 | 193,739,200 | - | 694,806,759 | 11/14 | 97% |
| ១១ | អគ្គលេខាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | 171,095,200 | 644,913,200 | 2,222,688,400 | 3,038,696,800 | 27/34 | 95% |
| ១២ | អគ្គាធិការដ្ឋាន | 504,767,304 | 261,079,000 | - | 765,846,304 | 15/19 | 98% |
| ១៣ | អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង | 48,231,040 | 1,140,174,800 | 126,033,600 | 1,314,439,440 | 18/20 | 95% |
| ១៤ | វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | 179,633,166 | 299,485,600 | 455,794,800 | 934,913,566 | 10/12 | 95% |
| ១៥ | ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | 20,711,016,952 | 2,805,780,800 | - | 23,516,797,752 | 18/23 | 98% |
| ១៦ | លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម | 371,566,399 | 599,526,000 | - | 971,092,399 | 8/9 | 99% |
| ១៧ | អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគណនេយ្យ | 331,526,145 | 101,608,200 | 372,415,200 | 805,549,545 | 4/4 | 100% |
| ១៨ | អង្គភាពភាពជាដៃគូរវាងរដ្ឋ និងឯកជនថ្នាក់កណ្តាល | - | 223,557,800 | - | 223,557,800 | 0/4 | 78% |

## ឧបសម្ព័ន្ធទី ៣ ÷ តារាងថវិកា និងសមិទ្ធកម្ម តាមក្រសួង-ស្ថាប័ន

| ល.រ | ក្រសួង-ស្ថាប័ន | ថវិកាឆ្នាំ២០១៩ | | | ចំនួនសកម្មភាពសម្រេចបាន | វឌ្ឍនភាពប្រចាំឆ្នាំ ២០១៩ (%) |
|---|---|---|---|---|---|---|
| | | ថវិកាអនុវត្ត PFMRP | ប្រាក់ឧបត្ថម្ភលើកទឹកចិត្ត PFM | ថវិកាសរុប | | |
| **ស្ថាប័នសេវាសេដ្ឋកិច្ច** | | | | | | |
| ១ | រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | 109,756,087.00 | 141,600,000 | **251,356,087.00** | 23/29 | 90% |
| ២ | ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | 107,911,260.00 | 141,600,000 | **249,511,260.00** | 17/18 | 98% |
| ៣ | ក្រសួងរ៉ែ និងថាមពល | 107,964,260.00 | 141,600,000 | **249,564,260.00** | 10/10 | 100% |
| ៤ | ក្រសួងពាណិជ្ជកម្ម | 31,613,100.00 | 141,600,000 | **173,213,100.00** | 32/37 | 99% |
| ៥ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ | 132,131,923.55 | 141,600,000 | **273,731,923.55** | 28/39 | 94% |
| ៦ | ក្រសួងអភិវឌ្ឍន៍ជនបទ | 133,830,107.95 | 141,600,000 | **275,430,107.95** | 30/30 | 100% |
| ៧ | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | 126,459,760.00 | 141,600,000 | **268,059,760.00** | 16/22 | 98% |
| ៨ | ក្រសួងសាធារណៈការនិងដឹកជញ្ជូន | 315,085,958.00 | 123,600,000 | **438,685,958.00** | 44/52 | 87% |
| ៩ | ក្រសួងទេសចរណ៍ | 47,129,408.00 | 141,600,000 | **188,729,408.00** | 22/27 | 88% |
| ១០ | ក្រសួងធនធានទឹកនិងឧតុនិយម | 214,388,031.55 | 141,600,000 | **355,988,031.55** | 9/13 | 98% |
| ១១ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | 193,636,985.85 | 141,600,000 | **335,236,985.85** | 26/28 | 99% |
| **ស្ថាប័នសេវាហិរញ្ញវត្ថុ ការបរទេស និងសេវាសាធារណៈ** | | | | | | |
| ១ | ទីស្តីការគណៈរដ្ឋមន្ត្រី | 20,409,920.00 | 105,600,000 | **126,009,920.00** | 7/14 | 94% |
| ២ | ក្រសួងមុខងារសាធារណៈ | 137,614,770.00 | 145,200,000 | **282,814,770.00** | 17/17 | 100% |
| ៣ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | 17,326,080.00 | 141,600,000 | **158,926,080.00** | 30/30 | 100% |
| ៤ | ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | 101,937,800.00 | 129,600,000 | **231,537,800.00** | 18/18 | 100% |
| ៥ | ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | 161,356,536.00 | 141,600,000 | **302,956,536.00** | 20/21 | 98% |
| ៦ | ក្រសួងព័ត៌មាន | 111,623,728.00 | 105,600,000 | **217,223,728.00** | 13/16 | 92% |
| ៧ | ក្រសួងផែនការ | 289,620,675.00 | 141,600,000 | **431,220,675.00** | 26/27 | 98% |
| ៨ | គណៈកម្មការមូលបត្រកម្ពុជា | 158,828,552.00 | 105,600,000 | **264,428,552.00** | 11/11 | 100% |

| ល.រ | ក្រសួង-ស្ថាប័ន | ថវិកាឆ្នាំ២០១៩ | | | ចំនួនសកម្មភាពសម្រេចបាន | វឌ្ឍនភាពប្រចាំឆ្នាំ ២០១៩ (%) |
|---|---|---|---|---|---|---|
| | | ថវិកាអនុវត្ត PFMRP | ប្រាក់ឧបត្ថម្ភលើក-ទឹកចិត្ត PFM | ថវិកាសរុប | | |
| ស្ថាប័នការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ | | | | | | |
| ១ | ក្រសួងការពារជាតិ | 88,235,243.00 | 119,100,000 | **207,335,243.00** | 23/24 | 99% |
| ២ | ក្រសួងមហាផ្ទៃ-ផ្នែករដ្ឋបាលទូទៅ | 134,652,572.00 | 141,600,000 | **276,252,572.00** | 29/29 | 100% |
| ៣ | ក្រសួងមហាផ្ទៃ-សន្តិសុខសង្គម | 136052930 | 142,800,000 | **278,852,930.00** | 19/21 | 98% |
| ៤ | ក្រសួងបរិស្ថាន | 117,185,120.00 | 117,600,000 | **234,785,120.00** | 22/22 | 100% |
| ៥ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | - | 105,600,000 | **105,600,000.00** | 20/23 | 99% |
| ស្ថាប័នសង្គមកិច្ច | | | | | | |
| ១ | ក្រសួងសុខាភិបាល | 103,331,351.00 | 141,600,000 | **244,931,351.00** | 15/15 | 100% |
| ២ | ក្រសួងអប់រំ យុវជន និងកីឡា | 140,581,210.00 | 141,600,000 | **282,181,210.00** | 26/28 | 98% |
| ៣ | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | 117,134,000.00 | 141,600,000 | **258,734,000.00** | 21/22 | 97% |
| ៤ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | 108,839,838.00 | 102,000,000 | **210,839,838.00** | 16/17 | 99% |
| ៥ | ក្រសួងធម្មការ និងសាសនា | 120,853,404.00 | 93,600,000 | **214,453,404.00** | 9/17 | 99% |
| ៦ | ក្រសួងកិច្ចការនារី | 123,878,488.00 | 117,600,000 | **241,478,488.00** | 13/14 | 99% |
| ស្ថាប័នកំពូល និងឯករាជ្យ | | | | | | |
| ១ | ក្រសួងព្រះបរមរាជវាំង | - | 117,600,000 | **117,600,000.00** | 13/13 | 100% |
| ២ | អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ | 71,400,420.00 | 81,600,000 | **153,000,420.00** | 8/8 | 100% |
| ៣ | អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា | 110977344 | 117,600,000 | **228,577,344.00** | 7/7 | 100% |
| ៤ | អគ្គលេខាធិការដ្ឋានរដ្ឋសភា | 41,071,050.00 | 105,600,000 | **146,671,050.00** | 1/10 | 10% |
| ៥ | អគ្គលេខាធិការដ្ឋានសាលាឧទ្ធរណ៍ | - | 75,600,000 | **75,600,000.00** | 3/3 | 100% |
| ៦ | អគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សាអង្គចៅក្រម | 71400420 | 81,600,000 | **153,000,420.00** | 5/6 | 95% |
| ៧ | គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | 85,141,100.00 | 81,600,000 | **166,741,100.00** | 7/7 | 100% |
| ៨ | អាជ្ញាធរសវនកម្មជាតិ | 285,302,086.50 | 141,600,000 | **426,902,086.50** | 26/28 | 98% |
| ៩ | អង្គភាពប្រឆាំងអំពើពុករលួយ | 90,551,602.00 | 141,600,000 | **232,151,602.00** | 8/10 | 97% |
| ១០ | អគ្គលេខាធិការដ្ឋានតុលាការកំពូល | 35185338 | 57,600,000 | **92,785,338.00** | 10/10 | 100% |
| ១១ | ក្រសួងយុត្តិធម៌ | 39018760 | 105,600,000 | **144,618,760.00** | 24/26 | 95% |

## ឧបសម្ព័ន្ធទី ៤ ÷ តារាងសង្ខេបវឌ្ឍនភាពប្រចាំឆ្នាំ២០១៩

| ល.រ. | គោលបំណង/ចង្កោមសកម្មភាព | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | ទម្ងន់ | វឌ្ឍន-ភាព % | ពិន្ទុ ថ្លឹង | វឌ្ឍនភាពសំខាន់ៗ |
|---|---|---|---|---|---|---|---|
| *ពិន្ទុរួមផែនការសកម្មភាពរួម ដំណាក់កាលទី ៣ (ផ្នែកទី១ + ទី២ + ទី៣ + ទី៤ + ទី៥)* | | | | | ៩៨% | | - |
| ផ្នែកទី១ ÷ បន្តពង្រឹងភាពជឿទុកចិត្តបាននៃថវិកា | | | | ០.១៥ | ៩៧% | ១៥% | - |
| **១១** | **បន្តពង្រឹងការគ្រប់គ្រងចំណូល និងការអនុវត្តផែនការប្រមូលចំណូល** | - | **១. ការអនុវត្តចំណូលប្រចាំត្រីមាស មានភាពរលូននិងអាចប៉ាន់ស្មានបាន (កម្រិតលម្អៀង+/-៥%)**<br>**២. ការប្រមូលចំណូលចរន្តធៀប ផ.ស.ស ត្រូវបានបង្កើនយ៉ាងហោចណាស់ ០,៣ ពិន្ទុភាគរយនៃ ផសស ប្រចាំឆ្នាំ** | ០.៤០ | **៩៧%** | ៣៩% | **១. ការអនុវត្តចំណូលសម្រេចបាន ១៣១.០% ធៀបនឹងច្បាប់ថវិកា**<br>**២. ការប្រមូលចំណូលធៀបនឹង ផសស មានកំណើន ៣.១៨%** |
| ១១.១ | ពង្រឹងការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ | - អគ្គ. គោលន/ប<br>- អគ្គ. គយ<br>- អគ្គ. ពន្ធដារ<br>- អគ្គ. ឧ.ហ<br>- អគ្គ. ទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ<br>- ក្រសួង-ស្ថាប័ន | ១. យុទ្ធសាស្ត្រកៀរគរចំណូល២០១៩-២០២៣ ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត<br>២. យន្តការតាមដាន និងវាយតម្លៃ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត<br>៣.របាយការណ៍ពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលត្រូវបានរៀបចំ | ០.២០ | ៩៨% | ១៩% | ១. យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត ។<br>២. យន្តការតាមដាន និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ ត្រូវបានរៀបចំ ។<br>៣. របាយការណ៍វាយតម្លៃលើការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមសម្រាប់រយៈពេល ៥ ឆ្នាំ (២០១៤-២០១៨) ត្រូវបានរៀបចំ ។ កំណើនជាមធ្យម ១.៤ ពិន្ទុភាគរយនៃ ផសស ។ |
| ១១.២ | បន្តកែលម្អគោលនយោបាយ និងរដ្ឋបាលគយ, ពន្ធដារ និងចំណូលមិនមែនសារពើពន្ធ | -អគ្គ. គោលន/ប<br>-អគ្គ. គយ<br>-អគ្គ. ពន្ធដារ<br>-អគ្គ. ទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ | ១. ស្តង់ដាសេវានៃការបង់ និងប្រមូលចំណូលត្រូវបានកែលម្អ និងអនុវត្ត<br>២. យន្តការផ្តល់សេវាបង់ចំណូល (បញ្ជរពិគ្រោះយោបល់) ត្រូវបានពង្រឹង<br>៣. ការអង្កេតលើគុណភាពសេវានៃការប្រមូលចំណូលពន្ធគយ ពន្ធដារ និងចំណូលមិន- | ០.២០ | ៩៤% | ១៩% | ១. របាយការណ៍ស្តីពីការវាយតម្លៃលើផលប៉ះពាល់នៃការចរចា និងការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន (ATIGA) ត្រូវបានរៀបចំ ។<br>២. បានរៀបចំសំណើមួយចំនួនរួមមាន (១) សំណើកែ-សម្រួលអត្រាអាករពិសេសលើមុខទំនិញបារី, (២) លិខិតអនុវត្តការបញ្ចុះអត្រាអាករនាំចេញលើមុខ |

| ល.រ. | គោលបំណង/ចង្កោមសកម្មភាព | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | ទម្ងន់ | វឌ្ឍន-ភាព % | ពិន្ទុថ្លឹង | វឌ្ឍនភាពសំខាន់ៗ |
|---|---|---|---|---|---|---|---|
| | | -អគ្គ.ឌ.ហ<br>-ក្រសួង-ស្ថាប័ន | មែនសារពើពន្ធ ត្រូវបានរៀបចំ និងអនុវត្ត | | | | ទំនិញប្រភេទឈើដាំ និងវត្ថុធ្វើពីឈើដាំ, (៣) សំណើបញ្ចុះអត្រាពន្ធគយ និងអត្រាអាករពិសេសរបស់សហគ្រាសធុនតូចនិងមធ្យម ទន្ទឹមនឹងការកែ-សម្រួលអត្រាពន្ធអាករ ដើម្បីប៉ះប៉ូវការបាត់បង់ចំណូលលើមុខទំនិញចំនួន ២៤៩ បន្ទាត់ពន្ធ ។<br>៣. សេចក្តីព្រាងអនុក្រឹត្យស្តីពីចំណាយ និងទាយជ្ជទានសម្រាប់គណនាប្រាក់ចំណូលជាប់ពន្ធរបស់រូបវន្តបុគ្គល (Personal Income Tax) ត្រូវបានរៀបចំពិនិត្យ និងបន្តកែសម្រួល កម្រិតអគ្គនាយកដ្ឋានពន្ធដារ ។<br>៤. មន្ទីរជំនាញចំនួន ៣ ទាំង២៥ រាជធានី-ខេត្ត ដែលមានចំនួនសរុប ៧៥ មន្ទីរជំនាញ ត្រូវបានរៀបចំ និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ។<br>៥. សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រូវបានបញ្ចប់ការតាក់តែង និងដាក់ឆ្លងយោបល់ពីក្រុមប្រឹក្សានីតិកម្ម ។<br>៦. សេចក្តីព្រាងច្បាប់នេះត្រូវបានបញ្ជូនពីទីស្តីការគណៈរដ្ឋមន្ត្រីមកក្រសួងយុត្តិធម៌និង.កសហវវិញដើម្បីពិនិត្យផ្នែកទោសបញ្ញត្តិឱ្យបានគ្រប់ជ្រុងជ្រោយបន្ថែមទៀត ។ |
| ១១.៣ | ពង្រឹងការវិភាគ និងការព្យាករចំណូល | - អគ្គ.គោលន/ប<br>- អគ្គ.គយ<br>- អគ្គ.ពន្ធដារ<br>- អគ្គ.ឌ.ហ<br>- អគ្គ.ទ្រព្យ.&ច | ១. ផែនការចំណូលប្រចាំឆ្នាំធៀបនឹងការអនុវត្តក្នុងរង្វង់ +/-៥%<br>២. ការព្យាករចំណូលប្រចាំឆ្នាំធៀបនឹងការអនុ-វត្តក្នុងរង្វង់ +/-៥%<br>៣. ម៉ូដែលព្យាករណ៍ចំណូលពន្ធនៅថ្នាក់អគ្គ- | ០.២០ | ១០០% | ២០% | ១. ការអនុវត្តចំណូលសម្រេចបាន ១៣១.០% ធៀបនឹងច្បាប់ថវិកា ។<br>២. គំរូព្យាករណ៍ចំណូលគយមួយត្រូវបានដាក់ឱ្យអនុវត្តសាកល្បង (ជ្រើសរើសវិធីសាស្ត្រ Buoyancy សម្រាប់ធ្វើការសាកល្បង) ។ |

| ល.រ. | គោលបំណង/ចង្កោមសកម្មភាព | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | ទម្ងន់ | វឌ្ឍន-ភាព % | ពិន្ទុថ្លឹង | វឌ្ឍនភាពសំខាន់ៗ |
|---|---|---|---|---|---|---|---|
| | | - ក្រសួង-ស្ថាប័ន | នាយកដ្ឋានត្រូវបានកែលម្អ | | | | |
| ១១.៤ | ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងបំណុលក្នុងឆ្នាំ | - អគ្គ. ពន្ធដារ<br>- អគ្គ. គយ<br>- អគ្គ. ទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ<br>- អគ្គ. ឧស្សាហកម្មហិរញ្ញវត្ថុ<br>-ក្រសួង- ស្ថាប័ន | ១. ឯកសារបំណុលពន្ធទាំងអស់នៅទូទាំងប្រទេសត្រូវបានកសាង<br>២. បំណុលពន្ធត្រូវបានចាត់ថ្នាក់ជាបំណុលអាចប្រមូលបាន និងមិនអាចប្រមូលបាន<br>៣. ទិន្នន័យបំណុលពន្ធត្រូវបានរៀបចំ និងដាក់ក្នុងប្រព័ន្ធគ្រប់គ្រង និងប្រមូលបំណុលពន្ធ<br>៤. បំណុលសារពើពន្ធ និងមិនមែនសារពើពន្ធសរុប ត្រូវបានរៀបចំចំណាត់ថ្នាក់ទៅតាមប្រភេទ ឬអាយុកាល | ០.២០ | ៩៧% | ១៩% | ១. សំណុំឯកសារសហគ្រាសជំពាក់បំណុលពន្ធទូទាំងប្រទេស និងការចាត់ថ្នាក់បំណុលពន្ធជា “បំណុលពន្ធអាចប្រមូលបាន” និង “បំណុលពន្ធមិនអាចប្រមូលបាន” ត្រូវបានរៀបចំរួចរាល់ សម្រាប់ដាក់ បញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រង និងប្រមូលបំណុលពន្ធដារថ្មី ។<br>២. តួលេខបំណុលពន្ធនិងអាករប្រចាំឆ្នាំ២០១៨ ត្រូវបានកំណត់ ។<br>៣. យន្តការការងារ និងប្រព័ន្ធគ្រប់គ្រង និងប្រមូលបំណុលពន្ធដារថ្មី សម្រាប់អគ្គនាយកដ្ឋានពន្ធដារត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ។<br>៤. ក្រុមការងារបំណុលវិស័យអាកាសចរស៊ីវិល, វិស័យកសិកម្ម និងវិស័យរ៉ែ បន្តនីតិវិធីគ្រប់គ្រងបំណុល ដូចជាតឹងទារ បំណុល និងជំរុញការអនុវត្តអនុក្រឹត្យលេខ៧២ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។ |
| ១១.៥ | អនុវត្តការប្រមូលចំណូលផ្ទាល់/ចំណូលចែករំលែករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | អគ្គ. ហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោម-ជាតិ | ១. យន្តការ និងនីតិវិធីនៃការបែងចែកប្រាក់រង្វាន់ដែលប្រមូលតាមច្រកចេញចូលតែមួយរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវបានរៀបចំ<br>២. យន្តការ និងនីតិវិធីនៃការបែងចែកចំណូលដែលប្រមូលតាមច្រកចេញចូលតែមួយរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវបានរៀបចំ | ០.២០ | ៩៧% | ១៩% | ១. របាយការណ៍សិក្សាលទ្ធភាពនៃការបង្កើនធនធានថវិកាជូនរដ្ឋបាលឃុំ សង្កាត់ត្រូវបានរៀបចំរួច និងដាក់ជូនថ្នាក់ដឹកនាំពិនិត្យ និងសម្រេច ។<br>២. អនុក្រឹត្យស្តីពីការបង្កើនធនធានថវិកាជូនរដ្ឋបាលឃុំសង្កាត់សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន ត្រូវបានរៀបចំរួច និងដាក់ឲ្យអនុវត្ត ។<br>៣. សេចក្តីព្រាងយន្តការនិងនីតិវិធី/អនុក្រឹត្យនៃការបែង-ចែកប្រាក់រង្វាន់ដែលប្រមូលតាមច្រកចេញចូលតែមួយរវាងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ត្រូវបានដាក់ប្រជុំ |

| ល.រ. | គោលបំណង/ចង្កោមសកម្មភាព | ក្រសួង-ស្ថាប័ន/ អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | ទម្ងន់ | វឌ្ឍន-ភាព % | ពិន្ទុទទួល | វឌ្ឍនភាពសំខាន់ៗ |
|---|---|---|---|---|---|---|---|
| | | | | | | | ពិភាក្សាជាមួយអ្នកពាក់ព័ន្ធ ។<br>៤. អនុក្រឹត្យស្តីពីការបង្កើនធនធានថវិកាជូនរដ្ឋបាលឃុំសង្កាត់ សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋានត្រូវបានផ្សព្វផ្សាយ ។ |
| **១២** | **បន្តពង្រឹងការគ្រប់គ្រងបំណុល** | - | **១. យុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈឆ្នាំ ២០១៩-២០២៣ ត្រូវបានរៀបចំ**<br>**២. យុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍទីផ្សារមូលបត្ររដ្ឋនៅកម្ពុជា ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត** | **០.១០** | **៩០%** | **៩%** | **១. យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩-២០២៣ ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត ។**<br>**២. ឯកសារយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍទីផ្សារមូលបត្ររដ្ឋនៅកម្ពុជា ត្រូវបានរៀបចំកម្រិតបឋម ។** |
| ១២.១ | ពង្រឹងការអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ ប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព | - អគ្គ.សហប្រតិបត្តិ-ការអន្តរជាតិ និងគ្រប់គ្រងបំណុល<br>- អគ្គ.ឧស្សាហកម្មហិរញ្ញវត្ថុ | ១. យុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈឆ្នាំ ២០១៩-២០២៣ ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត<br>២. អនុបាតបំណុលសំខាន់ៗទាំង៤ ស្ថិតក្រោមអនុបាតគោល<br>៣. យុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍទីផ្សារមូលបត្ររដ្ឋនៅកម្ពុជា ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត<br>៤. មូលបត្ររដ្ឋ នឹងត្រូវបានបោះផ្សាយ | ១.០០ | ៩០% | ៩% | ១. យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩-២០២៣ ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត ។<br>២. ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈ ត្រូវបានបោះផ្សាយ ។<br>៣. ឯកសារយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍន៍ទីផ្សារមូលបត្រ-រដ្ឋនៅកម្ពុជា ត្រូវបានរៀបចំកម្រិតបឋម ។<br>៤. របាយការណ៍ស្តីពីការវាយតម្លៃប្រតិបត្តិការនៃការគ្រប់-គ្រងបំណុលសាធារណៈ ត្រូវបានអនុម័ត ។<br>៥ នីតិវិធីរួមប្រតិបត្តិការសម្រាប់ការគ្រប់គ្រងបំណុលសាធា-រណៈ(SOP for PDM) ត្រូវបានតាមដាន និងត្រួតពិនិត្យ ។ |
| **១៣** | **ពង្រឹងការគ្រប់គ្រងសាច់ប្រាក់ និងគណនី** | | **១. ក្រសួង ស្ថាប័ន ចំនួន ៣០ បានប្រើប្រាស់ប្រព័ន្ធផែនការសាច់ប្រាក់**<br>**២. បំណុលកកស្ទះត្រូវកម្រិតមិនឱ្យលើសពី ២ %នៃចំណាយសរុប**<br>**៣. ពង្រឹង និងពង្រីកការអនុវត្តប្រព័ន្ធទូទាត់ EFT** | **០.២០** | **១០០** | **២០%** | **១. ប្រព័ន្ធ Online Web-based Application ត្រូវបានប្រើ-ប្រាស់សាកល្បងបន្ត ជាមួយក្រសួង ស្ថាប័នទាំង៣០ ។**<br>**២. គ្មានបំណុលកកស្ទះ ។**<br>**៣. ការទូទាត់តាមប្រព័ន្ធ E-Transfer ត្រូវបានរៀបចំ និងអនុវត្ត ។** |

| ល.រ. | គោលបំណង/ចង្កោមសកម្មភាព | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | ទម្ងន់ | វឌ្ឍន-ភាព % | ពិន្ទុ ទ្ទីង | វឌ្ឍនភាពសំខាន់ៗ |
|---|---|---|---|---|---|---|---|
| ១៣.១ | បន្តកែលម្អ និងពង្រឹងការរៀបចំផែនការសាច់ប្រាក់ (ចាប់ផ្តើមពីប្រចាំត្រីមាស/ ប្រចាំខែ និងឈានទៅរកការរៀបចំផែនការសាច់ប្រាក់ប្រចាំសប្តាហ៍និងប្រចាំថ្ងៃ) | អគ្គ.រតនាគារជាតិ | ក្រសួង ស្ថាប័ន ចំនួន ៣០ បានប្រើប្រាស់ប្រព័ន្ធផែនការសាច់ប្រាក់ | ០.៣០ | ១០០% | ៣០% | ១. ប្រព័ន្ធ Online Web-based Application ត្រូវបានប្រើ-ប្រាស់សាកល្បងបន្ត ជាមួយក្រសួង ស្ថាប័នទាំង៣០ ។<br>២. តួលេខដែលក្រសួង ស្ថាប័ន បានបញ្ចូលតាមប្រព័ន្ធ Web-based Application ត្រូវបានត្រួតពិនិត្យផ្ទៀង-ផ្ទាត់និងតាមដាន ។<br>៣. សាកល្បងអនុវត្តការធ្វើផែនការសាច់ប្រាក់ប្រចាំត្រីមាសដោយផ្អែកលើទិន្នន័យពីប្រព័ន្ធ Web-based Application ។ |
| ១៣.២ | បន្តពង្រឹងការប្រើប្រាស់ប្រព័ន្ធធនាគារព្រមទាំងសិក្សា និងពង្រឹង និងពង្រីកអនុវត្តការទូទាត់តាមប្រព័ន្ធ EFT (Electronic Fund Transfer) | អគ្គ.រតនាគារជាតិ | ១. បន្តពង្រឹងការប្រើប្រាស់ប្រព័ន្ធធនាគារ<br>២. ពង្រឹង និងពង្រីកការអនុវត្ត EFT | ០.៣០ | ១០០% | ៣០% | ១. ការបើកផ្តល់តាមប្រព័ន្ធធនាគារ ត្រូវបានអនុវត្តទូទាំងប្រទេស ។<br>២. ការទូទាត់តាមប្រព័ន្ធ E-Transfer ត្រូវបានរៀបចំនិងអនុវត្ត ។<br>៣. ទូទាត់ប្រាក់បៀវត្សមន្ត្រីរាជការស៊ីវិល ទូទាំងប្រទេសតាមប្រព័ន្ធធនាគារ ២ ដង/១ខែ ឱ្យបានទៀងទាត់និងទាន់ពេលវេលា ។ |
| ១៣.៣ | រៀបចំយន្តការប្រមូលផ្តុំ និងបូក-សរុបរបាយការណ៍អនុវត្តថវិកាគម្រោងរបស់ដៃគូអភិវឌ្ឍន៍ដែលនៅក្រៅប្រព័ន្ធរតនាគារជាជំហានៗ និងបន្តពង្រឹងគណនីទោលរតនាគារ | អគ្គ.រតនាគារជាតិ<br>អគ្គ.ទ្រព្យ-សម្បត្តិរដ្ឋ | ផ្សព្វផ្សាយដល់អង្គភាពដែលអនុវត្តថវិកាដៃគូអភិវឌ្ឍន៍រៀបចំរបាយការណ៍តាមប្លង់គណនេយ្យថវិកា (CoA) របស់រដ្ឋាភិបាល | ០.២០ | ១០០% | ២០% | ក្រសួងសុខាភិបាលបានអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិកា (CoA) ថ្មីសម្រាប់គម្រោង/ កម្មវិធីហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ។ |
| ១៣.៤ | បន្តតាមដានបំណុលកកស្ទះ និងអាយុកាលរបស់វា (រយៈពេល៦០ថ្ងៃ) | អគ្គ.រតនាគារជាតិ | បំណុលមិនលើស ២% នៃចំណាយសរុប | ០.១០ | ១០០% | ១០% | គ្មានបំណុលកកស្ទះ ។ |

| ល.រ. | គោលបំណង/ចង្កោមសកម្មភាព | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | ទម្ងន់ | វឌ្ឍន-ភាព % | ពិន្ទុ ទ្បីង | វឌ្ឍនភាពសំខាន់ៗ |
|---|---|---|---|---|---|---|---|
| ១៣.៥ | ពន្លឿនការទូទាត់បុរេប្រទានឱ្យបានទាន់ពេលវេលា | - អគ្គ. ថវិកា<br>- អគ្គ. រតនាគារជាតិ | ថវិកាបុរេប្រទានត្រូវបានទូទាត់ទាន់ពេលវេលា | ០.១០ | ១០០% | ១០% | របាយការណ៍ផ្តល់ និងទូទាត់បុរេប្រទានប្រចាំឆ្នាំត្រូវបានបូកសរុប ។ |
| **១៤** | **កែលម្អការអនុវត្តថវិកា និងពង្រឹងការអនុវត្តផែនការចំណាយ** | - | **ស្ថានភាពចំណាយមិនត្រូវតិចជាង ÷ត្រីមាសទី ១ : ១៥%, ត្រីមាសទី ២: ៤៥%, ត្រីមាសទី ៣: ៦៧% និងត្រីមាសទី ៤: ៩៦%** | **០.៣០** | **៩៦%** | **២៩%** | **ចំណាយថវិកាថ្នាក់ជាតិសម្រេចបាន ៩៥.៤៣% ធៀបនឹងច្បាប់ថវិកា ។** |
| ១៤.១ | ពិនិត្យឡើងវិញ និងកែលម្អប្រព័ន្ធលទ្ធកម្មសាធារណៈឱ្យស្របនឹងយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកាជាតិ | - អគ្គ. លទ្ធកម្ម<br>- អគ្គ. សហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល<br>- អគ្គ. ហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ<br>- អគ្គ. ថវិកា | ១. យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈត្រូវបានដាក់ឱ្យអនុវត្ត<br>២. ផែនការសកម្មភាពលម្អិតសម្រាប់អនុវត្តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៨-២០២៥ ត្រូវបានរៀបចំ<br>៣. ប្រកាសស្តីពីការបង្កើនសិទ្ធិសម្រេច និងការទទួលខុសត្រូវលើកិច្ចលទ្ធកម្មជាបណ្តើរៗជូនក្រសួងស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពសាធារណៈប្រហាក់ប្រហែល | ០.៣០ | ៩៩% | ២៩% | ១. យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធ លទ្ធកម្មសាធារណៈ ២០១៩-២០២៥ ត្រូវបានប្រកាសដាក់ឱ្យអនុវត្ត ។<br>២. ផែនការសកម្មភាពសម្រាប់អនុវត្តឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥ ត្រូវបានអនុម័ត ។<br>៣ ប្រកាសស្តីពីការផ្តល់កម្រិតទឹកប្រាក់សិទ្ធសម្រេចក្នុងកិច្ច-លទ្ធកម្មសាធារណៈ ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត ។<br>៤. គោលការណ៍ណែនាំស្តីពីការភ្ជាប់ផែនការលទ្ធកម្មជាមួយនឹងសំណើសុំថវិកាប្រចាំឆ្នាំត្រូវបានរៀបចំនិងអនុម័ត។ |
| ១៤.២ | ពង្រឹងការរៀបចំ និងអនុវត្តផែនការចំណាយឱ្យមានសុក្រឹត្យភាព | - អគ្គ. ថវិកា<br>- ក្រសួង ស្ថាប័ន | ការអនុវត្តថវិកាធៀបផែនការចំណាយ មានកម្រិតលម្អៀង +/-៥% | ០.២០ | ១០០% | ២០% | ចំណាយថវិកាថ្នាក់ជាតិសម្រេចបាន ៩៩.០៥% ធៀបនឹងច្បាប់ថវិកា ។ |
| ១៤.៣ | ពិនិត្យ និងធ្វើបច្ចុប្បន្នភាពក្របខណ្ឌគតិយុត្ត សម្រាប់ចំណាយ រជ្ជទេយ្យបុរេប្រទាន | -អគ្គ. រតនាគារជាតិ<br>-អគ្គ. ថវិកា | របាយការណ៍សិក្សាអំពីការធ្វើបច្ចុប្បន្ន ភាពក្របខណ្ឌគតិយុត្តនៃការអនុវត្តរជ្ជទេយ្យបុរេប្រទានត្រូវបាន រៀបចំ និងដាក់ជូន ថ្នាក់ដឹកនាំពិនិត្យ | ០.១០ | ១០០% | ១០% | របាយការណ៍ប្រមូលផ្តុំបញ្ហាប្រឈមនៃការអនុវត្តនីតិវិធីរជ្ជទេយ្យបុរេប្រទានត្រូវបានរៀបចំ ។ |
| ១៤.៤ | បន្តពង្រឹងប្រសិទ្ធភាពចំណាយវិនិយោគសាធារណៈ | - អគ្គ. សហប្រតិបត្តិ-ការអន្តរជាតិ និងគ្រប់គ្រងបំណុល | ១. ឯកសារក្របខណ្ឌទស្សនាទានស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | ០.៣០ | ៩១% | ២៨% | ១. យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិ-យោគសាធារណៈ ២០១៩-២០២៥ ត្រូវបានអនុម័ត ។ |

| ល.រ. | គោលបំណង/ចង្កោមសកម្មភាព | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | ឆមាស | វឌ្ឍន-ភាព % | ពិន្ទុ ជ្លឹម | វឌ្ឍនភាពសំខាន់ៗ |
|---|---|---|---|---|---|---|---|
| | | - អគ្គ.ថវិកា<br>- អគ្គ. ហិរញ្ញវត្ថុរដ្ឋ-បាលថ្នាក់ក្រោម-ជាតិ<br>- អគ្គ.រតនាគារជាតិ<br>- អគ្គ. លទ្ធកម្មសា-ធារណៈ<br>- PPP | ២. អនុក្រឹត្យគោលស្តីពីក្របខណ្ឌរួមសម្រាប់គ្រប់គ្រងការវិនិយោគសាធារណៈ ត្រូវបានរៀបចំ និងអនុម័ត<br>៣. ច្បាប់ស្តីពីយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន (ច្បាប់ស្តីពី PPP) ត្រូវបានរៀបចំ និងអនុម័ត<br>៤.អនុក្រឹត្យស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមសម្រាប់ការគ្រប់គ្រងការវិនិយោគសាធារ-ណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ត្រូវបានរៀបចំ និងប្រកាសដាក់ឱ្យអនុវត្ត<br>៥. ឯកសារទស្សនាស្តីពីការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានដោយថវិកាជាតិ ត្រូវបានរៀបចំ និងអនុម័ត<br>៦.អនុក្រឹត្យស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមបច្ចុប្បន្នកម្មសម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍ ត្រូវបានរៀបចំ និងប្រកាសដាក់ឱ្យអនុវត្ត<br>៧. ផែនការអភិវឌ្ឍន៍សមត្ថភាពការគ្រប់គ្រងវិនិយោគសាធារណៈ (២០១៩-២០២០) ត្រូវបានរៀបចំ និងអនុវត្ត | | | | ២. សេចក្តីព្រាងអនុក្រឹត្យគោលស្តីពីក្របខណ្ឌ រួមសម្រាប់គ្រប់គ្រងការវិនិយោគសាធារណៈ ត្រូវបានរៀបចំ ។<br>៣. សេចក្តីព្រាងច្បាប់ PPP ត្រូវបានរៀបចំ ។<br>៤. អនុក្រឹត្យដាក់ឱ្យអនុវត្ត នីតិវិធី ប្រតិបត្តិការរួម សម្រាប់គ្រប់គ្រងគម្រោងតាមយន្តការ PPP ពុំទាន់មានវឌ្ឍនភាព ។<br>៥. សេចក្តីព្រាងបឋមនីតិវិធីស្តង់ដាប្រតិបត្តិការនៃគម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានដោយថវិកាថ្នាក់ជាតិ (គម្រោងវិនិយោគផ្ទាល់) ត្រូវបានបញ្ចប់ ។<br>៦. សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំរួច ។<br>៧. សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រង និងប្រើប្រាស់មូលនិធិបំពេញផលហិរញ្ញវត្ថុ ត្រូវបានអង្គភាពកំពុងដំណើរការក្នុងការរៀបចំសេចក្តីព្រាងបឋម ។ |

| ល.រ. | គោលបំណង/ចង្កោមសកម្មភាព | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | ទម្ងន់ | វឌ្ឍន-ភាព % | ពិន្ទុខ្លឹម | វឌ្ឍនភាពសំខាន់ៗ |
|---|---|---|---|---|---|---|---|
| ១៤.៥ | ពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនិងការ-អនុវត្តការងារជួសជុលនិងថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ | - អគ្គ. ថវិកា<br>- អគ្គ. ហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ | សារាចរស្តីពីការអនុវត្តការងារជួសជុលថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ហិរញ្ញប្បទានសាធារណៈ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | 0.១0 | ៩0% | ៥% | ១. មជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ។<br>២. សេចក្តីព្រាងបឋម ស្តីពីការរៀបចំគោលការណ៍ណែនាំស្តីការគ្រប់គ្រងនិងការអនុវត្តថវិកាសម្រាប់ការងារជួសជុលនិងថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ (ផ្លូវថ្នល់ ៦១០៥៣) ត្រូវបានរៀបចំ និងពិភាក្សា ។ |
| **ផ្នែកទី២ ÷ គណនេយ្យភាពហិរញ្ញវត្ថុ** | | | | **0.២0** | **៦៧%** | **១៥%** | - |
| ២១ | **ពង្រឹងការអនុវត្តមាតិកាថវិកាថ្មី និងប្លង់គណនេយ្យថ្មី** | - | **ប្រកាសកែសម្រួលចំណាត់ថ្នាក់ទាំង៧ ត្រូវបានរៀបចំ** | **0.២0** | **៩៥%** | **១៥%** | - |
| ២១.១ | រៀបចំដាក់បញ្ចូល និងជំរុញការអនុវត្តចំណាត់ថ្នាក់ ថវិកាទាំង០៧ ក្នុងប្រព័ន្ធ FMIS | - អគ្គ. ថវិកា<br>- អគ្គ. សហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល<br>- FMWG<br>- អគ្គ. រតនាគារជាតិ | ១. ចំណាត់ថ្នាក់ថវិកា ៤ (សេដ្ឋកិច្ច, រដ្ឋបាល, កម្មវិធី, គម្រោង) ត្រូវបានត្រួតពិនិត្យ និងកែលម្អ តាមការចាំបាច់<br>២. ចំណាត់ថ្នាក់ភូមិសាស្ត្រ ត្រូវបានជំរុញការអនុវត្តឱ្យបានពេញលេញ។<br>៣. ចំណាត់ថ្នាក់មុខងារត្រូវបានអនុវត្តពេញ-លេញ<br>៤. តារាងឧបសម្ព័ន្ធចំណូលចំណាយសម្រាប់រៀបចំ ច្បាប់ទូទាត់ឆ្នាំ២០១៨ ត្រូវបានផលិតសាកល្បងចេញពីប្រព័ន្ធ FMIS | 0.៤0 | ៩៥% | ៣៥% | ១. ឯកសារទស្សនទានស្តីពី ចំណាត់ថ្នាក់សេដ្ឋកិច្ចបំព្រួញត្រូវបានរៀបចំ ។<br>២. ចំណាត់ថ្នាក់មុខងារត្រូវបានធ្វើបច្ចុប្បន្នភាព ។<br>៣ ប្រកាសស្តីពីការបន្ថែមឲ្យអនុវត្តចំណាត់ថ្នាក់គម្រោងនៃមាតិកានៃថវិការបស់រដ្ឋបាលថ្នាក់ជាតិ ត្រូវបានរៀចំ ។<br>៤ លេខកូដ និងសេចក្តីបរិយាយនៃ ចំណាត់ថ្នាក់ថវិកាទាំង០៧ បានធ្វើបច្ចុប្បន្នភាពរួចរាល់នៅក្នុងប្រព័ន្ធ **FMIS** ស្របតាមការកែសម្រួលពីអគ្គនាយកដ្ឋានពាក់ព័ន្ធ ។<br>៥. របាយការណ៍សាមញ្ញភាពតាមចំណាត់ថ្នាក់ថវិកាទាំង៧ ត្រូវបាន ផលិតសាកល្បងចេញពីប្រព័ន្ធ **FMIS** ។<br>៦. ប្រកាសស្តីពីការកែសម្រួលចំណាត់ថ្នាក់ភូមិសាស្ត្ររដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំរួច និងដាក់ឱ្យអនុវត្ត ។<br>៧. ទិន្នន័យនៃការរៀបចំថវិកា,ការ ឧបត្ថម្ភថវិកាពីថ្នាក់ជាតិ |

| ល.រ. | គោលបំណង/ចង្កោមសកម្មភាព | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | ទម្ងន់ | វឌ្ឍន-ភាព % | ពិន្ទុ ខ្លឹម | វឌ្ឍនភាពសំខាន់ៗ |
|---|---|---|---|---|---|---|---|
| | | | | | | | និងការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានកត់ត្រានៅក្នុងប្រព័ន្ធ **FMIS** អនុលោមតាមចំណាត់-ថ្នាក់ថវិកា ។ |
| ២១.២ | ធ្វើបច្ចុប្បន្នភាពប្លង់គណនេយ្យសាធារណៈ | អគ្គ.រតនាគារជាតិ | ១. ការអនុវត្តប្លង់គណនេយ្យសាធារណៈត្រូវបានពិនិត្យ និងកែលម្អ<br>២. ការអនុវត្តប្លង់គណនេយ្យសាធារណៈ នៅគ្រឹះស្ថានសាធារណៈរដ្ឋបាល ចំនួន០៣ ត្រូវបាន ពិនិត្យនិង ដកពិសោធន៍ដើម្បីកែលម្អ | ០.៤០ | ១០០% | ៤០% | ក. បានរៀបចំប្រកាសបំពេញបន្ថែមគណនី អនុគណនីក្នុងប្លង់គណនេយ្យសាធារណៈដូច ខាងក្រោម÷<br>*១. គណនី "គណនីចរន្តនៅធនាគារស្ថាបនា " (លេខ ១១១៨) សម្រាប់ចុះកិច្ចបញ្ជិកានៅគ្រឹះស្ថានសាធារណៈរដ្ឋបាល ។*<br>*២. គណនី "មូលនិធិអភិវឌ្ឍន៍អគ្គិសនី " (លេខ ៤៤១៤) សម្រាប់ចុះកិច្ចបញ្ជិកានៅក្នុងគណនេយ្យថវិការាជធានីខេត្ត មួយចំនួន ។*<br>*៣. គណនី "មូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ " (លេខ ៤៤១៥) សម្រាប់ចុះកិច្ចបញ្ជិកាគណនេយ្យ នៅរតនាគារកណ្តាលពេលទទួលបានការផ្ទេរ អតិរេកថវិការបស់រដ្ឋបាលរាជធានី ខេត្ត និងអតិរេកថវិការបស់រដ្ឋបាលក្រុង ស្រុក ។*<br>*៤. អនុគណនី "ឧបត្ថម្ភធនបន្ថែមត្រូវផ្តល់ជូន រដ្ឋបាលឃុំសង្កាត់ " (លេខ ៤៧០៧២ ) ប្រើសម្រាប់កត់ត្រានៅរតនាគារកណ្តាលនូវចំនួន ទឹកប្រាក់វិភាគទានបន្ថែម ១ ភាគរយដែលត្រូវផ្ទេរ ជូនរដ្ឋបាល ឃុំ សង្កាត់ ។*<br>*៥. អនុគណនី "ពន្ធលើកម្រៃការប្រាក់ " (លេខ ៦៣០៦៤) ប្រើសម្រាប់កត់ត្រានៅគ្រឹះស្ថាន សាធារណៈរដ្ឋបាលនូវចំនួនទឹកប្រាក់ចំណាយ ថវិកាបង់ពន្ធលើកម្រៃការប្រាក់ ។*<br>*៦. គណនី "ការធ្លាក់ចុះតម្លៃនៃអចលកម្ម "(លេខ ៦៧០២)* |

| ល.រ. | គោលបំណង/ចង្កោមសកម្មភាព | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | ឆមាស | វឌ្ឍន-ភាព % | ពិន្ទុថ្លឹង | វឌ្ឍនភាពសំខាន់ៗ |
|---|---|---|---|---|---|---|---|
| | | | | | | | ប្រើសម្រាប់កត់ត្រានៅគ្រឹះ ស្ថានសាធារណៈរដ្ឋបាលនូវចំនួនទឹកប្រាក់នៃ ការថយចុះតម្លៃអចលកម្មរូបី និងអចលកម្ម រូបីក្រោយពីមានការវាយតម្លៃឡើងវិញ ។<br>៧. អនុគណនី "ឧបត្ថម្ភធនពីមូលនិធិរដ្ឋបាល ថ្នាក់ក្រោម-ជាតិ ដែលបានពីអតិរេករបស់រដ្ឋ បាលរាជធានី ខេត្ត" (លេខ ៧៥២០៤ ) ប្រើ ប្រើសម្រាប់កត់ត្រានៅក្នុងគណនេយ្យរបស់ រតនាគាររាជធានី ខេត្ត នូវចំណូលថវិការបស់ រដ្ឋបាលរាជធានី ខេត្ត ដែលបានពីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ ។<br>៨. អនុគណនី "ឧបត្ថម្ភធនពីមូលនិធិរដ្ឋបាលថ្នាក់ក្រោម-ជាតិដែលបានពីអតិរេករបស់រដ្ឋ បាលក្រុង ស្រុក" (លេខ ៧៥២០៥ ) ប្រើ សម្រាប់កត់ត្រានៅក្នុងគណនេយ្យរបស់រតនាគារ រាជធានី ខេត្ត នូវចំណូលថវិការបស់រដ្ឋបាល ក្រុង ស្រុក ដែលបានពីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ ។<br>ខ. ក្រុមការងារបានចុះទៅពិនិត្យវាយតម្លៃ និង តម្រង់ទិសការអនុវត្តប្លង់គណនេយ្យសាធារណៈ និងការអនុវត្តថវិកា និងកិច្ចបញ្ជិកាគណនេយ្យ ឆ្នាំ២០១៩ របស់មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត, សាលាជាតិកសិកម្មព្រែក លៀប ដើម្បីពិនិត្យការអនុវត្តប្លង់គណនេយ្យ និងកិច្ចបញ្ជិកាគណនេយ្យរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងសាលាជាតិកសិកម្មកំពង់ចាម ។ |

| ល.រ. | គោលបំណង/ចង្កោមសកម្មភាព | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | ទម្ងន់ | វឌ្ឍន-ភាព % | ពិន្ទុថ្លឹង | វឌ្ឍនភាពសំខាន់ៗ |
|---|---|---|---|---|---|---|---|
| ២១.៣ | ពង្រឹងសង្គតិភាពរវាងចំណាត់ថ្នាក់នៃមាតិកាថវិកា, ជញ្ជីងទូទាត់ (BoP), គណនេយ្យជាតិ (National Accounts) និងស្ថិតិរូបិយវត្ថុ និង ហិរញ្ញវត្ថុ (Monetary and Financial Statistics) ជាមួយក្របខណ្ឌស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល (GFS) | -អគ្គ.គោលនយោបាយ | តារាងចំនួន ០៧/០៧ នៃស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលត្រូវបានរៀបចំឱ្យមានសង្គតិភាពជាមួយចំណាត់-ថ្នាក់នៃមាតិកាថវិកា | ០.២០ | ១០០% | ២០% | ១. កម្រងទិន្នន័យធាតុចូលសម្រាប់រៀបចំស្ថិតិ GFS ថ្នាក់-ក្រោមជាតិ (ទាំង៣កម្រិត) ត្រូវបានប្រមូលនិងពិនិត្យផ្ទៀងផ្ទាត់តាមបច្ចេកទេសស្ថិតិ GFSM ។<br>២. តារាងស្ថិតិ GFS សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិចំនួន ០៣ តារាង ត្រូវបានរៀបចំ ។<br>៣. លទ្ធផលបឋមនៃតារាងចំណូលរបស់ស្ថិតិ GFS ថ្នាក់ជាតិពីការធ្វើសន្ទានកម្មក្នុងប្រព័ន្ធ FMIS ត្រូវបានពិនិត្យនិងផ្ទៀងផ្ទាត់ ។ |
| **២២** | **ពង្រឹងការអនុវត្តប្រព័ន្ធអនុវត្តថវិកាថ្មី និងដំណើរការប្រតិបត្តិការថ្មី** | - | **១. នីតិវិធីអនុវត្តការងារស្របតាមប្រព័ន្ធ FMIS ត្រូវបានកែលម្អ និងអនុវត្ត**<br>**២. ការបិទកិច្ចបញ្ជីការគណនេយ្យប្រចាំឆ្នាំត្រូវបានបញ្ចប់ទាន់ពេលវេលា និងមានសុក្រឹតភាព** | **០.២៥** | **៩៨%** | **២៤%** | - |
| ២២.១ | រៀបចំបរិបទនៃប្រតិបត្តិការចំណាយ (សំណើសុំធានាចំណាយ, កិច្ចលទ្ធកម្ម និងសំណើសុំទូទាត់) នៅតាមក្រសួងស្ថាប័នឱ្យស្របតាមប្រព័ន្ធ FMIS | -ក្រសួង ស្ថាប័ន,<br>-ក្រុមការងារ FMWG<br>-អគ្គ.រតនាគារ<br>-អគ្គ.ថវិកា | ១. គោលការណ៍ណែនាំនិងប្រកាសត្រូវបានរៀបចំ<br>២. ក្រសួងស្ថាប័នចំនួន ១ ត្រូវបានសិក្សាអំពីតម្រង់ទិសនិងកែលម្អនីតិវិធីអនុវត្តការងារ (Business Process Streamline) សាកល្បងការអនុវត្តប្រព័ន្ធស្វ័យប្រវត្តិកម្មនៃការអនុវត្តថវិកាលើចំណាយទូទាត់ត្រង់<br>៣. សន្ទានកម្មប្រព័ន្ធ FMIS នឹងប្រព័ន្ធផ្សេងទៀតត្រូវបានបន្តរៀបចំ និងបញ្ចប់ (ប្រព័ន្ធចំណូលមិនមែនសារពើពន្ធ, ប្រព័ន្ធបៀវត្សរ៍, ប្រព័ន្ធធនាគារជាតិ/ពាណិជ្ជ, ប្រព័ន្ធពន្ធដារ) | ០.២៥ | ៩៩% | ២៤% | ១. ឯកសារស្តីពីនីតិវិធីអនុវត្តថ្មីលើការទូទាត់ចំណាយបៀវត្ស និងទូទាត់ត្រង់ក្រៅពីបៀវត្ស ក្នុងក្របខណ្ឌកសហវ. ត្រូវបានរៀបចំរួចរាល់ និងបានធ្វើបទបង្ហាញជូនថ្នាក់នាំ កសហវ ដោយទទួលបាននូវអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់ក្នុងការរៀបចំដាក់អនុវត្តសាកល្បងលើនីតិវិធីអនុវត្តការងារថ្មី សម្រាប់ការចំណាយបៀវត្សនិងចំណាយត្រង់ដែលមានហានិភ័យទាបនេះ តាមប្រព័ន្ធ FMIS ទាំងស្រុងនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅក្នុងឆ្នាំ២០២០ ។<br>២. ផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រង |

| ល.រ. | គោលបំណង/ចង្កោមសកម្មភាព | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | ទម្ងន់ | វឌ្ឍន-ភាព % | ពិន្ទុ ទ្បីង | វឌ្ឍនភាពសំខាន់ៗ |
|---|---|---|---|---|---|---|---|
| | | | ៤. ការណែនាំស្តីពីការបញ្ចូលប្រតិបត្តិការចំណាយក្នុងប្រព័ន្ធ FMIS ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | | | | ហិរញ្ញវត្ថុសាធារណៈ (FMIS) ២០២០-២០២៥ ត្រូវបានអនុម័ត ។<br>៣. ផ្នែកបច្ចេកទេសនៃការសន្ធានកម្មទិន្នន័យរវាងប្រព័ន្ធ FMIS ជាមួយប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) ត្រូវបានរៀបចំ អភិវឌ្ឍ និងប្រកាសដាក់ដំណើរការអនុវត្តជាផ្លូវការចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០២០ តទៅ ។ លក្ខណៈបច្ចេកទេសលើការធ្វើសន្ធានកម្មរវាងប្រព័ន្ធ FMIS ជាមួយប្រព័ន្ធពន្ធដារ ត្រូវបានរៀបចំ និងអភិវឌ្ឍរួចរាល់ និងកំពុងស្នើសុំការធ្វើតេស្តសាកល្បងទៅកាន់អគ្គនាយកដ្ឋានពន្ធដារ ដើម្បីជំរុញដល់ការដាក់ឱ្យដំណើរការក្នុងឆ្នាំ ២០២០ នេះ ។ សន្ធានកម្មរវាងប្រព័ន្ធ FMIS និងប្រព័ន្ធធនាគារ ANZ Royal ត្រូវបានរៀបចំរួចរាល់ និងដាក់ដំណើរការជាផ្លូវការ ។ បានជួបពិភាក្សាជាមួយតំណាងក្រសួងមុខងារសាធារណៈចំនួន ៣លើក និងទទួលបានការយល់ស្របគ្នារវាងក្រុមការងារបច្ចេកទេសនៃប្រព័ន្ធ FMIS និងប្រព័ន្ធ Payroll លើការកំណត់ផែនការសកម្មភាពសម្រាប់ឆ្នាំ ២០២០ ។ |
| ២២.២ | កែលម្អប្រតិបត្តិការគណនេយ្យហិរញ្ញវត្ថុនៅក្នុងកសហវ/ក្រសួង ស្ថាប័នដើម្បីឱ្យស្របទៅនឹងការវិវឌ្ឍនៃប្លង់គណនេយ្យ និងបទដ្ឋានគណនេយ្យ ព្រមទាំងធ្វើការផ្ទៀង-ផ្ទាត់គណនីធនាគារជាប្រចាំ | -អគ្គ. រតនាគារជាតិ<br>-ក្រសួង ស្ថាប័ន | រតនាគារជាតិពិនិត្យសុក្រឹតភាព និងភាពទាន់ពេលវេលានៃរបាយការណ៍សម្រេចទូទាត់របស់ក្រសួង- ស្ថាប័ន ដែលត្រូវធ្វើមិនឱ្យលើសពី២ខែ ក្រោយថ្ងៃឈប់ទទួលអាណត្តិនៅអគ្គនាយកដ្ឋានរតនាគារជាតិ | ០.២៥ | ១០០% | ២៥% | សេចក្តីព្រាងគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យនៃទ្រព្យសកម្មរយៈពេលវែង Fixed Asset Threshold ត្រូវបានរៀបចំ ។ |

| ល.រ. | គោលបំណង/ចង្កោមសកម្មភាព | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | ទម្ងន់ | វឌ្ឍន-ភាព % | ពិន្ទុថ្លឹង | វឌ្ឍនភាពសំខាន់ៗ |
|---|---|---|---|---|---|---|---|
| ២២.៣ | កសាងសមត្ថភាពគ្រប់គ្រងគម្រោង **FMIS**ដោយរួមទាំងនៅកសហាវ ក្រសួង ស្ថាប័ន និងអង្គភាពថ្នាក់មូលដ្ឋាន | -ក្រុមការងារ FMWG<br>-ក្រសួង ស្ថាប័ន | ១. មន្ត្រីរាជការនៃក្រសួង-ស្ថាប័នចំនួន ១៧ បន្ថែមទៀត ទទួលបានការយល់ដឹងអំពីប្រព័ន្ធ FMIS<br>២. មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទាំង២៥ រាជធានី-ខេត្ត ទទួលបានការបំប៉នសមត្ថភាពបន្ថែមលើប្រព័ន្ធ FMIS<br>៣. របាយការណ៍វាយតម្លៃអំពីប្រសិទ្ធភាពនៃការបណ្តុះបណ្តាលលើប្រព័ន្ធ FMIS ត្រូវបានរៀបចំ | ០.២៥ | ១០០% | ២៥% | ១. មន្ត្រីក្រសួង-ស្ថាប័នចំនួន ១៧ បន្ថែមថ្មី និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ៥ រួមទាំងក្រសួង-ស្ថាប័នចំនួន ៧ ទៀតដែលអនុវត្តប្រព័ន្ធ FMIS ឆ្នាំកន្លងទៅ សរុប ៣៧២រូប បានទទួលការបណ្តុះបណ្តាលលើការប្រើប្រាស់ប្រព័ន្ធ FMIS រួចរាល់ទៅតាមមុខងារដែលបានកំណត់ដោយក្រសួង-ស្ថាប័ន ។<br>២. ក្រសួងស្ថាប័នចំនួន ២០ និងមន្ទីរ សហវ ទាំង២៥ បានចាត់មន្ត្រីជំនាញបន្ថែមចូលរួមក្នុងវគ្គបណ្តុះបណ្តាលលើការប្រើប្រាស់ប្រព័ន្ធ FMIS និងចូលរួមក្នុងកម្មវិធីបង្ហាញអំពីគន្លឹះថ្មីៗនៅក្នុងការប្រើប្រាស់ប្រព័ន្ធ FMIS ។<br>៣. របាយការណ៍លទ្ធផលនៃការវាយតម្លៃអំពីសមត្ថភាពប្រើប្រាស់ប្រព័ន្ធ FMIS របស់មន្ត្រីក្រសួង-ស្ថាប័នថ្មីចំនួន ១៧ ត្រូវបានរៀបចំរួចរាល់តាមរយៈរបាយការណ៍បណ្តុះបណ្តាល ។ |
| ២២.៤ | ពង្រីកការអនុវត្ត **FMIS** (ម៉ូឌុលស្នូល និងម៉ូឌុលថ្មី និងពង្រីកការអនុវត្ត **FMIS** ទៅក្រសួង ស្ថាប័ន) | -ក្រុមការងារ FMWG<br>-ក្រសួង ស្ថាប័ន | ១. ក្រសួងស្ថាប័នចំនួន ១៧ បន្ថែមត្រូវបានពង្រីកការដាក់ឱ្យអនុវត្តគម្រោងអនុវត្ត FMIS ជាផ្លូវការ(រួមមានមុខងាររៀបចំនីតិវិធីអនុវត្តការងារ, ការបណ្តុះបណ្តាល, ការរៀបចំដំឡើងហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍប្រព័ន្ធ FMIS)<br>២. ក្រសួង-ស្ថាប័នចំនួន១០បន្ថែម មន្ទីសេដ្ឋ-កិច្ចនិងហិរញ្ញវត្ថុទាំង២៥ រាជធានី-ខេត្ត ត្រូវបានអនុវត្ត FMIS ជំហានទី២ | ០.២៥ | ៩៧% | ២៤% | ១. ប្រព័ន្ធ FMIS ត្រូវបានអភិវឌ្ឍ និងដាក់អោយប្រើ-ប្រាស់នៅក្នុងមជ្ឈដ្ឋានផ្លូវការរួចរាល់សម្រាប់ត្រៀមអោយអ្នកប្រើប្រាស់នៅក្រសួងស្ថាប័នចំនួន ១៧ បន្ថែមថ្មី ។<br>២. ក្រសួងស្ថាប័នចំនួន ១០ បន្ថែមថ្មី រួមទាំងមន្ទីរសហវទាំង២៥ បានប្រើប្រាស់ប្រព័ន្ធ FMIS ជាផ្លូវការសម្រាប់ប្រតិបត្តិការឆ្នាំ ២០១៩ ។<br>៣. ម៉ូឌុលរៀបចំថវិកា ត្រូវបានគណៈកម្មការវាយតម្លៃលើឯកសារដេញថ្លៃរួចរាល់ និងបានត្រៀមដាក់ |

| ល.រ. | គោលបំណង/ចង្កោមសកម្មភាព | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | ទម្ងន់ | វឌ្ឍន-ភាព % | ពិន្ទុ ថ្លឹង | វឌ្ឍនភាពសំខាន់ៗ |
|---|---|---|---|---|---|---|---|
| | | | ៣. ម៉ូឌុលថ្មី២ នៃដំណាក់កាលទី២ (លទ្ធកម្ម និងការរៀបចំថវិកា) ត្រូវបាន រៀបចំ<br>៤. អង្គភាពថវិកាផ្ទេរសិទ្ធិពេញលេញចំនួន ១២ អាចផលិតរបាយការណ៍ចេញពីប្រព័ន្ធ FMIS សម្រាប់ការវិភាគ | | | | របាយការណ៍វាយតម្លៃ និងជ្រើសរើសក្រុមហ៊ុនដែលត្រូវផ្គត់ផ្គង់ ជូនថ្នាក់ដឹកនាំពិនិត្យ និងសម្រេច ។ ម៉ូឌុលលទ្ធកម្ម និងគ្រប់គ្រងកិច្ចសន្យា បានប្រជុំពិនិត្យ និងចរចាតម្លៃរួចរាល់រវាងគណៈកម្មការ និងក្រុមហ៊ុនផ្គត់ផ្គង់ដែលនឹងត្រៀមដាក់របាយការណ៍ និងស្នើសុំគោលការណ៍របស់ថ្នាក់ដឹកនាំ ក្នុងការចុះកិច្ចសន្យាផ្ទាល់ជាមួយក្រុមហ៊ុនផ្គត់ផ្គង់ ។ |
| **២៣** | **ពង្រឹងការអនុវត្តប្រព័ន្ធគណនេយ្យថ្មី ប្រព័ន្ធកត់ត្រាថ្មី ប្រព័ន្ធរបាយការណ៍ថ្មី** | - | **១. សមាសធាតុចំនួន ៣ នៅក្នុងរបាយការណ៍ IPSAS Cash Basis ត្រូវបានកែលម្អដើម្បីឱ្យ compliance តាមស្តង់ដា IPSAS Cash Basis**<br>**២. ប្រព័ន្ធគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវបានដាក់ឱ្យអនុវត្តនៅក្រសួងចំនួន១០** | **០.២០** | **៦៨%** | **១៤%** | - |
| ២៣.១ | រៀបចំស្តង់ដាគណនេយ្យសាធារណៈស្របតាមស្តង់ដា IPSAS និងដាក់ឱ្យអនុវត្តជាបណ្តើរៗតាមលំដាប់លំដោយ ព្រមទាំងផ្សារភ្ជាប់ទៅនឹងការពង្រីកការប្រើប្រាស់ FMIS ស្របតាមតម្រូវការជាក់ស្តែង និងបង្កើតជម្រើសសម្រាប់ការអនុវត្តជាជំហានៗទៅរកការអនុវត្ត គណនេយ្យបង្គរ | -ក្រុមប្រឹក្សាជាតិគណនេយ្យ<br>-អគ្គ.រតនាគារជាតិ<br>-អគ្គ.សហប្រតិបត្តិ-ការអន្តរជាតិ និងគ្រប់គ្រងបំណុល | ១. ក្របខណ្ឌសម្រាប់ការអនុវត្តគណនេយ្យតាម Cash Basis IPSAS ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត<br>២. របាយការណ៍ IPSAS Cash Basis ឆ្នាំ២០១៧ ត្រូវបានរៀបចំលើមូលដ្ឋានប្រព័ន្ធ FMIS<br>៣. សមាសធាតុចំនួន ៣ នៅក្នុងរបាយការណ៍ IPSAS Cash Basis ត្រូវបានកែលម្អដើម្បីឱ្យ compliance តាមស្តង់ដា IPSAS Cash Basis | ០.៣០ | ១០០% | ៣០% | ១. ដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសាធាណៈកម្ពុជាមូលដ្ឋានសាច់ប្រាក់ត្រូវបានផ្សព្វផ្សាយដល់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ ហើយបានបណ្តុះបណ្តាលដល់រតនាគារជាតិ ២៥ រាជធានី-ខេត្ត ។<br>២. សេចក្តីព្រាងចុងក្រោយនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍគណនេយ្យសាធារណៈកម្ពុជា ត្រូវបានរៀបចំរួចរាល់សម្រាប់ប្រឹក្សាពិគ្រោះយោបល់ ។<br>៣. សេចក្តីព្រាងទី ២ នៃឯកសារក្របខណ្ឌរាយការណ៍ហិរញ្ញវត្ថុសាធារណៈកម្ពុជា ត្រូវបានរៀបចំរួចរាល់ ។ |

| ល.រ. | គោលបំណង/ចង្កោមសកម្មភាព | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | ទម្ងន់ | វឌ្ឍន-ភាព % | ពិន្ទុថ្លឹង | វឌ្ឍនភាពសំខាន់ៗ |
|---|---|---|---|---|---|---|---|
| | | | | | | | ៤. សេចក្តីព្រាងរបាយការណ៍ IPSAS Cash Basis ឆ្នាំ ២០១៧ ដោយយកមូលដ្ឋាន តួលេខចេញពីប្រព័ន្ធ FMIS ត្រូវបានរៀបចំ ។ |
| ២៣.២ | កែលម្អទម្រង់របាយការណ៍អនុវត្តថវិកាដែលត្រូវផ្ញើទៅគណៈរដ្ឋមន្ត្រី និងស្ថាប័ននីតិប្បញ្ញត្តិ | -អគ្គ. ថវិកា<br>-អគ្គ.រតនាគារជាតិ | ១.ទម្រង់របាយការណ៍អនុវត្តថវិកា (របាយការណ៍សមិទ្ធកម្ម) ត្រូវបានរៀបចំ<br>២.ទម្រង់របាយការណ៍អនុវត្តថវិកា (របាយការណ៍ហិរញ្ញវត្ថុ) ត្រូវបានកែលម្អ | ០.៣០ | ៩៨% | ២៩% | ១. ទម្រង់របាយការណ៍ស្តីពីការអនុវត្តថវិកា ០៩ ខែ ត្រូវបានកែលម្អតាមស្ថានភាពជាក់ស្តែង ។<br>២. ច្បាប់ទូទាត់ថវិកាប្រចាំឆ្នាំត្រូវបានរៀបចំ និងកែលម្អមុនដាក់ ជូនទីស្តីការគណៈរដ្ឋមន្ត្រី ។<br>៣. របាយការណ៍អនុវត្តថវិកា និងតារាងឧបសម្ព័ន្ធសម្រាប់ច្បាប់ទូទាត់ត្រូវបានអភិវឌ្ឍ និងដាក់ដំណើរ-ការសាកល្បងចេញពីប្រព័ន្ធ FMIS ។ |
| ២៣.៣ | ដាក់ឱ្យអនុវត្តយន្តការដើម្បីបញ្ចប់ការចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិ-រដ្ឋ និងធ្វើបច្ចុប្បន្នភាពជាប្រចាំ | -អគ្គ.ទ្រព្យសម្បត្តិ-រដ្ឋ និងចំណូលមិនមែនសារពើពន្ធ<br>-ក្រសួង ស្ថាប័ន | ១. លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវបានបញ្ចប់<br>២. ប្រព័ន្ធគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវបានដាក់ឱ្យប្រើប្រាស់សាកល្បងតាមក្រសួងស្ថាប័នមួយចំនួន (ត្រីមាសទី១ និងត្រីមាសទី២ ឆ្នាំ២០១៩)<br>៣. ប្រព័ន្ធគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវបានដាក់ឱ្យអនុវត្តគ្រប់ក្រសួងស្ថាប័ន និងរាជធានី-ខេត្ត (ត្រីមាសទី៣ និងទី៤ ឆ្នាំ២០១៩)<br>៤. របាយការណ៍របកគំហើញក្រសួងស្ថាប័នដែលមិនចូលរួម ត្រូវបានរៀបចំ និងបញ្ចូលអនុសាសន៍សម្រាប់ជំរុញប្រសិទ្ធភាពនៃការអនុវត្ត | ០.៤០ | ៩៨% | ៣៩% | ១. ប្រកាសស្តីពីគំរូ នៃសៀវភៅបញ្ជីសារពើភណ្ឌឆ្នាំគោល និងតារាងកើនឡើងនិងថយចុះនូវទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ ត្រូវបានរៀបចំជាសេចក្តីព្រាង ។<br>២. ប្រកាសស្តីពីវិធាន និងនីតិវិធីលម្អិតនៃការជម្រះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត ។<br>៣. ឆ្នាំ២០២០ ក្រសួងចំនួន១០ នឹងត្រូវបណ្តុះបណ្តាលលម្អិតពីរបៀបបញ្ចូល និងប្រើប្រាស់ព័ត៌មាននៃប្រព័ន្ធ **SARMIS** នៅ.អទច ។<br>៤. បានបញ្ចូលទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់អង្គភាពប្រើប្រាស់ថ្នាក់មូលដ្ឋាននៃកសហវ.ចំនួន ៦ រាជធានី-ខេត្ត ក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់កសហវ ។ |

| ល.រ. | គោលបំណង/ចង្កោមសកម្មភាព | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | ទម្ងន់ | វឌ្ឍន-ភាព % | ពិន្ទុទទួល | វឌ្ឍនភាពសំខាន់ៗ |
|---|---|---|---|---|---|---|---|
| | | | ៥. យន្តការតាមដាននិងវាយតម្លៃលើប្រសិទ្ធ-ភាពនៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួងស្ថាប័ន ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | | | | ៥. សេចក្តីពន្យល់ណែនាំស្តីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋសម្រាប់ប្រើប្រាស់ផ្ទៃក្នុងរបស់កសហវ ត្រូវបានរៀបចំ ផ្សព្វផ្សាយណែនាំ និងដាក់ឱ្យអនុវត្ត ។<br>៦ ប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដំណើរការលើឧបករណ៍ទូរស័ព្ទវៃឆ្លាតលើមុខងារដែលបានកំណត់ ។ |
| ២៤ | **ពង្រឹងការអនុវត្តឧបករណ៍ និងយន្តការដើម្បីបង្កើនការទទួលខុសត្រូវ និងគណនេយ្យភាព (ប្រព័ន្ធត្រួតពិនិត្យ)** | - | **ប្រព័ន្ធ FMIS ត្រូវបានត្រួតពិនិត្យនិងតាមដានតាមយន្តការសវនកម្មអង្គភាពចំនួន ៦ ក្រោមនិវាទ កសហវ អង្គភាពថវិកាចំនួន ៤ នៃក្រសួង-ស្ថាប័ន** | **០.២០** | **១០០%** | **២០%** | - |
| ២៤.១ | បង្កើតឱ្យមានទណ្ឌកម្មរដ្ឋបាលសម-ស្របចំពោះកំហុសឆ្គង ឬការគ្រប់គ្រងធនធានសាធារណៈ មិនសមស្រប និងគ្មានប្រសិទ្ធភាព | -ក្រុមប្រឹក្សានីតិកម្មនៃកសហវ<br>-ក្រសួង ស្ថាប័ន | ទណ្ឌកម្មរដ្ឋបាលសមស្របចំពោះកំហុសឆ្គង ឬការគ្រប់គ្រងធនធានសាធារណៈមិនសមស្រប និងគ្មានប្រសិទ្ធភាព ត្រូវបានដាក់ឱ្យអនុវត្ត | ០.២០ | ១០០% | ២០% | សៀវភៅកម្រងសម្រង់វិធានការរួមនៃការដាក់ទណ្ឌកម្មហិរញ្ញវត្ថុសាធារណៈត្រូវបានបោះពុម្ពរួចរាល់ ។ |
| ២៤.២ | រៀបចំ និងដាក់ឱ្យអនុវត្តទម្រង់របាយការណ៍វឌ្ឍនភាពអនុវត្តថវិកាប្រចាំត្រីមាស ឆមាសនិងប្រចាំឆ្នាំ | -អគ្គ.ថវិកា<br>-ក្រសួង ស្ថាប័ន | ទម្រង់របាយការណ៍ថ្មីត្រូវបានបន្តកែលម្អ និងដាក់ឱ្យគ្រប់ក្រសួង-ស្ថាប័នអនុវត្ត | ០.៣០ | ១០០% | ២០% | ១. អង្គភាពថវិកាក្រសួង-ស្ថាប័ន បានអនុវត្តទម្រង់របាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស និងឆមាស ។<br>២. អង្គភាពថវិកាក្រសួង-ស្ថាប័ន បានអនុវត្តទម្រង់របាយការណ៍សមិទ្ធកម្ម/លទ្ធផលប្រចាំឆមាស ។<br>៣. បាយការណ៍ត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តថវិកាពាក់កណ្តាល ២០១៩ របស់ កសហវ. ត្រូវបានរៀបចំ ។ |
| ២៤.៣ | ពង្រឹងការត្រួតពិនិត្យលើប្រព័ន្ធព័ត៌មានវិទ្យា និង **FMIS (IT audit)** | - អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង<br>- FMWG | ១. អង្គភាពចំនួន ៦ ក្រោមនិវាទ កសហវ ត្រូវបានធ្វើសវនកម្មលើប្រព័ន្ធ FMIS<br>២. អង្គភាពថវិកាចំនួន ៤ នៃក្រសួង-ស្ថាប័ន ត្រូវបានត្រួតពិនិត្យលើការអនុវត្ត FMIS | ០.៥០ | ១០០% | ២០% | ១. អង្គភាពក្រោមនិវាទ កសហវចំនួន ៦ គោលដៅ ត្រូវបានធ្វើសវនកម្មលើប្រព័ន្ធ **FMIS** ។<br>២. អង្គភាពថវិកានៃក្រសួង ស្ថាប័នចំនួន ៤ ត្រូវបានធ្វើសវនកម្មលើប្រព័ន្ធ **FMIS** ។ |

| ល.រ. | គោលបំណង/ចង្កោមសកម្មភាព | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | ទម្ងន់ | វឌ្ឍន-ភាព % | ពិន្ទុ ថ្លឹង | វឌ្ឍនភាពសំខាន់ៗ |
|---|---|---|---|---|---|---|---|
| **២៥** | **២៥. បង្កើនតម្លាភាពថវិកា** | **-** | **សន្ទស្សន៍ការស្ទង់មតិតម្លាភាពថវិកាខ្ពស់ជាងមុន** | **០.១៥** | **៩៥%** | **១៥%** | **-** |
| ២៥.១ | បង្កើនការចូលរួមសាធារណៈជនក្នុងដំណើរការថវិកា | -អគ្គ.ថវិកា<br>-អគ្គ.គោលនយោបាយ | ១.វេទិកាសាធារណៈស្តីពីក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចត្រូវបានរៀបចំ<br>២.កិច្ចពិគ្រោះយោបល់តាមវិស័យត្រូវបានរៀបចំ | ០.៣០ | ១០០% | ៣០% | ១. វេទិកាសាធារណៈ ស្តីពីក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច និងក្របខណ្ឌថវិកាប្រចាំឆ្នាំ ត្រូវបានរៀបចំ ។<br>២. សិក្ខាសាលាពិគ្រោះយោបល់លើវិស័យអាទិភាពចំនួន ០២ ត្រូវបានរៀបចំ ។ |
| ២៥.២ | បង្កើនការផ្សព្វផ្សាយឯកសារថវិកា | -អគ្គ.ថវិកា<br>-អគ្គ.គោលនយោបាយ<br>- NAA<br>-អគ្គ.ហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ | ១. សារាចររៀបចំផែនការយុទ្ធសាស្ត្រថវិកា និងកញ្ចប់ថវិកាត្រូវបានផ្សព្វផ្សាយលើគេហទំព័រ<br>២.របាយការណ៍ត្រួតពិនិត្យថវិកាពាក់កណ្តាលឆ្នាំត្រូវបានផ្សព្វផ្សាយ<br>៣.ច្បាប់ទូទាត់ត្រូវបានផ្សព្វផ្សាយ<br>៤. របាយការណ៍សវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានផ្សព្វផ្សាយលើគេហទំព័ររបស់ អ.ជ.ស<br>៥. ថវិកាសង្ខេបត្រូវបានផ្សព្វផ្សាយ (Budget in Brief)<br>៦. តារាងប្រតិបត្តិការហិរញ្ញវត្ថុ (TOFE & GFS) ត្រូវបានផ្សព្វផ្សាយ<br>៧. ថវិកាសង្ខេបរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានផ្សព្វផ្សាយជាសាធារណៈ<br>៨. ខ្លឹមសារសង្ខេបនៃសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ត្រូវបានផ្សព្វផ្សាយជាសាធារណៈ<br>៩. ក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចត្រូវបានផ្សព្វផ្សាយ | ០.៣០ | ១០០% | ៣០% | ១. សារាចររៀបចំផែនការយុទ្ធសាស្ត្រថវិកា និងកញ្ចប់ថវិកាត្រូវបានផ្សព្វផ្សាយ ។<br>២. ប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ ( ស្តង់ដា TOFE) ប្រចាំខែត្រូវបានចេញផ្សាយលើគេហទំព័រក្រសួងមិនលើសពី២សប្តាហ៍បន្ទាប់ពីដាក់ជូនថ្នាក់ដឹកនាំ ។<br>៣. របាយការណ៍ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលថ្នាក់ជាតិ (GFS budgetary Central Govt) ប្រចាំខែ និងស្ថិតិថ្នាក់ក្រោមជាតិ (GFS Local Govt) ប្រចាំឆមាសត្រូវបានចេញផ្សាយ លើគេហទំព័រក្រសួង ។<br>៤.របាយការណ៍និន្នាការសេដ្ឋកិច្ច-សង្គម (SET) ប្រចាំខែត្រូវបានចេញផ្សាយលើគេហទំព័រក្រសួង ។<br>៥. ព្រឹត្តិបត្រស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រចាំត្រីមាស (Bulletin) ត្រូវបានពង្រឹងគុណភាពផ្នែកព្យាករណ៍ និងបន្ថែមការចេញផ្សាយជាសាធារណៈ លើគេហទំព័រក្រសួង/អគ្គនាយកដ្ឋាន ។<br>៦ ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោល-នយោបាយហិរញ្ញវត្ថុសាធារណៈត្រូវបានផ្សព្វផ្សាយលើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ |

| ល.រ. | គោលបំណង/ចង្កោមសកម្មភាព | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | ទម្ងន់ | វឌ្ឍន-ភាព % | ពិន្ទុ ខ្លឹម | វឌ្ឍនភាពសំខាន់ៗ |
|---|---|---|---|---|---|---|---|
| | | | | | | | ៧. របាយការណ៍សង្ខេបអនុវត្តថវិកាពាក់កណ្ដាលឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានផ្សព្វផ្សាយជាសាធារណៈ។<br>៨. សារាចរណែនាំស្ដីពីការអនុវត្តច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ របស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានផ្សព្វផ្សាយ ៩. សារាចរណែនាំស្ដីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា របស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានផ្សព្វផ្សាយ ។<br>១០. សារាចរណែនាំស្ដីពីនីតិវិធីបច្ចេកទេសរៀបចំគម្រោងថវិកាឆ្នាំ២០២០ របស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានផ្សព្វផ្សាយ ។<br>១១. សារាចរណែនាំស្ដីពីបិទបញ្ជីថវិកានិងរៀបចំរបាយ-ការណ៍ចំណូលចំណាយ២០១៩ របស់រដ្ឋបាលថ្នាក់-ក្រោមជាតិត្រូវបានផ្សព្វផ្សាយ ។ |
| ២៥.៣ | បង្កើនតម្លាភាពកិច្ចលទ្ធកម្មសាធារណៈ | អគ្គ.លទ្ធកម្ម | ១. ប្រព័ន្ធទិន្នន័យគ្រប់គ្រងលទ្ធកម្មសាធារណៈ (PPMIS) ត្រូវបានបន្តរៀបចំ<br>២. ស្ថិតិលទ្ធកម្មត្រូវបានរៀបចំ និងផ្សព្វផ្សាយលើគេហទំព័ររបស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ<br>៣. បទដ្ឋានគតិយុត្តពាក់ព័ន្ធដែលតម្រូវដោយច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ (២០១២) ត្រូវបានរៀបចំបំពេញបន្ថែម និងផ្សព្វផ្សាយដាក់ឱ្យអនុវត្ត | ០.៤០ | ៨៧% | ៣៥% | ១. មុខងារគ្រប់គ្រងការប្រគល់ទទួលបានរៀបចំនិងអភិវឌ្ឍន៍ជាប្រព័ន្ធ និងដាក់ឱ្យប្រើប្រាស់សាកល្បងក្នុងកម្រិតក្រុមការងារបច្ចេកទេស។ មុខងារគ្រប់គ្រងតាមដានលំហូរឯកសារកំពុងរៀបចំនិងអភិវឌ្ឍន៍ជាប្រព័ន្ធ÷<br>• វិភាគនិងរៀបចំទិន្នន័យមេ( ៦០%)<br>• រៀបចំ Database( ៩០%)<br>• រៀបចំ Table Definition( ៩០%)<br>• រៀបចំ User Interface(UI)( ៩០%)<br>២. ប្រកាសស្ដីពីបុរេលក្ខណសម្បត្តិអ្នកដេញថ្លៃ ត្រូវបានការកែសម្រួលជាសេចក្ដីព្រាងចុងក្រោយ និងចុះហត្ថលេខាដាក់ឲ្យអនុវត្ត ។ |

| ល.រ. | គោលបំណង/ចង្កោមសកម្មភាព | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | ទម្ងន់ | វឌ្ឍន-ភាព % | ពិន្ទុថ្លឹង | វឌ្ឍនភាពសំខាន់ៗ |
|---|---|---|---|---|---|---|---|
| | | | | | | | ៣. សេចក្ដីព្រាងស្ថិតិលទ្ធកម្មត្រូវបានរៀបចំ និងត្រៀមគោរពដាក់ជូនឯកឧត្ដមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ ដើម្បីដាក់ប្រជុំកម្រិតអគ្គនាយកដ្ឋាន ។<br>៣. ផែនការលទ្ធកម្មប្រចាំឆ្នាំ២០១៩ របស់ស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ត្រូវបានផ្សព្វផ្សាយលើគេហទំព័រ GDPP ។<br>៤. របាយការណ៍ត្រួតពិនិត្យកិច្ចលទ្ធកម្មតាមក្រោយប្រចាំឆ្នាំ២០១៨ លើការិយបរិច្ឆេទឆ្នាំ២០១៧ ត្រូវបានផ្សព្វផ្សាយលើគេហទំព័រ GDPP ។ |
| **ផ្នែកទី៣ ៖ ការផ្សារភ្ជាប់ថវិកាទៅគោលនយោបាយ** | | | | **០.៣** | **៩៨%** | **២៩%** | **-** |
| **៣១** | **ពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី និងការត្រួតពិនិត្យថវិកា** | **-** | **ថវិកាកម្មវិធីក្រសួង-ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្តចំនួន ១៨ ត្រូវបានអនុវត្ត ប្រកបដោយប្រសិទ្ធភាព** | **០.២៥** | **៩៨%** | **២៥%** | **ថវិកាកម្មវិធីត្រូវបានដាក់ឱ្យអនុវត្តនៅរដ្ឋបាលរាជធានី-ខេត្តចំនួន ១៨ ។** |
| ៣១.១ | ពិនិត្យឡើងវិញ និងកែលម្អការអនុវត្តថវិកាកម្មវិធី ទាំងថ្នាក់ជាតិ និងថ្នាក់-ក្រោមជាតិ | -អគ្គ.ថវិកា<br>-អគ្គ.ហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ<br>-អគ្គ.រតនាគារជាតិ<br>-ក្រសួង ស្ថាប័ន | ១. របាយការណ៍ស្ដីពីការពិនិត្យឡើងវិញ និងការកែលម្អ ត្រូវបានរៀបចំ ដោយរំលេចឱ្យឃើញពីរបកគំហើញ និងអនុសាសន៍នានា និងដាក់ឱ្យអនុវត្ត<br>២. តាមដានការអនុវត្តថវិកាកម្មវិធីដោយកំណត់នូវបញ្ហាប្រឈមឱ្យបានច្បាស់លាស់ និងរៀបចំយន្តការដោះស្រាយ | ០.២៥ | ៩៩% | ២៥% | ១. គោលការណ៍ណែនាំស្ដីពីការរៀបចំថវិកាសមិទ្ធកម្មត្រូវបានដាក់ឱ្យប្រើប្រាស់ ។<br>២. ទម្រង់តារាងសម្រាប់ តាមដានចលនាឥណទានសរុបតាមថវិកាកម្មវិធីត្រូវបានកែលម្អ ។<br>៣. ការរៀបចំថវិកាប្រចាំឆ្នាំមានភ្ជាប់ផែនការលទ្ធកម្មជាមួយនឹងសំណើថវិកា ។<br>៤. ការរៀបចំថវិកាប្រចាំឆ្នាំមានភ្ជាប់ផែនការរជ្ជទេយ្យបុរេប្រទានជាមួយនឹងសំណើថវិកា ។ |

| ល.រ. | គោលបំណង/ចង្កោមសកម្មភាព | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | ទម្ងន់ | វឌ្ឍន-ភាព % | ពិន្ទុ ថ្លឹង | វឌ្ឍនភាពសំខាន់ៗ |
|---|---|---|---|---|---|---|---|
| | | | | | | | ៥. របាយការណ៍ស្តីពីការពិនិត្យឡើងវិញការអនុវត្តថវិកាកម្មវិធីក្នុងឆ្នាំ២០១៩បានរៀបចំនឹងដាក់ជូនថ្នាក់ដឹកនាំពិនិនិត្យនិងចុះហត្ថលេខា ។<br>៦. ប្រព័ន្ធកញ្ចក់ថវិកា ត្រូវបានកែសម្រួលលើស្ថិរភាព និងសុវត្ថិភាពសម្រាប់ជំនាន់ទី២<br>៧. ការចុះត្រួតពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីនៅខេត្តគោលដៅទាំង១៨ ត្រូវបានរៀបចំរួច និងមានរបាយការណ៍ពីរបកគំហើញ និងអនុសាសន៍នានានិងដាក់ឱ្យអនុវត្ត ។ |
| ៣១.២ | រៀបចំយុទ្ធសាស្ត្រ ពង្រីកថវិកាកម្មវិធីដល់ ក្រសួង ស្ថាប័ន នៅឆ្នាំ ២០១៨ និងរដ្ឋបាលរាជធានី-ខេត្ត នៅឆ្នាំ ២០២០ | -អគ្គ.ថវិកា<br>-អគ្គ.ហិរញ្ញវត្ថុរដ្ឋ-បាលថ្នាក់ក្រោមជាតិ | រដ្ឋបាល ខេត្តចំនួន ១៨ ត្រូវបានដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ | ០.១៥ | ៩៣% | ១៤% | ១. សៀវភៅថវិកាកម្មវិធីរដ្ឋបាលរាជធានី ខេត្តទាំង ២៤ ត្រូវបានរៀបចំរួច ។<br>២. របាយការណ៍វាយតម្លៃសមិទ្ធកម្មពាក់កណ្តាលឆ្នាំរបស់រដ្ឋបាលខេត្តទាំង ១៨ ត្រូវបានរៀបចំ ។<br>៣. ទម្រង់របាយការណ៍អនុវត្តថវិកាកម្មវិធីប្រចាំឆ្នាំត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ។ |
| ៣១.៣ | អនុវត្តផែនការបណ្តុះបណ្តាលនិងការកសាងសមត្ថភាពសម្រាប់ការពង្រឹងនិងពង្រីកការអនុវត្តថវិកាតាមកម្មវិធី | -អគ្គ.ថវិកា<br>-អគ្គ.លទ្ធកម្មសាធារណៈ<br>-អគ្គ.រតនាគារជាតិ<br>-វិទ្យាស្ថានសេដ្ឋកិច្ច<br>-ក្រសួង ស្ថាប័ន | ១. ក្រសួង ស្ថាប័នទទួលបានការបណ្តុះបណ្តាលស្តីពីថវិកាកម្មវិធី និងកិច្ចលទ្ធកម្ម<br>២. ក្រសួងស្ថាប័ន ទទួលបានការបណ្តុះបណ្តាលស្តីពីការរៀបចំរបាយការណ៍ចំណូល និងចំណាយថវិកានិង រដ្ឋទេយ្យតាមកម្មវិធី | ០.២៥ | ១០០% | ២៥% | ១. មន្ត្រីនៃក្រសួង-ស្ថាប័ន អនុវត្តថវិកាកម្មវិធីទទួលបានការបណ្តុះបណ្តាល រួមមាន÷<br>-ក្រសួងមហាផ្ទៃ (ផ្នែកសន្តិសុខ)<br>- ក្រសួងយុត្តិធម៌<br>- ក្រសួងការពារជាតិ<br>- តុលាការកំពូល<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងធម្មការ និងសាសនា<br>- ក្រសួងកិច្ចការនារី |

| ល.រ. | គោលបំណង/ចង្កោមសកម្មភាព | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | ទម្ងន់ | វឌ្ឍន-ភាព % | ពិន្ទុថ្លឹង | វឌ្ឍនភាពសំខាន់ៗ |
|---|---|---|---|---|---|---|---|
| | | | | | | | - ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>២. រដ្ឋបាលរាជធានីទាំង ២៥ ទទួលបានការបណ្តុះ-បណ្តាលការរៀបចំថវិកាកម្មវិធី ។ |
| ៣១.៤ | ត្រួតពិនិត្យឡើងវិញ លើការអនុវត្តសិទ្ធិអំណាច និងភាពទន់ភ្លន់ដែលបានផ្តល់ជូនអង្គភាពថវិកា និងធ្វើបច្ចុប្បន្នភាព | -អគ្គ. ថវិកា<br>-ក្រសួង ស្ថាប័ន | ១. របាយការណ៍តាមដានការអនុវត្តវិធានការកែលម្អ នៃការអនុវត្តសិទ្ធិអំណាចរបស់អង្គភាពថវិកា ត្រូវបានរៀបចំ(ក្រសួង-ស្ថាប័ន)<br>២. គោលការណ៍ណែនាំ ត្រូវបានដាក់ឱ្យអនុវត្ត | ០.៣៥ | ១០០% | ៣៥% | កិច្ចប្រជុំត្រួតពិនិត្យលើការអនុវត្តសិទ្ធិនិងភារកិច្ចរបស់អង្គភាពថវិកា ២ លើក ជាមួយក្រសួង ស្ថាប័ន ចំនួន ២៧ ក្នុងខែកញ្ញា ត្រូវបានរៀបចំ ។ |
| **៣២** | **រៀបចំថវិកាឱ្យមានលក្ខណៈ គ្រប់ជ្រុង-ជ្រោយ និងធ្វើសមាហរណកម្មថវិកា** | **-** | **-** | **០.១៥** | **១០០%** | **១៥%** | |
| ៣២.១ | បន្តកែលម្អការធ្វើសមាហរណកម្មថវិកាចរន្ត និងថវិកាមូលធនតាមរយៈក្របខណ្ឌចំណាយរយៈពេលមធ្យម (MTFF) ផែនការយុទ្ធសាស្ត្រថវិកា (BSP) និងថវិកាកម្មវិធី (PB) ដោយរំលេចពីការកាត់បន្ថយភាពក្រីក្រ និងយេនឌ័រនៅក្នុងការរៀបចំ PB និងផែនការយុទ្ធសាស្ត្រថវិកា | -អគ្គ. ថវិកា,<br>-អគ្គ. រតនាគារ ជាតិ<br>-អគ្គ. លទ្ធកម្មសាធារណៈ<br>-អគ្គ. គោលនយោបាយ,<br>-អគ្គ. សហប្រតិបត្តិ-ការអន្តរជាតិនិងគ្រប់គ្រងបំណុល<br>-ក្រសួង- ស្ថាប័ន | ១. គោលការណ៍ណែនាំស្តីពីផែនការលទ្ធកម្មដោយភ្ជាប់ជាមួយសំណើថវិកាប្រចាំឆ្នាំត្រូវបានអនុម័ត<br>២. គោលការណ៍ណែនាំស្តីពីផែនការរជ្ជទេយ្យបុរេប្រទានដោយភ្ជាប់ជាមួយសំណើថវិកាប្រចាំឆ្នាំត្រូវបានអនុម័ត<br>៣. រៀបចំផែនការលទ្ធកម្ម និងផែនការរជ្ជទេយ្យបុរេប្រទានដោយភ្ជាប់ជាមួយនូវសំណើថវិកាប្រចាំឆ្នាំ<br>៤. របាយការណ៍ស្តីពីសមាហរណកម្មថវិកាចរន្តនិងវិនិយោគតាមកម្មវិធី នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា | ០.៦៥ | ១០០% | ៦៥% | ១. បានកែលម្អការធ្វើសមាហរណកម្មថវិកាចរន្ត និងថវិកាមូលធន ក្នុងផែនការយុទ្ធសាស្ត្រថវិកា ។<br>២. ក្រសួង- ស្ថាប័នទាំង២៥ ដែលអនុវត្តថវិកាកម្មវិធីបានត្រួតពិនិត្យ និងវាយតម្លៃលើការរៀបចំ ផ.យ.ថ ។<br>៣. របាយការណ៍ស្តីពីការបែងចែកឥណទានថវិកាចំណាយវិនិយោគសាធារណៈហិរញ្ញប្បទានដោយថវិកាជាតិ (គម្រោងវិនិយោគផ្ទាល់) តាមកម្មវិធីត្រូវបានរៀបចំ ។ |

| ល.រ. | គោលបំណង/ចង្កោមសកម្មភាព | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | ទម្ងន់ | វឌ្ឍន-ភាព % | ពិន្ទុថ្មី | វឌ្ឍនភាពសំខាន់ៗ |
|---|---|---|---|---|---|---|---|
| ៣២.២ | បញ្ចូលចំណូល ចំណាយដែលនៅក្រៅបរិបទថវិកា ទៅក្នុងថវិកាប្រចាំឆ្នាំ ដោយរួមទាំងថវិកាគ្រឹះស្ថានសាធារណៈរដ្ឋបាល និងថវិកាដៃគូអភិវឌ្ឍ | -អគ្គ. ថវិកា<br>-អគ្គ. សហប្រតិ-បត្តិការ និងគ្រប់គ្រងបំណុល<br>-អគ្គ.ទ្រព្យសម្បត្តិ-រដ្ឋនិងចំណូលមិនមែនសារពើពន្ធ<br>-ក្រសួង ស្ថាប័ន | ១.ប្រតិបត្តិការចំណូល - ចំណាយសង្ខេបរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបានដាក់-បញ្ចូលក្នុងឧបសម្ព័ន្ធនៃច្បាប់ថវិកាប្រចាំឆ្នាំ<br>២.យន្តការប្រមូលការអនុវត្តថវិកាដៃគូអភិវឌ្ឍន៍ត្រូវបានបង្កើត | ០.៣៥ | ១០០% | ៣៥% | មាតិកាគណនីនៃប្លង់គណនេយ្យថវិកា (CoA) ថ្មីសម្រាប់គម្រោង/កម្មវិធីហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ត្រូវបានអនុវត្តទៅក្នុងក្រសួងសុខាភិបាល ។ |
| **៣៣** | **រៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធបន្ទាត់គណនេយ្យភាព (រវាងនីតិបញ្ញត្តិ និងនីតិប្រតិបត្តិ, រវាងកសហវ និងក្រសួង-ស្ថាប័ន និងនៅក្នុងក្រសួងស្ថាប័ន)** | **-** | **-** | **០.១៥** | **៩៥%** | **១៤%** | **-** |
| ៣៣.១ | ពិនិត្យ និងរៀបចំលិខិតបទដ្ឋានគតិយុត្តក្នុងក្របខណ្ឌនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ រដ្ឋាភិបាលក្នុងបរិបថនៃការអនុវត្តថវិកាកម្មវិធី | -កសហវ (គ្រប់អគ្គនាយកដ្ឋាន)<br>-ក្រសួង ស្ថាប័ន | របាយការណ៍ស្តីពីការពិនិត្យ និងសំណើរៀបចំលិខិតបទដ្ឋានគតិយុត្ត ត្រូវបានរៀបចំ | ០.២០ | ៩៥% | ១៩% | សេចក្តីពន្យល់ណែនាំស្តីពីទម្រង់នៃការរៀបចំការអនុវត្តនិងការរៀបចំរបាយការណ៍ចំណាយបន្ទុកបុគ្គលិកសម្រាប់ប្រើប្រាស់ផ្ទៃក្នុង កសហវ ត្រូវបានប្រជុំពិភាក្សា ។ |
| ៣៣.២ | កំណត់ឱ្យបានច្បាស់នូវបន្ទាត់គណនេយ្យភាពក្នុងការរៀបចំកម្មវិធីវិនិយោគសាធារណៈដើម្បីធានាសង្គតិភាពក្នុងថវិកាប្រចាំឆ្នាំ (កំណត់ពីការទទួលខុសត្រូវឱ្យបានច្បាស់លាស់រវាងក្រសួង ស្ថាប័ននីមួយៗ រួមមានក្រសួងផែនការ, ក្រុមប្រឹក្សាអភិវឌ្ឍន៍ | -ក្រសួងផែនការ<br>-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>-កសហវ | ១. ឯកសារទស្សនាទានស្តីពីក្របខណ្ឌរួមសម្រាប់គ្រប់គ្រងការវិនិយោគសាធារណៈត្រូវបានរៀបចំ<br>២. ឯកសារទស្សនាទានស្តីពីការគ្រប់គ្រងវិនិយោគសាធារណៈត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត | ០.៣០ | - | - | - |

| ល.រ. | គោលបំណង/ចង្កោមសកម្មភាព | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | ទម្ងន់ | វឌ្ឍន-ភាព % | ពិន្ទុថ្មីង | វឌ្ឍនភាពសំខាន់ៗ |
|---|---|---|---|---|---|---|---|
| | កម្ពុជា និងកសហរ. | | | | | | |
| ៣៣.៣ | កែលម្អសេចក្ដីព្រាងច្បាប់ថវិកាប្រចាំឆ្នាំ ដោយរួមបញ្ចូលព័ត៌មាន សំខាន់ដែលរួមមាន<br>(១)ការកំណត់ឱនភាពថវិកាស្របតាមប្រព័ន្ធ GFS<br>(២)សេចក្ដីព្រាងច្បាប់ទូទាត់ឆ្នាំមុន (N-1), លទ្ធផលការអនុវត្តថវិកាឆ្នាំបច្ចុប្បន្ន (ឆ្នាំ N) បណ្ដោះ-អាសន្ន (៣)តួលេខស្ដីពីបំណុល | -អគ្គ. ថវិកា<br>-អគ្គ. រតនាគារ ជាតិ<br>-អគ្គ. គោលនយោបាយ<br>-អគ្គ. សហប្រតិបត្តិការ និងគ្រប់គ្រងបំណុល | សេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវបានកែលម្អដោយរួមបញ្ចូលព័ត៌មាន សំខាន់រួមមាន÷<br>(១) សេចក្ដីព្រាងច្បាប់ ទូទាត់ឆ្នាំមុន (N-1)<br>(២) លទ្ធផលការអនុវត្ត ថវិកាឆ្នាំបច្ចុប្បន្ន (ឆ្នាំN) បណ្ដោះអាសន្ន<br>(៣).ការកំណត់ឱនភាពថវិកាស្របតាមប្រព័ន្ធ GFS | ០.៥០ | ១០០% | ៥០% | សេចក្ដីព្រាងច្បាប់ទូទាត់ឆ្នាំមុន(N-1), លទ្ធផលការអនុវត្តថវិកា ឆ្នាំបច្ចុប្បន្ន (ឆ្នាំ N)បណ្ដោះអាសន្ន ត្រូវបានរៀបចំ ។ |
| **៣៤** | **ពង្រឹងការរៀបចំគោលនយោបាយនិងការធ្វើផែនការហិរញ្ញវត្ថុ សាធារណៈ (ការរៀបចំគោលនយោបាយនិងផែនការចំណូលនិងចំណាយរយៈពេលមធ្យម)** | - | - | **០.២៥** | **១០០%** | **២៥%** | - |
| ៣៤.១ | រៀបចំ និងបង្កើនស័ក្ដិសិទ្ធភាពនិងប្រសិទ្ធភាពនៃក្របខណ្ឌ គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច | -អគ្គ. គោលនយោបាយ<br>- អគ្គ. ថវិកា | ១. គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដែលផ្អែកលើការវិភាគតាមវិស័យ ដោយបន្ថែមការវិភាគតាមអនុវិស័យមួយចំនួនត្រូវបានអនុវត្តដើម្បីបង្កើនប្រសិទ្ធភាពក្របខណ្ឌគោលនយោ-បាយម៉ាក្រូសេដ្ឋកិច្ច<br>២. បន្តពង្រឹង និងពង្រីកការរៀបចំគោលនយោ-បាយហិរញ្ញវត្ថុសាធារណៈសម្រាប់វិស័យអាទិភាពឱ្យស្របតាមបរិបទសេដ្ឋកិច្ច និង | ០.២៥ | ១០០% | ២៥% | ១. របាយការណ៍វឌ្ឍនភាពពាក់កណ្ដាលឆ្នាំស្ដីពីស្ថានភាពសេដ្ឋកិច្ច (CMM) រយះពេល ០៩ខែ ត្រូវបានរៀបចំ ។<br>២. របាយការណ៍ Economic Surveillance ប្រចាំត្រីមាសទី២ ឆ្នាំ២០១៩ ត្រូssវបានរៀបចំ ។<br>៣ ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលន-យោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២០ត្រូវបានរៀបចំ ។<br>៤. របាយការណ៍ស្ដីពីសកម្មភាពសេដ្ឋកិច្ចតាមវិស័យប្រចាំត្រីមាសទី២ ឆ្នាំ២០១៩ ត្រូវបានរៀបចំ ។ |

| ល.រ. | គោលបំណង/ចង្កោមសកម្មភាព | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | ទម្ងន់ | វឌ្ឍន-ភាព % | ពិន្ទុថ្លឹង | វឌ្ឍនភាពសំខាន់ៗ |
|---|---|---|---|---|---|---|---|
| | | | គោលនយោបាយជាតិសម្រាប់ប្រើប្រាស់ជាធាតុចូលសម្រាប់ការរៀបចំក្របខណ្ឌសារពើ-ពន្ធ រយៈពេលមធ្យម។ | | | | |
| ៣៤.២ | រៀបចំ និងបង្កើន ស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃក្របខណ្ឌហិរញ្ញវត្ថុសាធារណៈ (MTFF) រយៈពេលមធ្យម (ចំណូល-ចំណាយ) និងក្របខណ្ឌថវិការយៈពេលមធ្យម (MTBF) | -អគ្គ.គោលនយោបាយ<br>-ក្រសួងផែនការ<br>-អគ្គ.ថវិកា<br>-ទីស្តី.គណៈរដ្ឋមន្ត្រី<br>-អគ្គលេខា.រដ្ឋសភា<br>-អគ្គលេខាធិការ-ដ្ឋានព្រឹទ្ធសភា | ១. ក្របខណ្ឌហិរញ្ញវត្ថុសាធារណៈ (MTFF) រយៈពេលមធ្យម ត្រូវបានដាក់ឲ្យអនុវត្តសាកល្បង<br>២. ទស្សនទានក្របខណ្ឌថវិការយៈពេលមធ្យម ត្រូវបានរៀបចំ និងអនុម័ត<br>៣. សេចក្តីព្រាងក្របខណ្ឌថវិការយៈពេលមធ្យម (MTBF) ត្រូវបានធ្វើសុពលភាព | ០.៥០ | ១០០% | ៥០% | ១. MTFF ត្រូវបានដាក់ជូនថ្នាក់ដឹកនាំ កសហវ ។<br>២. ទស្សនទានក្របខណ្ឌថវិការយៈពេលមធ្យមត្រូវបានរៀបចំ និងអនុម័ត ។<br>៣. សេចក្តីព្រាងក្របខណ្ឌថវិការយៈពេលមធ្យម (MTBF) ត្រូវបានធ្វើសុពលភាព ។ |
| ៣៤.៣. | ពង្រឹងសមត្ថភាពវិភាគ និងព្យាករណ៍ស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | -អគ្គ. គោលនយោបាយ<br>-ក្រសួងផែនការ | ១. ម៉ូដែលព្យាករណ៍ម៉ាក្រូសេដ្ឋកិច្ចត្រូវបានធ្វើបច្ចុប្បន្នកម្ម និងប្រើប្រាស់ (Version 2)<br>២. ប្រព័ន្ធ MEF Database Web-based System ត្រូវបានធ្វើបច្ចុប្បន្នភាព និងពង្រីកទិន្នន័យ<br>៣. ស្ថិតិគណនេយ្យជាតិត្រូវបានកែលម្អទាំងវិធីសាស្ត្រ និងឆ្នាំគោលថ្មី<br>៤. ស្ថិតិគណនេយ្យជាតិឆ្នាំ ២០១៨ ត្រូវបានផ្សព្វផ្សាយ | ០.២៥ | ១០០% | ២៥% | ១. វគ្គបណ្តុះបណ្តាលស្តីពីសារសំខាន់ និងការប្រើប្រាស់ Online MEF Database សម្រាប់ការវិភាគសេដ្ឋកិច្ច និងផែនការថវិកាមូលដ្ឋានដល់មន្ត្រីស្ថិតិថ្នាក់ក្រោម-ជាតិ ត្រូវបានរៀបចំ ។<br>២. ម៉ូដែលព្យាករម៉ាក្រូសេដ្ឋកិច្ចកម្ពុជា (Cambodia Macroeconomic Forecasting Model - CMFM) ត្រូវបានធ្វើបច្ចុប្បន្នកម្ម និងប្រើប្រាស់ (version ២.០) ដោយមានជារបាយការណ៍វាយតម្លៃលើម៉ូដែលព្យាករម៉ាក្រូសេដ្ឋកិច្ច ។<br>៣. របាយការណ៍សិក្សា (Feasibility Study) ស្តីពីការអភិវឌ្ឍ Mobile MEF Database Application ពីប្រព័ន្ធ MEF Database ។ |
| **៣៥** | **ពង្រឹងការអនុវត្តគោលនយោបាយ** | - | - | **០.២០** | **៩០%** | **១៨%** | - |

| ល.រ. | គោលបំណង/ចង្កោមសកម្មភាព | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | ទម្ងន់ | វឌ្ឍន-ភាព % | ពិន្ទុថ្លឹង | វឌ្ឍនភាពសំខាន់ៗ |
|---|---|---|---|---|---|---|---|
| | **វិមជ្ឈការហិរញ្ញវត្ថុ** | | | | | | |
| ៣៥.១ | អនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិឆ្នាំ ២០១៩-២០២៥ | អគ្គ. ហិរញ្ញវត្ថុរដ្ឋបា-លថ្នាក់ក្រោមជាតិ | ១. យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់-ក្រោមជាតិឆ្នាំ២០១៩-២០២៥ត្រូវបានអនុម័ត<br>២. ផែនការសកម្មភាពគាំទ្រដល់ការអនុវត្តយុទ្ធ-សាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥ត្រូវបានរៀបចំ | ០.១៥ | ៩២% | ១៤% | ១. យុទ្ធសាស្ត្រកំណែទម្រង់ប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិ ២០១៩-២០២៥ ត្រូវបានដាក់ឱ្យអនុវត្តនិងផ្សព្វផ្សាយ ។<br>២. ផែនការសកម្មភាពលម្អិតសម្រាប់អនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ។ |
| ៣៥.២ | អនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុដែលបានកំណត់ នៅក្នុងផែនការអនុវត្ត ៣ ឆ្នាំ (២០១៨-២០២០) នៃកម្មវិធីជាតិ | -អគ្គ. ហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ | ១. ដាក់ឱ្យអនុវត្តអនុក្រឹត្យពីការផ្ទេរធនធានពីថវិកាថ្នាក់ជាតិជូនរដ្ឋបាល ក្រុង ស្រុក និងឃុំ សង្កាត់<br>២. ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ថ្មីត្រូវបាន ដាក់ឱ្យអនុវត្ត | ០.២០ | ៧៣% | ១៤% | ១. អនុក្រឹត្យស្តីពីការតំឡើងប្រាក់ឧបត្ថម្ភក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំរួច និងដាក់ឲ្យអនុវត្ត ។<br>២. សេចក្តីព្រាងប្រកាសបង្កើតក្រុមការងារបច្ចេកទេស D&D ប្រចាំកសហវ ត្រូវបានរៀបចំរួច ។<br>៣. សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃមូលនិធិឃុំ សង្កាត់ ត្រូវបានរៀបចំ និងដាក់ពិភាក្សាជាមួយអ្នកពាក់ព័ន្ធ ។<br>៤. សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងជំនួយការរដ្ឋបាលឃុំ សង្កាត់ត្រូវបានរៀបចំរួច ។ |
| ៣៥.៣ | អនុវត្តសាកល្បង និងពង្រីកមូលនិធិវិនិយោគសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ (SNIF) | អគ្គ. ហិរញ្ញវត្ថុរដ្ឋបា-លថ្នាក់ក្រោមជាតិ | ក្រុង៥ និងស្រុកចំនួន ២៨ត្រូវបានជ្រើសរើសសម្រាប់អនុវត្តមូលនិធិវិនិយោគសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ | ០.២០ | ១០០% | ២០% | ១. សេចក្តីព្រាងអនុក្រឹត្យស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៣២ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំរួច ។<br>២. គោលការណ៍ណែនាំស្តីពីការវាយតម្លៃសមិទ្ធិកម្មរដ្ឋបាលក្រុង ខណ្ឌ ត្រូវបានរៀបចំដាក់ឱ្យអនុវត្ត និងផ្សព្វផ្សាយ។<br>៣. សេចក្តីណែនាំបន្ថែមស្តីពីសំណើគម្រោងវិនិយោគរដ្ឋបាលក្រុង ត្រូវបានរៀបចំរួច ។ |

| ល.រ. | គោលបំណង/ចង្កោមសកម្មភាព | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | ទម្ងន់ | វឌ្ឍន-ភាព % | ពិន្ទុ ទ្ធីឯ | វឌ្ឍនភាពសំខាន់ៗ |
|---|---|---|---|---|---|---|---|
| | | | | | | | ៤. ទម្រង់បាយការណ៍ផែនការសកម្មភាពការងាររដ្ឋបាលខណ្ឌត្រូវបានរៀបចំជាសេចក្តីព្រាង ។ |
| ៣៥.៤ | ពិនិត្យមើលឡើងវិញនិងដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីផែនការយុទ្ធសាស្ត្រថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ | អគ្គ.ហិរញ្ញវត្ថុរដ្ឋបា-លថ្នាក់ក្រោមជាតិ | ផែនការយុទ្ធសាស្ត្រថវិកា ត្រូវបានដាក់ឱ្យអនុវត្តនៅ ៦ រដ្ឋបាលខណ្ឌ និង ១៣ ក្រុង | ០.៣០ | ១០០% | ៣០% | ១. គោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិការដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកែលម្អ ជាពិសេសការផ្សារភ្ជាប់គោលនយោបាយទៅនឹងកម្មវិធី ។<br>២. ផែនការយុទ្ធសាស្ត្រថវិការដ្ឋបាលរាជធានី ខេត្ត ត្រូវបាន ផ្សព្វផ្សាយ និងបណ្តុះបណ្តាលជូនមន្ត្រីរដ្ឋបាលរាជធានី ខេត្ត ។ |
| ៣៥.៥ | ពិនិត្យនិងកែសម្រួលគោលការណ៍ណែនាំស្តីពីការរៀបចំនិងនីតិវិធីអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកា សម្រាប់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ | អគ្គ.ហិរញ្ញវត្ថុរដ្ឋបា-លថ្នាក់ក្រោមជាតិ | រដ្ឋបាលខេត្តសរុបចំនួន ១៨ ត្រូវបានដាក់ឱ្យអនុវត្តថវិកាកម្មវិធី | ០.០៥ | ១០០% | ៥% | គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធីសម្រាប់រដ្ឋបាលរាជធានី ខេត្ត ត្រូវបានកែលម្អ និងដាក់ឱ្យអនុវត្ត ។ |
| ៣៥.៦ | ពិនិត្យនិងវាយតម្លៃការអនុវត្តថវិកាការផ្ទេរមុខងាររបស់ក្រសួង- ស្ថាប័នជូនរដ្ឋបាលថ្នាក់ក្រោមជាតិ | អគ្គ.ហិរញ្ញវត្ថុរដ្ឋបា-លថ្នាក់ក្រោមជាតិ | ១.របាយការណ៍ពិនិត្យ និងវាយតម្លៃការអនុវត្តថវិកាការផ្ទេរមុខងាររបស់ក្រសួងបរិស្ថាន និងក្រសួងអភិវឌ្ឍន៍ជនបទត្រូវបានរៀបចំ<br>២.ក្របខណ្ឌគតិយុត្តិ/ ប្រកាសនៃការអនុវត្តថវិកាការផ្ទេរមុខងាររបស់ក្រសួងបរិស្ថានត្រូវបានរៀបចំរួច និងដាក់ឱ្យអនុវត្ត | ០.១០ | ៦៧% | ៧% | ១. របាយការណ៍នៃការពិនិត្យ វាយតម្លៃនិងរបកគំហើញនៃការអនុវត្តថវិកា ការផ្ទេរមុខងាររបស់ក្រសួងបរិស្ថាន និងក្រសួងអភិវឌ្ឍជនបទ ត្រូវបានដាក់ជូនថ្នាក់ដឹកនាំពិនិត្យនិងផ្តល់យោបល់ ។<br>២. សេចក្តីព្រាងប្រកាសស្តីពីការគ្រប់គ្រងកញ្ចប់ថវិកាសេវាអនាម័យបរិស្ថានត្រូវបានរៀបចំ ។ |
| **ផ្នែកទី៤ ÷ គណនេយ្យភាពសមិទ្ធកម្ម** | | | | **០.២០** | **៨៨%** | **១៨%** | **-** |
| **៤១** | **បង្កើតក្របខណ្ឌថវិកាផ្អែកលើព័ត៌មានសមិទ្ធកម្ម (Performance Informed Budgeting)** | **-** | **១.ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ត្រូវបានត្រួតពិនិត្យ**<br>**២.អនុក្រឹត្យលេខ ៨១ និង៨២ ត្រូវបានសិក្សា** | **០.៣០** | **១០០%** | **៣០%** | **-** |

| ល.រ. | គោលបំណង/ចង្កោមសកម្មភាព | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | ទម្ងន់ | វឌ្ឍន-ភាព % | ពិន្ទុថ្លឹង | វឌ្ឍនភាពសំខាន់ៗ |
|---|---|---|---|---|---|---|---|
| | | | **៣. គោលការណ៍ណែនាំស្តីពីរៀបចំថវិកាសមិទ្ធកម្មត្រូវបានរៀបចំ និងអនុម័ត**<br>**៤. គោលការណ៍ណែនាំស្តីពីការអនុវត្តថវិកាសមិទ្ធកម្មត្រូវបានសិក្សា** | | | | |
| ៤១.១ | សិក្សានិងរៀបចំក្របខណ្ឌគោលនៃគោលការណ៍ថវិកាព័ត៌មានសមិទ្ធកម្ម (Performance informed Budgeting) | អគ្គ.ថវិកា | ១. ទម្រង់កិច្ចព្រមព្រៀងព័ត៌មានសមិទ្ធកម្មត្រូវបានរៀបចំ<br>២. ចំណាត់ថ្នាក់សេដ្ឋកិច្ចបំព្រួញត្រូវបានរៀបចំសម្រាប់ភ្ជាប់ច្បាប់ថវិកាប្រចាំឆ្នាំ | ០.២៥ | ១០០% | ២៥% | ១. ទម្រង់កិច្ចព្រមព្រៀងព័ត៌មានសមិទ្ធកម្មត្រូវបានរៀបចំបឋម ។<br>២. ចំសណាត់ថ្នាក់សេដ្ឋកិច្ចបំព្រួញត្រូវបានរៀបចំជាឯកសារទស្សនាទាន ។ |
| ៤១.២ | សិក្សា និងរៀបចំបទដ្ឋានគតិយុត្តិសម្រាប់ការអនុវត្តថវិកាសមិទ្ធកម្ម | អគ្គ.ថវិកា | ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ ត្រូវបានត្រួតពិនិត្យ និងដាក់ឱ្យពិភាក្សាផ្ទៃក្នុង កសហវ | ០.២០ | ១០០% | ២០% | ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ ត្រូវបានត្រួតពិនិត្យ និងសិក្សា ។ |
| ៤១.៣ | រៀបចំយន្តការ និងឧបករណ៍សាកល្បងសម្រាប់ត្រួតពិនិត្យសមិទ្ធកម្មសម្រាប់ក្រសួង-ស្ថាប័ន អនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម | អគ្គ. ថវិកា | ក្របខណ្ឌទស្សនាទាននៃការតាមដាន និងត្រួតពិនិត្យព័ត៌មានសមិទ្ធកម្ម ត្រូវបានរៀបចំ | ០.២០ | ១០០% | ២៥% | តារាងពាក់ព័ន្ធនឹងថវិកាព័ត៌មានសមិទ្ធកម្ម (នៅត្រូវឆ្លងការពិភាក្សាកម្រិតនាយកដ្ឋាន) ត្រូវបានរៀបចំ ។ |
| ៤១.៤ | ត្រួតពិនិត្យអនុក្រឹត្យលេខ ៨១ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័តរាជធានីភ្នំពេញ និងអង្គការ សាធារណៈ និងអនុក្រឹត្យ លេខ ៨២ ស្តីពីបទបញ្ជាទូទៅ នៃ គណនេយ្យសាធារណៈ និងរៀបចំគោលការណ៍ណែនាំស្តីពី | -អគ្គ. ថវិកា<br>-អគ្គ.រតនាគារជាតិ | អនុក្រឹត្យលេខ ៨១ និងលេខ ៨២ ត្រូវបានត្រួតពិនិត្យ (មានរបាយការណ៍វឌ្ឍនភាព) | ០.១០ | ១០០% | ១០% | ក្រុមការងាររៀបចំកែសម្រួលអនុក្រឹតលេខ ៨១ ស្តីពីការ-បង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័តរាជធានីភ្នំពេញនិងអង្គការសាធារណៈ និងអនុក្រឹតលេខ៨២ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ បានបង្កើត ព្រមទាំងបានរៀបចំកិច្ចប្រជុំត្រួតពិនិត្យជាបន្តបន្ទាប់ជាមួយជំនាញការបារាំង ។ |

| ល.រ. | គោលបំណង/ចង្កោមសកម្មភាព | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | ទម្ងន់ | វឌ្ឍន-ភាព % | ពិន្ទុ ទ្ធិង | វឌ្ឍនភាពសំខាន់ៗ |
|---|---|---|---|---|---|---|---|
| | ការអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម | | | | | | |
| ៤១.៥ | សិក្សាការរៀបចំមុខងារអភិបាលថវិកា (អភិបាលហិរញ្ញវត្ថុ និង លទ្ធកម្មសាធារណៈ) នៅតាមក្រសួង ស្ថាប័ន | -អគ្គ. ថវិកា<br>-អគ្គ. លទ្ធកម្មសាធារណៈ<br>-អគ្គ.រតនាគារ | - | ០.២៥ | - | - | - |
| **៤២** | **រៀបចំ និងដាក់ឱ្យអនុវត្តក្របខណ្ឌគណនេយ្យភាពសមិទ្ធកម្ម** | - | **១. របាយការណ៍សនវកម្មសមិទ្ធកម្មរបស់អាជ្ញាធរសវនកម្មជាតិចំនួន ៤ ត្រូវបានដាក់ជូនរដ្ឋសភាជាតិ**<br>**២. គោលការណែនាំស្ដីពីការធ្វើសវនកម្មលើសមិទ្ធកម្ម ត្រូវបានរៀបចំ និងដាក់អនុវត្ត** | **០.៣០** | **១០០%** | **៣០%** | - |
| ៤២.១ | រៀបចំគោលការណ៍ណែនាំស្តីពីការធ្វើសវនកម្មសមិទ្ធកម្ម សម្រាប់សវនកម្មផ្ទៃក្រៅ | -អាជ្ញាធរសវនកម្មជាតិ<br>- អគ្គ.សវនកម្មផ្ទៃក្នុង | សេចក្តីព្រាងគោលការណ៍ណែនាំស្តីពីការធ្វើសវនកម្មសមិទ្ធកម្មត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | ០.៥០ | ១០០% | ៥០% | គោលការណ៍ណែនាំស្តីពីការធ្វើសវនកម្មសមិទ្ធកម្មត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត (ដោយអាជ្ញាធរសវនកម្មជាតិ) ។ |
| ៤២.២ | រៀបចំ និងដាក់ជូនស្ថាប័ននីតិប្បញ្ញត្តិនូវរបាយការណ៍សវនកម្មសមិទ្ធកម្ម | -អាជ្ញាធរសវនកម្មជាតិ | របាយការណ៍សវនកម្មសមិទ្ធកម្មចំនួន ៤ ត្រូវបានដាក់ជូនស្ថាប័ននីតិប្បញ្ញត្តិ | ០.៥០ | ១០០% | ៥០% | របាយការណ៍សវនកម្មសមិទ្ធកម្មចំនួន ៤ ត្រូវបានដាក់ជូនស្ថាប័ននីតិប្បញ្ញត្តិ (ដោយអាជ្ញាធរសវនកម្មជាតិ) ។ |
| **៤៣** | **ពង្រឹងប្រសិទ្ធភាពប្រព័ន្ធត្រួតពិនិត្យ** | - | **ប្រព័ន្ធនិងយន្តការត្រួតពិនិត្យផ្ទៃក្នុង ត្រូវបានបង្កើតនិងអនុវត្តនៅក្រសួង-ស្ថាប័នចំនួន ៨** | **០.២០** | **៨០%** | **១៦%** | - |
| ៤៣.១ | ត្រួតពិនិត្យមើលឡើងវិញពីប្រព័ន្ធត្រួតពិនិត្យអធិការកិច្ច និង សវនកម្មផ្ទៃក្នុងនាពេលបច្ចុប្បន្ននៅគ្រប់ក្រសួង ស្ថាប័ន | - ក្រុមប្រឹក្សានីតិកម្ម<br>- អគ្គ.សវនកម្មផ្ទៃក្នុង<br>- អគ្គាធិការដ្ឋាន<br>- ក្រសួង-ស្ថាប័ន | ១. មុខងារសវនកម្មរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃក្រសួងស្ថាប័ន ចំនួន ៨ ត្រូវបានត្រួតពិនិត្យដោយអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃកសហវ. | ០.២០ | ១០០% | ២០% | ១. អង្គភាពសវនកម្មផ្ទៃក្នុងនៃក្រសួង ស្ថាប័នចំនួន ៨គោលដៅ ត្រូវបានពិនិត្យប្រសិទ្ធភាពនៃមុខងារសវនកម្មផ្ទៃក្នុង ។<br>២. ឧបករណ៍សវនកម្មនានាសម្រាប់ គាំទ្រមុខងារសវនកម្មផ្ទៃក្នុងត្រូវបានរៀបចំ និងអនុវត្ត ។<br>៣. ក្រសួងចំនួន ៥ បានធ្វើការវិភាគលើមុខងារនៃប្រព័ន្ធអធិការកិច្ចហិរញ្ញវត្ថុ ។ |

| ល.រ. | គោលបំណង/ចង្កោមសកម្មភាព | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | ទម្ងន់ | វឌ្ឍន-ភាព % | ពិន្ទុ ថ្លឹង | វឌ្ឍនភាពសំខាន់ៗ |
|---|---|---|---|---|---|---|---|
| | | | ២. ឧបករណ៍សវនកម្មនានាសម្រាប់ គាំទ្រមុខងារសវនកម្មផ្ទៃក្នុង ចំនួន ១០ ត្រូវបានរៀបចំ និងអនុវត្ត | | | | |
| ៤៣.២ | ពង្រីកបន្ថែមមុខងារនៃការត្រួតពិនិត្យតាមប្រព័ន្ធព័ត៌មានវិទ្យា និងសមិទ្ធកម្ម ដើម្បីឱ្យស្របនឹងមុខងារប្រព័ន្ធថវិកាថ្មី | - អគ្គ. សវនកម្មផ្ទៃក្នុង<br>- អគ្គាធិការដ្ឋាន<br>- ក្រសួង ស្ថាប័ន | ១. គោលការណែនាំស្តីពីការធ្វើសវនកម្មលើបច្ចេកវិទ្យាព័ត៌មាន ត្រូវបានរៀបចំ និងដាក់អនុវត្ត<br>២. គោលការណែនាំស្តីពីការធ្វើសវនកម្មលើសមិទ្ធកម្ម ត្រូវបានរៀបចំ និងដាក់អនុវត្ត | ០.២០ | ៥៨ | ១២% | ១. គោលការណ៍ណែនាំស្តីពីសវនកម្មបច្ចេកវិទ្យាព័ត៌មាន (IT audit) ត្រូវបានរៀបចំ និងដាក់អនុវត្ត ។<br>២. គោលការណែនាំស្តីពីការធ្វើសវនកម្មលើសមិទ្ធកម្ម ត្រូវបានរៀបចំ (គ្រោងដាក់ឱ្យអនុវត្តនៅឆ្នាំ២០២០) ។ |
| ៤៣.៣ | ថ្នាក់ដឹកនាំគ្រប់ក្រសួង-ស្ថាប័ន ឆ្លើយតបនឹងអនុសាសន៍/វិធានការ ដែលបានលើកឡើងដោយសវនករផ្ទៃក្នុង និងអធិការកិច្ចហិរញ្ញវត្ថុ | - អគ្គ. សវនកម្មផ្ទៃក្នុង<br>- អគ្គាធិការដ្ឋាន<br>- ក្រសួង ស្ថាប័ន | ១. យ៉ាងតិចអនុសាសន៍ ៥០% ដែលបានលើកឡើងដោយសវនករផ្ទៃក្នុងនៃអង្គភាពក្រោមនិវាទ កសហវ ត្រូវបានកែលម្អ និងយ៉ាងតិច ៣០%នៃអង្គភាពដែលបានកែលម្អតាមអនុសាសន៍សវនករតិចជាង ៥០% ត្រូវអនុវត្តវិធានការបន្ថែម<br>២. ក្រសួង-ស្ថាប័ន/អង្គភាព ៥០% បានឆ្លើយតប និងកែលម្អតាមវិធានការ | ០.២០ | ១០០% | ២០% | ១. យ៉ាងតិច ៥០%នៃអនុសាសន៍របស់អង្គភាពក្រោមនិវាទ កសហវ ចំនួន ១៥គោលដៅ ដែលបានលើកឡើងដោយសវនករត្រូវបានកែលម្អ និងយ៉ាងតិច ៣០% នៃអង្គភាពដែលបានកែលម្អតិចជាង៥០%ត្រូវមានវិធានការបន្ថែម ។<br>២. ៥០%នៃក្រសួងស្ថាប័នដែលត្រូវបានចាត់វិធានក្នុងឆ្នាំ២០១៨ ត្រូវបានតាមដាន ។ |
| ៤៣.៤ | រៀបចំនិងកែលម្អផែនការសកម្មភាពកម្មវិធី និង របាយការណ៍ សវនកម្ម/អធិការកិច្ចប្រចាំឆ្នាំ របស់ក្រសួងស្ថាប័នដោយផ្អែកលើលក្ខណៈ វិនិច្ឆ័យ និងចាត់វិធានការវាយតម្លៃហានិភ័យ ដែលផ្តល់អនុសាសន៍ ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | - អគ្គ. សវនកម្មផ្ទៃក្នុង<br>- អគ្គាធិការដ្ឋាន<br>-ក្រសួង ស្ថាប័ន | ១. ក្រសួង-ស្ថាប័ន ចំនួន ២៥ មានផែនការយុទ្ធសាស្ត្រសវនកម្ម និងផែនការសវនកម្មប្រចាំឆ្នាំ<br>២. យ៉ាងតិច ៩០% នៃផែនការសកម្មភាពទាំងអស់ដែលមាននៅក្នុងផែនការសវនកម្មប្រចាំឆ្នាំរបស់កសហវ ត្រូវបានអនុវត្ត<br>៣. យ៉ាងតិច ៦០% នៃផែនការសកម្មភាពទាំងអស់ដែលមាននៅក្នុងផែនការសវនកម្មប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័នត្រូវបានអនុវត្ត | ០.២០ | ១០០% | ២០% | ១. ក្រសួង ស្ថាប័នចំនួន ២៥ ត្រូវបានតាមដានលើការរៀបចំផែនការយុទ្ធសាស្ត្រនិងផែនការសវនកម្មប្រចាំឆ្នាំ និងចាត់វិធានការជំរុញចំពោះក្រសួង ស្ថាប័ន ដែលពុំទាន់មានផែនការយុទ្ធសាស្ត្រនិងផែនការសវនកម្មប្រចាំឆ្នាំ ។<br>២. សេចក្តីព្រាងបឋមនៃផែនការយុទ្ធសាស្ត្រអធិការកិច្ចហិរញ្ញវត្ថុ២០២១-២០២៥ ត្រូវបានរៀបចំ ។ |

| ល.រ. | គោលបំណង/ចង្កោមសកម្មភាព | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | ទម្ងន់ | វឌ្ឍន-ភាព % | ពិន្ទុថ្លឹង | វឌ្ឍនភាពសំខាន់ៗ |
|---|---|---|---|---|---|---|---|
| | | | ៤. យ៉ាងតិច ៩០% នៃផែនការសកម្មភាពអធិការកិច្ចប្រចាំឆ្នាំ និងកម្មវិធីអធិការកិច្ចប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័នត្រូវបានអនុវត្ត | | | | ៣. ផែនការយុទ្ធសាស្ត្រ និងផែនការសវនកម្មប្រចាំឆ្នាំរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃក្រសួង ស្ថាប័នចំនួន ១២ ត្រូវបានពិនិត្យនិងផ្តល់យោបល់កែលម្អតាមនីតិវិធីជាស្តង់ដា ។<br>៤. យ៉ាងតិច ៩០%នៃផែនការសកម្មភាពដែលមាននៅក្នុងផែនការសវនកម្មប្រចាំត្រីមាសទី៣ ចំនួន ៣០ គោលដៅ ត្រូវបានអនុវត្ត ។<br>៥. យ៉ាងតិច៦០%នៃផែនការកម្មភាពដែលមាននៅក្នុងផែនការសវនកម្មប្រចាំត្រីមាសទី៣ របស់អង្គភាពសវន-កម្មផ្ទៃក្នុងនៃក្រសួង ស្ថាប័ន ចំនួន ៨ត្រូវបានអនុវត្ត ។ |
| ៤៣. ៥ | រៀបចំក្របខណ្ឌអធិការកិច្ចហិរញ្ញវត្ថុ | - អគ្គាធិការដ្ឋាន<br>- ក្រសួង ស្ថាប័ន | ១. អនុក្រឹត្យស្តីពីវិធាននិងនីតិវិធីអធិការកិច្ចហិរញ្ញវត្ថុត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត<br>២. សៀវភៅគោលស្តីពីអធិការកិច្ចហិរញ្ញវត្ថុត្រូវបានរៀបចំនិងដាក់ឱ្យអនុម័ត<br>៣. សេចក្តីព្រាងស្តង់ដាអធិការកិច្ចហិរញ្ញវត្ថុត្រូវបានរៀបចំ<br>៤. ប្រព័ន្ធការងារអធិការកិច្ចហិរញ្ញវត្ថុតាមបច្ចេក-វិទ្យាព័ត៌មានត្រូវបានរៀបចំនិងអនុវត្តសាកល្បង<br>៥. ក្រមសីលធម៌វិជ្ជាជីវៈអធិការកិច្ចហិរញ្ញវត្ថុរៀបចំ និងដាក់ឱ្យអនុវត្ត | ០.២០ | ៩២% | ១៨% | ១. អនុក្រិតស្តីពីវិធាន និងនីតិវិធីអធិការកិច្ចហិរញ្ញវត្ថុត្រូវបានថ្នាក់ដឹកនាំ កសហវ សម្រេចព្យួរទុកសិន<br>២. សៀវភៅគោលស្តីពីអធិការកិច្ចហិរញ្ញវត្ថុត្រូវបានរៀបចំ និងអនុម័ត តាមប្រកាសលេខ០០៩ សហវ ប្រក ចុះថ្ងៃទី១៣ មករា ឆ្នាំ២០២០ ។<br>៣. សេចក្តីព្រាងស្តីពីស្តង់ដាអធិការកិច្ចហិរញ្ញវត្ថុត្រូវបានរៀបចំ<br>៤. ដាក់ឱ្យប្រើប្រាស់សាកល្បងនូវប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងការងារអធិការកិច្ចហិរញ្ញវត្ថុ (FIDS)<br>៥. ក្រមសីលធម៌វិជ្ជាជីវៈអធិការកិច្ចហិរញ្ញវត្ថុត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ដោយថ្នាក់ដឹកនាំ កសហវ |
| **៤៤** | **រៀបចំ និងអនុវត្តផែនការកសាងសមត្ថភាព (ដោយរួមទាំងស្ថាប័ននីតិប្បញ្ញត្តិ និង អាជ្ញាធរ សវនកម្មជាតិ)** | **-** | **មានសេចក្តីព្រាងផែនការយុទ្ធសាស្ត្រកសាងនិងអភិវឌ្ឍសមត្ថភាពក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤** | **០.២០** | **៩២%** | **១៨%** | **-** |

| ល.រ. | គោលបំណង/ចង្កោមសកម្មភាព | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | ទម្ងន់ | វឌ្ឍន-ភាព % | ពិន្ទុ ថ្លឹង | វឌ្ឍនភាពសំខាន់ៗ |
|---|---|---|---|---|---|---|---|
| ៤៤.១ | រៀបចំធ្វើបច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រស្តីពីការកសាងនិងអភិវឌ្ឍសមត្ថភាពក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ (២០២០-២០២៥) | វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សេចក្តីព្រាងឯកសារស្តីពីការបច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រស្តីពីការកសាងនិងអភិវឌ្ឍសមត្ថភាពក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញ-វត្ថុសាធារណៈ ដំណាក់កាលទី០៤ (២០២០-២០២៥) ត្រូវបានរៀបចំ | ០.៥០ | ១០០% | ៥០% | ១. របាយការណ៍ស្តីពី ការត្រួតពិនិត្យ និងវាយតម្លៃនៃការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការកសាងនិងអភិវឌ្ឍសមត្ថភាពក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣ ត្រូវបានរៀបចំ និងបោះពុម្ព ។<br>២. សេចក្តីព្រាងផែនការយុទ្ធសាស្ត្រស្តីពីការកសាងនិងអភិវឌ្ឍសមត្ថភាពក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៤ (២០២១-២០២៥) ត្រូវបានរៀបចំ និងពិគ្រោះយោបល់ជាមួយអគ្គនាយកដ្ឋានពាក់ព័ន្ធ នៃកសហវ និងដៃគូអភិវឌ្ឍន៍ ។ |
| ៤៤.២ | រៀបចំ និងអនុវត្តផែនការសកម្មភាពកសាងសមត្ថភាព(ដោយរួមទាំងស្ថាប័ននីតិប្បញ្ញត្តិ និងអាជ្ញាធរសវនកម្មជាតិ) | វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១. រៀបចំផែនការសកម្មភាពកសាងសមត្ថភាព ឆ្នាំ២០២០<br>២. វគ្គបណ្តុះបណ្តាលចំនួន ២ ត្រូវបានរៀបចំ | ០.៥០ | ៨៥% | ៤២% | បានរៀបចំនិងវាយតម្លៃផែនការបណ្តុះបណ្តាលនិងវិក្រឹតការ ឆ្នាំ២០១៩ ។ |
| **ផ្នែកទី ៥÷ ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព** | | | | **០.១៥** | **៩៦%** | **១៤%** | |
| **៥១** | **បង្កើនភាពជាអ្នកដឹកនាំ, សមត្ថភាពគ្រប់គ្រង, និង បណ្តុះឆន្ទៈកែទម្រង់ ព្រមទាំង បង្កើនភាពជាម្ចាស់ និងការទទួលខុសត្រូវ** | - | **យន្តការ នីតិវិធី នៃការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមក្រសួងស្ថាប័ន ត្រូវបានអនុវត្ត** | ០.៤០ | **៩៨%** | **៣៩%** | - |
| ៥១.១ | ពង្រឹងការអនុវត្តវិធាននិងនីតិវិធីពាក់ព័ន្ធនឹងយន្តការរៀបចំនិងអនុវត្តការងារកែទម្រង់តាមក្រសួង-ស្ថាប័ន និងអង្គភាព តាមសារាចរលេខ ០៩ | គ្រប់ក្រសួង ស្ថាប័ន | យន្តការ នីតិវិធី នៃការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមក្រសួងស្ថាប័ន ត្រូវបានអនុវត្ត | ០.៣០ | ១០០% | ៣០% | អង្គភាពក្រោមឱវាទ កសហវ ទាំង ១៨ និងក្រសួង-ស្ថាប័នទាំង៤១ បានរៀបចំផែនការសកម្មភាព (GDAP3/MAP3) និងពិភាក្សាកម្រិតជំនាញជាមួយ អ.គ.ហ. ដើម្បីកំណត់សកម្មភាពកែទម្រង់ ។ ទន្ទឹមនេះ គ្រប់អង្គភាពក្រោមឱវាទ |

| ល.រ. | គោលបំណង/ចង្កោមសកម្មភាព | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | ទម្ងន់ | វឌ្ឍន-ភាព % | ពិន្ទុ ថ្លឹង | វឌ្ឍនភាពសំខាន់ៗ |
|---|---|---|---|---|---|---|---|
| | និងប្រកាសស្តីពីវិធាននិងនីតិវិធីនៃការលើកទឹកចិត្ត | | | | | | កសហវ. ទាំង១៨ និងក្រសួង-ស្ថាប័នទាំង ៤១ មានការរាយការណ៍ជាប្រចាំត្រីមាសអំពីវឌ្ឍនភាព និងផ្ញើជូន អ.គ.ហ. ដើម្បីបូកសរុប និងដាក់របាយការណ៍ជូនកិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងដៃគូអភិវឌ្ឍន៍ជាប្រចាំត្រីមាស និងប្រចាំឆ្នាំ ។ |
| ៤១.២ | រៀបចំប្រព័ន្ធគ្រប់គ្រងការផ្លាស់ប្តូរ (Change Management) | -FMWG<br>-អគ្គ. ថវិកា<br>-អគ្គ. រតនាគារជាតិ<br>-ក្រសួង-ស្ថាប័ន<br>- អគ្គ. កសហវ<br>- ក្រសួងមុខងារសាធារណៈ<br>-វិទ្យាស្ថានសេដ្ឋកិច្ច | ១. យន្តការការងារក្នុងការគ្រប់គ្រងការផ្លាស់ប្តូរត្រូវបានអនុវត្តពីគ្រប់តួអង្គពាក់ព័ន្ធ<br>២. ក្រុមការងារអនុវត្តគម្រោង FMIS តាមក្រសួងស្ថាប័នត្រូវបានធ្វើបច្ចុប្បន្នភាព និងបង្កើតថ្មីសម្រាប់ក្រសួង-ស្ថាប័ន ១៧ បន្ថែមថ្មី<br>៣. ក្រសួងស្ថាប័នចំនួន១៧ ត្រូវរៀបចំផែនការគ្រប់គ្រងការផ្លាស់ប្តូរសម្រាប់អនុវត្តប្រព័ន្ធ FMIS | ០.៧០ | ៩៨% | ៦៨% | ១. កម្រងសម្រង់បទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធលទ្ធកម្មសាធារណៈត្រូវបានរៀបចំរួចសម្រាប់ការបោះពុម្ព ។<br>២. កម្រងសម្រង់បទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធកិច្ចដំណើរការស្ថាប័នត្រូវបានរៀបចំចងក្រងរួចសម្រាប់ការបោះពុម្ព ។<br>៣. បច្ចុប្បន្នកម្មកម្រងសម្រង់បទប្បញ្ញត្តគតិយុត្តទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធត្រូវបានរៀបចំចងក្រងរួចសម្រាប់ការបោះពុម្ព ។<br>៤. មគ្គុទ្ទេសក៍នីតិសាស្ត្រពាក់ព័ន្ធទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធត្រូវបានរៀបចំចងក្រងរួចសម្រាប់ការបោះពុម្ព ។<br>៥. មគ្គុទ្ទេសក៍ក្រមនីយកម្មត្រូវបានរៀបចំចងក្រងរួចសម្រាប់កាបោះពុម្ព ។<br>៦. កម្មវិធីបច្ចេកវិទ្យាព័ត៌មានតាមវឌ្ឍនភាពនៃកម្រងសម្រង់ ត្រូវបានរៀបចំនិងដាក់ឱ្យដំណើរការ ។ |
